EXT/RGC-136

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អគ្គលេខាធិការដ្ឋាន

# នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

## កម្រងឯកសារ

## ស្តីពី

# ការកែលំអសេវាសាធារណៈ

- គោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីវិសហមជ្ឈការ
- ការអនុវត្តន៍សាកល្បងនូវប្រព័ន្ធគ្រប់គ្រង និងរចនាសម្ព័ន្ធរដ្ឋបាលថ្មី នៅស្រុកបាត់ដំបង និងស្រុកសៀមរាប
- ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយ

**SERVICE DELIVERY IMPROVEMENT**
**( SDI )**

- Policy and Strategy on De-concentration
- The Piloting Implementation of the New Administrative Structure of Srok Battambang and Srok Siem Reap
- One Window Service Office (OWS)

រាជធានីភ្នំពេញ ថ្ងៃទី ២៥-២៦ ខែ សីហា ឆ្នាំ ២០០៤

Inter-Continental Hotel

HPS

បណ្ណាល័យ
គ.ជ.អ.ប

កម្រងឯកសារ

ស្ដីពី

# ការកែលំអសេវាសាធារណៈ

- គោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីវិសហមជ្ឈការ
- ការអនុវត្តន៍សាកល្បងនូវប្រព័ន្ធគ្រប់គ្រង និងរចនាសម្ព័ន្ធរដ្ឋបាលថ្មី នៅស្រុកបាត់ដំបង និងស្រុកសៀមរាប
- ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយ

# SERVICE DELIVERY IMPROVEMENT
# ( SDI )

- Policy and Strategy on De-concentration
- The Piloting Implementation of the New Administrative Structure of Srok Battambang and Srok Siem Reap
- One Window Service Office (OWS)

353-33
COM

គាំទ្រហិរញ្ញវត្ថុដោយ

កម្មវិធីសីលា និង អង្គការ GTZ

NCDD Library
001029

# មាតិកា

១-បង្វិតរដ្ឋបាលសាធារណៈអោយទៅជិតប្រជាពលរដ្ឋ

២-ទស្សនាទាន ផែនការសកម្មភាព និង លទ្ធផលដែលទទួលបាន ស្តីពីការកែលំអសេវាសាធារណៈ

៣-សេចក្តីព្រាងលើកទី៣ ស្តីពីគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីវិសហមជ្ឈការ

( បន្ទាប់ពីកែសំរួល និងបញ្ចូលយោបល់មួយចំនួនដែលសមស្របតាមបច្ចេកទេស )

៤-តារាងសង្ខេបការផ្តល់យោបល់ត្រឡប់ពីក្រសួងនានា លើកទី១

៥- តារាងសង្ខេបការផ្តល់យោបល់ត្រឡប់ពីក្រសួងនានា លើកទី២

៦-គំរោងសាកល្បងនៅស្រុកបាត់ដំបង នៃខេត្តបាត់ដំបង និងស្រុកសៀមរាបនៃខេត្តសៀមរាបត្រូវបានគាំទ្រយ៉ាងសកម្ម និងសំរបសំរួលយ៉ាងរលូនពីថ្នាក់ដឹកនាំ ដោយមាន :

-លិខិតលេខ ១៦០/០៤ សជណ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-លិខិតលេខ ១៧៤/០៤ សជណ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-លិខិតលេខ ១៧៥/០៤ សជណ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-លិខិតលេខ ១៧៦/០៤ សជណ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-លិខិតលេខ ១៧៧/០៤ សជណ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-លិខិតលេខ ១៧៨ /០៤ សជណ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-លិខិតលេខ ១៧៩/០៤ សជណ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-លិខិតលេខ ៩៧៥ សជណ របស់ក្រសួងមហាផ្ទៃ

៧-ការគ្រោងផែនការសកម្មភាពគាំទ្រដល់ការរៀបចំដំណើរការប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្មីនៅស្រុកបាត់ដំបង នៃខេត្តបាត់ដំបង និងស្រុកសៀមរាបនៃខេត្តសៀមរាប

៨- ប្រកាសទាំងបីរបស់ក្រសួងមហាផ្ទៃ

- ស្តីពី រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់រដ្ឋបាល ស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

- ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យប្រជាពលរដ្ឋ ស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

- ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យច្រកចេញ-ចូលតែមួ ស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

៩- ប្រកាសស្តីពីការបង្កើតថវិកាផ្នែក សំរាប់ ស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១០-សេចក្តីព្រាងប្រកាសប្រតិភូកម្មអំណាច ជូនដល់ស្រុកសៀមរាប នៃខេត្តសៀមរាប ស្រុកបាត់ដំបង នៃខេត្តបាត់ដំបង របស់ក្រសួងជំនាញទាំង៥មាន :

- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីប្រតិភូកម្មអំណាចការងារ ឧស្សាហកម្ម

- សេចក្តីព្រាងប្រកាសរបស់ក្រសួងទេសចរណ៍ ស្តីពីប្រតិភូកម្មអំណាចកាងារទេសចរណ៍

-សេចក្តីព្រាងប្រកាស របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ស្តីពីប្រតិភូកម្មអំណាចការងារ សាធារណការ និងដឹកជញ្ជូន

- សេចក្តីព្រាងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ស្តីពីប្រតិភូកម្មអំណាចការងារពាណិជ្ជកម

- សេចក្តីព្រាងប្រកាស របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ស្តីពីប្រតិភូកម្មអំណាចការងារវប្បធម៌ និងវិចិត្រសិល្បៈ

១១- របាយការណ៍ទស្សនៈកិច្ចសិក្សានៅប្រទេសវៀតណាម ស្តីពីការផ្តល់សេវាជូនប្រជាពលរដ្ឋតាមគោលការណ៍ " ទ្វាមួយ ត្រាមួយ " កាលពីថ្ងៃទី៣០ មិថុនា ដល់ថ្ងៃទី ១១ កក្កដា ២០០៣ ។

១២- របាយការណ៍លទ្ធផលនៃកិច្ចប្រជុំ ស្តីពីការរៀបចំដាក់អោយដំណើរការការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញ-ចូលតែមួយនៅស្រុកបាត់ដំបង និងស្រុកសៀមរាបថ្ងៃទី ២១-២៤ ធ្នូ ឆ្នាំ ២០០៣ ។

១៣- របាយការណ៍ ស្តីពីការចុះផ្សព្វផ្សាយខ្លឹមសារលិខិបទដ្ឋានដែលពាក់ព័ន្ធដល់ការរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមច្រកចេញចូលតែមួយនៅស្រុកបាត់ដំបង ខេត្តបាត់ដំបង ស្រុកសៀមរាប ខេត្តសៀមរាប ថ្ងៃ ទី ២៥ - ៣១ កក្កដា ឆ្នាំ២០០៤

# TABLE OF CONTENT


1- Moving Public Service Closer to People

2- Draft of Concept, Action Plan and the Achievements of Service Delivery Improvement, SDI

3- The Third Draft of the Policy and Strategy on De-concentration
( After having received the feedbacks and comments from Ministries/Institutions concerned )

4- List of the briefing on the FIRST feedbacks and comments from Ministries and Institutions concerned

5- List of the briefing on the SECOND feedbacks and comments from Ministries and Institutions concerned

6- Piloting Project in Srok Battambang and Srok Siem Reap has been actively supported and facilitated from Leaders:

- Letter # 160/04 of Council for Administrative Reform
- Letter # 174/04 of Council for Administrative Reform
- Letter # 175/04 of Council for Administrative Reform
- Letter # 176/04 of Council for Administrative Reform
- Letter # 177/04 of Council for Administrative Reform
- Letter # 178/04 of Council for Administrative Reform
- Letter # 179/04 of Council for Administrative Reform
- Letter # 575 of Ministry of Interior

7- Step-Action Plan supporting the new administrative structure of Srok Battambang and Srok Siem Reap

8-Three Prakas of the Ministry of Interior on :

- The Structure and Administrative System of Srok Siem Reap. Siem Reap Province and Srok Battambang. Battambang Province.
- The Structure and Management of the Citizen's Office in Srok Siem Reap. Siem Reap Province and Srok Battambang, Battambang Province.
- The Structure and Management of the One Widow Service Office in Srok Siem Reap, Siem Reap Province and Srok Battambang, Battambang Province.

9- Prakas of Ministry of Economic and Finance on Partial Budget for Srok Siem Reap. Siem Reap Province and Srok Battambang. Battambang Province.

10- Draft of the Prakas on the Delegation of Power from the Ministry to Srok Battambang and Srok Siem Reap of the 5 Ministries, namely:

- The delegation of Power and function of the industrial, mineral and energy related work from the Ministry of Industry, Mine and Energy
- The delegation of Power and functions of the tourism related work from the Ministry of Tourism
- The delegation of Power and function of the public work and transportation related work from the Ministry of Public Work and Transports.
- The delegation of Power and function of the commercial related work from the Ministry of Commerce
- The delegation of Power and function of the cultural and fine art related work from the Ministry of Culture and Fine Arts.

11- Report of Study Tour to Vietnam dated 30 June to 11 July 2003; to see the implementation of One Window Service "One door, One Stamp" Principle

12- Report of Meeting dated 21-24 December 2003 on Preparations for the implementation of new administrative structural system, One Window Service Office in Srok Siem Reap, and Srok Battambang.

13- Report of the Dissemination and Circulation of the Related Regulations of the Line Ministries regarding One Window Service, dated on 25-31 July 2004; in Srok Siem Reap and Srok Battambang.

បង្វិតរដ្ឋបាលសាធារណៈអោយទៅជិតប្រជាពលរដ្ឋ

## ៥. បង្វិតរដ្ឋបាលសាធារណៈឱ្យទៅជិតប្រជាពលរដ្ឋ

ការធ្វើវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ជាដំណើរការបដិវត្តន៍មួយព្រោះថា ជាធម្មតាប្រទេសនានាគេធ្វើវិមជ្ឈការ និងវិសហមជ្ឈការ នៅពេលដែលអំណាចកណ្តាលខ្លាំង ។ ប៉ុន្តែប្រទេសកម្ពុជាវិញបានផ្លោះដំណាក់កាលនេះ ដោយក្រោយពីបានឆ្លងកាត់ដំណាក់កាលសង្គ្រាមមក រាជរដ្ឋាភិបាលមិនបានរង់ចាំទាល់តែអំណាច កណ្តាលខ្លាំងទើបធ្វើការផ្ទេរ និងរំលែកអំណាចខ្លះទៅឱ្យថ្នាក់មូលដ្ឋាននោះទេ ។ នេះជាសក្ខីភាពបញ្ជាក់នូវការតាំងចិត្តដ៏មោះមុត និងសេចក្តីក្លាហានរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងនីតិរដ្ឋ និងប្រជាធិបតេយ្យនៅកម្ពុជា ។

រាជរដ្ឋាភិបាលបានបង្វិតរដ្ឋបាលសាធារណៈឱ្យទៅជិតប្រជាពលរដ្ឋ តាមរយៈការដាក់ឱ្យដំណើរការនូវវិមជ្ឈការបច្ចេកទេស ( ក្រុមហ៊ុនអគ្គិសនីកម្ពុជា មន្ទីរពេទ្យកាល់ម៉ែត ...) និងតាមរយៈដំណើរការវិមជ្ឈការដែនដីនៅក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ខាងមុខនេះ ។ ទន្ទឹមគ្នានេះ វិសហមជ្ឈការនឹងចូលរួមជាមួយវិមជ្ឈការទាំងពីរបែបនេះ ដើម្បីរុញរដ្ឋបាលសាធារណៈឱ្យខិតជិតនឹងប្រជាពលរដ្ឋ ដែលជាគន្លឹះមួយសំរាប់ធ្វើការអភិវឌ្ឍន៍ និងពង្រឹងលទ្ធិប្រជាធិបតេយ្យនៅទូទាំងប្រទេស ។ តាមរយៈឯកសារផែនការសកម្មភាពអភិបាលកិច្ច រាជរដ្ឋាភិបាលបានចាត់ទុកថាការធ្វើវិសហមជ្ឈការរដ្ឋបាលដោយចែករំលែកសមត្ថកិច្ច និងធនធានមួយចំនួនពីរដ្ឋបាលកណ្តាលទៅខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ ក្នុងគោលបំណងពង្រឹង ខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ ដើម្បីផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើងជូនប្រជាពលរដ្ឋ និងជួយទ្រទ្រង់សកម្មភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

ការដាក់ឱ្យដំណើរការប្រព័ន្ធវិសហមជ្ឈការនៅថ្នាក់កណ្តាល ខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ ជាការងារមួយមានទំហំធំធេង និងអាចទទួលជោគជ័យបានតាមរយៈការរៀបចំទិដ្ឋភាពជាច្រើន ជាពិសេស ការរៀបចំគោលនយោបាយយុទ្ធសាស្ត្រ ការរៀបចំក្របខ័ណ្ឌច្បាប់ ការពង្រឹងសមត្ថភាពរដ្ឋបាលខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ តាមរយៈការបង្កើតឧបករណ៍គ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស ការរៀបចំធនធានហិរញ្ញវត្ថុ សំភារៈ និងការធានាឱ្យមានភាពរលូន រវាងគោលនយោបាយនេះ ទៅនឹងគោលនយោបាយកំណែទំរង់ដទៃទៀត ជាពិសេសគោលនយោបាយវិមជ្ឈការ ។

ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល នឹងដើរតួយ៉ាងសកម្មជាមួយបណ្តាក្រសួង-ស្ថាប័ន ដើម្បីរៀបចំការងារសំខាន់ៗ និងចាំបាច់ដូចខាងក្រោម :

ទីមួយ: ពិនិត្យលទ្ធភាព និងជំរុញការដាក់ឱ្យដំណើរការវិមជ្ឈការបច្ចេកទេសជាបន្តបន្ទាប់ នៅតាមវិស័យនានា

ទីពីរៈ រៀបចំសេចក្តីព្រាងគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីវិសហមជ្ឈការ ៈ

ក- កំណត់គោលការណ៍ធំៗស្តីពីវិសហមជ្ឈការ

ខ- កំណត់លក្ខណៈវិនិច្ឆ័យសំរាប់បែងចែកសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ថ្នាក់រដ្ឋបាលនីមួយៗ

គ- កំណត់ឡើងវិញនូវតួនាទី មុខងាររបស់ខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ និងធនធានសំរាប់ដំណើរការ

ឃ-កំណត់ឡើងវិញនូវតួនាទីរបស់អភិបាលខេត្ត-ក្រុង និង ស្រុក-ខ័ណ្ឌ

ង-វាយតំលៃ និងកំណត់ដំណាក់កាលអនុវត្តឱ្យបានសមស្របតាមធនធានដែលមាន

ទីបី ៈ រៀបចំបង្កើតក្របខ័ណ្ឌគតិយុត្តស្តីពីវិសហមជ្ឈការ

ទីបួន ៈ រៀបចំ និងពង្រឹងអង្គភាពទ្រទ្រង់នៅថ្នាក់ខេត្ត-ក្រុង និង ស្រុក-ខ័ណ្ឌ

*ក-រៀបចំនីតិវិធីដំណើរការរបស់ផ្នែកទាំង៥នៃអង្គភាពទ្រទ្រង់ (Back office) នៅខេត្ត-ក្រុង និង ស្រុក-ខ័ណ្ឌ*

អង្គភាពទ្រទ្រង់ ៈ អង្គភាពទ្រទ្រង់ជាអង្គភាពដែលធានានូវមុខងារទ្រទ្រង់ដល់ការធ្វើសកម្មភាពស្នូលរបស់ស្ថាប័នមួយ និងធានាពីខាងក្រោយនៃផ្នែកសេវាឈានមុខ ដើម្បីឱ្យអង្គភាពនេះមានលទ្ធភាពផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋដោយផ្ទាល់ប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់ ។ រាល់ក្រសួង-ស្ថាប័នទាំងអស់សុទ្ធតែមានផ្នែកទាំង ៥ គឺ ផ្នែកគ្រប់គ្រងធនធានមនុស្ស រដ្ឋបាល កិច្ចការហិរញ្ញវត្ថុ ផែនការ និង អធិការកិច្ច ជារួមដូចគ្នាទាំងអស់ដែលយើងហៅថា ផ្នែកសេវាទ្រទ្រង់ ។ ការរៀបចំឧបករណ៍គ្រប់គ្រងលើផ្នែកទាំង៥នេះ តាមនីតិវិធីមួយច្បាស់លាស់ សាមញ្ញ និង ខ្លី ជាយុទ្ធសាស្ត្រធានានូវជោគជ័យនៃការធ្វើវិសហមជ្ឈការផង និងជាឧបករណ៍គ្រប់គ្រងដ៏មានប្រសិទ្ធភាពផង ។

តាមទិសដៅនេះ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានចាត់ទុកការបង្កើតបទដ្ឋាន និងនីតិវិធីគ្រប់គ្រងមន្ត្រីរាជការតាមបែបវិសហមជ្ឈការ ជាការងារដ៏ចាំបាច់ និងត្រូវរៀបចំជាបន្ទាន់ ព្រោះថា ទី១ ៈ បានបញ្ចប់ការធ្វើជំរឿនមន្ត្រីរាជការ ទី២ ៈ មានលទ្ធផលនៃការវិភាគមុខងារធ្វើជាមូលដ្ឋាន (លទ្ធផលវិភាគមុខងារបង្ហាញថា ស្តង់ដាមុខងារនៃការគ្រប់គ្រងធនធានមនុស្ស មាន ១៩ អភិក្រម ៈ ដូចជា ការចូលក្របខ័ណ្ឌ ការតាំងស៊ប់ ...) ទី៣ ៈ នីតិវិធីគ្រប់គ្រងធនធានមនុស្សច្បាស់លាស់ និង ខ្លី នឹងរៀបចំបញ្ចូលក្នុងប្រព័ន្ធពត៌មានវិទ្យាសំរាប់ធានាដល់ការគ្រប់គ្រងក្របខ័ណ្ឌឱ្យបានម៉ត់ចត់ ការចាត់ចែងធនធានមនុស្សចំទិសដៅ និងការអភិវឌ្ឍន៏ធនធានមនុស្ស ។ បទដ្ឋាន និងស្តង់ដាតាមបែបវិសហមជ្ឈការរបស់ផ្នែកទាំង៤ផ្សេងទៀតនៅក្នុងផ្នែកសេវាទ្រទ្រង់នឹងត្រូវរៀបចំជាបន្តបន្ទាប់ ។

*ខ- រៀបចំកម្មវិធី និង បណ្តុះបណ្តាលមន្ត្រីជំនាញដែលបំរើការនៅផ្នែកសេវាទ្រទ្រង់* ។

ទីប្រាំ ៈ ពង្រឹងផ្នែកអង្គភាពជួរមុខសំរាប់ប្រតិបត្តិការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ៈ

- ផ្នែកអង្គភាពជួរមុខជាអង្គភាពធានានូវសកម្មភាពស្នូលរបស់ក្រសួង និងផ្តល់សេវាសាធារណៈដោយផ្ទាល់ ជូនប្រជាពលរដ្ឋ ឧទាហរណ៍ ដូចជា ច្រកទ្វារព្រំដែន មន្ទីរពេទ្យ សាលារៀន ។ល។ ដើម្បីធ្វើការងារពង្រឹងផ្នែកសេវា ឈានមុខនេះ ចាំបាច់ត្រូវមានការវិភាគមុខងារតាមសេវាសាធារណៈនីមួយៗ ។

- ពិនិត្យលទ្ធភាពផ្តល់សមត្ថកិច្ចជាអាទិភាពមួយចំនួនឱ្យខេត្ត-ក្រុង និង ស្រុក-ខណ្ឌ ដើម្បីផ្តល់សេវាសាធារណៈជាមូលដ្ឋានជូនប្រជាពលរដ្ឋដែលលោកត្រូវការសំរាប់លើកកំពស់គុណជីវភាពរបស់ខ្លួន (ឧទាហរណ៍ : អប់រំ សុខាភិបាល កសិកម្ម និងសេវាសង្គមកិច្ច) និង សេវារដ្ឋបាលទូទៅជាសេវាសាធារណៈដែលធានាដល់ការអនុវត្តន៍សិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ រួមមានការអនុញ្ញាត្ត អាជ្ញាប័ណ្ណ ឬការចុះបញ្ជីជាដើម ។
- មូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយស្តីពីនីតិវិធី និងការអនុវត្តន៍ពាក់ព័ន្ធនឹង ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងរៀបចំបញ្ចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាពត៌មាន ដែលជាមធ្យោបាយសំរាប់បង្កើនប្រសិទ្ធភាព និងតម្លាភាព ក្នុងការផ្តល់សេវាសាធារណៈ ។

**ទីប្រាំមួយ : រៀបចំនីតិវិធីផ្តល់សេវាសាធារណៈ និងបង្កើតឱ្យមានច្រកចេញ-ចូលតែមួយនៃសេវារដ្ឋបាល :**

ការដាក់ឱ្យមានច្រកចេញ-ចូលតែមួយនៃសេវារដ្ឋបាល (one window service) នឹងជួយសំរួលដល់ប្រជាពលរដ្ឋឱ្យងាយទទួលបាន នូវសេវាទាំងនេះផង និងជាដំណោះស្រាយមួយខាងមិនបានសំរាប់បង្កើនតម្លាភាព និងកាត់បន្ថយនូវភាពមិនប្រក្រតីផ្សេងៗ ។

**ទីប្រាំពីរ : ពង្រឹងយន្តការសម្របសម្រួល និងតាមដាន :**

ក្រុមការងារអន្តរក្រសួងវិសហមជ្ឈការ ក្រោមការសំរបសំរួលរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និងក្រុមការងារតាមបណ្តាក្រសួងនានាចំនួន១០ បានបង្កើតរួចហើយ ។ កន្លងមកក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបាននឹងកំពុងបំពេញតួនាទីជាអ្នកសម្របសម្រួលលើការងារនេះយ៉ាងសស្រាក់សស្រាំ (ឧទា. ការប្រមូលចងក្រងនូវឯកសារមូលដ្ឋានគតិយុត្ត និងបញ្ជីសរុបស្តីពីសេវាសាធារណៈដែលក្រសួងនានាកំពុងផ្តល់ជូនប្រជាពលរដ្ឋ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលកំពុងសម្របសម្រួល និងជំរុញឱ្យក្រសួងសាមីធ្វើកិច្ចការនេះឱ្យបានឆាប់ និងត្រឹមត្រូវ) ។ ដូចនេះការពង្រឹងក្រុមការងារវិសហមជ្ឈការតាមរយៈការបណ្តុះបណ្តាល និងមធ្យោបាយ សំភារៈ ជាការចាំបាច់មួយដើម្បីអាចឱ្យយន្តការនេះអាចបំពេញការងារនេះបានដោយមានប្រសិទ្ធភាព ។

# ទស្សនាទាន ផែនការសកម្មភាព និង
# លទ្ធផលដែលទទួលបាន ស្តីពីការកែលំអសេវាសាធារណៈ

ឯកសារសង្ខេប

# ទស្សនាទាន ផែនការសកម្មភាព និង លទ្ធផលដែលទទួលបាន
# ស្តីពី
# ការកែលំអសេវាសាធារណៈ

- គោលនយោបាយ វិសហមជ្ឈការ
- គំរោងអនុវត្តន៍សាកល្បងនៅស្រុកបាត់ដំបង និងស្រុកសៀមរាប
- ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយនៅស្រុកបាត់ដំបង និង ស្រុកសៀមរាប

## ផ្នែកទី I - ទស្សនាទាន

### I- សេចក្តីផ្តើម

ក្នុងបរិបទសកលភាវូបនីយកម្ម មិនថាតែប្រទេសកម្ពុជាទេ គឺមានប្រទេសជាច្រើន បានធ្វើការផ្លាស់ប្តូរប្រព័ន្ធផ្តល់សេវាដែលពីមុនមកតាមរបៀប ជាទំនាក់ទំនងរវាងអ្នកគ្រប់គ្រង (Administrateur) និងអ្នកដែលត្រូវគេគ្រប់គ្រង (Administré) ទៅជាទំនាក់ទំនងថ្មី គឺជាទំនាក់ទំនងរវាងអ្នកផ្តល់សេវា (offre de service) និង អ្នកប្រើប្រាស់សេវា (usager) ទៅវិញពោលគឺ ផ្តល់សេវាជូនប្រជាពលរដ្ឋ នៅកន្លែង និង ពេលវេលាដែលប្រជាពលរដ្ឋត្រូវការ ។

ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តន៍ នូវយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ការកែលំអការផ្តល់សេវាសាធារណៈជាការងារចាំបាច់ និងជាមធ្យោបាយមួយខានមិនបាន ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋក្រីក្រនៅជនបទដាច់ស្រយាល ។

ការរីកចំរើនខាងវិស័យឯកជន ក៏ជាស្ថានភាពមួយដែរ ដែលតំរូវឱ្យរដ្ឋត្រូវពង្រឹងស្ថាប័ន និង តួនាទីរបស់ខ្លួនដើម្បីធ្វើការកែលំអការផ្តល់សេវាសាធារណៈ ជូនផ្នែកឯកជនដែលជាដៃគូរបស់ខ្លួន ក្នុងកិច្ចអភិវឌ្ឍន៍ប្រទេសជាតិ ។

ការកែលំអសេវាសាធារណៈមានន័យថាជា វិធានការណ៍ជាក់ស្តែងមួយ នៅក្នុងក្របខ័ណ្ឌកំណែទំរង់ដើម្បីនាំទៅដល់គោលដៅ ឬស្ថានភាពមួយ ដែលប្រជាពលរដ្ឋអាចទទួលបានសេវាសាធារណៈ ដោយមានគុណភាព មានតម្លាភាព ទាន់ពេលវេលា និង តាមតំលៃសមរម្យ ។

អាស្រ័យហេតុនេះ ការកែលំអសេវាសាធារណៈជាកម្មវិធីអាទិភាពដ៏ខ្ពស់បំផុតមួយ ដែលនឹងធានាបាននូវការប្រើប្រាស់ធនធាន និងពេលវេលាសំរាប់ឆ្លើយតបឱ្យបានចំៗទៅនឹងតំរូវការពិតប្រាកដរបស់ប្រជាពលរដ្ឋជាង បើធៀបទៅនឹងការកំណែទំរង់ដោយផ្តោតតែទៅលើមុខងារ និង រចនាសម្ព័ន្ធ ។

## II- គោលការណ៍

ដើម្បីសំរេចឱ្យបាននូវគោលដៅនេះ យើងត្រូវរៀបចំដោយម៉តចត់បំផុតក្នុងការផ្លាស់ប្តូរ ដោយប្រើប្រាស់គោលការណ៍មួយចំនួន :

- បែងចែកនូវសេវាដែលប្រតិបត្តិការដោយរដ្ឋបាលសាធារណ ជាពីរផ្នែកធំៗ : គឺ សេវាទ្រទ្រង់ និង សេវាជូរមុខ ។
- កែលំអសេវាទ្រទ្រង់ដោយកាត់បន្ថយភាពចំនួនបទអនរគមន៍ និង ការិយាធិបតេយ្យដោយមានការបង្រួមនីតិវិធីខ្លី សាមញ្ញ និងមានតម្លាភាព
- កែលំអសេវាជូរមុខតាម រយៈ :
    - ❖ *តាមគូរ ជា អ្នកផ្តល់សេវា (offre de service ) និង អ្នកទទួលសេវា (usager ) ។*
    - ❖ *កំណត់ និង ធ្វើការបែងចែកសេវាសាធារណៈឡើងវិញតាមរូបភាព ជា វិសហមជ្ឈការ ជា វិមជ្ឈការដែនដី ជាវិមជ្ឈការ បច្ចេកទេស និងឯកជនភាវូបនីយកម្ម ។*
- កាត់បន្ថយការប្រើប្រាស់តាមរបៀបបុរាណ ដោយប្រើប្រាស់បច្ចេកពត៌មានវិទ្យា និង ឧបករណ៍ទំនើបជំនួសវិញ ក្នុងលក្ខណៈចាំបាច់ និង អាចធ្វើទៅបាន។
- ពង្រឹងប្រសិទ្ធភាពស្ថាប័ន និង ការងារមន្ត្រីរាជការ គួរបង្កើត ផ្នែកឯកទេសសំរាប់ ដោះស្រាយវិវាទរដ្ឋបាលក្នុងប្រព័ន្ធតុលាការសព្វថ្ងៃ។
- បង្កើននូវទំនុកចិត្ត របស់ប្រជាពលរដ្ឋមកលើរដ្ឋក្នុងការផ្តល់សេវាសាធារណៈឱ្យមានប្រសិទ្ធភាព ដោយផ្តល់លទ្ធភាពជូនប្រជាពលរដ្ឋដើម្បីអាចតាមដាន និងពិនិត្យមើលកំហុសឆ្គង របស់មន្ត្រីរាជការ ។

## III- វិធីសាស្ត្រ :

ការកែលំអសេវាសាធារណៈឱ្យមានប្រសិទ្ធភាពត្រូវរៀបចំ និង អនុវត្តន៍នូវការងារមួយចំនួនដូចតទៅ :

- កែលំអសេវាសាធារណៈដោយចែកជាដំណាក់កាលឱ្យបានស្របតាមធនធាន
- ធ្វើជំរឿន និង រៀបចំបញ្ជីសេវាសាធារណៈដោយធ្វើអត្តសញ្ញាណកម្មទៅតាមវិស័យដែលរដ្ឋបាលគ្រប់លំដាប់ថ្នាក់ កំពុងធ្វើការផ្តល់ជូនប្រជាពលរដ្ឋ ។
- ធ្វើការលប់បំបាត់ការងារជាន់គ្នាមួយចំនួនប្រសិនបើមាន និងកាត់បន្ថយចំនួនបទអន្តរគមន៍ ឱ្យនៅក្នុងកំរិតមួយសមស្រប។
- កំណត់លក្ខណៈវិនិច្ឆ័យដើម្បីវិភាគ និងកំណត់ថាតើ *សេវាសាធារណៈ*ណាខ្លះដែលត្រូវធ្វើ :

- *វិមជ្ឈការទៅឱ្យឃុំ សង្កាត់ ។*
- *វិសហមជ្ឈការទៅឱ្យខេត្ត ក្រុង និងស្រុក ខណ្ឌ ។*
- *វិមជ្ឈការបច្ចេកទេស*
- *ឯកជនភាវូបនីយកម្ម*
- *ការផ្តល់សេវាតាមច្រកចេញចូលតែមួយ ( OWSD)*
- *ការផ្តល់សេវាតាមរបៀបចំលាស់ (ALTERNATIVE SERVICE DELIVERY) ផ្សេងៗទៀត*

– កែលំអនីតិវិធី *ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ តាមរបៀប សាមញ្ញ មានគុណភាព និង ចំណាយអស់តិច ហើយអាច* សំរួលឱ្យ ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈទាន់ពេលវេលា ។

## IV- សេវាសាធារណៈជាអាទិភាពដែលត្រូវកែលំអ

ការកែលំអសេវាសាធារណៈ ដោយផ្តោតទៅលើការធានា ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ទៅលើសេវាជាអាទិភាព ចំនួន ដូចខាងក្រោម:

១- សេវាសាធារណៈផ្នែករដ្ឋបាលដែលពាក់ព័ន្ធដល់អធិតេយ្យភាព ( ឧទា: អត្រានុកូលដ្ឋាន លិខិតអនុញ្ញាតផ្សេងៗ ប័ណ្ណកម្មសិទ្ធដីធ្លី ....)

២- សេវាពាក់ព័ន្ធ នឹងការវិនិយោគ

៣- សេវាពាក់ព័ន្ធ នឹងការគ្រប់គ្រងចំណូល និង ចំណាយ

៤- សេវាជាមូលដ្ឋាន ( អប់រំ សុខាភិបាល និង កសិកម្ម)

៥- សេវាពាក់ព័ន្ធនឹងយុត្តិធម៌ ( ការសំរបសំរួលជំលោះក្រៅប្រព័ន្ធតុលាការ និង ការសំរបសំរួលរវាងប្រជាពលរដ្ឋ និង អាជ្ញាធរ ដោយការិយាល័យប្រជាពលរដ្ឋ )

---

# ផ្នែកទី ២ ៖ លទ្ធផលដែលទទួលបាន

## V- សេចក្តីព្រាង នៃ គោលនយោបាយ និង យុទ្ធសាស្ត្រស្តីពីការធ្វើវិសហមជ្ឈការត្រូវបាន រៀបចំរួចជាស្រេច ដើម្បីធ្វើការពិភាក្សា និង អនុម័ត

### *១- បរិបទ និង វិធីសាស្ត្ររៀបចំ :*

ការរៀបចំគោលនយោបាយ និង យុទ្ធសាស្ត្រ ស្តីពីការធ្វើវិសហមជ្ឈការ ជាចំនុចការងារដ៏ធំមួយនៃកម្មវិធីបង្វិតរដ្ឋបាលសាធារណៈទៅជិតប្រជាពលរដ្ឋដែលអនុម័តដោយគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០១។

ចាប់តាំងពីពេលនោះមក ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានខិតខំរៀបចំដោយមានការសហការយ៉ាងសកម្មពីក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា តាមរយៈវិធីសាស្ត្រជាក់លាក់មួយដោយជា៥ដំណាក់កាល :

*ដំណាក់កាលទី ១* - ការរៀបចំក្រុមការងារអន្តរក្រសួង និង រៀបចំការងារជាមួយដៃគូអភិវឌ្ឍន៍រួមមាន: UNDP, KAF, GTZ

*ដំណាក់កាល ទី ២*- ពង្រឹងសមត្ថភាពដល់ក្រុមការងារ និង ផ្សព្វផ្សាយគោលការណ៍ទូទៅ

*ដំណាក់កាល ទី ៣*- ប្រមូលពតិមាន និងបទពិសោធន៍ក្នុងស្រុក ដើម្បីធ្វើការវិភាគ និងសំយោគ : បានធ្វើទស្សនកិច្ចទៅខេត្ត ចំនួន ៨ នៅឆ្នាំ ២០០៣ និង ២០០៤។

*ដំណាក់កាល ទី ៤*- ធ្វើការពិគ្រោះយោបល់ជាទ្វេភាគី ជាមួយក្រសួងគន្លឹះមួយចំនួនពាក់ព័ន្ធនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធ សង្គមកិច្ច រៀបចំដែនដី ផែនការ ហិរញ្ញវត្ថុ និង អាជ្ញាធរដែនដី។

*ដំណាក់កាល ទី ៥*- រៀបចំជាសេចក្តីព្រាង និង ចែកជូនដៃគូ សំរាប់ផ្តល់យោបល់ចំនួន ពីរលើក គឺលើកទី១ ខែធ្នូ ឆ្នាំ ២០០២ និង លើកទី ២ ខែមិថុនា ឆ្នាំ ២០០៤ និង ទទួលបានការចូលរួមផ្តល់យោបល់ត្រឡប់មកវិញយ៉ាងទូលំទូលាយពី ក្រសួងស្ថាប័នពាក់ព័ន្ធ ចំនួនពីរលើក ដូចមានឯកសារជូនភ្ជាប់។

### ២- *លទ្ធផលដែលទទួលបាន :*

*តាមរយៈវិធីសាស្ត្រដូចជំរាបជូនខាងលើ និងឈរលើមូលដ្ឋាននៃការចូលរួមយ៉ាងសកម្មពីក្រសួងស្ថាប័ន ខេត្ត-ក្រុង និងដៃគូអភិវឌ្ឍន៍ សេចក្តីព្រាងនៃគោលនយោបាយ និងយុទ្ធសាស្ត្រ ស្តីពីការធ្វើវិសហមជ្ឈការ នេះត្រូវបានកែសំរួលជាបន្តបន្ទាប់រួចហើយនឹងធានាបាននូវខ្លឹមសារមួយ ដែលសមស្របទៅនឹងស្ថានភាពលទ្ធភាពជាក់ស្តែងរបស់ប្រទេស និងអាចអនុវត្តន៍បាន។*

## VI– ការអនុវត្តជាបំរោងគំរូ នៅស្រុកបាត់ដំបង និងស្រុកសៀមរាប

### ៣ -*សាវតា :*

- រាជរដ្ឋាភិបាលបានអនុម័តកម្មវិធី ការបង្កិតរដ្ឋបាលសាធារណៈទៅជិតប្រជាពលរដ្ឋ នៅថ្ងៃទី ១៩ តុលា ឆ្នាំ ២០០១។ ការកសាងឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រ នៃវិសហមជ្ឈការ ជាចំនុចជាក់ស្តែងមួយ នៃកម្មវិធីដ៏សំខាន់នេះ។
- សេចក្តីសំរេច លេខ ៤៧ របស់រាជរដ្ឋាភិបាល សំរាប់ការដាក់ឱ្យស្រុកបាត់ដំបង និងស្រុកសៀមរាប ដំណើរការអនុវត្តន៍សាកល្បងនូវប្រព័ន្ធគ្រប់គ្រង និងរចនាសម្ព័ន្ធរដ្ឋបាលដោយឡែកខុសពីស្រុកនានា គឺជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រធំៗទាំងឡាយ ក្នុងការដាក់ឱ្យដំណើរការនូវប្រព័ន្ធវិសហមជ្ឈការឱ្យបានសមស្របទៅនឹងទិដ្ឋភាពជាក់ស្តែង នៅកម្ពុជា " ធ្វើបណ្តើរ រៀនសូត្របណ្តើរ កែសំរួលបណ្តើរ និង ពង្រីកជាបន្តបន្ទាប់ " ។

### ៤- តាមរយៈខ្លឹមសារនៃសេចក្តីសំរេច លេខ ៤៧ របស់រាជរដ្ឋាភិបាល ការងារវិសហមជ្ឈការត្រូវបានបោះមួយជំហានយ៉ាងធំទៅមុខ រួមមាន :

*ក -ស្រុកទីរួមខេត្តមានលក្ខណៈជាក្រុងទាំងពីរ មានប្រព័ន្ធ និងរចនាសម្ព័ន្ធសមស្រប និងទំនើបជាងមុន*

- មានក្រុមប្រឹក្សាពិគ្រោះយោបល់នៅអមអភិបាលស្រុក ដែលជាយន្តការពិគ្រោះយោបល់ និងសំរបសំរួលផែនការអភិវឌ្ឍន៍នៅក្នុងស្រុក
- មានយន្តការរដ្ឋបាលទំនើប គឺ ការិយាល័យច្រកចេញចូលតែមួយនៃសេវារដ្ឋបាល " ONE WINDOW SERVICE " សំរាប់ផ្តល់សេវាកម្ម រដ្ឋបាលជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា និង មានតម្លាភាព
- មានយន្តការពារប្រជាពលរដ្ឋទល់នឹង ការបំពារបំពានពី មន្ត្រីរាជការ និង សំរាប់បង្កើនតម្លាភាព នៅក្នុងកិច្ចការសាធារណៈ ដោយបង្កើតនូវការិយាល័យពលរដ្ឋ

*ខ- ស្រុកមានទីរួមខេត្តទាំងពីរនេះទទួលបាន អំណាចសមត្ថកិច្ច និង សេវាកម្មច្រើនជាងមុនពី ក្រសួង* ស្ថាប័នពាក់ព័ន្ធនានា :

- ជាភ្នាក់ងារដ៏មានប្រសិទ្ធភាពរបស់រដ្ឋបាលកណ្តាល ក្នុងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល
- ជារដ្ឋបាលមូលដ្ឋានដែលមានថវិកា ចំណូល និង ចំនាយផ្ទាល់
- តួនាទី មុខងារ និងសេវាមួយចំនួនត្រូវបានកំណត់ នឹងត្រូវធ្វើការផ្ទេរជាជំហានៗទៅឱ្យស្រុកទាំងពីរនេះតាមការកំណត់របស់ក្រសួង ស្ថាប័នសាមី ( ជាពិសេសមុខងារផ្តល់សេវាកម្មរដ្ឋបាលដូចជា ការអនុញ្ញាតអាជីវកម្ម និងសាងសង់ ។ល ។) ដើម្បីអភិវឌ្ឍន៍មូលដ្ឋានស្រុករបស់ខ្លួន ។

### ៥-ការងារសំរបសំរួលជាមួយ ក្រសួងមហាផ្ទៃ ដើម្បីរៀបចំបទដ្ឋានគតិយុត្ត:

*តាមស្មារតីនៃសេចក្តីសំរេច លេខ ៤៧ របស់រាជរដ្ឋាភិបាល រាល់ប្រកាសរបស់ក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធទាំងអស់ដែលត្រូវធ្វើការផ្ទេរសិទ្ធិអំណាច និងសេវាកម្មជូនស្រុកបាត់ដំបង និងស្រុកសៀមរាបត្រូវមានការពិគ្រោះយោបល់ពីក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។*

*កន្លងមកនេះក្រុមការងារ វិសហមជ្ឈការក.ក.រ បានធ្វើការជាមួយក្រសួងមហាផ្ទៃ ដោយបានដាក់ចេញនូវប្រកាសចំនួន៣គឺ :*

*ក- ប្រកាស ស្តីពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង*

*ខ-ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យប្រជាពលរដ្ឋ នៅស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង*

*គ-ប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យច្រកចេញចូលតែមួយ នៅស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង*

**៦-ការសំរបសំរួលជាមួយក្រសួងមហាផ្ទៃ សំរាប់ការផ្សព្វផ្សាយ និងរៀបចំការអនុវត្តន៏ត្រូវបាន ដំណើការយ៉ាងរលូន :**

*ក- សហការជាមួយក្រសួងមហាផ្ទៃ ធ្វើការបែងចែកការងារ និងការទទួលខុសត្រូវ ដោយមានកម្មវិធីការងារ ច្បាស់លាស់ គាំទ្រការអនុវត្តន៏ គំរោងសាកល្បងនៅស្រុកបាត់ដំបង និងស្រុកសៀមរាប*

*ខ- សហការជាមួយក្រសួងមហាផ្ទៃ បានបើកវគ្គផ្សព្វផ្សាយ ខ្លឹមសារប្រកាសចំនួន បី ដែលជាមូលដ្ឋានសំរាប់ អនុវត្តន៏ គំរោងសាកល្បងនៅ ស្រុកបាត់ដំបង និងស្រុកសៀមរាប នៅថ្ងៃទី ២៥-៣១ ខែកក្កដា ឆ្នាំ ២០០៤ ដឹកនាំដោយ ឯកឧត្តម អគ្គលេខាធិការគក.រ និង ឯកឧត្តម អគ្គនាយករដ្ឋបាលក្រសួងមហាផ្ទៃ ។*

## VI- ការរៀបចំ និងឈានទៅអនុវត្តសាកល្បង ក្នុងការការផ្តល់សេវាកម្មរដ្ឋតាមយន្តការ ច្រកចេញចូលតែមួយនៅស្រុក បាត់ដំបង និងស្រុកសៀមរាប នាដើមឆ្នាំ ២០០៥:

### *៧-សេចក្តីផ្តើម :*

តាមរយៈការបង្វិតរដ្ឋបាលសាធារណៈទៅជិតប្រជាពលរដ្ឋ ដែលបានអនុម័ត ដោយគណៈរដ្ឋមន្ត្រី ថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០១ និងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី៣ នៃរដ្ឋសភា បានចាត់ទុកថា **ការផ្តល់សេវាកម្មតាមយន្តការច្រកចេញចូលតែមួយ** ជាគំរោងអាទិភាព ដ៏ខ្ពស់បំផុតមួយក្នុងចំណោមអាទិភាពជាច្រើនដូចជា គំរោងកន្សោមអាទិភាព គំរោងបង្កើនសមត្ថភាព មន្ត្រីរាជការ និងគំរោង ពតិមានវិទ្យា និង ជាយុទ្ធសាស្ត្រគន្លឹះ ដើម្បីផ្តល់សេវាសាធារណៈដ៏មានគុណភាពជូនប្រជាពលរដ្ឋបាន ទាន់ពេលវេលា។

បច្ចុប្បន្ននេះ និន្នាការសាកលការូបនីយកម្មនៃទំនាក់ទំនងរវាងតួនាទីរបស់រដ្ឋបាលសាធារណៈ និង ប្រជាពលរដ្ឋបានផ្លាស់ប្តូរពីទំនាក់ទំនងចាស់ គឺតាមរបៀបជាអ្នកដែលគ្រប់គ្រង (Administrateur) និងអ្នកដែត្រូវគេគ្រប់គ្រង (Administré) ទៅជាទំនាក់ទំនងថ្មីគឺតាមរបៀបជាអ្នកផ្តល់សេវា ( offer de Service )និង អ្នកប្រើប្រាស់សេវា(usager)ទៅវិញ។ ពោលគឺប្រជាពលរដ្ឋមិនត្រូវរត់សំណុំឯកសាររបស់ខ្លួនទៅរាប់សិបអង្គភាព រដ្ឋបាល និងចំណាយពេលយ៉ាងច្រើន ដើម្បីបានការអនុញ្ញាត្តិដូចមុនទៀតហើយ ព្រោះថាការបញ្ជូនឯកសារចុះ ឡើងរបៀបនេះជាកិច្ចការរបស់រដ្ឋ ដែលរដ្ឋត្រូវរ៉ាប់រងធ្វើមិនត្រូវឱ្យប្រជាពលរដ្ឋធ្វើជំនួសឡើយ។

អាស្រ័យហេតុនេះ សេវាសាធារណៈផ្នែករដ្ឋបាលមានការចុះបញ្ជី ការបញ្ជាក់ និង ការអនុញ្ញាត ត្រូវរៀបចំតាមបែប " អតិថិជន អ្នកផ្គត់ផ្គង់ : Client Supplier" ដោយបង្កើតឱ្យមានច្រកចេញចូលតែមួយ ដោយប្រមូលផ្តុំការិយាល័យមុខងារទាំងអស់ឱ្យនៅកន្លែងតែមួយ និងមានយន្តការតាមដានដ៏មានប្រសិទ្ធភាពមួយ ដែល

ហៅថា ការិយាល័យប្រជាពលរដ្ឋ ដើម្បីឃ្លាំមើលការងារនៅក្នុងការិយាល័យច្រកចេញចូលតែមួយ និងសំរបសំរួលទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងអាជ្ញាធរ ។ យន្តការទាំងនេះ ជាឧបករណ៍ខានមិនបានសំរាប់ធានាការផ្តល់សេវាមួយប្រកបដោយគុណភាព តម្លាភាព និង ទាន់ពេលវេលា ។

ផ្តើមចេញពីទស្សនាទាននេះ រាជរដ្ឋាភិបាលក្នុងក្របខណ្ឌកំណែទំរង់រដ្ឋបាលតែងតែខិតខំគិតគូរផ្សារភ្ជាប់គោលនយោបាយកំណែទំរង់ទៅនឹងជីវភាពផ្ទាល់របស់ប្រជាពលរដ្ឋ ឆ្ពោះទៅរកការទន្ទឹងរង់ចាំ របស់ប្រជាពលរដ្ឋ និងផ្នែកឯកជននានា ដោយបានដាក់ចេញនូវវិធានជាក់ស្តែងស្របតាមធនធានដែលមានតាមរយៈការរៀបចំ និងដាក់អោយដំណើរការ ជាជំហានគំរូនូវច្រកចេញចូលតែមួយនេះ នៅស្រុកបាត់ដំបង និងស្រុកសៀមរាប ។

## *៨- លទ្ធផលដែលទទួលបាន :*

### ក-មូលដ្ឋានបច្ចេកទេសត្រូវបានរៀបចំ

- បានកសាង បញ្ជីសរុបនៃសេវាសាធារណៈផ្នែករដ្ឋបាល ដែលទាក់ទងដល់ការអនុវត្តន៏សិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋមាន ការចុះបញ្ជី ការបញ្ជាក់ និង ការអនុញ្ញាតិ ទៅតាមសមត្ថកិច្ចរបស់ក្រសួងនីមួយៗ
- បានរៀបចំ លក្ខណៈវិនិច្ឆ័យដើម្បីវិភាគ និង កំណត់ថាតើបេសកកម្ម និងសេវាសាធារណៈ ទាំងឡាយណាខ្លះដែលត្រូវផ្ទេរជូនស្រុកបាត់ដំបង និងស្រុកសៀមរាប ដើម្បីអនុវត្តសាកល្បង
- បានធ្វើការណែនាំជាបច្ចេកទេសជូនក្រសួងពាក់ព័ន្ធ ក្នុងការរៀបចំឯកសារ មូលដ្ឋានគតិយុត្តិចាំបាច់មួយចំនួនដើម្បី មានលទ្ធភាពឈានទៅអនុវត្តនូវសេចក្តីសំរេចនេះបាន ។

### ខ-មូលដ្ឋានគតិយុត្តត្រូវបានរៀបចំរួចជាស្រេច

ក្របខណ្ឌគតិយុត្តិ ឯកសារណែនាំផ្នែកបច្ចេកទេសសំរាប់ឱ្យស្រុកបាត់ដំបង និងស្រុកសៀមរាប អនុវត្តន៏ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយបានបញ្ចប់ រួមមាន :

- ប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យច្រកចេញ ចូលតែមួយ នៅស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង
- ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យប្រជាពលរដ្ឋ នៅស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង
- ក្រសួងតាមវិស័យចំនួន៦ ( ក្រសួងឧស្សាហកម្ម ពាណិជ្ជកម្ម សាធារណការ និងដឹកជញ្ជូន វប្បធម៌ ទេសចរណ៍ និង រៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ) ដែលក្រសួងនីមួយៗ ត្រូវបានរៀបចំប្រកាសប្រតិភូកម្មអំណាច ពីក្រសួងជូនដល់ស្រុកសៀមរាប និងស្រុកបាត់ដំបង

បញ្ជីរាយនាមសេវា ដែលត្រូវប្រគល់ជូនស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

- សេចក្តីណែនាំលើការអនុវត្តន៍ ប្រកាសស្តីពី ការធ្វើប្រតិភូកម្មអំណាចរបស់ ក្រសួងតាមវិស័យចំនួន៦ ជូនដល់ ស្រុក សៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង

**៩. ជំហានបន្ទាប់ :**

ត្រូវបំពេញកិច្ចមួយចំនួនជាចាំបាច់ទៀត សំរាប់ដាក់ឱ្យដំណើរការការផ្តល់សេវាកម្មរដ្ឋបាល នៅស្រុកបាត់ដំបង និង ស្រុកសៀមរាប នាដើមឆ្នាំ ២០០៥ ខាងមុខនេះ

- ធ្វើការវាយតម្លៃអំពីសេចក្តីត្រូវការធនធានមនុស្ស និងសម្ភារៈសំរាប់ដំណើរការអនុវត្តគំរោងដោយរួមសហកាជាមួយក្រសួងស្ថាប័នដែលពាក់ព័ន្ធ ។
- រៀបចំការបណ្តុះបណ្តាលមន្ត្រីប្រតិបត្តិគំរោងនៅតាមស្រុកទាំងពីរដោយរួមសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ។
- រៀបចំបង្កើត និងដាក់ឱ្យអនុវត្តកម្មវិធីកន្សោមអាទិភាព ( PMG ) នៅស្រុកទាំងពីរ ដោយសហការជាមួយ ក្រសួងពាក់ព័ន្ធ ។

**ជារួមមកយើងឃើញថា** ការអនុវត្តន៍គោលការណ៍ច្រកចេញ-ចូលតែមួយ នេះអាចនឹងត្រូវពង្រីកទៅស្រុក រឺខ័ណ្ឌ នៃខេត្ត-ក្រុង ផ្សេងៗ ទៀតជាបន្តបន្ទាប់ រឺក៏ឈានទៅដាក់អោយដំណើរការទូទាំងប្រទេស សំរាប់ គាំទ្រដល់គោលនយោបាយ និង យុទ្ធសាស្ត្រ ចតុកោណរបស់រាជរដ្ឋាភិបាលក្នុងការសំរួលដល់ការ វិនិយោគ និងលើកស្ទួយជីវភាពប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ ដោយសារមានការយកចិត្តដាក់ខ្ពស់ របស់ថ្នាក់ដឹកនាំជាន់ខ្ពស់ របស់រាជរដ្ឋាភិបាល និងមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ។

# សកម្មភាព របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល



**ឯកឧត្តម ខៅ ហុងលី** ពិភាក្សាជាមួយឯកឧត្តម អភិបាលខេត្តសៀមរាប ស្តីពី ការរៀបចំអនុវត្តគំរោង សាកល្បងនៅស្រុកបាត់ដំបង នៃខេត្តបាត់ដំបង និងស្រុកសៀមរាប នៃខេត្តសៀមរាប



**ឯកឧត្តម ខៅ ហុងលី** ពិភាក្សាជាមួយឯកឧត្តម អភិបាលស្រុកសៀមរាប ស្តីពី ការរៀបចំអនុវត្តគំរោង សាកល្បងនៅស្រុកបាត់ដំបង នៃខេត្តបាត់ដំបង និងស្រុកសៀមរាប នៃខេត្តសៀមរាប

# ផ្នែកទី១

# គោលនយោបាយ

# និងយុទ្ធសាស្ត្រស្តីពីវិសហមជ្ឈការ

# សេចក្តីព្រាងលើកទី៣ ស្តីពីគោលនយោបាយនិងយុទ្ធសាស្ត្រ ស្តីពីវិសហមជ្ឈការ

( បន្ទាប់ពីកែសំរួលនិងបញ្ចូលយោបល់មួយចំនួនដែលសមស្របតាមបច្ចេកទេស )

DRAFT

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

## សេចក្តីព្រាងលើកទីបី

## ស្តីពី

## គោលនយោបាយ និង យុទ្ធសាស្ត្រ នៃការធ្វើវិសមជ្ឈការ

Third Draft on

De-concentration Policy and Strategy Formulation

DRAFT

## យោងតាម :

- កម្មវិធី " ការបង្វិតរដ្ឋបាលសាធារណៈទៅជិតប្រជាពលរដ្ឋ " ដែលអនុម័តដោយគណៈរដ្ឋមន្ត្រីនៅ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០១
- ស្មារតីនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០២
- ស្មារតីនៃកិច្ចប្រជុំកិរិតបច្ចេកទេសជាមួយក្រសួងគន្លឹះនានា នៅអំឡុងខែ មិនា -មេសា -ឧសភា និង ខែ មិថុនា ឆ្នាំ ២០០២
- ការផ្តល់យោបល់ពីក្រសួង ស្ថាប័ន ពាក់ព័ន្ធលើសេចក្តីព្រាងដំបូងស្តីពីគោលនយោបាយ និង យុទ្ធសាស្ត្រ នៃការធ្វើ វិសហមជ្ឈការ
- របាយការណ៍ទស្សនកិច្ចសិក្សានៅ ខេត្តកំពត ខេត្តព្រះវិហារ ខេត្តព្រៃវែង ខេត្តមណ្ឌលគីរី ខេត្តបាត់ដំបង នាឆ្នាំ២០០៣ ដើម្បីដកស្រង់បទពិសោធន៏វិសហមជ្ឈការ វិមជ្ឈការ និងការអនុវត្តន៏ កម្មវិធីសីលា
- របាយការណ៍ទស្សនកិច្ចសិក្សានៅ ខេត្តស្ទឹងត្រែង ខេត្តពោធិសាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និង ខេត្តសៀមរាប នាឆ្នាំ ២០០៤ ដើម្បីដកស្រង់បទពិសោធន៏វិសហមជ្ឈការ វិមជ្ឈការ និង ការអនុវត្តន៏ កម្មវិធីសីលា
- របាយការណ៍និងអនុសាសន៏របស់ លោក **Patrict Gillbert Desvallons** , លោក **Dominique Henry** និងលោកបណ្ឌិត **Hoffchulte**

DRAFT

# ខ្លឹមសារសង្ខេប

( Executive Summary )

## I - បរិបទ :

តាមរយៈកម្មវិធីបង្វិតរដ្ឋបាលសាធារណៈ ទៅជិតប្រជាពលរដ្ឋដែលអនុម័តដោយគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០១ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានទទួលអាណត្តិជាអ្នកសំរបសំរួលលើការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ នៃការធ្វើវិសហមជ្ឈការ ។

ការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ នេះ ជាការងារបច្ចុប្បន្នភាពដ៏សំខាន់ និងចាំបាច់មួយនៅក្នុងកំណែទំរង់រដ្ឋបាល និង កំណែទំរង់រដ្ឋ ដើម្បីៈ

១- គាំទ្រដល់ការអនុវត្តន៏គោលនយោបាយវិមជ្ឈការ នៅឃុំ-សង្កាត់ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ។

២-កែលំអការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាព និង ការកាត់បន្ថយភាពក្រីក្រ ។

## II- ខ្លឹមសារសំខាន់ៗនៃសេចក្តីព្រាងនេះមានដូចតទៅ :

***1- បែងចែកបានច្បាស់លាស់រវាងមុខងារ និងភារកិច្ច របស់ថ្នាក់កណ្តាល ខេត្ត ក្រុង ស្រុក ខ័ណ្ឌ និង ឃុំ សង្កាត់ :***

**ក- *ថ្នាក់កណ្តាល*** : តួនាទី មុខងាររបស់ថ្នាក់កណ្តាល នឹងផ្តោតទៅលើការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រ និង ត្រួតពិនិត្យតាមដានការអនុវត្តន៏ ។

**ខ- *ខេត្ត-ក្រុង*** : តួនាទី មុខងាររបស់ ខេត្ត-ក្រុងនឹងផ្តោតទៅលើការងាររៀបចំផែនការ និងការវិនិយោគសំរាប់គុណប្រយោជន៏ខេត្ត-ក្រុង និង ការងាររៀបចំដែនដី ។ អភិបាលខេត្ត -ក្រុង គួរដើរតួនាទីជាអ្នកសំរបសំរួលលើការអនុវត្តន៏គោលនយោបាយរបស់រាជរដ្ឋាភិបាល និងវិស័យនានា និងមានអំណាចសំរេចមួយចំនួនតាមរយៈគណៈកម្មាធិការ ឬ ក្រុមប្រឹក្សាអភិវឌ្ឍន៏ខេត្ត -ក្រុង ។

**គ- *ស្រុក -ខណ្ឌ*** :

- តួនាទី មុខងារផ្ទាល់របស់ស្រុក - ខណ្ឌ នឹងផ្តោតទៅលើការងាររដ្ឋបាលទូទៅ ( ដូចជាការងារស្ថិតិពលរដ្ឋ និងការផ្តល់សេវាកម្មរដ្ឋបាល ) ការដោះស្រាយជំលោះថ្នាក់មូលដ្ឋានក្រៅប្រព័ន្ធតុលាការការងារសន្តិសុខ និង គ្រោះមហន្តរាយ ។
- មុខងារស្រុក- ខណ្ឌ ក្នុងការគាំទ្រ ឃុំ -សង្កាត់ :ការពង្រឹងមុខងារស្រុកខ័ណ្ឌ ដើម្បីឱ្យថ្នាក់នេះអាចជួយវិមជ្ឈការឃុំ-សង្កាត់បានមានសារៈសំខាន់ណាស់ ។ តួនាទីរបស់ថ្នាក់ស្រុកទៅលើការអនុវត្តន៏វិមជ្ឈការឃុំ - សង្កាត់ រួមមាន ការសំរបសំរួល ជំរុញ តាមដាន និង វាយតំលៃ ។
- ចំពោះស្រុកទីរួមខេត្តមានលក្ខណៈជាក្រុងត្រូវរៀបចំតាមរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងដោយឡែក

**- ឃុំ - សង្កាត់** : ពង្រឹងមុខងារជាភ្នាក់ងាររដ្ឋរបស់ឃុំ -សង្កាត់ ដោយពិនិត្យលទ្ធភាពផ្ទេរសេវាសាធារណៈ និងធនធានចាំបាច់មួយចំនួនជាជំហានៗជូនឃុំ-សង្កាត់ ( ការងារអត្រានុកូលដ្ឋានបានផ្ទេរជូនរួចហើយ) ។

***2- រៀបចំយន្តការសម្របសម្រួលការអនុវត្តន៏នៅថ្នាក់ខេត្ត -ក្រុង និងស្រុក -ខណ្ឌ ឱ្យបានប្រសើរជាងមុន***

ក- ខេត្ត -ក្រុង គួរបង្កើតគណៈកម្មការផែនការ និង វិនិយោគខេត្ត-ក្រុង ឬ ក្រុមប្រឹក្សាអភិវឌ្ឍន៏ខេត្ត-ក្រុង ដែលសមាសភាពតាមការតែងតាំង ដែលមានភារកិច្ចរៀបចំ និង អនុម័តផែនការ និងវិនិយោគសំរាប់គុណប្រយោជន៏ខេត្ត -ក្រុង ។

ខ- ស្រុក-ខណ្ឌ គួរបង្កើតគណៈកម្មការពិគ្រោះយោបល់ ដែលសមាសភាពតាមការតែងតាំង និងមួយផ្នែកទៀតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នានាក្នុងស្រុក ខណ្ឌនោះ ។

*3- រាល់ការផ្ទេរសមត្ថកិច្ចនីមួយៗត្រូវធ្វើជាជំហានៗ ដោយផ្អែកលើបទពិសោធន៏ក្រៅប្រទេស និង ក្នុងស្រុកមួយចំនួនដូចជា កម្មវិធីសីលា គំរោងសាកល្បងនៅស្រុកឡឹមខេត្តបាត់ដំបង និងសៀមរាបគំរោងមួយចំនួននៅក្រសួងសុខាភិបាល និង ក្រសួងអប់រំ ជាដើម ។*

*4- កែលំអសេវាសាធារណៈដោយប្រើប្រាស់ទស្សនៈទាននៃការបែងចែករវាង សេវាខ្នងទ្រង់ (Back office) និងសេវាជួរមុខ( Front office ) ។ ការកែសំរួលនីតិវិធី នៃការផ្តល់សេវាខ្នងទ្រង់ ជាកិច្ចការចាំបាច់ និងត្រូវឱ្យបានស្របគ្នាជាមួយ ការកែលំអសេវាជួរមុខទើបធានាបាន ការកែលំអសេវាសាធារណៈ ។*

*5- ធ្វើវិសហមជ្ឈការដើម្បីពង្រឹងមុខងារជា បញ្ញត្តិករ (Régulateur) របស់រដ្ឋ និងដើម្បីសំរួលដល់ការធ្វើវិនិយោគ ជាពិសេស សហគ្រាសខ្នាតតូច និង មធ្យម (ការចុះបញ្ជី ការបញ្ជាក់ និងការ អនុញ្ញាត) ។*

*6- ធ្វើវិសហមជ្ឈការដើម្បីកាត់បន្ថយភាពក្រីក្រ គួរផ្តោតជាសំខាន់លើវិស័យសង្គមកិច្ច និង កសិកម្មៈ លើផ្នែកសង្គកិច្ចគួររៀបចំកែលំអ មន្ទីរពេទ្យ សាលារៀន មជ្ឈមណ្ឌលផ្សេងៗដែលអាចផ្តល់សេវាសាធារណៈ សង្គមកិច្ចជូនដល់ប្រជាពលរដ្ឋក្រីក្រ និងចំពោះវិស័យកសិកម្មគួរផ្តោតលើការរៀបចំប្រព័ន្ធធារាសាស្ត្រជំរើសពូជ និងកែលំអដីធ្លី ។ ការបង្កើត សហគមន៍កសិករ សហគមន៏ការពារធនធានធម្មជាតិក៏ជាចំនុចមួយយកចិត្តទុកដាក់ផងដែរ ។* នេះជាការផ្សារភ្ជាប់ការ ធ្វើវិសហមជ្ឈការ និង គោលនយោបាយតាមវិស័យដូចជា (វិស័យអប់រំ វិស័យកសិកម្ម វិស័យសុខាភិបាល និងវិស័យ អភិវឌ្ឍន៏ជនបទ) ។ ការផ្សារភ្ជាប់មានសារៈសំខាន់ណាស់ក្នុងការកាត់បន្ថយភាពក្រីក្រឱ្យមានប្រសិទ្ធភាព ។

*7-ផ្សារភ្ជាប់រវាងគោលនយោបាយវិសហមជ្ឈការទៅនឹងគោលនយោបាយស្តីពីនគូបនីយកម្មៈ*
*កំណើនសេដ្ឋកិច្ច និង ប្រជាពលរដ្ឋនឹងតំរូវឱ្យបង្កើតទីក្រុងមួយចំនួនថែមទៀត ។ ទីក្រុង ឬ ទីប្រជុំជនទាំងនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងតាមរបបគតិយុត្ត ពិសេសដោយឡែកមួយ ទើបធានាបាននូវការអភិវឌ្ឍន៏សេដ្ឋកិច្ចប្រកបដោយចិរភាព* ។

*8- ការគ្រប់គ្រងហិរញ្ញវត្ថុ និង ថវិកា :*

- ថវិកាខេត្ត ក្រុង ជាថវិកាឧបសម្ព័ន្ធរបស់ថវិកាជាតិ និង មានគណនីពិសេស ដែលត្រូវអនុម័តដោយសភាជាតិ
- ថវិកាស្រុក-ខណ្ឌ ជាថវិកានៅក្នុងកញ្ចប់ថវិកាខេត្ត-ក្រុង *ដែលត្រូវមានការសិក្សា ដើម្បីកំនត់ដោយឡែក នៅពេលខាងមុខ ។*
- ពិនិត្យលទ្ធភាព និង កំណត់ធនធានសំរាប់ថ្នាក់ខេត្ត-ក្រុង និង ឃុំ-សង្កាត់ ។ ដោយឡែកអភិបាលខេត្តគួរមានសិទ្ធិអំណាចមួយចំនួន ដើម្បីតាមដាន និង ជំរុញការប្រមូលចំណូលនេះ ។
- គួរបង្កើតឱ្យមានសាខារតនាគារនៅតាមស្រុកដើម្បីធានាការបើកផ្តល់ថវិកាឱ្យឃុំ សង្កាត់បានទាន់ពេលវេលា។
- ចំពោះថវិកា ខេត្ត -ក្រុង និង ឃុំ-សង្កាត់ គួរពិនិត្យលទ្ធភាព ដើម្បីប្រើប្រាស់ប្រព័ន្ធធនាគារសំរាប់ផ្ទេរ ឬទូទាត់ថវិកាលើជំពូកចំណាយចាំបាច់មួយចំនួន ។

***៦- ការគ្រប់គ្រង និង អភិវឌ្ឍន៍ធនធានមនុស្ស :***

- ពង្រឹងឱ្យខេត្តមានលទ្ធភាពរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីរាជការនៅថ្នាក់ខេត្ត -ក្រុង និងផ្តល់លទ្ធភាពឱ្យខេត្តក្រុង មានថវិកាច្បាស់លាស់មួយសំរាប់ការបណ្តុះបណ្តាលនេះ។
- ផ្តល់លទ្ធភាពឱ្យថ្នាក់ខេត្ត -ក្រុង (សាលាខេត្ត និងមន្ទីរខេត្ត) អាចជ្រើសរើសមន្ត្រីរាជការ ឬ បុគ្គលិកជាប់កិច្ចសន្យា ការតែងតាំងមន្ត្រីមួយចំនួន ហើយនិងការដាក់ពិន័យដល់មន្ត្រីដែលប្រព្រឹត្តខុសផងដែរ។
- គួរប្រើប្រាស់មន្ត្រីនៅមន្ទីរផែនការថ្នាក់ខេត្ត -ក្រុងជាសេនាធិការឱ្យក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលដើម្បីផ្សព្វផ្សាយជូនមន្ត្រីថ្នាក់ខេត្ត-ក្រុង ពីការងារទាំងឡាយរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល។
- គួរមានការលើកទឹកចិត្តដល់មន្ត្រីរាជការដែលធ្វើការនៅតំបន់ដាច់ស្រយាលដោយប្រើប្រាស់កម្មវិធីកន្ទ្រោមអាទិភាព ។

---

DRAFT

# ផ្នែកទី ១

# ស្ថានភាពបច្ចុប្បន្ន
# នៃរដ្ឋបាលខេត្ត-ក្រុង និងស្រុក-ខណ្ឌ
# នៅព្រះរាជាណាចក្រកម្ពុជា

DRAFT

# ស្ថានភាពបច្ចុប្បន្ន នៃរដ្ឋបាលខេត្ត ក្រុង និងស្រុក ខណ្ឌ
# នៅ
# ព្រះរាជាណាចក្រកម្ពុជា

តាមការសិក្សានូវច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធ បានឱ្យដឹងថាវិសហមជ្ឈការពុំមែនជារូបភាពថ្មីស្រឡាងទេ ។ រដ្ឋបាលខេត្ត-ក្រុង និង ស្រុក-ខណ្ឌ លើករណីខ្លះ ត្រូវបានដំណើរការតាមរូបភាពវិសហមជ្ឈការរួចទៅហើយ គ្រាន់តែពុំទាន់បានរៀបចំឱ្យទៅជាប្រព័ន្ធវិសហមជ្ឈការមួយមានលក្ខណៈជាក់លាក់ ។ ដោយហេតុនេះ អ្វីដែលចាំបាច់ គឺការដឹងឱ្យបានច្បាស់ពីសមត្ថកិច្ច តួនាទី និងបេសកកម្មជាក់ស្តែងណាខ្លះដែលពាក់ព័ន្ធនឹងដំណើរការវិសហមជ្ឈការដែលមានកន្លងមកនៅកម្ពុជា (ទិដ្ឋភាពគតិយុត្តិនិងរចនាសម្ព័ន្ធរដ្ឋបាល ) ដែលជាមូលដ្ឋានគ្រឹះមួយសំរាប់សំរួលដល់ការ រៀបចំគោលនយោបាយ និង យុទ្ធសាស្ត្រឱ្យសមស្របតាមតថភាពសង្គមកម្ពុជា ។

## ១. អំពីស្ថានភាពភូមិសាស្ត្រ

ប្រទេសកម្ពុជាមានផ្ទៃក្រឡាចំនួន ១៨១ ០៣៥ គ.ម ការ៉េ ប្រជាជនជាង ១២ លាននាក់ ដែលបានបែងចែកការគ្រប់គ្រង ទៅតាមមណ្ឌលរដ្ឋបាលចំនួន ៣ ថ្នាក់ គឺ :

១.១. ខេត្ត-ក្រុង: មានខេត្ត ២០ និងក្រុង ៤

១.២. ស្រុក-ខណ្ឌ : មានស្រុក ១៧៣ និង ខណ្ឌ ១៤

១.៣. ឃុំ-សង្កាត់ : មានឃុំ ១៥១០ និង សង្កាត់ ១១១

ក្រៅពីថ្នាក់ទាំងបីខាងលើនេះ នៅមានភូមិចំនួន ១៣៤០៥ ដែលជាថ្នាក់មួយកំពុងដំណើរការយ៉ាងសកម្មជាពិសេស ទៅលើការងារអភិវឌ្ឍន៍ជនបទ។ នៅពេលសព្វថ្ងៃនេះ ភូមិពុំទាន់មានលក្ខណៈពេញលេញ ជាមណ្ឌលរដ្ឋបាលនៅឡើយទេ ។

## ២. អំពីស្ថានភាពគតិយុត្តិ និង រដ្ឋបាលខេត្ត- ក្រុង ស្រុក-ខណ្ឌ

មាត្រា ១៤៥ - ១៤៦ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បានចែងថា " ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា បែងចែកជាខេត្ត និង ក្រុង ខេត្តចែកជាស្រុក ។ ស្រុកចែកជាឃុំ ។ ក្រុងចែកជាខណ្ឌ ។ ខណ្ឌចែកជាសង្កាត់ ។ ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ- សង្កាត់ ត្រូវគ្រប់គ្រងតាមលក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីការរៀបចំអង្គការមួយ ។

ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិខេត្ត-ក្រុង ឆ្នាំ១៩៩៨ ចែងថា ខេត្តត្រូវចាត់ទុកជានីតិបុគ្គល នៃច្បាប់សាធារណៈ។ ខេត្តមានសមត្ថកិច្ចធនធាន និងថវិកា "ស្វយ័ត" ។ តាមខ្លឹមសារនៃច្បាប់នេះមិនអាចចាត់ខេត្តជា

អង្គភាពវិមជ្ឈការបានទេ បើប្រៀបធៀបនឹងរដ្ឋគ្រាន់តែ អាចហៅថា " ឧបវិសហមជ្ឈការ " ប៉ុណ្ណោះ ។ ខេត្តនៅតែជាមណ្ឌលរដ្ឋបាលមួយរបស់រដ្ឋ នៅក្រោមក្របខណ្ឌ នីតិបុគ្គលនៃ នីតិសាធារណៈ របស់រដ្ឋដដែល ។

## ២.១ ស្ថានភាពគតិយុត្តិនៃថវិកាខេត្ត-ក្រុង

មានលិខិតបទដ្ឋានគតិយុត្តិសំខាន់ចំនួន ៣ បានបង្កើតឱ្យមានថវិកាស្វយ័តនៅថ្នាក់ខេត្ត -ក្រុង :

ប្រកាសលេខ ០៣១ ចុះថ្ងៃទី ១៥ កុម្ភៈ ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ច សិទ្ធិ និងរចនាសម្ព័ន្ធរបស់រដ្ឋបាល ខេត្ត-ក្រុង ត្រង់ ចំនុចទី៨ មាត្រា២ ចែងថា " ខេត្ត-ក្រុងជានីតិបុគ្គលមានសិទ្ធិប្តឹង និងការពារខេត្ត-ក្រុង នៅមុខតុលាការ ទទួលអំណោយ និងអច្ច័យទាន " ។

ច្បាប់ ឆ្នាំ ១៩៩៨ ស្តីពី របបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិខេត្ត-ក្រុងនៅមាត្រា២ចែងថា " ខេត្ត-ក្រុងជានីតិបុគ្គលនៃនីតិសាធារណៈ ........." ។

បទបញ្ញត្តិនេះ មានចែងនៅមាត្រាទី ៦" អភិបាលខេត្ត ជាអ្នករៀបចំថវិកា ខេត្ត-ក្រុង ។ ក្នុងការអនុវត្តន៍ ថវិកានេះ អភិបាលខេត្ត-ក្រុងជាអ្នកគ្រប់គ្រងក្នុងឋានៈជាអាណាប័កដើមខ្សែ និងជាអ្នកបង្កើត និងបិទទូវគណនីរដ្ឋបាល ." ។

មាត្រាទី១៨ " គំរោងរបស់ថវិកាខេត្តក្រុងត្រូវរៀបចំដោយអភិបាលខេត្តក្រុងទៅតាមនីតិវិធីដែលបានកំណត់ដោយ ប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ " ។

អនុក្រឹត្យលេខ៤ ចុះថ្ងៃទី ២០ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមាត្រា ១០ ចែងថា :

" រតនាគារជាតិទទួលបន្ទុកគ្រប់គ្រងបេឡានៃថវិកាជាតិ ថវិកាស្វយ័ត......" ។

" ជួយក្រសួងស្ថាប័ន ខេត្ត-ក្រុងទាំងអស់ ក្នុងការប្រមូលចំណូលផ្សេងៗ និង ការចំណាយ...." ។

២-១-១ ខេត្ត ក្រុង ហាក់ដូចជាមានអំណាចៈ

- ប្រមូលចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ
- ទទួលមូលនិធិពីម្ចាស់អំណោយ
- បញ្ចេចំណាយលើគំរោងនានាដែលទាក់ទងនឹងគុណប្រយោជន៍ខេត្ត ។

២-១-២ ប្រភពធនធានហិរញ្ញវត្ថុនៃថវិកាខេត្ត -ក្រុង :

តាមច្បាប់ស្តីពីហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលចូលជាធរមានតាំងពីខែ កុម្ភៈ ឆ្នាំ ១៩៩៨ ធ្វើអោយ ថវិកាខេត្ត -ក្រុងបានមកពីប្រភពទាំងឡាយដូចខាងក្រោម :

- ចំណូលសារពើពន្ធ មានពន្ធដីធ្លីមិនប្រើប្រាស់ ពន្ធប្រថាប់ត្រា ពន្ធប៉ាតង់ ពន្ធសត្តឃាត និង ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ។

- ចំណូលមិនមែនសារពើពន្ធ មានចំណូលពីផ្សារ ចំណតរថយន្ត កំពង់ផ កន្លែងលក់ដេញថ្លៃ ចំណូលពីទំរង់ការរដ្ឋបាលចំណូលពីការអនុញ្ញាតរដ្ឋបាល ... ។

DRAFT

## ២.២ សមត្ថកិច្ចខេត្ត-ក្រុង

តាមច្បាប់ស្តីពីហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ ខេត្ត-ក្រុង រាជរដ្ឋាភិបាល បានដាក់ចេញនូវអនុក្រឹត្យមួយដើម្បីកំណត់សមត្ថកិច្ច ចំនួនបួនធំៗអោយខេត្ត -ក្រុងគឺ :

- សមត្ថកិច្ចអំពីការរៀបចំផែនការ និង កម្មវិធីអភិវឌ្ឍន៍មានជាអាទិ៍ : ការរៀបចំផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង ការផ្តល់យោបល់ទៅលើកម្មវិធីរបស់ជាតិ ដែលមានការពាក់ព័ន្ធជាមួយខេត្ត-ក្រុង ការរៀបចំកម្មវិធីអភិវឌ្ឍន៍ ខេត្ត -ក្រុង និង ការសំរបសំរួលកម្មវិធីខេត្ត -ក្រុង ជាមួយកម្មវិធីជាតិ ។

- សមត្ថកិច្ចស្តីពីការរៀបចំដែនដីនគរូបនីយកម្ម សំណង់ ជាអាទិ៍ : ការរៀបចំប្លង់គោល ប្លង់ប្រើប្រាស់ដីធ្លី និង សំណង់ ការអនុញ្ញាតផ្សេងៗដែលពាក់ព័ន្ធផ្លូវថ្នល់របស់ខេត្ត ក្រុង ការអនុញ្ញាតអោយកាន់កាប់ដីឡូតិ៍ សាងសង់ ជួសជុល រុះរើសំណង់ ក្នុងសមត្ថកិច្ចរបស់ខេត្ត ក្រុង និងការពិនិត្យបទល្មើសនៃការសាងសង់ ។

- ការកសាង ថែទាំផ្លូវនៅជនបទ និង ផ្លូវរបស់ខេត្ត ក្រុង ។

- សមត្ថកិច្ចអំពីសេវាសាធារណៈជាអាទិ៍ ការបំភ្លឺសាធារណៈ សណ្តាប់ធ្នាប់ចរាចរ ការដឹកជញ្ជូន អគ្គីភ័យ អនាម័យ សុខភាព ការប្រមូលសំរាម ទីផ្សារ សត្តឃាតដ្ឋាន កីឡា វប្បធម៌ និង សួនច្បារ ... ។ល។

ជារួមមក ខេត្ត ក្រុង ជាថ្នាក់មានផែនការ និង ថវិកាដោយឡែក។

## ២.៣ អំពីស្ថានភាពគតិយុត្ត និង រដ្ឋបាលស្រុក-ខណ្ឌ

- ស្រុក ខណ្ឌតាមរដ្ឋធម្មនុញ្ញគឺជាថ្នាក់រដ្ឋបាលដែនដីមួយ ប៉ុន្តែតាមដំណើរការជាក់ស្តែង សព្វថ្ងៃនេះ ស្រុក -ខណ្ឌ មិនទាន់បានបំពេញមុខងារពេញលេញជាថ្នាក់រដ្ឋបាលដែនដីមួយទេ ហាក់ដូចជាផ្នែកមួយ (Fraction) របស់ខេត្ត - ក្រុង ។ ស្រុក - ខណ្ឌ ជាថ្នាក់មួយចាំតែអនុវត្តន៍តាមបញ្ជារបស់ខេត្ត -ក្រុងប៉ុណ្ណោះ។
- ការិយាល័យជំនាញដែលជាខ្សែបណ្តោយរបស់មន្ទីរក្រសួងស្ទើរតែទាំងអស់ មាននៅថ្នាក់ស្រុក- ខណ្ឌ ។ ស្រុក - ខណ្ឌ ធំៗមួយចំនួន មានមន្ត្រីរាជការលើសពី ១០០០នាក់។
- ស្រុក -ខណ្ឌ ពុំមែនជាថ្នាក់មានផែនការឬថវិកាដោយឡែកទេ ។

## ២.៤ តួនាទីអភិបាលខេត្ត ក្រុង

- ប្រធានគណៈបញ្ជាការឯកភាពខេត្ត -ក្រុង
- អាណាប័កនៃថវិកាខេត្ត -ក្រុង ( ថវិកាស្វយ័ត )
- អាណាប័កផ្ទេរសិទ្ធិ នៃថវិកាបណ្តាមន្ទីរជុំវិញខេត្ត ក្រុង
- ផ្តល់យោបល់លើការតែងតាំងប្រធានមន្ទីរ
- ចាត់តំណាងឱ្យទទួលខុសត្រូវលើការគ្រប់គ្រងច្រកទ្វារព្រំដែន
- ប្រធានគណៈកម្មការលទ្ធកម្មសាធារណៈនៅខេត្ត-ក្រុង និងអាចដោះស្រាយវិវាទលើវិស័យរតនាគារ

DRAFT

នៅខេត្ត -ក្រុង

- ប្រធានគណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ដែលជាយន្តការដឹកនាំអនុវត្តន៍កម្មវិធីសីលាខេត្ត
- សំរេចលើផែនការអភិវឌ្ឍន៍របស់ខេត្ត ក្រុង និង បញ្ជូនសំណើមកក្រសួងផែនការ ។

## ២.៥ តួនាទីអភិបាលស្រុក-ខ័ណ្ឌ

- ប្រធានគណៈបញ្ជាការឯកភាពស្រុក-ខ័ណ្ឌ
- ផ្តល់យោបល់លើការតែងតាំងប្រធានការិយាល័យ( ក្រសួងសាធារណការនិងដឹកជញ្ជូនចាប់ផ្តើមអនុវត្ត) ។
- ប្រធានគណៈកម្មការលទ្ធកម្មសាធារណៈនៅស្រុក-ខណ្ឌ
- ធ្វើសំណើទៅក្រសួងមហាផ្ទៃតាមរយៈអភិបាលខេត្ត ដើម្បីតែងតាំងប្រធាន អនុប្រធាន មន្ទីរស្រុក និង ការិយាល័យទាំង ៣ របស់ស្រុក ។
- ចំពោះសេវាសាធារណៈ ធ្វើសៀវភៅគ្រួសារ ធ្វើសំរង់លិខិតអត្រានុកូលដ្ឋាន និងចុះហត្ថលេខាលើលិខិតស្នាមមួយចំនួនដែលឃុំបញ្ជូនមក និងជាភ្នាក់ងារបញ្ជូនបន្តទៅឱ្យសាលាខេត្ត -ក្រុង ឬមន្ទីរជុំវិញ ។

## ២.៦ មន្ទីរជំនាញនានាជុំវិញខេត្ត-ក្រុង

ក្រសួង ស្ថាប័នស្ទើរទាំងអស់របស់រដ្ឋាភិបាល បានបង្កើតអោយមានមន្ទីរមួយនៅថ្នាក់ខេត្ត-ក្រុង និងការិយាល័យនៅថ្នាក់ស្រុក-ខណ្ឌ លើកលែងតែការិយាល័យទេសចរណ៍ ដែលគប្បីពិចារណាឡើងវិញអោយបានរហ័សស្របតាមនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងការិយាល័យពាណិជ្ជកម្មពុំទាន់មាននៅថ្នាក់ស្រុក ។

ចំពោះរបៀបចាត់ចែងការងារនៃមន្ទីរឬអង្គភាពដែលជាខ្សែបណ្តោយទាំងនោះ គឺរដ្ឋមន្ត្រីសាមីក្រសួងមានភារកិច្ចទទួលខុសត្រូវដឹកនាំអនុវត្តន៍គោលនយោបាយរបស់ក្រសួងខ្លួន លើកិច្ចការជំនាញ ការងារបុគ្គលិក (តែងតាំងនិងដកហូតពីមុខតំណែង ប្រធាន អនុប្រធានមន្ទីរ..) និងជាអ្នករៀបចំថវិកានៃបណ្តាអង្គភាពទាំងនោះ ។ ឯអភិបាលខេត្ត -ក្រុង រួមយោបល់លើការងារតែងតាំងផ្លាស់ប្តូរប្រធានមន្ទីរ ។ អភិបាលខេត្ត-ក្រុង ជាអ្នកទទួលសិទ្ធិប្រទានពី រដ្ឋមន្ត្រីសាមីចំពោះ ថវិកាចំណាយ របស់អង្គភាពទាំងនោះ ។

ចំពោះការងារតាមវិស័យ រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័ន អាចវិលែកសមត្ថកិច្ចមួយចំនួន ទៅឱ្យអង្គភាពជំនាញរបស់ខ្លួននៅតាមខេត្ត-ក្រុង ដោយមានគោលការណ៍ណែនាំត្រង់ទៅមន្ត្រីតាមឋានានុក្រមរបស់ខ្លួន ។ ប្រធានមន្ទីរខ្លះ មានសមត្ថកិច្ចគ្រប់គ្រងអង្គភាពប្រត្តិបត្តិការ (Service opérationel ou Front Office) និងសំរេចលើសេវារដ្ឋបាលមួយចំនួន ។

រីឯការត្រួតពិនិត្យវាយតំលៃកិច្ចការតាមវិស័យក្រសួងនីមួយៗ គឺអធិការកិច្ចតាមវិស័យផ្ទាល់របស់ក្រសួងនីមួយៗ សំដៅលើកកំពស់ប្រសិទ្ធភាពការងារ ។ កញ្ចប់ថវិការបស់មន្ទីរ ជាផ្នែកមួយនៃថវិការបស់ក្រសួងសាមីតាមខ្សែបណ្តោយនិងយុទ្ធសាស្ត្រដែលសំរេចដោយប្រធានស្ថាប័ន ។ តាមការជាក់ស្តែងកញ្ចប់នេះ មានសំរាប់តែដំណើរការរដ្ឋបាល និងប្រាក់បៀវត្សតែប៉ុណ្ណោះ ។

DRAFT

## ២.៧ អំពីការគ្រប់គ្រងធនធានមនុស្សនៅថ្នាក់ខេត្ត-ក្រុង

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល លក្ខន្តិកៈដោយឡែក លិខិតបទដ្ឋានគតិយុត្តិមួយចំនួន បានតំរូវឱ្យមានការគ្រប់គ្រងធនធានមនុស្សក្នុងប្រព័ន្ធតែមួយ ព្រោះកម្ពុជាជាឯករដ្ឋ និងស្ទើរតែទាំងស្រុង ជាសមត្ថកិច្ចរបស់ថ្នាក់កណ្តាល ។ ករណីតែងតាំង គេសង្កេតឃើញនៅក្រសួងសុខាភិបាល និងក្រសួងសាធារណការ និងដឹកជញ្ជូន ប្រធានមន្ទីរមានសិទ្ធិតែងតាំងមន្ត្រីក្នុងតំណែងទាបៗនៅថ្នាក់ខេត្ត-ក្រុង និងស្រុក-ខណ្ឌ ។

ប្រកាសលេខ ០៣១ របស់ក្រសួងមហាផ្ទៃ អភិបាលខេត្ត មានសិទ្ធិដាក់ពិន្ទុឱ្យថ្នាក់ដឹកនាំមន្ទីរជុំវិញខេត្ត តែការអនុវត្តន៍ មិនទាន់ដំណើរការបានទៀងទាត់និងបានល្អទេ ព្រោះតាមការអនុវត្តន៍ជាក់ស្តែង ទំនាក់ទំនងខ្សែបណ្តោយពីក្រសួងសាមី មកមន្ទីរមានប្រៀបជាង បើធៀបនឹងទំនាក់ទំនងខ្សែទទឹងរវាងសាលាខេត្ត ក្រុង និងមន្ទីរ និងទំនាក់ទំនងរវាង សាលាខេត្ត ក្រុង និងក្រសួងនានា ។ ចាប់ពីឆ្នាំ១៩៩៨ មកអភិបាលខេត្ត ក្រុង មានសិទ្ធិចូលរួមតែងតាំងប្រធានមន្ទីរដោយធ្វើការផ្តល់យោបល់ តែយោបល់របស់ខេត្តនេះ ក៏មិនអាចយកជាការបានដែរ បើផ្ទុយពីចំណង់ចំណូលចិត្តរបស់ក្រសួងសាមី ។

ការិយាល័យគ្រប់គ្រងបៀវត្សនៃមន្ទីរផែនការ ជាអ្នកធ្វើការសំរបសំរួលការងារធនធានមនុស្សនៅថ្នាក់ខេត្ត-ក្រុង ។

មន្ត្រីរាជការនៅតាមខេត្ត-ក្រុង បើធៀបទៅនឹងទំហំការងារជាក់ស្តែងក៏នៅតែខ្វះគឺខ្វះអ្នកដែលមានជំនាញ និងមានសមត្ថភាព ។

## ២.៨ អំពីបណ្តាញសាខារបស់ថ្នាក់កណ្តាលនៅខេត្ត-ក្រុង និងស្រុក-ខណ្ឌ

ក្រៅពីមន្ទីរ បណ្តាញសាខាជាច្រើន របស់ថ្នាក់កណ្តាលក៏មានតាំងនៅខេត្ត -ក្រុងដែរដូចជា :

- រតនាគារ មានស្ទើរតែនៅគ្រប់ខេត្ត-ក្រុង លើកលែងតែ *ក្រុងកែបមួយ* ដែលពុំទាន់មាន ។
- សាខាពន្ធដារមានស្ទើរតែនៅគ្រប់ខេត្ត-ក្រុង និងស្រុក-ខណ្ឌ លើកលែងតែខេត្តឧត្តរមានជ័យ ដែលពុំទាន់មាន តែកំពុងនឹងរៀបចំអោយមាន ។
- ស្នងការប៉ូលីស អធិការប៉ូលីស និង ប៉ុស្តិប៉ូលីស មានរហូតដល់ឃុំ សង្កាត់ ។
- កងរាជអាវុធហត្ថ មានស្នាក់ការនៅថ្នាក់ខេត្ត-ក្រុង និងស្រុក-ខណ្ឌ ។
- យោធាចែកជាយោធភូមិភាគ ឬមួយក៏ "តំបន់ប្រតិបត្តិការសឹករង" នៅថ្នាក់ខេត្ត-ក្រុង និង "ផ្នែកសឹករង" នៅថ្នាក់ស្រុក-ខណ្ឌ ។
- អគ្គិសនីកម្ពុជាមានសាខាចំនួន ៤ នៅខេត្ត បាត់ដំបង សៀមរាប តាកែវ និងក្រុងព្រះសីហនុ

DRAFT

## ៣_អំពីគំរោងសាកល្បងដែលពាក់ព័ន្ធនឹងវិសហមជ្ឈការតាមវិស័យ

នៅប៉ុន្មានឆ្នាំចុងក្រោយនេះ យើងឃើញមានសេចក្តីផ្តួចផ្តើមសាកល្បងសំខាន់ៗមួយចំនួន ដែលខ្លះមានទំនាក់ទំនងដោយផ្ទាល់ និង ខ្លះទៀតដោយប្រយោលទៅនឹងវិសហមជ្ឈការតាមវិស័យដូចជាៈ គណៈកម្មាធិការ អភិវឌ្ឍន៍ភូមិ នៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ ។ ដំណោះស្រាយតាមវិស័យទូលាយ និងការគ្រប់គ្រងតាមវិស័យទូលាយបូករួមជាមួយកិច្ចសន្យាក្នុង/ក្រៅ ( SWAP, SWIP and Contracting in/out ) និងការអភិវឌ្ឍន៍ស្រុក ខណ្ឌ ដោយបង្កើនល្បឿន (ADD) នៅក្នុងក្រសួងសុខាភិបាល ។ កម្មវិធីសកម្មភាពអាទិភាព (PAP) កម្មវិធីវិនិយោគសាធារណៈ(PIP) ដែលរៀបចំដោយក្រសួងផែនការ កម្មវិធីសីលាដែលផ្តោតជាពិសេសទៅលើការអភិវឌ្ឍន៍ជនបទ និង មានរួមបញ្ចូលនូវកម្មវិធីអភិវឌ្ឍន៍ ខេត្តមួយចំនួនតូចដែរតាមរយៈមូលនិធិអភិវឌ្ឍន៍ខេត្ត ក្រុង ( PIF) និងការអភិវឌ្ឍន៍កសិកម្មដើម្បីគាំទ្រដល់កម្មវិធី សីលា (ADESS)។ ក្រៅពីនេះនៅមានគំរោងមួយចំនួនទៀត ដែលមានលក្ខណៈស្រដៀងគ្នា នឹងបណ្តាគំរោងខាងលើនេះដែរដូចជា ការបង្កើតសហគមន៍ ការពារធនធានធម្មជាតិ និងព្រៃឈើ សហគមន៍កសិករ សហគមន៍នេសាទ និង *សហគមន៍កសិករប្រើប្រាស់ទឹក* នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងបរិស្ថាន និងក្រសួងធនធាន ទឹក និងឧត្តុនិយម ។ល។

---

DRAFT

# ផ្នែកទី ២

# គោលនយោបាយ និង យុទ្ធសាស្ត្រ
# នៃការធ្វើវិសហមជ្ឈការ

DRAFT

# គោលនយោបាយ និង យុទ្ធសាស្ត្រ នៃ ការធ្វើវិសហមជ្ឈការ

## ១. សេចក្តីផ្តើម

ការរៀបចំគោលការណ៍វិសហមជ្ឈការឱ្យស្របតាមតថភាពសង្គមកម្ពុជា ជាកត្តាកំណត់នូវជោគជ័យនៃការដាក់ឱ្យដំណើរការនូវប្រព័ន្ធវិសហមជ្ឈការនៅកម្ពុជា ។ ទោះបីមានប្រទេសជាច្រើនធ្លាប់អនុវត្តនូវប្រព័ន្ធនេះហើយក៏ដោយក៏យើងពុំអាចចំលង ឬយកគំរូណាមួយមកអនុវត្តនៅប្រទេសយើងបានទេ ព្រោះប្រទេសនីមួយៗមានគោលការណ៍ផ្ទាល់ខ្លួនរបស់គេ ។ គំរូទាំងនេះគ្រាន់តែជាបទពិសោធន៍សំរាប់ធ្វើការពិចារណាជាមួយអ្វីដែលយើងហៅថា តថភាពសង្គមកម្ពុជា រួមមានទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ប្រជាសាស្ត្រ ភូមិសាស្ត្រ និង រដ្ឋបាល-ច្បាប់របស់ប្រទេសយើង ។

បន្ទាប់ពីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់រួចមក ការដាក់ឱ្យដំណើរការវិមជ្ឈការនៅឃុំ-សង្កាត់បានជះឥទ្ធិពលដល់មុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ស្រុក- ខណ្ឌ ថ្នាក់ខេត្ត - ក្រុង និងរហូតដល់ថ្នាក់កណ្តាល ។ ដំណើរការវិមជ្ឈការដែនដីនៅឃុំ - សង្កាត់នេះ ទោះជាមានអត្ថប្រយោជន៍ជាច្រើនយ៉ាងណាក៏ដោយ ក៏នឹងនាំមកនូវគុណវិបត្តិមួយចំនួន បើសិនជាមិនបានគិតទុកជាមុន ។ អាស្រ័យហេតុនេះ ដើម្បីឆ្លើយតបទៅ នឹងការជះឥទ្ធិពលរបស់វិមជ្ឈការនៅឃុំ- សង្កាត់ និង ដើម្បីធ្វើការងារវិសហមជ្ឈការឱ្យបានល្អ មុនអ្វីៗទាំងអស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មការជាតិគាំទ្រឃុំ-សង្កាត់ ត្រូវរៀបចំឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រនៃការធ្វើវិសហមជ្ឈការ នេះឱ្យបានទាន់ពេលវេលា និងស្របគ្នាជាមួយល្បឿនវិមជ្ឈការ នៅឃុំ-សង្កាត់ ។ ការរៀបចំឯកសារ គោលនយោបាយ និង យុទ្ធសាស្ត្រនៃការធ្វើវិសហមជ្ឈការនេះ ដើម្បីមានគោលគំនិតល្អៗ និង មានការឯកភាពគ្នាអំពី និយមន័យស្តីពី វិសហមជ្ឈការសំរាប់បញ្ចូលទៅក្នុងច្បាប់រៀបចំអង្គការស្តីពីការរៀបចំរដ្ឋបាលដែនដី និងមួយចំនួនទៀតសំរាប់ធ្វើជាឧបករណ៍កែលំអសេវាសាធារណៈ និងកែលំអគោលនយោបាយតាមវិស័យផ្សេងៗទៀត ជាពិសេសការកាត់បន្ថយនូវភាពក្រីក្រ ព្រោះថាវិមជ្ឈការ និងវិសហមជ្ឈការនឹងចូលរួមកាត់បន្ថយនូវភាពក្រីក្រយ៉ាង មានប្រសិទ្ធភាពនៅគ្រប់ទីកន្លែងទាំងអស់ ។

បទពិសោធន៍របស់ប្រទេសមួយចំនួន បង្ហាញថាសេវាសាធារណៈដែលផ្តល់ដោយរដ្ឋបាលមូលដ្ឋានតែងមានប្រសិទ្ធភាពជាងការផ្តល់ដោយរដ្ឋបាលកណ្តាល ។ វត្ថុបំណងចម្បងបំផុតនៃវិមជ្ឈការ និងវិសហមជ្ឈការ គឺ បង្កើនលទ្ធិប្រជាធិបតេយ្យដោយមានការចូលរួមរបស់តួអង្គទាំងនៅគ្រប់លំដាប់ថ្នាក់ក្នុងការដោះស្រាយបញ្ហាសង្គម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចឱ្យបានសព្វទីកន្លែង ជាពិសេសនៅឯមូលដ្ឋាន ។ តាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការមានន័យថាបើកទូលាយឱ្យរដ្ឋបាលមូលដ្ឋាន និងប្រជាពលរដ្ឋចូលរួមកាន់តែសកម្មថែមទៀតក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍

សេដ្ឋកិច្ច-សង្គម ។ ការគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ និង ការកាត់បន្ថយភាពក្រីក្រ គឺជាបញ្ហាដែលមានទំនាក់ទំនងគ្នា និងជះឥទ្ធិពលឱ្យគ្នាទៅវិញទៅមក ។ បញ្ហានេះ កំពុងត្រូវបានយកចិត្តទុកដាក់កាន់តែច្រើនឡើងៗនៅបណ្តាប្រទេសជិតខាងយើងនេះ ។

## ២. គោលនយោបាយនៃការធ្វើវិសហមជ្ឈការ

**គោលដៅនៃការកំណត់នូវគោលនយោបាយ នៃការធ្វើវិសហមជ្ឈការនេះគឺដើម្បីបានគោលគំនិតធំៗមួយចំនួនសំរាប់រៀបចំនៅក្នុងច្បាប់អង្គការស្តីពីរដ្ឋបាលដែនដី ដោះស្រាយផលប៉ះពាល់ដែលបានកើតចេញពីដំណើរការវិមជ្ឈការនៅ ឃុំ - សង្កាត់ និង សំរាប់យកទៅអនុវត្តន៍សាកល្បង ឬទាំងស្រុង តាមបែបវិសហមជ្ឈការនៅតាមវិស័យនានា។**

២.១ ការរៀបចំគោលនយោបាយនៃការធ្វើវិសហមជ្ឈការឱ្យបានសមស្របតាមតថភាពជាក់ស្តែងរបស់កម្ពុជា គឺត្រូវឈរលើមូលដ្ឋាន ដូចតទៅ :

- *ត្រូវគោរពនូវគោលការណ៍បច្ចេកទេសជាមូលដ្ឋាននៃការធ្វើវិសហមជ្ឈការក្នុងក៏រិតសមស្រប ក្នុងការដាក់ឱ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងតាមបែបវិសហមជ្ឈការនៅកម្ពុជា ។*
- *វិសហមជ្ឈការជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយដទៃទៀត ដូចជា វិមជ្ឈការបច្ចេកទេស វិមជ្ឈការដែនដី និងឯកជនភាវូបនីយកម្ម ដើម្បីកែលំអការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋមានប្រសិទ្ធភាពទាន់ពេលវេលា និងតាមតំលៃសមរម្យ ។ ហើយមធ្យោបាយទាំង៤នេះ នឹងត្រូវដើរទន្ទឹមគ្នា*
- *តាមឯកសារផ្លូវការនានា និងតាមការអនុវត្តន៍ជាក់ស្តែងរបស់រាជរដ្ឋាភិបាល មុខងាររបស់រដ្ឋ បានដើរតួជាដៃគូ ឬជាបញ្ញត្តករ របស់ផ្នែកឯកជន ។*
- *ប្រទេសកម្ពុជាក៏រិតផ.ស.សមានប្រហែល២៦១ដុល្លាអាមេរិកនៅឆ្នាំ២០០០និងប្រមាណ២៥៩ដុល្លាអាមេរិកនៅឆ្នាំ២០០១ និងយោងតាមលទ្ធផលអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៩ អត្រានៃភាពក្រីក្រទូទាំងប្រទេសមានប្រហែល ៣៦ % ។ រាជរដ្ឋាភិបាលបានចាត់ទុកការកាត់បន្ថយភាពក្រីក្រ ជាកម្មវិធីអាទិភាពបំផុត ដោយបានដាក់ចេញរួចមកហើយនូវយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (PRSP) និងផែនការអភិវឌ្ឍន៍ សេដ្ឋកិច្ច-សង្គមកិច្ច លើកទី២ (SEDP II) និង បានកំណត់នូវវិស័យអាទិភាពចំនួន ៤ មានវិស័យអប់រំ សុខាភិបាល សង្គមកិច្ច និងអភិវឌ្ឍន៍ជនបទ ។*

### ២.២ ត្រូវគោរពនូវគោលការណ៍បច្ចេកទេសជាមូលដ្ឋាននៃការធ្វើវិសហមជ្ឈការ

#### ២.២.១ កំណត់ឱ្យបានច្បាស់ពីលក្ខន្តិកៈគតិយុត្ត (Statut juridique) របស់ខេត្ត ក្រុងឡើងវិញ :

- ***រដ្ឋបាលវិសហមជ្ឈការ និង នីតិបុគ្គលៈ*** ក្នុងប្រព័ន្ធវិសហមជ្ឈការ អង្គភាពទទួលខុសត្រូវនៅនឹងមូលដ្ឋានផ្ទាល់ គេហៅថារដ្ឋបាលវិសហមជ្ឈការ ។ មូលដ្ឋាន ឬតំបន់ដែលរដ្ឋបាលវិសហមជ្ឈការនេះគ្រប់គ្រង នៅតែជាមណ្ឌលរដ្ឋបាលរបស់រដ្ឋដដែល មានន័យថា មណ្ឌលរដ្ឋបាលត្រូវឋិតនៅក្រោមនីតិបុគ្គលរបស់រដ្ឋ ។ រដ្ឋបាលវិសហមជ្ឈការនេះ គ្មានបុគ្គលភាពគតិយុត្ត ដូចរដ្ឋបាលវិមជ្ឈការទេ ។

- ***ការប្រើប្រាស់ពាក្យនីតិបុគ្គល និង ស្ថានភាពអនុវត្តន៍ជាក់ស្តែង របស់រដ្ឋបាលខេត្ត-ក្រុង :***

មានបទដ្ឋានគតិយុត្តចំនួន ៣ បានចែងថាខេត្ត -ក្រុងមាននីតិបុគ្គលៈ

-ប្រកាសលេខ ០៣១ ចុះថ្ងៃទី ១៥ កុម្ភះ ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ច សិទ្ធិ និង រចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្ត -ក្រុង ត្រង់ចំនុចទី ៨ មាត្រា២ ចែងថា " ខេត្ត - ក្រុង ជា **នីតិបុគ្គល** មានសិទ្ធិប្តឹងនិងការពារខេត្ត - ក្រុង នៅមុខ តុលាការ ទទួល អំណោយ និងអច្ច័យទាន " ។

- ព្រះរាជក្រមលេខ ២៩៨-០៣ ជស.រកតចុះថ្ងៃទី ១០ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិខេត្ត -ក្រុងនៅមាត្រា២ចែងថា "**ខេត្ត-ក្រុង ជានីតិបុគ្គលនៃនីតិសាធារណៈ** " ។

✧ បទបញ្ញត្តិនេះ មានចែងនៅមាត្រា៦ " អភិបាលខេត្ត-ក្រុងជាអ្នករៀបចំថវិកាខេត្ត-ក្រុង ។ ក្នុងការអនុវត្តន៍ ថវិកានេះ អភិបាលខេត្តក្រុង ជាអ្នកគ្រប់គ្រងក្នុងឋានៈជាអាណាប័កដើមខ្សែ និងជាអ្នកបង្កើត និង បិទទូវគណនីរដ្ឋបាល " ។

✧ មាត្រា១៨ " គំរោងរបស់ថវិកាខេត្ត-ក្រុង ត្រូវរៀបចំដោយអភិបាលខេត្ត-ក្រុង ទៅតាមនីតិវិធីដែលបានកំនត់ដោយប្រកាសរបស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ។

✧អនុក្រឹត្យលេខ៤ អនក្រ ចុះថ្ងៃ ទី២០ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មាត្រា ១០ ចែងថា :" រតនាគារជាតិទទួលបន្ទុកគ្រប់គ្រងបេឡានៃថវិកាជាតិ **៥ទិភាស្វយ័ត**...។ ជួយក្រសួង-ស្ថាប័ន ខេត្ត-ក្រុង ទាំងអស់ក្នុងការប្រមូលចំណូលផ្សេងៗ និង ការចំណាយ..." ។ សព្វថ្ងៃនៅខេត្ត -ក្រុងហាក់ដូចជាមាន :

- ការប្រមូលចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ
- ការទទួលមូលនិធិពីម្ចាស់អំណោយ
- ការបញ្ចាចំណាយលើគំរោងនានាដែលទាក់ទងនឹងគុណប្រយោជន៍ខេត្ត ។

ដូច្នេះខេត្ត-ក្រុង មានអំណាចមួយមិនច្បាស់លាស់ និងស្ថានភាពគតិយុត្តិជានីតិបុគ្គលមិនពេញលេញ អាស្រ័យហេតុនេះ ការកំណត់ពីលក្ខន្តិកៈគតិយុត្តិ (Statut juridique) របស់ខេត្ត-ក្រុងឡើងវិញជាការចាំបាច់ និងជាចំនុចមួយខានមិនបានដែលត្រូវរៀបចំនៅក្នុងឯកសារនេះ ថាតើគួររក្សាទុកឬធ្វើការលុបចោលនូវនីតិបុគ្គលមិនពេញលក្ខណៈនេះ (Personne Morale non qualifiée) ? ។

DRAFT

➢ *ជំរើសគោលនយោបាយ :*

*ស្ថានភាពគតិយុត្តរបស់ខេត្ត-ក្រុងសំរាប់ថ្ងៃអនាគត ជាជំរើសបច្ចេកទេស ទោះជាមានបទដ្ឋានគតិយុត្តិសំខាន់ៗ ចំនួន ៣ បានចែងថាខេត្ត-ក្រុងជានីតិបុគ្គលមែនក៏ដោយ ក៏ស្ថានភាពគតិយុត្តិបច្ចុប្បន្នរបស់ខេត្ត-ក្រុងជានីតិបុគ្គលនៅតែមិនទាន់ពេញលក្ខណៈ ។ នៅក្នុងក្របខ័ណ្ឌវិសហមជ្ឈការ ខេត្ត-ក្រុង គ្រាន់តែជាមណ្ឌលរដ្ឋបាលមួយដែលត្រូវឋិតនៅក្រោមបុគ្គលភាពរបស់រដ្ឋដដែល ឬ ហៅម្យ៉ាងទៀតថារដ្ឋបាលវិសហមជ្ឈការ ។ ដូច្នេះគួរចៀសវាងការប្រើប្រាស់ពាក្យ " នីតិបុគ្គល " សំរាប់រដ្ឋបាលខេត្ត-ក្រុង ព្រោះខេត្ត-ក្រុង ត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌបុគ្គលភាពគតិយុត្តិរបស់រដ្ឋ ពោលគឺ ខេត្ត-ក្រុងគ្រាន់តែជាមណ្ឌលរដ្ឋបាលរបស់រដ្ឋ ៖*

### ២.២.២ ការផ្ទេរអំណាច និងមុខងារទៅឱ្យថ្នាក់ក្រោមត្រូវផ្សារភ្ជាប់ជាមួយការផ្ទេរធនធាន

មណ្ឌលរដ្ឋបាលវិសហមជ្ឈការ មិនមានធនធាននិងទ្រព្យសម្បត្តិផ្ទាល់ខ្លួនទេ ដែលខុសពីរដ្ឋបាលវិមជ្ឈការមានធនធាន និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនតាមការកំណត់របស់ច្បាប់ ។ រដ្ឋបាលវិសហមជ្ឈការនេះ នៅតែប្រើប្រាស់មធ្យោបាយរបស់រដ្ឋ ជាពិសេសមធ្យោបាយហិរញ្ញវត្ថុ ដូចមានគ្រោងក្នុងថវិការបស់រដ្ឋ ដែលអនុម័តដោយសភាខុសពីថវិកា ផ្ទាល់របស់រដ្ឋបាលវិមជ្ឈការដែលអនុម័តដោយក្រុមប្រឹក្សាជាប់ឆ្នោត។

➢ *ជំរើសគោលនយោបាយ :*

- *ធនធានហិរញ្ញវត្ថុខេត្ត -ក្រុង ត្រូវតែជាផ្នែកមួយនៅក្នុងថវិការបស់រដ្ឋ ។ ចំណូល និងចំណាយរបស់ខេត្ត -ក្រុង ត្រូវបញ្ចូលទៅក្នុងថវិកាឧបសម្ព័ន្ធ និងត្រូវបង្កើតគណនីពិសេសនៅក្នុងរតនាគារ ។ ដំណោះស្រាយបែបនេះអាចសមស្របតាមបច្ចេកទេសផង និងអាចជួយសំរួលដល់ការអភិវឌ្ឍន៍ខេត្ត -ក្រុងផង។*
- *ការផ្ទេរមុខងារ និង អំណាច គួរតែឱ្យបង្កើនសមាមាត្ររវាងថវិកាដែលត្រូវចំនាយសំរាប់វិនិយោគនៅថ្នាក់ខេត្ត -ក្រុង ឃុំ -សង្កាត់ទៅនឹងថវិកាជាតិ ។ ថវិកាស្រុក-ខណ្ឌ ជាថវិកានៅក្នុងកញ្ចប់ថវិកាខេត្ត-ក្រុងដែលមានបែងចែកសន្ទស្សន៍ច្បាស់លាស់អំពីចំណាយរដ្ឋបាល និង លើកលែងតែស្រុកដែលមានលក្ខណៈជាក្រុង (ស្រុកសៀមរាប និង ស្រុក បាត់ដំបង) ត្រូវមានការកំនត់ដោយឡែក។*

### ២.២.៣ គោលការណ៍ជាមូលដ្ឋានដទៃទៀតរួមមាន :

- *ការធ្វើវិសហមជ្ឈការ ត្រូវបែងចែកការទទួលខុសត្រូវឱ្យបានច្បាស់លាស់។*
- *ថ្នាក់មួយ ការសំរេចមួយ និងមានការទទួលខុសត្រូវមួយ។*
- *បែបបទពិសេសនៃការត្រួតពិនិត្យតាមបែបវិសហមជ្ឈការ គឺការត្រួតពិនិត្យឋានានុក្រម។*

### ក១. ការធ្វើវិសហមជ្ឈការ ត្រូវបែងចែកការទទួលខុសត្រូវឱ្យបានច្បាស់លាស់ :

- ការទទួលខុសត្រូវ ត្រូវបែងចែកជា ៣ កំរិតខុសៗគ្នាគឺ :

កំរិតទី ១- ការទទួលខុសត្រូវលើគោលនយោបាយ

កំរិតទី ២- ការទទួលខុសត្រូវលើការចាត់ចែង

កំរិតទី ៣- ការទទួលខុសត្រូវលើការអនុវត្តន៍

- នៅតាមបណ្តាក្រុមហ៊ុនឯកជនបានយកគោលការណ៍ *នេះ ទៅប្រើដែរ* ដោយក្រុមប្រឹក្សាភិបាលទទួលខុសត្រូវលើគោលនយោបាយរបស់ក្រុមហ៊ុន ។ នាយកប្រតិបត្តិទទួលខុសត្រូវលើការងារចាត់ចែង និងផ្នែកផ្សេងៗជាអ្នកប្រតិបត្តិ ។ នៅតាមបណ្តាសហគ្រាសសាធារណៈក៏អនុវត្តន៍តាមគោលការណ៍នេះដែរ ដោយមានក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ និងប្រតិបត្តិករ ។
- តាមលក្ខខណ្ឌនៃរដ្ឋបាលវិមជ្ឈការ ដាច់ខាតត្រូវមានក្រុមប្រឹក្សា ឬ អង្គសំរាប់ចេញសេចក្តីសំរេច និង អង្គប្រតិបត្តិដែលចាត់ចែង ។
- បើគិតតាមលក្ខខណ្ឌភូមិសាស្ត្រ ជាពិសេសការគ្រប់គ្រងដែនដីតាមគោលការណ៍វិសហមជ្ឈការ ការទទួល-ខុសត្រូវលើគោលនយោបាយនិងការឯកភាពជាតិ ត្រូវរ៉ាប់រងដោយថ្នាក់កណ្តាល ការចាត់ចែងគួរត្រូវរ៉ាប់រងដោយថ្នាក់រដ្ឋបាលដែនដីណាមួយដែលសមស្រប (ឧទា.ខេត្ត-ក្រុង នៅប្រទេសកម្ពុជា) និងការប្រតិបត្តិគួររ៉ាប់រង ដោយស្រុក និង ឃុំ ។

➢ ***ជំរើសគោលនយោបាយ :***

***សំរាប់ពេលអនាគត រដ្ឋបាលកណ្តាល ត្រូវផ្តោតតែទៅលើបេសកកម្ម ជាយុទ្ធសាស្ត្រ ដូចជាការងារធ្វើគោលនយោបាយ ការណែនាំ បទបញ្ញត្តិ តាមដាន និង ការត្រួតពិនិត្យ ។ រីឯការងារចាត់ចែង និងប្រតិបត្តិនឹងត្រូវផ្ទេរជាបណ្តើរៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោម ។***

## ***ក២~ ថ្នាក់មួយ ការសំរេចមួយ មានការទទួលខុសត្រូវមួយ និងត្រូវមានក្រុមប្រឹក្សាឬគណៈកម្មការសំរបសំរួលមួយ :***

សព្វថ្ងៃ រដ្ឋបាលមាន៤ថ្នាក់គឺ រដ្ឋបាលកណ្តាល រដ្ឋបាលខេត្ត-ក្រុង រដ្ឋបាលស្រុក ខណ្ឌ និងរដ្ឋបាល មូលដ្ឋាន ឃុំ -សង្កាត់។ តាមការជាក់ស្តែង ការសំរបសំរួលនៅថ្នាក់កណ្តាល មានភាពល្អប្រសើរ រាល់ការងារធំៗរបស់ជាតិ សំរេចឡើងដោយគណៈរដ្ឋមន្ត្រី។ រីឯការសំរបសំរួលនៅថ្នាក់ខេត្ត-ក្រុង និងស្រុក-ខណ្ឌ ពុំទាន់ធ្វើបានល្អទេ អភិបាលខេត្ត ក្រុងភាគច្រើនតែងត្អូញត្អែថា "មេមាន់បណ្តើរកូនទា" ដោយសារពុំទាន់មានយន្តការ និងលិខិតបទដ្ឋានច្បាស់លាស់សំរាប់សំរបសំរួល ដូច្នេះហើយ នៅតាមខេត្ត-ក្រុង ខ្លះលើវិស័យមួយអាចមានសេចក្តីសំរេចពីរ មួយធ្វើឡើងដោយអភិបាលខេត្ត និង មួយទៀតធ្វើឡើង ដោយប្រធានមន្ទីរ ។

➢ ***ជំរើសគោលនយោបាយ:***

- ***នៅគ្រប់កំរិតរដ្ឋបាលដែនដីទាំងអស់ គួរបង្កើតក្រុមប្រឹក្សាឬគណៈកម្មការ ។***

DRAFT

- *នៅថ្នាក់ខេត្ត-ក្រុងត្រូវបង្កើតគណៈកម្មការផែនការនិង វិនិយោគ ឬក្រុមប្រឹក្សាអភិវឌ្ឍន៍ ខេត្ត-ក្រុងដែលមានប្រធានមន្ទីរផែនការ ជា លេខាធិការ ។*
- *នៅថ្នាក់ស្រុក-ខណ្ឌត្រូវបង្កើតគណៈកម្មាធិការសំរបសំរួល និង ពិគ្រោះយោបល់លើការងារផែនការ និង អភិវឌ្ឍន៍ របស់ឃុំ-សង្កាត់ ដែលមានប្រធានការិយាល័យស្រុក-ខណ្ឌ ជាលេខាធិការ ។*
- *ថ្នាក់ឃុំ-សង្កាត់បានបង្កើតក្រុមប្រឹក្សាតាមរយៈការបោះឆ្នោត រួចហើយ ។*

### *៣៣- បែបបទពិសេសនៃការត្រួតពិនិត្យតាមបែបវិសហមជ្ឈការ គឺការត្រួតពិនិត្យឋានានុក្រមៈ*

កាលណាថ្នាក់កណ្តាល បានរំលែកអំណាចខ្លះឱ្យអង្គភាពក្រោមឋានានុក្រមរបស់ខ្លួនធ្វើការសំរេចនៅនឹងកន្លែងលើករណីខ្លះ នោះហៅថា វិសហមជ្ឈការ ។ អង្គភាពក្រោមឋានានុក្រមនោះ ត្រូវចេញសេចក្តីសំរេចលើកិច្ចការមួយចំនួនក្នុងនាមអំណាចកណ្តាលឬក្នុងនាមរដ្ឋដោយមានចែងនូវលក្ខខ័ណ្ឌយ៉ាងច្បាស់លាស់នៅក្នុងលិខិតបទដ្ឋានគតិយុត្ត និងមានការត្រួតពិនិត្យតាមឋានានុក្រមដ៏ហ្មត់ចត់ពីថ្នាក់កណ្តាល ។ ការត្រួតពិនិត្យតាមឋានានុក្រមរបស់ថ្នាក់កណ្តាលដែលមានលក្ខណៈពិសេសដូចតទៅ :

- ថ្នាក់លើមានសិទ្ធិពេញលេញក្នុងការលុបចោល (Le pouvoir d'annulation) រាល់សេចក្តីសំរេចខុសច្បាប់របស់ថ្នាក់ក្រោមដោយមិនចាំបាច់ប្តឹងទៅតុលាការដូចនៅក្នុងប្រព័ន្ធវិមជ្ឈការ ។
- ថ្នាក់លើមានសិទ្ធិកែសំរួល (Le pouvoir de réformation) លើសេចក្តីសំរេចខុសឆ្គងមួយចំនួនរបស់ថ្នាក់ក្រោម ។
- បើសិនថ្នាក់ក្រោមចេញសេចក្តីសំរេចមិនប្រក្រតីច្រើនលើកច្រើនសារពេក ថ្នាក់លើអាចដកការងារនេះមកធ្វើខ្លួនឯងវិញបាន (Le pouvoir de substitution) ក្នុងបំណងបង្ការកុំឱ្យមានកំហុសតទៅទៀត និងបំពេញការខ្វះខាតរបស់ថ្នាក់ក្រោម ។

➢ *ជំរើសគោលនយោបាយ :*

- *ក្នុងក្របខ័ណ្ឌវិមជ្ឈការ ឃុំមានមុខងារពីរ គឺ មុខងារផ្ទាល់ និង មុខងារជាតំណាងរដ្ឋ ។ ដូច្នេះពេលអនុវត្តមុខងារណាមួយជំនួសឱ្យរដ្ឋ មេ ឃុំ-សង្កាត់ ត្រូវធ្វើរបាយការណ៍ជូនអភិបាលស្រុក-ខណ្ឌ និងមានការត្រួតពិនិត្យដោយផ្ទាល់ពី អភិបាល ស្រុក-ខណ្ឌ ។ អំណាចត្រួតពិនិត្យរបស់អភិបាលស្រុក-ខណ្ឌ នេះតំរូវឱ្យមានប្រតិភូកម្មអំណាចពីអភិបាល ខេត្ត-ក្រុង តាមរយៈក្រសួងមហាផ្ទៃ ។*
- *អភិបាលខេត្ត-ក្រុង តំណាងឱ្យរាជរដ្ឋាភិបាល និងប្រធានមន្ទីរទាំងអស់នៅក្នុងខេត្ត ។ អភិបាលខេត្ត-ក្រុងគ្រាន់តែពិនិត្យ និងឯកភាពលើរបាយការណ៍របស់បណ្តាមន្ទីរតាមវិស័យក្នុងខេត្ត និងត្រូវធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីនីមួយៗអំពីការអនុវត្តន៍ តាមជានវិស័យក្នុងខេត្តរបស់ខ្លួន ដើម្បីមានការទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រីទាំងនេះ ។ ដើម្បីបំពេញមុខងារជាតំណាងនេះបានអភិបាលខេត្ត-កុង ត្រូវមានតួនាទីជាអ្នកសំរបសំរួល*

លើការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល និងវិស័យនានា និងមានអំណាចសំរេចមួយចំនួនតាមរយៈគណៈកម្មាធិការ ឬ ក្រុមប្រឹក្សាអភិវឌ្ឍន៍ខេត្ត ក្រុង ។

- ទំនាក់ទំនងរវាងប្រធានមន្ទីរ និងរដ្ឋមន្ត្រីក្រសួងសាមី ជាទំនាក់ទំនងតាមឋានានុក្រមមិនដាច់ខាតព្រោះប្រធានមន្ទីរជាមន្ត្រីក្រោមឋានានុក្រមរបស់អភិបាលខេត្តមួយផ្នែកដែរ (ខុសពីទំនាក់ទំនងរបស់រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ជាមួយប្រធានសាខាគយ ពន្ធដារ.........ដែលទំនាក់ទំនងនេះគេហៅថា " ទំនាក់ទំនងឋានានុក្រម ដាច់ខាត " ។

## ៣_ យុទ្ធសាស្ត្រនៃការធ្វើវិសហមជ្ឈការ

ការធ្វើវិមជ្ឈការ និង វិសហមជ្ឈការ ជាដំណើរការកំណែទំរង់មួយយ៉ាងធំ ឬអាចថា ជាបដិវត្តន៍ក៏បានដែរ ។ ដូច្នេះផលប៉ះពាល់ជាវិជ្ជមានក្តី ឬអវិជ្ជមានក្តីត្រូវតែកើតឡើងដោយចៀសពុំរួច ។ ដូច្នេះវាពុំមែនជាការងាយស្រួលទេក្នុងការជំរុញល្បឿនកំណែទំរង់ដ៏ធំនេះ នៅពេលដែលធនធានរបស់យើងនៅមានកំរិត ហើយដោយលៃយ៉ាងណាកុំឱ្យមានផលប៉ះពាល់ទៀតនោះ ។ ហេតុនេះ ការរៀបចំយុទ្ធសាស្ត្រនេះ **ក្នុងបំណងសំរេចឱ្យបាននូវការផ្លាស់ប្តូរជាជុំកំភួន (កំណែទំរង់នេះឱ្យបានស៊ីជំរៅ) ដោយលៃយ៉ាងណាមិនឱ្យមានការប៉ះពាល់ធ្ងន់ធ្ងរទៅលើ ស្ថេរភាពនយោបាយសេដ្ឋកិច្ច រចនា សម្ព័ន្ធរដ្ឋបាល និង ប្រព័ន្ធច្បាប់ដែលមានស្រាប់ និង ជាពិសេសអាចយកទៅអនុវត្តន៍បានតាមធនធានដែលមាន ។**

### ៣_១_ការកំណត់គោលដៅជាអាទិភាព និង ទស្សនវិស័យ :

ការកំណត់គោលដៅជាអាទិភាព និងទស្សនវិស័យឱ្យបានសមស្របតាមធនធាន និងអាចសំរេចបានជាចំនុចចាប់ផ្តើមខាងយុទ្ធសាស្ត្រ ។ គោលដៅគួរចែកចេញជាពីរដំណាក់កាល : **គោលដៅសំរាប់រយៈពេលខ្លី រឺ គោលដៅបន្ទាន់ និងគោលដៅសំរាប់រយៈពេលវែង ឬ ទស្សនៈវិស័យ ។**

➢ ចំនុចជាយុទ្ធសាស្ត្រ :

- គោលដៅបន្ទាន់មានពីរ: ទី១ ធ្វើវិសហមជ្ឈការដើម្បីកែលំអសេវាសាធារណៈ និង ទី២ ធ្វើវិសហមជ្ឈការដើម្បីជួយទ្រទ្រង់ឃុំ សង្កាត់ ។
- គោលដៅសំរាប់រយៈពេលវែង : ជាទស្សនៈវិស័យ យើងនឹងបន្តធ្វើវិសហមជ្ឈការរហូតដល់ថ្នាក់រដ្ឋបាលដែនដីនីមួយៗ ត្រូវបានដំណើរការតាមបែបវិសហមជ្ឈការយ៉ាងពេញលេញអាចទទួលខុសត្រូវ និងរ៉ាប់រងនូវមុខងារសំខាន់ៗ ដោយខ្លួនបានក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច នឹងជាពិសេសអាចឆ្លើយតបទៅនឹងតំរូវការរបស់ប្រជាពលរដ្ឋ បានយ៉ាងមានប្រសិទ្ធភាព ។
- កំណត់ទំហំនៃការធ្វើវិសហមជ្ឈការដោយផ្ទេរអំណាច និងការទទួលខុសត្រូវ ត្រូវធ្វើឡើងជាជំហានៗ ព្រោះថា ការធ្វើវិសហមជ្ឈការ ដោយផ្ទេរអំណាចនិងការទទួលខុសត្រូវតែមួយដងជាការស្រេច មិនអាចធ្វើឡើងបានទេ ។ ការផ្ទេរជាជំហានៗស្របគ្នាជាមួយការពង្រឹងសមត្ថភាពរដ្ឋបាលដោយការបង្កើតឧបករណ៍គ្រប់គ្រង ត្រួតពិនិត្យ និងការបណ្តុះបណ្តាលធនធានមនុស្ស វាគ្រាន់តែជាបន្ទុកមួយដែលយើងអាចរ៉ាប់រងបាន

*និងហានិភ័យនឹងត្រូវបានកាត់បន្ថយ ។ ការធ្វើវិសហមជ្ឈការជាជំហានៗ នេះមិនមានន័យថាត្រូវឱ្យមានការរៀបចំរដ្ឋបាលដែនដីឡើងវិញទាំងស្រុងទេ ហើយក៏មិនទាន់ប៉ះពាល់ដល់អំណាច និងបេសកកម្មរដ្ឋបាលកណ្ដាលទាំងស្រុងដែរ ។ ការផ្ទេរអំណាចនឹងត្រូវកំណត់ឡើងជាដំណាក់កាលស្របតាមលទ្ធភាព និងធនធានទន្ទឹមនឹងការកែ សំរួលបេសកកម្មខ្លះៗរបស់ថ្នាក់រដ្ឋបាលទាំងបួនក្នុងកំរិតមួយសមស្របអាចទទួលយកបាន ។*

- *ដំណាក់កាលទី១ ផ្ទេរតែអំណាច និងការទទួលខុសត្រូវ ជាអាទិភាពណាដែលសំរាប់ធ្វើការកែលំអសេវាសាធារណៈ និងការជួយទ្រទ្រង់ឃុំ សង្កាត់ជាមុនសិន ។*

## ៣.២.ការកំណត់ដំណាក់កាលផ្ទេរឱ្យបានសមស្រប :

ការងាររៀបចំការធ្វើវិសហមជ្ឈការនៅកម្ពុជា គួរចែកចេញជា ៣ ដំណាក់កាលៈ

**ដំណាក់កាលទី១ (២០០៥-២០០៨):**

- ដំណាក់កាលចាក់គ្រឹះ និងកែលំអសេវាទ្រទ្រង់ (Back-office)

-ផ្ទេរសេវាមួយចំនួនសំរាប់កែលំអសេវាសាធារណៈក្នុងក្របខណ្ឌពង្រឹងមុខងាររដ្ឋជាបញ្ញត្តិករ (Régulateur ) និង ការកាត់បន្ថយភាពក្រីក្រ

**ដំណាក់កាលទី២ (២០០៨-២០១៣):**

- ផ្ទេរខាងវិស័យសេដ្ឋកិច្ច និង វិនិយោគសាធារណៈ

**ដំណាក់កាលទី៣ (២០១៣-២០១៨):**

- ដំណាក់កាលវាយតំលៃ និង ធ្វើការកែសំរួលលើដំណាក់កាលទី១

- បន្តអនុវត្តនូវគោលនយោបាយថ្មី

### ៣.២.១ ដំណាក់កាលទី១ (២០០៥-២០០៨): ដំណាក់កាលចាក់គ្រឹះ និងសាកល្បង

- *រៀបចំ និង កែសំរួលនីតិវិធីនៃសេវាទ្រទ្រង់*
- *វិសហមជ្ឈការ និងការពង្រឹងនូវមុខងារជា Régulateur របស់រដ្ឋ ។*
- *វិសហមជ្ឈការ និង ការកាត់បន្ថយនូវភាពក្រីក្រ*

#### ៣.២.១.១ រៀបចំ ឬកែលំអនីតិវិធីនៃអង្គភាពទ្រទ្រង់ (ឧបករណ៍គ្រប់គ្រង)

- ***ការបែងចែកបេសកកម្មរដ្ឋបាលនៃថ្នាក់នីមួយៗជាពីរផ្នែកគឺ សេវាទ្រទ្រង់ (Back-office) និងសេវាជួរមុខ** (Front-office) នឹងធានានូវជោគជ័យនៃការធ្វើវិសហមជ្ឈការផង និង ជួយសំរួលដល់ការធ្វើសនិទានកម្មបេសកកម្មនៃរដ្ឋបាលសាធារណៈផង ជាពិសេសទៅលើការបង្កើនគុណភាពសេវាសាធារណៈដោយចំណាយអស់តិច ។*

- **ការកែលំអនីតិវិធី និង អភិក្រមនៃសេវាទ្រទ្រង់**ឱ្យបានជាមុន ឬទន្ទឹមគ្នានឹងការផ្ទេរធនធាន ឬមុខងារណាមួយឱ្យទៅរដ្ឋបាលថ្នាក់ក្រោម ជាយុទ្ធសាស្ត្រគន្លឹះមួយមិនអាចខ្វះបាននៅក្នុងការបង្វិតរដ្ឋបាលសាធារណៈឱ្យខិតទៅ

ជិតប្រជាពលរដ្ឋព្រោះដោយគ្រាន់តែកែសម្រួលរបៀបរបបធ្វើការ និង ***នីតិវិធីឱ្យបានច្បាស់លាស់ សាមញ្ញ និងខ្លី*** សេវាឈានមុខ (សេវាសាធារណៈ) បានរំកិលទៅជិតប្រជាពលរដ្ឋមួយជំហានរួចជាស្រេច ដោយមិនទាន់គិត ដល់ការរំលែកអំណាចនិងធនធានបន្ថែមទៀតឱ្យទៅ ខេត្ត- ក្រុង ស្រុក -ខណ្ឌ និងឃុំ- សង្កាត់ផង ។

➢ ***ចំនុចជាយុទ្ធសាស្ត្រ***

- ***ការពង្រឹងសេវាទ្រទ្រង់នៅដំណាក់កាលដំបូងនេះ គួរផ្ដោតការយកចិត្តទុកដាក់ទៅលើ ការកែសម្រួលនីតិវិធីគ្រប់គ្រងធនធានមនុស្ស ការកែសម្រួលនីតិវិធីគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុ និងពង្រឹងលើការតាមដានត្រួតពិនិត្យ ។***
- ***ពង្រឹងឱ្យខេត្តមានលទ្ធភាពរៀបចំវគ្គបណ្ដុះបណ្ដាលដល់មន្ត្រីរាជការនៅថ្នាក់ខេត្ត និងផ្ដល់លទ្ធភាពឱ្យខេត្តមានថវិកា ច្បាស់លាស់មួយសំរាប់ការបណ្ដុះបណ្ដាលនេះ ។***
- ***ផ្ដល់លទ្ធភាពឱ្យថ្នាក់ខេត្ត (សាលាខេត្ត និងមន្ទីរនានាជុំវិញខេត្ត ) អាចជ្រើសរើសមន្ត្រីរាជការ ឬបុគ្គលិកជាប់កិច្ចសន្យា ការតែងតាំងមន្ត្រីមួយចំនួន ហើយនិងការដាក់ពិន័យដល់មន្ត្រីដែលប្រព្រឹត្តខុសផងដែរ***
- ***ត្រូវប្រើប្រាស់មន្ត្រីនៅមន្ទីរផែនការ និងសាលាខេត្ត-ក្រុង ជាលេខាធិការឱ្យក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីផ្សព្វផ្សាយជូនមន្ត្រីថ្នាក់ខេត្តអំពីការងារទាំងឡាយរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។ គួរត្រូវមានការលើកទឹក ចិត្តដល់មន្ត្រីរាជការដែលទៅធ្វើការនៅតំបន់ដាច់ស្រយាលដោយប្រើប្រាស់កន្សោមអាទិភាព ។***
- ***ពិនិត្យលទ្ធភាព និងកំណត់ធនធានសំរាប់ថ្នាក់ខេត្ត -ក្រុង និង ឃុំ-សង្កាត់ ដោយឡែកអភិបាលខេត្តក្រុងគួរមានសិទ្ធិអំណាចមួយចំនួនដើម្បីតាមដាន និងជំរុញការប្រមូលចំណូលនេះ ។***
- ***គួរបង្កើតឱ្យមានសាខាធនាគារនៅតាមស្រុកដើម្បីធានាការបើកផ្ដល់ថវិកាឱ្យឃុំសង្កាត់បានទាន់ពេលវេលា ។***
- ***ចំពោះថវិកា ខេត្ត -ក្រុង និង ឃុំ គួរពិនិត្យលទ្ធភាពដើម្បីប្រើប្រាស់ប្រព័ន្ធធនាគារសំរាប់ផ្ទេរ ឬ ទូទាត់ថវិកាលើជំពូកចំណាយចាំបាច់ មួយចំនួន ។***
- ***ការពិនិត្យលទ្ធភាពបង្កើតអង្គភាពពិគ្រោះលើការងារច្បាប់រដ្ឋបាល និងតុលាការរដ្ឋបាលជាការងារចាំបាច់នៅក្នុងដំណើរការអនុវត្តនិមជ្ឈការ និង វិសហមជ្ឈការឱ្យមានប្រសិទ្ធភាព និង ចៀសវាងបាន នូវបញ្ហាផ្សេងៗ ។***
- ***ការពង្រឹងមុខងារសវនកម្មរហូតទៅដល់ខេត្ត -ក្រុងជាការងារខានមិនបាន ។***

## ៣.២.១.២ វិសហមជ្ឈការ និង ការពង្រឹងនូវមុខងារជាបញ្ញត្តិកររបស់រដ្ឋ

ធ្វើវិសហមជ្ឈការដើម្បីពង្រឹងមុខងាររបស់រដ្ឋក្នុងនាមជាបញ្ញត្តិករ ឬជាដៃគូរបស់ផ្នែកឯកជន ។ ជាការពិតណាស់ដែលផ្នែកឯកជនជាកំលាំងចលករខាងសេដ្ឋកិច្ច ដែលអាចរុញឱ្យសង្គមជាតិរីកលូតលាស់ទៅមុខ ក៏ប៉ុន្តែដើម្បីឱ្យការលូតលាស់នោះមានស្ថេរភាព សុវត្ថិភាព និងចិរភាព លុះត្រាតែមានការតម្រង់ទិសយ៉ាងហោចណាស់ក៏ក្នុងក្របខ័ណ្ឌអប្បបរមា ដែលយើងហៅថា រដ្ឋជាអ្នកសម្រួល ឬជាបញ្ញត្តិករ របស់ផ្នែកឯកជន ។ មុខងារបញ្ញត្តិករនេះ ត្រូវមានធាតុ ៤ សំខាន់ៗ :

- *រដ្ឋជាអ្នកបង្កើតនយោបាយយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍តាមផ្នែក និងកំណត់វិធាននៃល្បែង ( Règle de jeux ) ពោលគឺ កំណត់គោលការណ៍ និង បញ្ញត្តិទាំងឡាយ ។*
- *ឯកជនជាអ្នកផ្តួចផ្តើមនូវគំរោងវិនិយោគនានា ( ដូចជា ផ្គត់ផ្គង់ទឹកស្អាត ប្រមូលសំរាម. )*
- *រដ្ឋ ភ្នាក់ងារតំណាងរដ្ឋ ឬរដ្ឋបាលមូលដ្ឋាន ជាអ្នកពិនិត្យសំណើចុះកិច្ចសន្យា ឬអនុញ្ញាតឱ្យឯកជនធ្វើអាជីវកម្ម ។*
- *រដ្ឋ ភ្នាក់ងារតំណាងរដ្ឋ ឬរដ្ឋបាលមូលដ្ឋានត្រូវតាមដាន ត្រួតពិនិត្យ ។ បើផ្នែកឯកជនមានសកម្មភាពមិនប្រក្រតី រដ្ឋត្រូវមានវិធានការណ៍ទៅតាមច្បាប់ ។*

តាមការសិក្សា និងការកសាងបញ្ជីសរុបនៃសេវាសាធារណៈ ក្នុងចង្កោមរដ្ឋបាលដែលទាក់ទងដល់ការអនុវត្តន៍សិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋមាន ***ការចុះបញ្ជី ការបញ្ជាក់ និង ការអនុញ្ញាត*** របស់ក្រុមការងារវិសហមជ្ឈការកន្លងមកបានបង្ហាញថា ***រាល់ការផ្តល់សេវាប្រភេទនេះស្ទើរតែទាំងអស់ជូនប្រជាពលរដ្ឋធ្វើឡើងដោយថ្នាក់កណ្តាលច្រើនមានការយឺតយ៉ាវនិងមិនសូវមានប្រសិទ្ធភាព ។***

➢ *ចំនុចជាយុទ្ធសាស្ត្រ :*

- ***អាស្រ័យហេតុនេះ សេវាសាធារណៈផ្នែករដ្ឋបាល (រួមមាន ការចុះបញ្ជី ការបញ្ជាក់ និងការអនុញ្ញាត) ជាសេវាដ៏មានអាទិភាពសំរាប់ធ្វើការផ្ទេរទៅឱ្យខេត្ត-ក្រុង ស្រុក - ខណ្ឌ និងឃុំ - សង្កាត់នាពេលដ៏ខ្លីខាងមុខនេះ ។***

- ***ជាមួយការផ្ទេរនូវសេវារដ្ឋបាលដ៏មានសារៈសំខាន់នេះ យើងនឹងដាក់ឱ្យមានផងដែរនូវច្រកចេញចូលតែមួយសំរាប់ផ្តល់សេវាកម្មរដ្ឋបាលនៅថ្នាក់ខេត្ត-ក្រុង ស្រុក-ខណ្ឌ និងអាចឈានរហូតទៅដល់ឃុំ-សង្កាត់ ប្រសិនបើមានលទ្ធភាព ។ ការដាក់ឱ្យដំណើរការនៃច្រកចេញចូលតែមួយជាវិធានការជាក់ស្តែងសំរាប់សំរួលដល់ប្រជាពលរដ្ឋងាយទទួលបានលិខិតស្នាមពីរដ្ឋ រហ័សទាន់ចិត្ត ក្នុងតំលៃថោក និងប្រកបដោយតម្លាភាព ។ ច្រកចេញចូលតែមួយនេះ នឹងផ្តល់នូវភាពចំនេញច្រើនយ៉ាងណាស់ដូចជា ការកាត់បន្ថយនូវជំងឺការិយាធិបតេយ្យ អំពើពុករលួយ និង អនុញ្ញាតឱ្យប្រជាពលរដ្ឋនៅគ្រប់កន្លែងទូទាំងប្រទេស អាចទទួលបាននូវសេវាប្រភេទនេះបានដោយស្រួល ជាកត្តាមួយជំរុញឱ្យផ្នែកឯកជនរីកនៅក្នុងក្របខណ្ឌ ច្បាប់កាន់តែច្រើនឡើងៗ ដែលជួយសំរួលដល់ការយកពន្ធអាករផ្សេងៗផង និងជាកំលាំងចលករ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និង កាត់បន្ថយនូវភាពក្រីក្រ ព្រោះថាការកើនឡើងនូវមុខរបរខ្នាតតូចដូចជា សិប្បកម្ម សហគ្រាសធុនតូច និងមធ្យមនៅពាសពេញផ្ទៃប្រទេស នោះហើយជាទីផ្សារការងារសំរាប់ជនក្រីក្រ ។***

## ៣.២.១.៣ វិសហមជ្ឈការ និង ការកាត់បន្ថយភាពក្រីក្រ

គ្រប់វិស័យ ពិសេសវិស័យអប់រំ សុខាភិបាល កសិកម្ម ទេសចរណ៍ ធនធានធម្មជាតិ បរិស្ថាន និងធនធានទឹក ការលើកកំពស់សមត្ថភាពយេនឌ័រ និងអភិវឌ្ឍន៍ជនបទ ជាវិស័យដែលជះឥទ្ធិពលទៅដល់ការ កាត់បន្ថយភាពក្រីក្រ ។

DRAFT

បន្ទាប់ពីបានទទួលអំណាច និងធនធាន ថ្នាក់រដ្ឋបាលនីមួយៗ អាចស្គាល់បញ្ហារបស់ខ្លួនបានច្បាស់លាស់ និងអាចរ៉ាប់រងដោះស្រាយបញ្ហារបស់ខ្លួនបានដោយខ្លួនឯង ។ ដោយហេតុថា នៅពេលអនាគត ថ្នាក់នីមួយៗត្រូវក្តាប់ឱ្យបាននូវសក្តានុពលសេដ្ឋកិច្ច អត្រាអ្នកអត់ការងារធ្វើ អត្រាប្រជាពលរដ្ឋក្រោមបន្ទាត់ក្រីក្រ និងកំរិតចំណូលរបស់ប្រជាពលរដ្ឋម្នាក់ៗ ( GDP per capita ) នៅតាមមូលដ្ឋានរបស់ខ្លួនផ្ទាល់ ។

សព្វថ្ងៃនេះ ដូចជាអត្រាប្រជាពលរដ្ឋដែលរស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រនៅតាមឃុំ-សង្កាត់នីមួយៗ នៅតាម ខេត្ត-ក្រុងនីមួយៗ យើងពុំទាន់បានធ្វើនៅឡើយទេ គឺមានតែក្នុងកំរិតជាតិ ទីប្រជុំជន និងរាជធានីភ្នំពេញ ។

➢ *ចំនុចជាយុទ្ធសាស្ត្រ :*

គោលគំនិតសំរាប់ផ្សារភ្ជាប់ការធ្វើវិសហមជ្ឈការលើវិស័យសង្គមកិច្ចទៅនឹងការកាត់បន្ថយ ភាពក្រីក្រ ដោយធានាឱ្យមានការប្រើប្រាស់សេវាសង្គមកិច្ច ប្រកបដោយសមធម៌ ប្រសិទ្ធភាព និង ចីរភាព :

- *ដើម្បីឱ្យស្របទៅនឹងអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ និង លទ្ធភាពសេដ្ឋកិច្ច សេវាសាធារណៈដែលឋិតនៅក្នុងចង្កោមសង្គមកិច្ច-វប្បធម៌-កីឡា និងចង្កោមកសិកម្ម ជាមុខសញ្ញាដែលត្រូវធ្វើវិសហមជ្ឈការជាបន្ទាន់នៅដំណាក់កាលដំបូងនេះ ។*
- *សាលារៀន មន្ទីរពេទ្យ មជ្ឈមណ្ឌលសង្គមកិច្ច គួរបង្កើតឱ្យមានមូលនិធិសំរាប់ទ្រទ្រង់ ឬ ជាមូលនិធិសមធម៌ ។*
- *មូលនិធិទ្រទ្រង់នេះ ជាប្រអប់រួមដែលមានប្រភពមកពីថវិកាបដិភាគរបស់រដ្ឋ ជំនួយពីម្ចាស់ជំនួយ ពីអង្គការក្រៅរដ្ឋាភិបាល ពីផ្នែកឯកជន ពីប្រជាពលរដ្ឋ (នឹងអាចបានពីអ្នកប្រើប្រាស់សេវា) ។*
- *ប្រគល់សមត្ថកិច្ចជូនអភិបាលខេត្ត-ក្រុង ស្រុក-ខណ្ឌ និង រដ្ឋបាលឃុំ-សង្កាត់ ជាអ្នកគៀងគរធនធានគ្រប់គ្រងមូលនិធិ និងកំណត់ថាប្រជាពលរដ្ឋណាដែល គួរបានប្រយោជន៍ពីមូលនិធិនេះ ។*

## ៣.២.២.ការផ្ទេរក្នុងជំហានទី២ និង បន្តបន្ទាប់ឱ្យស្របទៅនឹងគោលដៅសំរាប់រយៈពេលវែង :

➢ *ចំនុចជាយុទ្ធសាស្ត្រ :*

- *សេវាសាធារណៈ ជាពិសេសក្នុងចង្កោមសេដ្ឋកិច្ច វិនិយោគ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តត្រូវធ្វើការផ្ទេរជាបន្តបន្ទាប់ទៅឱ្យ ខេត្ត -ក្រុង ។*
- *មុខងាររបស់ខេត្ត -ក្រុង មិនត្រូវមានត្រឹមតែមុខងាររដ្ឋបាលធម្មតាប៉ុណ្ណោះទេ ( ពីព្រោះ មុខងាររដ្ឋបាលមួយចំនួននឹង ត្រូវវិលែកទៅឱ្យស្រុក -ខណ្ឌ និងឃុំ -សង្កាត់ នាពេលខាងមុខនេះ ) តែត្រូវមានមុខងារ សំខាន់ៗបន្ថែមទៀត ជាពិសេស ការរៀបចំដែនដី ការបង្កើតប្លង់មេ ការគៀងគរធនធាន ជំរុញនិង សំរបសំរួលកំលាំង ចលករនានា ដើម្បីដំណើរការអនុវត្តប្លង់មេនេះ ។*

DRAFT

- *ការផ្សារភ្ជាប់គ្នារវាងគោលនយោបាយនៃការរៀបចំរដ្ឋបាលដែនដី ជាមួយគោលនយោបាយនគរូបនីយកម្ម ជាការចាំបាច់ណាស់ក្នុងដំណាក់កាលសកលភាវូបនីយកម្មបច្ចុប្បន្ន និង ដោះស្រាយជាមួយកំណើនប្រជាពលរដ្ឋ និងការវិវត្តន៍ខាងសេដ្ឋកិច្ច ។*

## ៣.៣.មានវិធីសាស្ត្រត្រឹមត្រូវ :

ការកំណត់មុខងារ ឬបេសកកម្មជាលំអិតណាមួយដើម្បីធ្វើការផ្ទេរឱ្យទៅថ្នាក់ក្រោមទៅតាមដំណាក់កាលនីមួយៗ ដូចមានចែងខាងលើ គួរមានវិធីសាស្ត្រដូចខាងក្រោម :

- *កំណត់ឡើងតាមរបៀបពីក្រោមឡើងមកលើ (Bottom Up) ដោយមានការស្រុះស្រួលគ្នាជាទូទៅ (គ្រប់ក្រសួង ឬស្ថាប័នដែលពាក់ព័ន្ធ) និងត្រូវផ្អែកលើបទពិសោធន៍នៃកម្មវិធីសីលា កម្មវិធីមួយចំនួនទៅក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសុខាភិបាល និងក្រសួងអប់រំដែលកំពុងអនុវត្តន៍សាកល្បង និងកម្មវិធីអនុវត្តសាកល្បងនៅស្រុក គឺស្រុកបាត់ដំបង និង ស្រុកសៀមរាប ។*
- *កំណត់ឡើងតាមរបៀបពីលើចុះមកក្រោម (Top Down) ដោយមានការអារកាត់ពីខាងលើ ជាពិសេស ពីប្រមុខរាជរដ្ឋាភិបាល ទើបល្បឿននៃការធ្វើវិសហមជ្ឈការបានលឿន ។*
- *ដំណាក់កាលអនុវត្តន៍សាកល្បងសំរាប់ខេត្ត-ក្រុង ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ណា ដែលមានលក្ខខ័ណ្ឌភូមិសាស្ត្រល្អប្រសើរ និងមានសក្តានុពលភាពខាងសេដ្ឋកិច្ច ជាចំណុចមួយដែលគួរពិចារណា ។*

## ៣.៤. មានស្ថាប័នទទួលខុសត្រូវ និងសំរបសំរួលច្បាស់លាស់

មានការងារធំៗចំនួន ៤ ដែលពាក់ព័ន្ធនឹងការងារវិសហមជ្ឈការគឺ:

ទី១ : បន្ទាប់ពីធ្វើវិមជ្ឈការ និងវិសហមជ្ឈការ នឹងមានការជះឥទ្ធិពលដល់មុខងារនិងរចនាសម្ព័ន្ធមួយចំនួនរបស់រដ្ឋបាលកណ្តាល ដែលតំរូវឱ្យមានការកែសំរួល និងពង្រឹងរដ្ឋបាលកណ្តាលដោយផ្តោតជាពិសេសទៅលើមុខងារសំខាន់ៗ មួយចំនួនដូចជាការធ្វើគោលនយោបាយ និងការត្រួតពិនិត្យ ។

ទី២ : ពង្រឹងរដ្ឋបាលខេត្ត -ក្រុង និង ស្រុក -ខណ្ឌ ដើម្បីឱ្យរដ្ឋបាលនេះ មានលទ្ធភាពផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និង គុណភាព ។

ទី៣ : ក្រោយការបោះឆ្នោត ឃុំ -សង្កាត់មានមុខងារពីរគឺ: មុខងារផ្ទាល់ខ្លួនក្នុងនាមឃុំ សង្កាត់ជានីតិបុគ្គល និង មុខងារតំណាងអោយរដ្ឋ ។ មុខងារតំណាងអោយរដ្ឋ ឃុំ-សង្កាត់ ជាភ្នាក់ងាររបស់រដ្ឋដែលនឹងទទួលបាននូវមុខងារ តួនាទីថ្មីតាមរយៈការធ្វើវិសហមជ្ឈការ ។

ទី៤ : ពង្រឹងរដ្ឋបាលខេត្ត-ក្រុង និងស្រុក-ខណ្ឌដើម្បីឱ្យរដ្ឋបាលនេះជួយឃុំ សង្កាត់បាន តែមិនមែនទទួលខុសត្រូវជំនួសឃុំ សង្កាត់ទេ ។

DRAFT

➢ ចំនុចបែងចែកការសំរបសំរួល និង ការទទួលខុសត្រូវ:

- ការងារពាក់ព័ន្ធទី១ និង ទី២ ត្រូវសំរបសំរួលដោយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និងមានការចូលរួមយ៉ាងសកម្មពី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងផែនការ និង ក្រសួងពាក់ព័ន្ធនានា ។
- ការងារពាក់ព័ន្ធនឹងចំណុចទី៣ និង ទី៤ ត្រូវសំរបសំរួលដោយគណៈកម្មការជាតិ ទ្រទ្រង់ឃុំ-សង្កាត់ និងមានការចូលរួមយ៉ាងជិតស្និទ្ធពីក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

# ៤-មុខងាររបស់ខេត្ត-ក្រុង និងស្រុក-ខណ្ឌ

## ៤-១- មុខងារផ្ទាល់របស់ខេត្ត-ក្រុង :

ដោយមិនស្រពិចស្រពិលក្នុងក្របខណ្ឌវិសហមជ្ឈការខេត្ត-ក្រុងគ្មាននីតិបុគ្គលទេ តែអាចអនុញ្ញាតឱ្យមានថវិកាផ្ទាល់បាន ( ប្រមូលគៀងគរធនធាន) ដោយធ្វើឡើងតាមរយៈការបង្កើតថវិកាឧបសម្ព័ន្ធ និងគណនីពិសេស ។ ថវិកា ផ្ទាល់ពុំមានន័យថាជាស្វយ័តទេ មានន័យថាខេត្ត-ក្រុង មានកញ្ចប់ថវិកាដាច់ដោយឡែកពីថ្នាក់កណ្តាល ។ ព្រោះថារដ្ឋបាលមួយជារដ្ឋបាលវិសហមជ្ឈការ កាលណារដ្ឋបាលនោះ នៅតែឋិតនៅក្នុងក្របខណ្ឌបុគ្គលភាព គតិយុត្តិរបស់រដ្ឋ និងគ្មានស្វ័យភាពខាងហិរញ្ញវត្ថុ ។ ដូច្នេះ ថវិកាផ្ទាល់របស់ខេត្ត ក្រុងត្រូវឋិតនៅក្នុងថវិការបស់រដ្ឋ ហើយវិធានគណនេយ្យសាធារណៈ និងលទ្ធកម្មសាធារណៈរបស់រដ្ឋមានអំណាចអនុវត្តទៅលើថវិកានោះ ។ ការអនុមតិ និង ការកែសំរួលថវិកាឧបសម្ព័ន្ធត្រូវធ្វើឡើងដោយសភាជាតិ ។

➢ វិធីសគោលនយោបាយ :

- ខេត្ត-ក្រុង ត្រូវមានមុខងារច្បាស់លាស់ខាងការអភិវឌ្ឍន៍សេដ្ឋកិច្ច ដូចជា ការរៀបចំដែនដី ការបង្កើតប្លង់មេ និងផែនការកម្មប្រើប្រាស់ដីធ្លី ជីជាងរ៉ាប់រងនូវមុខងាររដ្ឋបាលទូទៅ ដូចសព្វថ្ងៃ ព្រោះថាមុខងាររដ្ឋបាលទូទៅនេះនឹងផ្ទេរទៅឱ្យស្រុក -ខណ្ឌ វិញ ។
- ខេត្ត -ក្រុងគួរជាថ្នាក់មានថវិកា និង ផែនការសំរាប់វិនិយោគផ្ទាល់សំរាប់ជាគុណប្រយោជន៍របស់ខេត្ត -ក្រុង ។

## ៤-២- មុខងារខេត្ត ក្រុងពាក់ព័ន្ធនឹងឃុំ-សង្កាត់ :

- តាមដាន និងត្រួតពិនិត្យនីត្យានុកូលភាពទៅលើសេចក្តីសំរេចរបស់រដ្ឋបាលវិមជ្ឈការឃុំ សង្កាត់ ។
- ធានាឱ្យមានភាពស៊ីសង្វាក់គ្នា រវាងផែនការរបស់ឃុំនីមួយៗនៅក្នុងខេត្ត និង រវាងផែនការរបស់ឃុំទៅនឹង ផែនការរបស់ខេត្ត និងរបស់ជាតិ ។
- ជាយន្តការដែមានប្រសិទ្ធភាពសំរាប់គាំទ្រការអនុវត្តនីវិមជ្ឈការនៅឃុំ-សង្កាត់ដោយរួមទាំងការបណ្តុះបណ្តាល ផង និងទប់ស្កាត់បាននូវគំលាតគ្នាខ្លាំងរវាង ឃុំដែលមាន និង ឃុំដែលក្រ ។

DRAFT

## ៤.៣. មុខងារផ្ទាល់របស់ស្រុក-ខណ្ឌ

- ស្ថានភាព និងមុខងារបច្ចុប្បន្នរបស់ស្រុក-ខណ្ឌ :
  - *តាមរដ្ឋធម្មនុញ្ញ ស្រុកជាថ្នាក់រដ្ឋបាលដែនដីមួយ និងពេលបច្ចុប្បន្ននេះមានការិយាល័យ ជំនាញស្ទើរតែគ្រប់វិស័យ និងស្រុកភាគច្រើនមានមន្ត្រីរាជការច្រើនរយនាក់ កំពុងបំពេញការងារ ។*
  - *ស្រុក-ខណ្ឌពុំមែនជាថ្នាក់មានផែនការឬថវិកាដោយឡែកទេ ។*
  - *ស្រុក-ខណ្ឌបាននិងកំពុងរ៉ាប់រងលើការងារភាគច្រើនជាការងាររដ្ឋបាលទូទៅ និង សន្តិសុខ ។*
- មតិទី១បានឱ្យយោបល់ថាទៅថ្ងៃអនាគត ស្រុកគួរតែជាផ្នែកមួយរបស់ខេត្តមិនមែនជាថ្នាក់រដ្ឋបាលមួយ របស់រដ្ឋទេ និងអភិបាលស្រុកគ្រាន់តែជាភ្នាក់ងាររបស់អភិបាលខេត្តបានហើយ ។
- មតិទី២បានយល់ថា តាមប្រវត្តិសាស្ត្រ តាមរដ្ឋធម្មនុញ្ញ និងតាមដំណើរការជាក់ស្តែងសព្វថ្ងៃនេះ ស្រុកជាថ្នាក់រដ្ឋបាលដែនដីមួយ ពុំមែនជាផ្នែកមួយរបស់ខេត្ត ឬគ្រាន់តែជាភ្នាក់ងាររបស់ខេត្តប៉ុណ្ណោះទេ ស្រុកគួរជាថ្នាក់មួយមានការទទួលខុសត្រូវច្បាស់លាស់ ។ អាស្រ័យហេតុនេះ ការធ្វើវិសហមជ្ឈការរហូតដល់ថ្នាក់ស្រុកឬការពង្រឹងមុខងារស្រុកឡើងវិញជាការចាំបាច់ ។

➢ ***ជំរើសគោលនយោបាយ :*** តាមទស្សនៈទី២

- ***ស្រុកគួរជាថ្នាក់ទទួលខុសត្រូវលើការងាររដ្ឋបាលទូទៅ***
- ***ស្រុកជាថ្នាក់ប្រតិបត្តិការផ្តល់សេវាសាធារណៈក្នុងកំរិតសមស្របណាមួយជូនប្រជាពលរដ្ឋ ដូចជា សេវាកម្មរដ្ឋបាល (ការចុះបញ្ជីការបញ្ជាក់ ការអនុញ្ញាត).....***
- ***ពង្រឹងលើការងារសន្តិសុខ ដោះស្រាយវិវាទ និង គ្រោះមហន្តរាយ***
- ***ស្រុកគួរជាថ្នាក់ គាំទ្របច្ចេកទេស សំរបសំរួល ជំរុញ និង តាមដាន ការអនុវត្តវិមជ្ឈការនៅឃុំ-សង្កាត់***

## ៤.៤.២.មុខងារពាក់ព័ន្ធនិងឃុំ សង្កាត់

- ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ រដ្ឋបាលឃុំ-សង្កាត់នឹង ដំណើរការតាម ប្រព័ន្ធថ្មីមួយ ដែល យើងហៅថាវិមជ្ឈការ ។ ជាទូទៅវិមជ្ឈការដែនដីនៅថ្នាក់ឃុំ -សង្កាត់នេះនឹងនាំមកនូវ វិបត្តិ ៣យ៉ាងគឺ :
  - *មានគំលាតគ្នាខ្លាំងរវាងឃុំដែលមាននិងឃុំដែលក្រ ។ ថ្លៃសេវាសាធារណៈមានការខុសគ្នា គឺឃុំដែលក្រច្រើនប្រជាពលរដ្ឋបង់ថ្លៃច្រើនជាងឃុំដែលមាននៅក្នុងការប្រើប្រាស់ប្រភេទសេវាដូចគ្នា ។*
  - *ផែនការអភិវឌ្ឍន៍រវាងឃុំមួយទៅឃុំមួយពិបាកសមាហរណកម្មចូលគ្នា និងពិបាករកឃើញនូវប្រសិទ្ធភាពណាស់ ។*
  - *បង្កើតឱ្យមានបាតុភូតតំបន់និយម ។ ការសហការគ្នាមានការលំបាកជាពិសេស លើវិស័យសន្តិសុខ ។*

- ដូច្នេះការកំណត់មុខងារ តួនាទីរបស់ស្រុក-ខណ្ឌឡើងវិញដោយផ្សារភ្ជាប់ជាមួយនឹងតួនាទីមុខងារថ្មីរបស់រដ្ឋបាលវិមជ្ឈការឃុំ - សង្កាត់ ជាការចាំបាច់។ ស្រុក-ខណ្ឌ នឹងដើរតួយ៉ាងសកម្មដើម្បីជួយទ្រទ្រង់ និងទប់ស្កាត់មិនឱ្យកើតមានវិបត្តិទាំងឡាយណាដែលកើតចេញពីការធ្វើវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ ។ ប្រការនេះហើយដែលយើងហៅថា ការធ្វើវិសហមជ្ឈការដើម្បីជួយទ្រទ្រង់ឃុំ-សង្កាត់ ព្រោះថាលទ្ធភាពរបស់ឃុំក្នុងអាណត្តិទី១ មិនអាចដោះស្រាយ និងរ៉ាប់រងលើការផ្តល់សេវាសាធារណៈបានដោយខ្លួនឯងទាំងស្រុងទេ ហើយបើរ៉ាប់រងខ្លួនឯង បានឃុំតូចៗនឹងមានចោទជាបញ្ហាក្នុងការកំណត់តំលៃលើសេវាសាធារណៈនីមួយៗដែលត្រូវតែថ្លៃជាងបណ្តាឃុំធំៗ ផ្សេងទៀតដែលនៅក្នុងស្រុកតែមួយ ។
- នៅប្រទេសមួយចំនួន គេដោះស្រាយបញ្ហានេះដោយបង្កើតសម្ព័ន្ធឃុំ មានន័យថាឃុំតូចៗនៅជុំវិញត្រូវចងសម្ព័ន្ធជា មួយឃុំធំដើម្បីរួមគ្នាផ្គត់ផ្គង់សេវាសាធារណៈដោយរក្សាបានតំលៃថោក និងឯកភាពគ្នា។

➢ *ចំនុចជាយុទ្ធសាស្ត្រ:*

អាស្រ័យហេតុនេះ ដើម្បីទប់ស្កាត់បានបញ្ហាខាងលើនេះ ស្រុក ខណ្ឌគួរមាន តួនាទី មុខងារ :

- *ស្រុកគួរជាថ្នាក់សំរបសំរួលផែនការរបស់ឃុំនីមួយៗនៅក្នុងស្រុក ។*
- *ផ្តល់ការទ្រទ្រង់ខាងបច្ចេកទេស ពិគ្រោះយោបល់ និង បំផុសតួអង្គនីមួយៗនៅក្នុងស្រុកដូចជារដ្ឋបាលវិមជ្ឈការ ឃុំ -សង្កាត់ សមាគមនី សហការគ្នាក្នុងការផ្តល់សេវាសាធារណៈ ដូចជា កសិកម្ម អប់រំ សុខាភិបាល កសាងផ្លូវជនបទ ទឹក ភ្លើង អនាម័យ ។ល។*
- *តាមដានការអនុវត្តន៍ផែនការអភិវឌ្ឍន៍ផ្ទាល់របស់ឃុំនីមួយៗ ។*

៤.៥.ចំពោះស្រុកដែលមានលក្ខណៈពិសេស :

- *ជាពិសេសស្រុកទីរួមខេត្តដែលមានលក្ខណៈជាក្រុងគួរបង្កើតជាក្រុង ។ ក្រុងប្រភេទនេះគួរចាត់ទុកជាក្រុងមួយរបស់ខេត្ត តែត្រូវមានរចនាសម្ព័ន្ធពិសេស និងមុខងារដាច់ដោយឡែកពីស្រុកធម្មតា ។*

# តារាងសង្ខេបការផ្តល់យោបល់ត្រឡប់ពីក្រសួងនានា

# លើកទី១

## មតិយោបល់របស់បណ្តាក្រសួង-ស្ថាប័ន
## លើសេចក្តីព្រាង ស្តីពីគោលនយោបាយ និង យុទ្ធសាស្ត្រនៃការធ្វើវិសហមជ្ឈការលើកទី១

| ល.រ. | ឈ្មោះក្រសួង/ស្ថាប័ន | យោបល់ របស់ក្រសួង/ស្ថាប័ន | ការពិនិត្យលើសំណើ ដោយក្រុមវិសហមជ្ឈការ |
|---|---|---|---|
| ១. | ក្រសួង សាធារណៈ និងដឹកជញ្ជូន | ឯកភាពលើខ្លឹមសាររួម និងសំនូមពរឱ្យ កែសំរួលអក្ខរាវិរុទ្ធឡើងវិញ | |
| ២. | ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ឯកភាពទាំងស្រុងលើខ្លឹមសារ | |
| ៣. | ក្រសួង បរិស្ថាន | ឯកភាពទាំងស្រុងលើខ្លឹមសារ និងសំនូមពរឱ្យ<br>- កែសំរួលភាសាបរទេស ចំពោះពាក្យបច្ចេកទេស កុំប្រើភាសាអង់គ្លេស និងភាសាបារាំងលាយឡំគ្នា<br>- កែ និងលប់ឃ្លាឃ្លោងខ្លះនៅទំព័រទី ៤-១៣-១៤ និង ១៨ , ២០ និងបន្ថែមពាក្យបរិស្ថាននៅទំព័រទី ២២ ។ | |
| ៤. | ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល | សុំកែពាក្យ ឃ្លាឃ្លោង សំរួលខ្លឹមសារ និងឃ្លាខ្លះ ដើម្បីឱ្យងាយស្រួលស្តាប់ និងសុំបន្ថែម និងលប់ពាក្យខ្លះ | |
| ៥. | ក្រសួង ផែនការ | កែខ្លឹមសារមួយចំនួនដែលទាក់ទងនឹងសមត្ថកិច្ច របស់ក្រសួង និងកែទិន្នន័យ និងភាគរយខ្លះ ដែលទាក់ទងនឹង ការិតផលិតផលក្នុងស្រុកសរុប អត្រានៃភាពក្រីក្រ និង អត្រាប្រជាជនក្រោម បន្ទាត់ភាពក្រីក្រ ចំណែកខ្លឹមសារផ្សេងទៀត ក្រសួងយល់ស្របទាំងស្រុង | |
| ៦. | រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ឯកភាពលើខ្លឹមសាររួម និងសំនូមពរឱ្យកែសំរួលពាក្យ និងឃ្លាឃ្លោងមួយចំនួន | |

| | | | |
|---|---|---|---|
| ៧. | ក្រសួង អប់រំ យុវជន និងកីឡា | ឯកភាពលើការរៀបចំឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រ និងមានការផ្តល់យោបល់មួយចំនួន :<br>- ក្រសួងបានចេញការណែនាំមួយស្តីពីការតែងតាំងមន្ត្រីបំរើការនៅមន្ទីរ គឺក្រៅពីប្រធានមន្ទីរ សំណើតែងតាំងត្រូវធ្វើឡើងផ្ទាល់មកនាយកដ្ឋានបុគ្គលិក មិនឆ្លងយោបល់របស់ស្រុក ឬខេត្ត ប៉ុន្តែចំពោះលទ្ធកម្មក្រសួងគ្មានការអនុវត្តនៅស្រុកទេ ។<br>- ក្នុងការអនុវត្ត មន្ទីរអប់រំលើកថវិកាទៅមន្ទីរហិរញ្ញវត្ថុខេត្ត ដែលត្រូវសរុបមកក្រសួងហិរញ្ញវត្ថុ ដើម្បីធ្វើការ សំរេចទាំងថវិកាប្រចាំឆ្នាំ របស់កណ្តាល និងខេត្ត។<br>- សុំអោយមានវិសហមជ្ឈការក្នុងកំរិតមួយ ដើម្បីអោយខេត្ត ក្រុងមានសមត្ថកិច្ច និងមធ្យោបាយ បំពេញតួនាទី និងភារកិច្ចជាអាជ្ញាធរមូលដ្ឋាន ពិសេសលើធនធានហិរញ្ញវត្ថុ ( ទំព័រ ១០,១១)<br>- សុំបន្ថែមពាក្យខ្លះ និងពន្យល់ពាក្យមួយចំនួន ។ | |
| ៨ | ក្រសួងទំនាក់ទំនងសភា និងព្រឹទ្ធសភា | ឯកភាពទាំងស្រុកលើខ្លឹមសារ | |
| ៩ | ក្រសួងអភិវឌ្ឍន៍ជនបទ | - ឯកភាពលើខ្លឹមសាររួម សុំកែសំរួលលំដាប់លេខរៀង អក្ខរាវិរុទ្ធមួយចំនួន និងឃ្លាឃ្លោងមួយចំនួន<br>- សូមបញ្ជាក់បន្ថែមនូវខ្លឹមសារ ពាក្យ " ច្រកចេញចូលតែមួយ " នៃសេវាសាធារណៈមានអ្វីខ្លះ ។ | |
| ១០ | ក្រសួងទេសចរណ៍ | - ឯកភាពលើខ្លឹមសាររួម សុំកែអក្ខរាវិរុទ្ធមួយចំនួន និងឃ្លាឃ្លោងមួយចំនួន ។<br>- សុំបញ្ចូលវិស័យ ទេសចរណ៍ជាវិស័យដែលជះឥទ្ធិពលដល់ការកាត់បន្ថយ ភាពក្រីក្រ ។ | |

| | | | |
|---|---|---|---|
| ១១ | ក្រសួងសុខាភិបាល | ឯកភាពទាំងស្រុងលើខ្លឹមសាររួម | |
| ១២ | ក្រសួងពាណិជ្ជកម្ម | - ឯកភាពលើខ្លឹមសាររួម<br>- សុំរក្សាមតិទុកនូវអ្វីដែលពាក់ព័ន្ធនិងក្រសួង មានចែងក្នុងលិខិតលេខ ៣៨៩១ ចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០០២ របស់ក្រសួងពាណិជ្ជកម្ម ។ | |
| ១៣ | ក្រសួងមហាផ្ទៃ | កំពុងពិចារណា និងសិក្សាបន្ថែម | |
| ១៤ | ក្រសួងសង្គមកិច្ចការងារ | ទំនាក់ទំនងមិនបាន | |
| ១៥ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | កំពុងពិចារណា និងសិក្សាបន្ថែម | |
| ១៦ | ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | មិនទាន់ឆ្លើយតប | |
| ១៧ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | កំពុងពិចារណា និងសិក្សាបន្ថែម | |

# តារាងសង្ខេបការផ្តល់យោបល់ត្រឡប់ពីក្រសួងនានា

# លើកទី២

# មតិយោបល់របស់បណ្តាក្រសួង-ស្ថាប័ន ២១ ខេត្ត-ក្រុង ២៤
# លើសេចក្តីព្រាងគោលនយោបាយ និងយុទ្ធសាស្ត្រ នៃការធ្វើវិសហមជ្ឈការ

| ល.រ | ឈ្មោះក្រសួង/ស្ថាប័ន ខេត្ត/ក្រុង | យោបល់ របស់ក្រសួង/ស្ថាប័ន | ផ្សេងៗ |
|---|---|---|---|
| I | **ក្រសួង /ស្ថាប័ន** | | |
| ១ | ក្រសួងសាធារណការ និងដឹកជញ្ជូន | ឯកភាព និងគាំទ្រទាំងស្រុងលើខ្លឹមសារ | |
| ២ | ក្រសួងផែនការ | សូមឯកភាពជារួមលើខ្លឹមសារ និងសូមជូនយោបល់មួយចំនួន នៅត្រង់ចំណុច ក-២ ទំព័រទី ១៧ ចំណុច ៣ ទំព័រទី ២១ និង ចំណុច៤-៣ ទំព័រទី២៤ ឯកភាពតាមទស្សនៈទី២ | |
| ៣ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | -សុំឱ្យមាននិយមន័យលើវាក្យស័ព្ទសំខាន់ៗ<br>-សូមគាំទ្រទាំងស្រុង នូវសេចក្តីព្រាង គោលនយោបាយ និង យុទ្ធសាស្ត្រនៃកាធ្វើវិសហមជ្ឈការ<br>- សូមបញ្ចូលនូវសេវាមួយចំនួនដែលត្រូវផ្ទេរអោយរដ្ឋបាលមូលដ្ឋាន ឃុំ-សង្កាត់ | |
| ៤ | រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សូមកែពាក្យពេជន៍ និងបញ្ចូលឃ្លាឃ្លោង មួយចំនួន | |
| ៥ | ក្រសួងធនធានទឹក និងឧតុនិយម | ឯកភាពលើខ្លឹមសារ និងសូមបំពេញបន្ថែមលើពាក្យពេជន៍មួយចំនួន | |
| ៦ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ឯកភាពលើខ្លឹមសារ និងសូមកែឃ្លាឃ្លោងស្របតាមស្ថានភាពតំរូវការជាក់ស្តែង | |
| ៧ | ក្រសួងអភិវឌ្ឍន៍ជនបទ | ឯកភាព និងគាំទ្រទាំងស្រុងលើខ្លឹមសារ | |
| II | **ខេត្ត/ក្រុង** | | |
| ១ | សាលាក្រុងកែប | - ស្នើបង្កើតច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាល ខេត្ត-ក្រុង<br>- គួរបង្កើនកញ្ចប់ថវិកា ខេត្ត-ក្រុងសំរាប់គាំទ្រ រដ្ឋបាល ស្រុក- ខ័ណ្ឌ<br>-គួរផ្តល់អំណាចមួយច្បាស់លាស់ដល់ខេត្ត-ក្រុង ក្នុងការចាត់ចែង | |

| | | | |
|---|---|---|---|
| | | ថវិការបស់ខ្លួន<br>-គួរមានត្រឹមតែគណៈកម្មការគ្រប់គ្រងថវិការនៅថ្នាក់ខេត្ត-ក្រុង ដោយសារធ្លាប់មានការអនុវត្តន៏កន្លងមក ។<br>- ចំណុចគ្រប់ចំនួនផ្សេងទៀតសូមធ្វើការឯកភាព និងគាំទ្រទាំងស្រុង ។ | |
| ២ | សាលាខេត្តរតនគីរី | -ឯកភាពទាំងស្រុងទៅលើខ្លឹមសារសេចក្តីព្រាង<br>- ស្នើរបង្កើតច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ។ | |
| ៣ | សាលាខេត្តពោធិសាត់ | -ឯកភាពលើខ្លឹមសារមួយចំនួនធំ និងស្នើរសុំបញ្ចូលពាក្យពេជន៏ និងឃ្លាឃ្លោងមួយចំនួនតូច | |
| ៤ | សាលាខេត្តកណ្តាល | ឯកភាពលើខ្លឹមសារមួយចំនួនធំ និងស្នើបំពេញបន្ថែមឃ្លាឃ្លោង និងអត្ថន័យមួយចំនួន និងសុំលុបចេញមួយបន្ទាត់ | |
| ៥ | សាលាក្រុងព្រះសីហនុ | -ឯកភាពលើខ្លឹមសារ និងមានលក្ខណៈល្អិតល្អន់ស្ទើរតែគ្រប់ជ្រុងជ្រោយ និងសូមកែតំរូវអោយសមស្របតាមស្ថានភាពជាក់ស្តែង<br>- សូមបំពេញបន្ថែមនូវចំណុចមួយចំនួន ។ | |

# ផ្នែកទី ២

## -គំរោងសាកល្បងនៅស្រុកបាត់ដំបង នៃខេត្តបាត់ដំបង និងស្រុកសៀមរាប នៃខេត្តសៀមរាប

## -ការផ្ដល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយ នៅស្រុកបាត់ដំបង នៃខេត្តបាត់ដំបង និងស្រុកសៀមរាប នៃខេត្តសៀមរាប

# ការងារដែលត្រូវអនុវត្តបន្ត
# រហូតដល់បំណាច់ឆ្នាំ ២០០៤

## គំរោងសាកល្បងនៅស្រុកបាត់ដំបង នៃខេត្តបាត់ដំបង និងស្រុកសៀមរាបនៃខេត្តសៀមរាបត្រូវបានគាំទ្រយ៉ាងសកម្ម និងសំរបសំរួលយ៉ាងរលូនពីថ្នាក់ដឹកនាំ ដោយមាន :

-លិខិតលេខ ១៦០/០៤ សជណ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-លិខិតលេខ ១៧៤/០៤ សជណ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-លិខិតលេខ ១៧៥/០៤ សជណ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-លិខិតលេខ ១៧៦/០៤ សជណ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-លិខិតលេខ ១៧៧/០៤ សជណ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-លិខិតលេខ ១៧៨/០៤ សជណ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-លិខិតលេខ ១៧៩/០៤ សជណ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-លិខិតលេខ ៥៧៥ សជណ របស់ក្រសួងមហាផ្ទៃ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ឧត្តមក្រុមប្រឹក្សា កំណែទម្រង់រដ្ឋ

៨៨០៨៨

ក្រុមប្រឹក្សា កំណែទម្រង់រដ្ឋបាល

លេខ: ១៧៤/០៤ រសក៧

ភ្នំពេញ, ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៤

**សូមគោរពជូន**

**ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ** : ការផ្តល់យោបល់លើ សេចក្តីព្រាងប្រកាសស្តីពី "ប្រតិភូកម្មអំណាច" ជូនដល់ស្រុកសាកល្បងទាំងពីរ និង សេចក្តីណែនាំស្តីពី "ការអនុវត្តន៍ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញ-ចូលតែមួយ" ជូនប្រជាពលរដ្ឋរស់នៅស្រុកទាំងពីរ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមជំរាបជូន ឯកឧត្តមទេសរដ្ឋមន្ត្រី ជ្រាបថា ចាប់តាំងពីរាជរដ្ឋាភិបាលបានចេញសេចក្តីសំរេចលេខ ៤៧ ស្តីពីការកំណត់រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល នៅស្រុកបាត់ដំបង ខេត្តបាត់ដំបង និង ស្រុកសៀមរាប ខេត្តសៀមរាប ជាពិសេសដោយអនុលោមលើមាត្រាទី ៥ និង ទី ៦ នៃសេចក្តីសំរេចនេះ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានធ្វើការសំរបសំរួលជាមួយក្រសួងពាក់ព័ន្ធទាំងអស់ ដើម្បីរៀបចំបញ្ជីសេវាកម្មសំរាប់ផ្ទេរការផ្ទេរជាជំហាន១ ជូនស្រុកបាត់ដំបង និងស្រុកសៀមរាប និងផ្តល់យោបល់ពិគ្រោះយោបល់លើប្រកាស និងសេចក្តីណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធទាំងអស់ក្នុងកំរិតបច្ចេកទេសរួចហើយ ។

ដោយឈរលើមូលដ្ឋាននេះ ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សូមផ្តល់យោបល់ឯកភាព និងគាំទ្រទៅលើខ្លឹមសារនៃសេចក្តីព្រាងប្រកាសស្តីពី "ប្រតិភូកម្មអំណាច" ជូនដល់ស្រុកសាកល្បងទាំងពីរ និង សេចក្តីណែនាំស្តីពី "ការអនុវត្តន៍ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញ-ចូលតែមួយ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប៉ុន្តែនៅជំហានបន្ទាប់ដើម្បីអនុវត្តន៍គំរោងសាកល្បងនៅ ស្រុកទាំងពីរនេះបានជោគជ័យ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សូមធ្វើការកត់សំគាល់ដូចខាងក្រោម :

១-នាពេលកន្លងមកក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសង្កេតឃើញថាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានខិតខំប្រឹងប្រែងរៀបចំឯកសារដូចមានរៀបរាប់ខាងលើសំរាប់គំរោងសាកល្បងនេះយ៉ាងសកម្មជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល។ អាស្រ័យហេតុនេះ ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ខ្ញុំសូមសំដែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្រចំពោះស្មារតីទទួលខុសត្រូវដ៏ខ្ពង់ខ្ពស់នេះ ។

២-យោងតាមស្មារតីនៃមាត្រា ៥ និង ៦ នៃសេចក្តីសំរេចលេខ ៤៧ តំរូវអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្នើសុំការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់ លើសេចក្តីព្រាងនេះ ។

៣- បន្ទាប់ពីប្រកាស និងសេចក្តីណែនាំនេះត្រូវបាន ប្រកាសជាផ្លូវការហើយ ក្រសួងពាក់ព័ន្ធនីមួយៗ នឹងត្រូវធ្វើការងារជាច្រើនបន្តទៀតជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល លើការងារមួយចំនួន ដូចខាងក្រោម:

- វាយតំលៃពីស្ថានភាពជាក់ស្តែងនៃស្រុកទាំងពីរ អំពីសេចក្តីត្រូវការខាងសំភារៈដែលត្រូវបំពាក់តំរូវការបុគ្គលិក និងការបណ្តុះបណ្តាល (Need Assessment for staffing and trainings) និងធ្វើការវិភាគ លើរបៀបរបបប្រតិបត្តិការការងារនៅស្រុកទាំងពីរ (Operational Review). ។
- រៀបចំ និងតាមដានការអនុវត្តន៍ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ
- បណ្តុះបណ្តាលធនធានមនុស្ស សំរាប់ការអនុវត្តន៍ ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយនៅស្រុកទាំងពីរ
- រៀបចំបង្កើតកន្សោមអាទិភាព នៅការិយាល័យច្រកចេញចូលតែមួយ នៃស្រុកទាំងពីរ ។

សេចក្តីដូចបានជំរាបជូនខាងលើ និងក្នុងស្មារតីជំរុញការអនុវត្តន៍គំរោងសាកល្បងនេះឱ្យបានទទួលជោគជ័យតាមការរំពឹងទុករបស់រាជរដ្ឋាភិបាលក៏ដូចជាប្រជាពលរដ្ឋ សូមឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាជ្រាប និង ពិនិត្យលទ្ធភាពអនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការបន្តជាមួយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ចំពោះកិច្ចការដូចបានជំរាបជូនខាងលើនេះ ដោយក្តីអនុគ្រោះ ។

សូម ឯកឧត្តម ទេសរដ្ឋមន្ត្រី ទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ជ. ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

ប្រធាន

សុខ អាន

ចំលងជូន

-គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧត្តមក្រុមប្រឹក្សា កំណែទម្រង់រដ្ឋ

ក្រុមប្រឹក្សា កំណែទម្រង់រដ្ឋបាល

លេខៈ ១៧៦/០៤ សរស៧

ភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៤

**សូមគោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ** : ការផ្តល់យោបល់លើ សេចក្តីព្រាងប្រកាសស្តីពី "ប្រតិភូកម្មអំណាច" ជូនដល់ស្រុកសាកល្បងទាំងពីរ និង សេចក្តីណែនាំស្តីពី " ការអនុវត្តន៍ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញ-ចូលតែមួយ" ជូនប្រជាពលរដ្ឋរស់នៅស្រុកទាំងពីរ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកត្តិយសសូមជំរាប ឯកឧត្តមរដ្ឋមន្ត្រី ជូនជ្រាបថា ចាប់តាំងពីរាជរដ្ឋាភិបាលបានចេញសេចក្តីសំរេចលេខ ៤៧ ស្តីពីការកំណត់រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល នៅស្រុកបាត់ដំបង ខេត្តបាត់ដំបង និង ស្រុកសៀមរាប ខេត្តសៀមរាប ជាពិសេសដោយអនុលោមលើមាត្រាទី ៥ និង ទី ៦ នៃសេចក្តីសំរេចនេះ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល បានធ្វើការសំរបសំរួលជាមួយក្រសួងពាក់ព័ន្ធទាំងអស់ដើម្បីរៀបចំបញ្ជីសេវាកម្មសំរាប់ធ្វើការផ្ទេរជាជំហានៗជូនស្រុកបាត់ដំបង និងស្រុកសៀមរាប និងផ្តល់ការពិគ្រោះយោបល់លើប្រកាស និងសេចក្តីណែនាំ របស់ក្រសួងពាណិជ្ជកម្ម និង ក្រសួងពាក់ព័ន្ធទាំងអស់ក្នុងកិរិតបច្ចេកទេសរួចហើយ ។

ដោយឈរលើមូលដ្ឋាននេះ ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សូមផ្តល់យោបល់ឯកភាព និងគាំទ្រទៅលើខ្លឹមសារនៃសេចក្តីព្រាងប្រកាសស្តីពី "ប្រតិភូកម្មអំណាច" ជូនដល់ស្រុកសាកល្បងទាំងពីរ និង សេចក្តីណែនាំស្តីពី" ការអនុវត្តន៍ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញ-ចូលតែមួយ របស់ក្រសួងពាណិជ្ជកម្ម ។

ប៉ុន្តែនៅជំហានបន្ទាប់ដើម្បីអនុវត្តន៍គំរោងសាកល្បងនៅ ស្រុកទាំងពីរនេះបានជោគជ័យ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សូមធ្វើការកត់សំគាល់ដូចខាងក្រោម :

១-នាពេលកន្លងមកក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសង្កេតឃើញថា ក្រសួងពាណិជ្ជកម្មបានខិតខំប្រឹងប្រែងរៀបចំឯកសារដូចមានរៀបរាប់ខាងលើសំរាប់គំរោងសាកល្បងនេះយ៉ាងសកម្មជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល អាស្រ័យហេតុនេះ ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ខ្ញុំសូមធ្វើការកោតសរសើរដ៏ស្មោះស្ម័គ្រចំពោះស្មារតីទទួលខុសត្រូវដ៏ខ្ពង់ខ្ពស់នេះ ។

២-យោងតាមស្មារតីនៃមាត្រា ៥ និង ៦ នៃសេចក្ដីសំរេចលេខ ៤៧ តំរូវអោយក្រសួងពាណិជ្ជកម្ម ស្នើសុំការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់ លើសេចក្ដីព្រាងនេះ ។

៣- បន្ទាប់ពីប្រកាស និងសេចក្ដីណែនាំនេះត្រូវបានប្រកាសជាផ្លូវការ ហើយក្រសួងពាក់ព័ន្ធនីមួយៗ នឹងត្រូវធ្វើការងារជាច្រើនបន្តទៀតជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល លើការងារមួយចំនួន ដូចខាងក្រោម:

- វាយតំលៃពីស្ថានភាពជាក់ស្ដែងនៃស្រុកទាំងពីរ អំពីសេចក្ដីត្រូវការខាងសំភារៈដែលត្រូវបំពាក់តំរូវការបុគ្គលិក និងការបណ្ដុះបណ្ដាល (Need Assessment for staffing and trainings) និងធ្វើការវិភាគ លើរបៀបរបបប្រតិបត្តិការការងារនៅស្រុកទាំងពីរ (Operational Review). ។
- រៀបចំ និងតាមដានការអនុវត្តន៍ ការផ្ដល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ
- បណ្ដុះបណ្ដាលធនធានមនុស្ស សំរាប់ការអនុវត្តន៍ការផ្ដល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយនៅស្រុកទាំងពីរ
- រៀបចំបង្កើតកន្សោមអាទិភាព នៅការិយាល័យច្រកចេញចូលតែមួយ នៃស្រុកទាំងពីរ ។

សេចក្ដីដូចបានជំរាបជូនខាងលើ និងក្នុងស្មារតីជំរុញការអនុវត្តន៍គំរោងសាកល្បងនេះ ឱ្យបានទទួលជោគជ័យតាមការរំពឹងទុករបស់រាជរដ្ឋាភិបាលក៏ដូចជាប្រជាពលរដ្ឋ សូមឯកឧត្តម រដ្ឋមន្ត្រី មេត្តាជ្រាប និង ពិនិត្យលទ្ធភាពអនុញ្ញាតឱ្យក្រសួងពាណិជ្ជកម្ម ធ្វើការបន្តជាមួយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ចំពោះកិច្ចការ ដូចបានជំរាបជូនខាងលើនេះ ដោយក្ដីអនុគ្រោះ ។

សូម ឯកឧត្តមរដ្ឋមន្ត្រី ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ជ. ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

ប្រធាន

សុខ អាន

ចំលងជូន

-គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ឧត្តមក្រុមប្រឹក្សា កំណែទម្រង់រដ្ឋ

ក្រុមប្រឹក្សា កំណែទម្រង់រដ្ឋបាល

លេខៈ ១៧៤ /០៤

ភ្នំពេញ, ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៤

**សូមគោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**កម្មវត្ថុ** : ការផ្តល់យោបល់លើ សេចក្តីព្រាងប្រកាសស្តីពី "ប្រតិភូកម្មអំណាច" ជូនដល់ស្រុកសាកល្បងទាំងពីរ និង សេចក្តីណែនាំស្តីពី "ការអនុវត្តន៍ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញ-ចូលតែមួយ" ជូនប្រជាពលរដ្ឋរស់នៅស្រុកទាំងពីរ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកត្តិយសសូមជំរាបជូន ឯកឧត្តមរដ្ឋមន្ត្រី ជ្រាបថា ចាប់តាំងពីរាជរដ្ឋាភិបាលបានចេញសេចក្តីសំរេចលេខ ៤៧ ស្តីពីការកំណត់រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល នៅស្រុកបាត់ដំបង ខេត្តបាត់ដំបង និងស្រុកសៀមរាប ខេត្តសៀមរាប ជាពិសេសដោយអនុលោមលើមាត្រាទី ៥ និង ទី ៦ នៃសេចក្តីសំរេចនេះ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានធ្វើការសំរបសំរួលជាមួយក្រសួងពាក់ព័ន្ធទាំងអស់ដើម្បីរៀបចំបញ្ជីសេវាកម្មសំរាប់ធ្វើការផ្ទេរជាជំហាន១ជូនស្រុកបាត់ដំបង និងស្រុកសៀមរាប និងផ្តល់ការពិគ្រោះយោបល់លើប្រកាស និងសេចក្តីណែនាំរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និង ក្រសួងពាក់ព័ន្ធទាំងអស់ក្នុងកំរិតបច្ចេកទេសរួចហើយ ។

ដោយឈរលើមូលដ្ឋាននេះ ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សូមផ្តល់យោបល់ឯកភាព និងគាំទ្រទៅលើខ្លឹមសារនៃសេចក្តីព្រាងប្រកាសស្តីពី "ប្រតិភូកម្មអំណាច" ជូនដល់ស្រុកសាកល្បងទាំងពីរ និង សេចក្តីណែនាំស្តីពី "ការអនុវត្តន៍ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញ-ចូលតែមួយ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

ប៉ុន្តែនៅជំហានបន្ទាប់ដើម្បីអនុវត្តន៍គំរោងសាកល្បងនៅ ស្រុកទាំងពីរនេះបានជោគជ័យ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សូមធ្វើការកត់សំគាល់ដូចខាងក្រោម :

១-នាពេលកន្លងមកក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសង្កេតឃើញថា ក្រសួងសាធារណការ និងដឹកជញ្ជូនបានខិតខំប្រឹងប្រែងរៀបចំឯកសារដូចមានរៀបរាប់ខាងលើសំរាប់គំរោងសាកល្បងនេះយ៉ាងសកម្ម ជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល។ អាស្រ័យហេតុនេះ ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ខ្ញុំសូមសំដែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្រចំពោះស្មារតីទទួលខុសត្រូវដ៏ខ្ពង់ខ្ពស់នេះ ។ /.

២-យោងតាមស្មារតីនៃមាត្រា ៥ និង ៦ នៃសេចក្ដីសំរេចលេខ ៤៧ តំរូវអោយក្រសួងសាធារណការ និងដឹកជញ្ជូន ស្នើសុំការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់ លើសេចក្ដីព្រាងនេះ ។

៣- បន្ទាប់ពីប្រកាស និងសេចក្ដីណែនាំនេះត្រូវបាន ប្រកាសជាផ្លូវការហើយ ក្រសួងពាក់ព័ន្ធនីមួយៗ នឹងត្រូវធ្វើការងារជាច្រើនបន្តទៀតជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល លើការងារមួយចំនួន ដូចខាងក្រោមៈ

- វាយតំលៃពីស្ថានភាពជាក់ស្តែងនៃស្រុកទាំងពីរ អំពីសេចក្ដីត្រូវការខាងសំភារៈដែលត្រូវបំពាក់តំរូវការបុគ្គលិក និងការបណ្ដុះបណ្ដាល (Need Assessment for staffing and trainings) និងធ្វើការវិភាគ លើរបៀបរបបប្រតិបត្តិការការងារនៅស្រុកទាំងពីរ (Operational Review). ។
- រៀបចំ និងតាមដានការអនុវត្តន៍ការផ្ដល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ
- បណ្ដុះបណ្ដាលធនធានមនុស្ស សំរាប់ការអនុវត្តន៍ ការផ្ដល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយនៅស្រុកទាំងពីរ
- រៀបចំបង្កើតកន្សោមអាទិភាព នៅការិយាល័យច្រកចេញចូលតែមួយ នៃស្រុកទាំងពីរ ។

សេចក្ដីដូចបានជំរាបជូនខាងលើ និងក្នុងស្មារតីជំរុញការអនុវត្តន៍គំរោងសាកល្បងនេះ ឱ្យបានទទួលជោគជ័យតាមការរំពឹងទុករបស់រាជរដ្ឋាភិបាលក៏ដូចជាប្រជាពលរដ្ឋ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាប និង ពិនិត្យលទ្ធភាពអនុញ្ញាតឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន ធ្វើការបន្តជាមួយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ចំពោះកិច្ចការដូចបានជំរាបជូនខាងលើនេះ ដោយក្តីអនុគ្រោះ ។

សូម ឯកឧត្តម រដ្ឋមន្ត្រី ទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
ប្រធាន

សុខ អាន

ចំលងជូន

-គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ឧត្តមក្រុមប្រឹក្សា កំណែទំរង់រដ្ឋ
៥២៥២
ក្រុមប្រឹក្សា កំណែទំរង់រដ្ឋបាល
លេខ: ១៧៧//០៤ ស៥៣

ភ្នំពេញ, ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៤

### សូមគោរពជូន

### ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍

**កម្មវត្ថុ** : ការផ្ដល់យោបល់លើ សេចក្ដីព្រាងប្រកាសស្ដីពី "ប្រតិភូកម្មអំណាច" ជូនដល់ស្រុកសាកល្បងទាំងពីរ និង សេចក្ដីណែនាំស្ដីពី "ការអនុវត្តន៍ការផ្ដល់សេវាកម្មរដ្ឋបាលតាមច្រកចេញ-ចូលតែមួយ" ជូនប្រជាពលរដ្ឋរស់នៅស្រុកទាំងពីរ ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកត្តិយសសូមជំរាប ឯកឧត្តមទេសរដ្ឋមន្ត្រី ជូនជ្រាបថា ចាប់តាំងពី រាជរដ្ឋាភិបាលបានចេញសេចក្ដីសំរេចលេខ ៤៧ ស្ដីពីការកំណត់រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល នៅស្រុកបាត់ដំបង ខេត្តបាត់ដំបង និង ស្រុកសៀមរាប ខេត្តសៀមរាប ជាពិសេសដោយអនុលោមលើមាត្រាទី ៥ និង ទី ៦ នៃសេចក្ដីសំរេចនេះ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានធ្វើការសំរបសំរួលជាមួយក្រសួងពាក់ព័ន្ធទាំងអស់ ដើម្បីរៀបចំបញ្ជីសេវាការ សំរាប់ធ្វើការផ្ទេរជាជំហាន១ជូនស្រុកបាត់ដំបង និងស្រុកសៀមរាប និងផ្ដល់ការពិគ្រោះយោបល់ លើប្រកាស និងសេចក្ដីណែនាំ របស់ក្រសួងទេសចរណ៍ និង ក្រសួងពាក់ព័ន្ធទាំងអស់ក្នុងកិច្ចបច្ចេកទេសរួចហើយ ។

ផ្អែកលើមូលដ្ឋាននេះ ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សូមផ្ដល់យោបល់ឯកភាព និងគាំទ្រទៅលើខ្លឹមសារនៃសេចក្ដីព្រាងប្រកាសស្ដីពី "ប្រតិភូកម្មអំណាច" ជូនដល់ស្រុកសាកល្បងទាំងពីរ និង សេចក្ដីណែនាំស្ដីពី "ការអនុវត្តន៍ការផ្ដល់សេវាកម្មរដ្ឋបាលតាមច្រកចេញ-ចូលតែមួយ" របស់ក្រសួងទេសចរណ៍។

ក្នុងនាមជំហានបន្ទាប់ដើម្បីអនុវត្តន៍គំរោងសាកល្បងនៅ ស្រុកទាំងពីរនេះបានជោគជ័យ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សូមធ្វើការកត់សំគាល់ដូចខាងក្រោម :

១-កន្លងមកក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសង្កេតឃើញថា ក្រសួងទេសចរណ៍ បានខិតខំប្រឹងប្រែងរៀបចំឯកសារដូចមានរៀបរាប់ខាងលើ សំរាប់គំរោងសាកល្បងនេះ យ៉ាងសកម្មជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដោយហេតុនេះ ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ខ្ញុំសូមធ្វើការកោតសរសើរដ៏ស្មោះស្ម័គ្រចំពោះស្មារតីទទួលខុសត្រូវដ៏ខ្ពង់ខ្ពស់នេះ។

២-យោងតាមស្មារតីនៃមាត្រា ៥ និង ៦ នៃសេចក្តីសំរេចលេខ ៤៧ តំរូវអោយក្រសួងទេសចរណ៍ ស្នើសុំការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់ លើសេចក្តីព្រាងនេះ ។

៣- បន្ទាប់ពីប្រកាស និងសេចក្តីណែនាំនេះត្រូវបាន ប្រកាសជាផ្លូវការហើយ ក្រសួងពាក់ព័ន្ធនីមួយៗ នឹងត្រូវធ្វើការងារជាច្រើនបន្តទៀតជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល លើការងារមួយចំនួន ដូចខាងក្រោម:

- វាយតំលៃពីស្ថានភាពជាក់ស្តែងនៃស្រុកទាំងពីរ អំពីសេចក្តីត្រូវការខាងសំភារៈដែលត្រូវបំពាក់តំរូវការបុគ្គលិក និងការបណ្តុះបណ្តាល (Need Assessment for staffing and trainings) និងធ្វើការវិភាគ លើរបៀបរបបប្រតិបត្តិការការងារនៅស្រុកទាំងពីរ (Operational Review). ។
- រៀបចំ និងតាមដានការអនុវត្តន៍ ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ
- បណ្តុះបណ្តាលធនធានមនុស្ស សំរាប់ការអនុវត្តន៍ ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយនៅស្រុកទាំងពីរ
- រៀបចំបង្កើតគណៈកន្សោមអាទិភាព នៅការិយាល័យច្រកចេញចូលតែមួយ នៃស្រុកទាំងពីរ ។

សេចក្តីដូចបានជំរាបជូនខាងលើ និងក្នុងស្មារតីជំរុញការអនុវត្តន៍គំរោងសាកល្បងនេះឱ្យបានទទួលជោគជ័យតាមការរំពឹងទុករបស់រាជរដ្ឋាភិបាលក៏ដូចជាប្រជាពលរដ្ឋ សូមឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាជ្រាប និងពិនិត្យលទ្ធភាពអនុញ្ញាតឱ្យក្រសួងទេសចរណ៍ ធ្វើការបន្តជាមួយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ចំពោះកិច្ចការ ដូចបានជំរាបជូនខាងលើនេះ ដោយក្តីអនុគ្រោះ ។

សូម ឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ជ. ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
ប្រធាន

សុខ អាន

ចំលងជូន
-គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ឧត្តមក្រុមប្រឹក្សា កំណែទម្រង់រដ្ឋ
ក្រុមប្រឹក្សា កំណែទម្រង់រដ្ឋបាល
លេខ: ១៧៤/០៤ សជក

ភ្នំពេញ, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៤

**សូមគោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**កម្មវត្ថុ** : ការផ្ដល់យោបល់លើ សេចក្ដីព្រាងប្រកាសស្ដីពី "ប្រតិភូកម្មអំណាច" ជូនដល់ស្រុកសាកល្បងទាំងពីរ និង សេចក្ដីណែនាំស្ដីពី " ការអនុវត្តន៍ការផ្ដល់សេវាកម្មរដ្ឋបាលតាមច្រកចេញ-ចូលតែមួយ" ជូនប្រជាពលរដ្ឋរស់នៅស្រុកទាំងពីរ ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមជំរាបជូន ឯកឧត្តមរដ្ឋមន្ត្រី ជ្រាបថា ចាប់តាំងពីរាជរដ្ឋាភិបាលបានចេញសេចក្ដីសំរេចលេខ ៤៧ ស្ដីពីការកំណត់រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល នៅស្រុកបាត់ដំបង ខេត្តបាត់ដំបង និង ស្រុកសៀមរាប ខេត្តសៀមរាប ជាពិសេសដោយអនុលោមលើមាត្រាទី ៥ និង ទី ៦ នៃសេចក្ដីសំរេចនេះ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានធ្វើការសំរបសំរួលជាមួយក្រសួងពាក់ព័ន្ធទាំងអស់ដើម្បីរៀបចំបញ្ជីសេវាកម្មសំរាប់ធ្វើការផ្ទេរជាជំហានៗជូនស្រុកបាត់ដំបង និងស្រុកសៀមរាប និង ផ្ដល់ការពិគ្រោះយោបល់លើប្រកាស និងសេចក្ដីណែនាំរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រសួងពាក់ព័ន្ធទាំងអស់ក្នុងកិរិតបច្ចេកទេសរួចហើយ ។

ដោយឈរលើមូលដ្ឋាននេះ ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សូមផ្ដល់យោបល់ឯកភាព និងគាំទ្រទៅលើខ្លឹមសារនៃសេចក្ដីព្រាងប្រកាសស្ដីពី "ប្រតិភូកម្មអំណាច" ជូនដល់ស្រុកសាកល្បងទាំងពីរ និង សេចក្ដីណែនាំស្ដីពី" ការអនុវត្តន៍ការផ្ដល់សេវាកម្មរដ្ឋបាលតាមច្រកចេញ-ចូលតែមួយ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប៉ុន្តែនៅជំហានបន្ទាប់ដើម្បីអនុវត្តន៍គំរោងសាកល្បងនៅ ស្រុកទាំងពីរនេះបានជោគជ័យ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សូមធ្វើការកត់សំគាល់ដូចខាងក្រោម :

១-នាពេលកន្លងមកក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសង្កេតឃើញថា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានខិតខំប្រឹងប្រែងរៀបចំឯកសារដូចមានរៀបរាប់ខាងលើសំរាប់គំរោងសាកល្បងនេះយ៉ាងសកម្ម ជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល។ អាស្រ័យហេតុនេះ ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ខ្ញុំសូមសំដែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្រចំពោះស្មារតីទទួលខុសត្រូវដ៏ខ្ពង់ខ្ពស់នេះ។ /-

២-យោងតាមស្មារតីនៃមាត្រា ៥ និង ៦ នៃសេចក្តីសំរេចលេខ ៤៧ តំរូវអោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្នើសុំការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់ លើសេចក្តីព្រាងនេះ ។

៣- បន្ទាប់ពីប្រកាស និងសេចក្តីណែនាំនេះត្រូវបាន ប្រកាសជាផ្លូវការហើយ ក្រសួងពាក់ព័ន្ធនីមួយៗ នឹងត្រូវធ្វើការងារជាច្រើនបន្តទៀតជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល លើការងារមួយចំនួន ដូចខាងក្រោម:

- វាយតំលៃពីស្ថានភាពជាក់ស្តែងនៃស្រុកទាំងពីរ អំពីសេចក្តីត្រូវការខាងសំភារៈដែលត្រូវបំពាក់តំរូវការបុគ្គលិក និងការបណ្តុះបណ្តាល (Need Assessment for staffing and trainings) និងធ្វើការវិភាគ លើរបៀបរបបប្រតិបត្តិការការងារនៅស្រុកទាំងពីរ (Operational Review). ។
- រៀបចំ និងតាមដានការអនុវត្តន៍ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ
- បណ្តុះបណ្តាលធនធានមនុស្ស សំរាប់ការអនុវត្តន៍ ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយនៅស្រុកទាំងពីរ
- រៀបចំបង្កើតកន្សោមអាទិភាព នៅការិយាល័យច្រកចេញចូលតែមួយ នៃស្រុកទាំងពីរ ។

សេចក្តីដូចបានជំរាបជូនខាងលើ និងក្នុងស្មារតីជំរុញការអនុវត្តន៍គំរោងសាកល្បងនេះ ឱ្យបានទទួលជោគជ័យតាមការរំពឹងទុករបស់រាជរដ្ឋាភិបាលក៏ដូចជាប្រជាពលរដ្ឋ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាប និង ពិនិត្យលទ្ធភាពអនុញ្ញាតឱ្យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ធ្វើការបន្តជាមួយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ចំពោះកិច្ចការដូចបានជំរាបជូនខាងលើនេះ ដោយក្តីអនុគ្រោះ ។

សូម ឯកឧត្តមរដ្ឋមន្ត្រី ទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ជ. ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

សុខ អាន

ចំលងជូន

-គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧត្តមក្រុមប្រឹក្សា កំណែទំរង់រដ្ឋ
(ឧ.ក.ក.រ)
ក្រុមប្រឹក្សា កំណែទំរង់រដ្ឋបាល
លេខ: ១៧៩/០៤ ក.ក.រ

ភ្នំពេញ, ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៤

**សូមទទួលថ្វាយ**

**សម្តេចព្រះរៀម រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

**កម្មវត្ថុ** : ការផ្តល់យោបល់លើ សេចក្តីព្រាងប្រកាសស្តីពី "ប្រតិភូកម្មអំណាច" ជូនដល់ស្រុកសាកល្បងទាំងពីរ និង សេចក្តីណែនាំស្តីពី " ការអនុវត្តនីការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញ-ចូលតែមួយ" ជូនប្រជាពលរដ្ឋរស់នៅស្រុកទាំងពីរ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ទូលបង្គំខ្ញុំសូមទទួលថ្វាយសម្តេចព្រះរៀម សូមទ្រង់មេត្តាជ្រាបថា ចាប់តាំងពីរាជរដ្ឋាភិបាលបានចេញសេចក្តីសំរេចលេខ ៤៧ ស្តីពីការកំណត់រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅស្រុកបាត់ដំបង ខេត្តបាត់ដំបង និង ស្រុកសៀមរាប ខេត្តសៀមរាប ជាពិសេសដោយអនុលោមលើមាត្រាទី ៥ និង ទី ៦ នៃសេចក្តីសំរេចនេះ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល បានធ្វើការសំរបសំរួលជាមួយក្រសួងពាក់ព័ន្ធទាំងអស់ដើម្បីរៀបចំបញ្ជីសេវាកម្មសំរាប់ធ្វើការផ្ទេរជាជំហាន១ជូនស្រុកបាត់ដំបង និងស្រុកសៀមរាប និងផ្តល់ការពិគ្រោះយោបល់លើប្រកាស និងសេចក្តីណែនាំ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងពាក់ព័ន្ធទាំងអស់ក្នុងកិតបច្ចេកទេសរួចហើយ ។

ដោយឈរលើមូលដ្ឋាននេះ ក្នុងនាមទូលបង្គំខ្ញុំជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សូមផ្តល់យោបល់ឯកភាព និង គាំទ្រទៅលើខ្លឹមសារនៃសេចក្តីព្រាងប្រកាសស្តីពី "ប្រតិភូកម្មអំណាច" ជូនដល់ស្រុកសាកល្បងទាំងពីរ និងសេចក្តីណែនាំស្តីពី" ការអនុវត្តនីការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញ-ចូលតែមួយ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

ប៉ុន្តែនៅជំហានបន្ទាប់ដើម្បីអនុវត្តន៍គំរោងសាកល្បងនៅ ស្រុកទាំងពីរនេះបានជោគជ័យ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សូមធ្វើការកត់សំគាល់ដូចខាងក្រោម :

១-នាពេលកន្លងមកក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសង្កេតឃើញថា ក្រសួងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានខិតខំប្រឹងប្រែងរៀបចំឯកសារដូចមានរៀបរាប់ខាងលើ សំរាប់គំរោងសាកល្បងនេះយ៉ាងសកម្មជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល។ អាស្រ័យហេតុនេះ ក្នុងនាមទូលបង្គំខ្ញុំជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ទូលបង្គំខ្ញុំសូមសំដែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្រចំពោះស្មារតីទទួលខុសត្រូវដ៏ខ្ពង់ខ្ពស់នេះ ។ /១ -

២-យោងតាមស្មារតីនៃមាត្រា ៥ និង ៦ នៃសេចក្តីសំរេចលេខ ៤៧ តំរូវអោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ស្នើសុំការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់ លើសេចក្តីព្រាងនេះ ។

៣- បន្ទាប់ពីប្រកាស និងសេចក្តីណែនាំនេះត្រូវបានប្រកាសជាផ្លូវការហើយ ក្រសួងពាក់ព័ន្ធនីមួយៗ នឹងត្រូវធ្វើការងារជាច្រើនបន្តទៀតជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល លើការងារមួយចំនួន ដូចខាងក្រោមៈ

- វាយតំលៃពីស្ថានភាពជាក់ស្តែងនៃស្រុកទាំងពីរ អំពីសេចក្តីត្រូវការខាងសំភារៈដែលត្រូវបំពាក់តំរូវការបុគ្គលិក និងការបណ្តុះបណ្តាល (Need Assessment for staffing and trainings) និងធ្វើការវិភាគ លើរបៀបរបបប្រតិបត្តិការការងារនៅស្រុកទាំងពីរ (Operational Review). ។
- រៀបចំ និង តាមដានការអនុវត្តន៍ ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ
- បណ្តុះបណ្តាលធនធានមនុស្ស សំរាប់ការអនុវត្តន៍ ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយនៅស្រុកទាំងពីរ
- រៀបចំបង្កើតកន្សោមអាទិភាព នៅការិយាល័យច្រកចេញចូលតែមួយ នៃស្រុកទាំងពីរ ។

សេចក្តីដូចបានទូលថ្វាយខាងលើ និងក្នុងស្មារតីជំរុញការអនុវត្តន៍គំរោងសាកល្បងនេះឱ្យបានទទួលជោគជ័យតាមការរំពឹងទុករបស់រាជរដ្ឋាភិបាលក៏ដូចជាប្រជាពលរដ្ឋ សូមសម្តេចព្រះរៀមទ្រង់មេត្តាជ្រាប និង ពិនិត្យលទ្ធភាពអនុញ្ញាតឱ្យក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ធ្វើការបន្តជាមួយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ចំពោះកិច្ចការដូចបានជំរាបជូនខាងលើនេះ ដោយក្តីអនុគ្រោះ ។

សូម សម្តេចព្រះរៀមរដ្ឋមន្ត្រី ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីទូលបង្គំខ្ញុំ ។

ជ. ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

សុខ អាន

<u>ចំលងជូន</u>

-គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ឧត្តមក្រុមប្រឹក្សា កំណែទំរង់រដ្ឋ

ក្រុមប្រឹក្សា កំណែទំរង់រដ្ឋបាល

លេខ: ១៦០/០៤

ភ្នំពេញ, ថ្ងៃទី ២៣ ខែ មថុនា ឆ្នាំ ២០០៤

**សូមគោរពជូន**

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ**

**កម្មវត្ថុ** : ការផ្តល់យោបល់លើ សេចក្តីព្រាងប្រកាសស្តីពី "រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល" - ប្រកាសស្តីពី "ការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យប្រជាពលរដ្ឋ" - ប្រកាសស្តីពី "ការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយ" នៅស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកត្តិយសសូមជំរាប ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី ជូនជ្រាបថា ចាប់តាំងពីរាជរដ្ឋាភិបាលបានចេញ សេចក្តីសំរេចលេខ ៤៧ ស្តីពីការកំណត់រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅ ស្រុកបាត់ដំបង និង ស្រុកសៀមរាប ជាពិសេសដោយអនុលោមលើមាត្រាទី ៥ និង ទី ៦ នៃសេចក្តីសំរេចនេះ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល បានធ្វើការសំរបសំរួលជាមួយក្រសួងពាក់ព័ន្ធទាំងអស់ដើម្បីរៀបចំបញ្ជីសេវាកម្ម សំរាប់ធ្វើការផ្ទេរជាជំហាន១ជូនស្រុក បាត់ដំបង និងស្រុក សៀមរាប និង ផ្តល់ការពិគ្រោះយោបល់លើប្រកាសរបស់ក្រសួងមហាផ្ទៃ និង ក្រសួងពាក់ព័ន្ធទាំងអស់ក្នុងកិរិតបច្ចេកទេសរួចហើយ ។ ដោយឈរលើមូលដ្ឋាននេះ ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សូមឯកភាព និងគាំទ្រទៅលើខ្លឹមសារនៃសេចក្តីព្រាងប្រកាសទាំងបីរបស់ក្រសួងមហាផ្ទៃដែលបានកែសំរួលដោយគណៈកម្មការធិការជាតិគាំទ្រឃុំ-សង្កាត់ ប៉ុន្តែនៅជំហានបន្ទាប់ដើម្បីអនុវត្តន៏គំរោងសាកល្បងនៅស្រុកទាំងពីរនេះបានជោគជ័យ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សូមធ្វើការកត់សំគាល់ដូចខាងក្រោម :

១-នាពេលកន្លងមកដោយយល់ឃើញថា គំរោងនេះពាក់ព័ន្ធនឹងកំណែទំរង់រដ្ឋបាល គោលនយោបាយវិសហមជ្ឈការ និង ការងារអន្តរវិស័យ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលតែងតែយកចិត្តទុកដាក់ធ្វើការសំរបសំរួល និង សហការយ៉ាងសកម្មជាមួយក្រសួងមហាផ្ទៃ ក៏ដូចជាគណៈកម្មការធិការជាតិគាំទ្រឃុំ-សង្កាត់ទៅលើការរៀបចំគំរោងសាកល្បងនៅស្រុក បាត់ដំបង និង ស្រុក សៀមរាប ។

២-ដើម្បីដាក់ឱ្យដំណើរការនូវ ការអនុវត្តន៏សាកល្បងការផ្តល់សេវាកម្មតាមច្រកចេញ-ចូលតែមួយ នៅស្រុកសៀមរាបនៃ ខេត្តសៀមរាប និងស្រុកបាត់ដំបង នៃខេត្តបាត់ដំបងបាន តាមកាលបរិច្ឆេទច្បាស់លាស់មួយនោះ ចាំបាច់ត្រូវវាយតំលៃពីស្ថានភាពជាក់ស្តែងនៃស្រុកទាំងពីរ អំពីសេចក្តីត្រូវការខាងសំភារៈដែលត្រូវបំពាក់តំរូវ /.



ទីស្នាក់ការស្ថិតនៅ ទីស្តីការគណៈរដ្ឋមន្ត្រី មហាវិថីសហព័ន្ធរុស្ស៊ី រាជធានី ភ្នំពេញ
ទូរស័ព្ទ : (៨៥៥) ០២៣-៨៨ ១៣ ០៧ ប្រអប់សំបុត្រលេខ ១២៨១ ទូរសារ: (៨៥៥) ០២៣-៣៦ ២១ ៩១

ការបុគ្គលិក និងការបណ្តុះបណ្តាល (Need Assessment for staffing and trainings) និងធ្វើការវិភាគលើរបៀបរបបប្រតិបត្តិការការងារនៅស្រុកទាំងពីរ (Operational Review). ។

៣- គួរបែងចែកការងារ និង ការទទួលខុសត្រូវលើការអនុវត្តន៍គំរោងសាកល្បងនេះឱ្យបានច្បាស់លាស់រវាង គណៈកម្មការធិការជាតិគាំទ្រឃុំ-សង្កាត់ ក្រសួងមហាផ្ទៃ និង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដែលក្នុងនោះ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សូមស្នើទទួលបន្ទុកលើការងារមួយចំនួនដូចខាងក្រោមៈ

- រៀបចំ ពិនិត្យ និង តាមដានការអនុវត្តន៍ ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ
- បណ្តុះបណ្តាលធនធានមនុស្ស សំរាប់ការអនុវត្តន៍ ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញចូលតែមួយនៅស្រុកទាំងពីរ
- សហការជាមួយក្រសួងពាក់ព័ន្ធរៀបចំបង្កើតកន្សោមអាទិភាព នៅការិយាល័យច្រកចេញចូលតែមួយនៃស្រុកទាំងពីរ ។

៤- ការងារដែលមានលក្ខណៈជាអន្តរវិស័យដែលនឹងទទួលបន្ទុកដោយ ប្រឹក្សាកំណែទំរង់រដ្ឋបាល ដូចបានរៀបរាប់ជូនខាងលើនេះ និងការងារផ្សេងៗទៀតនៃគំរោងសាកល្បងរបស់ស្រុកទាំងពីរដែលស្ថិតនៅក្រោមសមត្ថកិច្ចក្រសួងមហាផ្ទៃ និង គណៈកម្មការធិការជាតិគាំទ្រឃុំ-សង្កាត់ ជាការងារពីរដែលបំពេញឱ្យគ្នាទៅវិញទៅមក ដោយខានពុំបានសំដៅអនុវត្តគំរោងសាកល្បងនៅស្រុកទាំងពីរឱ្យបានជោគជ័យ ។

សេចក្តីដូចបានជំរាបជូនខាងលើ និងក្នុងស្មារតីជំរុញការអនុវត្តន៍គំរោងសាកល្បងនេះឱ្យបានទទួលជោគជ័យតាមការរំពឹងទុករបស់រាជរដ្ឋាភិបាលក៏ដូចជាប្រជាពលរដ្ឋ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី មេត្តាជ្រាប និង ពិនិត្យលទ្ធភាពអនុញ្ញាតឱ្យ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលធ្វើការងារដូចជំរាបជូនខាងលើនេះជាបន្តទៀតជាមួយក្រសួងមហាផ្ទៃដោយក្តីអនុគ្រោះ ។

សូម ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ជ. ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

ប្រធាន

សុខ អាន

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
ក្រសួងមហាផ្ទៃ

លេខ: ៤៦៣៤ ទ.ស.១៣

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០០៤

**សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ**

**និងជា សហប្រធានគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់**

**ជំរាបជូន**

**ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជា ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**កម្មវត្ថុ** : ការបន្តសហការគាំទ្ររវាងគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ក្រសួងមហាផ្ទៃ និង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ក្នុងការអនុវត្តគំរោងសាកល្បងនៅស្រុកសៀមរាប និង ស្រុកបាត់ដំបង ។

**យោង** : លិខិតលេខ ១៦០/០៤ សជណ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជា ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលជ្រាបថា អនុលោមតាមសេចក្តីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពី រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងនៅស្រុកសៀមរាប និង ស្រុកបាត់ដំបង ក្រសួងមហាផ្ទៃមានភារកិច្ចរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅតាមស្រុកទាំង ០២ ខាងលើនេះក្នុងគោលដៅអនុវត្តគំរូសាកល្បង គ្រប់គ្រងរដ្ឋបាលនៅតាមស្រុកទីប្រជុំជន អោយកាន់តែមានប្រសិទ្ធភាពក្នុងការផ្តល់សេវារដ្ឋបាល និង កៀកជិតប្រជាពលរដ្ឋ ។

គណៈកម្មការជាតិគាំទ្រឃុំ សង្កាត់ ក្រសួងមហាផ្ទៃ សូមឯកភាព និង គាំទ្រកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធក្នុងការអនុវត្តគំរោងខាងលើនេះបន្តទៀត លើការងារដូចដែលបានបញ្ជាក់ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល នៅក្នុងលិខិតលេខ ១៦០/០៤ សជណ ចុះថ្ងៃ ទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជា ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ជ្រាបតាមការគួរ ។

សូមឯកឧត្តម ទេសរដ្ឋមន្ត្រី ទទួលនូវការរាប់អានដ៏ស្មោះអំពីយើងខ្ញុំ ។

**សហរដ្ឋមន្ត្រី**

**និងជា សហប្រធានគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់**

**ស៊ឹម ចេង**

# ការគ្រោងផែនការសកម្មភាពគាំទ្រដល់ការរៀបចំដំណើរការ
# ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្មីនៅស្រុកបាត់ដំបង នៃខេត្តបាត់ដំបង
# និងស្រុកសៀមរាបនៃខេត្តសៀមរាប

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ការគ្រោងផែនការសកម្មភាព
# គាំទ្រដល់ការរៀបចំដាក់អោយដំណើរការ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្មី
# នៅស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង

**សាវតា**

គំរោងកំណែទម្រង់រដ្ឋបាលនៅស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ត្រូវបានដំណើរការក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃ និង មូលនិធិខុនរាដអាដេណៅអ៊ែរ និងមានការចូលរួមពីស្ថាប័ននៅថ្នាក់ជាតិដែលពាក់ព័ន្ធ ក្រោមជំនួយឧបត្ថម្ភពីសហគមន៍អឺរុប ។ ចាប់តាំងពីឆ្នាំ ២០០១ រហូតមកដល់បច្ចុប្បន្ន គំរោងបានទទួលការគាំទ្រពីក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងពីរាជរដ្ឋាភិបាល ។ សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពី រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រង ស្រុកសៀមរាប និង ស្រុកបាត់ដំបង បាននឹងកំពុងអោយក្រសួងស្ថាប័ននៅថ្នាក់ជាតិបន្តអនុវត្តគំរោង សាកល្បងសំរាប់ស្រុកទាំង ០២ នេះជាបន្តទៅទៀត ។

ផ្អែកលើសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួងមហាផ្ទៃបានរៀបចំប្រកាសចំនួន ០៣ ក្នុងនោះមានប្រកាស ស្តីពី រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល " ស្រុកសៀមរាប "ខេត្តសៀមរាប និង "ស្រុកបាត់ដំបង " ខេត្តបាត់ដំបង , ប្រកាស ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញ-ចូលតែមួយ , ប្រកាសស្តីពីការរៀបចំ និង ការប្រព្រឹត្ត ទៅនៃការិយាល័យប្រជាពលរដ្ឋ ។ ក្រសួងស្ថាប័នមួយចំនួនទៀតក៏បានរៀបចំប្រកាសធ្វើប្រតិភូកម្មអំណាចទៅអោយស្រុក ទាំង ០២ ផ្តល់សេវារដ្ឋបាលដែលពាក់ព័ន្ធដល់អាជីវកម្ម សិប្បកម្ម ក្នុងកិតសមត្ថកិច្ចរបស់ស្រុកទាំង ០២ នេះផងដែរ ។

ដើម្បីបន្តអនុវត្តគំរោង និង ឆ្លើយតបតាមសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល គណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង នឹងត្រូវរៀបចំឡើងនឹងក្រោមការដឹកនាំរបស់អភិបាលខេត្ត ឬ អភិបាលរងខេត្តសាមី ។

គណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បងនេះ ដែលរួមមានសមាជិកមកពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ មានភារកិច្ចសម្របសម្រួល និង ជួយគាំទ្រគ្រប់សកម្មភាពរបស់គណៈកម្មការ ក្នុងគោលដៅអោយរដ្ឋបាលថ្មីរបស់ស្រុកដំណើរការបានដោយសកម្ម រលូន និង ស៊ីសង្វាក់គ្នាលើគ្រប់ផ្នែកដែលពាក់ព័ន្ធ ។

ផ្អែកលើខ្លឹមសារខាងលើនេះ ក្រសួងមហាផ្ទៃ និង អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល បានរៀបចំគ្រោងផែនការសកម្មភាព គាំទ្រដល់ការដាក់អោយដំណើរការប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្មីរបស់ស្រុកទាំង ០២នេះ ដូចខាងក្រោម ។

## ការគ្រោងសកម្មភាព និង ពេលវេលាសំរាប់អនុវត្ត នៅឆ្នាំ ២០០៤ ដល់ ២០០៦

សកម្មភាពសំរាប់អនុវត្តនៅតាមស្រុកទាំង ០២ សំរាប់រយៈពេល ០៣ ឆ្នាំ ( ២០០៤ -២០០៦) ដំណាក់កាលការងារសំខាន់ៗ ដែលត្រូវលើកយកមកពិចារណា មានដូចតទៅ ÷

**ដំណាក់កាលទី ១** ( ឆមាសទី ២ ឆ្នាំ ២០០៤ )

-ជាដំណាក់កាលរៀបចំសំរាប់អោយដំណើរការប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្មី របស់ស្រុកទាំង ០២ ស្របតាមសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល និង អនុវត្តទៅតាមប្រកាស ទាំង ០៣ របស់ក្រសួងមហាផ្ទៃ និង ប្រកាសផ្សេងៗទៀតរបស់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធដល់ការផ្តល់សេវានៅថ្នាក់ស្រុក ។ ការងារសំខាន់ៗ ដែលក្នុងនោះមាន ÷

①-ផ្សព្វផ្សាយដល់មន្ត្រីរាជការ ប្រជាពលរដ្ឋនៅមូលដ្ឋាន អំពីសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ប្រកាសរបស់ក្រសួងមហាផ្ទៃ និង ប្រកាសរបស់ក្រសួងដែលពាក់ព័ន្ធ ( ខែ កក្កដា ) ។

②-ហ្វឹកហ្វឺន និង បណ្តុះបណ្តាល អំពីរបៀបរបបធ្វើការងារ វិភាគមុខងារ និង ដំណើរការអនុវត្តប្រកាស លិខិតបទដ្ឋានរបស់ថ្នាក់ជាតិ ដល់ថ្នាក់ដឹកនាំ ខេត្ត ស្រុក មន្ទីរការិយាល័យជំនាញជុំវិញស្រុក ក្រុមប្រឹក្សាឃុំ ( ខែសីហា-កញ្ញា ) ។

③-រៀបចំចាត់តាំង មន្ត្រីបំពេញការងារនៅតាមស្រុកទាំង ០២ ទៅតាមរចនាសម្ព័ន្ធថ្មី និង បំពាក់មូលដ្ឋានសំភារៈ ( ខែតុលា-វិច្ឆិកា-ធ្នូ ) ។

**ដំណាក់កាលទី ២**

-ជាដំណាក់កាលអនុវត្តគំរោងបន្ត ក្នុងគោលបំណងពង្រឹងសមត្ថភាពរបស់ស្រុក ពាក់ព័ន្ធទៅលើចំណូលថវិកា ដោយមានការចូលរួមពីប្រជាពលរដ្ឋ និង តម្លាភាព ក្នុងនោះចាប់ពីដើមឆ្នាំ ២០០៥ រហូតដល់ចុងឆ្នាំ ២០០៦ (២៤ខែ) ជាដំណាក់កាលអនុវត្តគំរោងដែលមានគោលដៅ ÷

-អភិវឌ្ឍន៍ចំណូលថវិកាតាមរយៈចំណូលពន្ធដារ និង ទេសចរណ៍ ។

-អភិវឌ្ឍន៍ទៅលើតម្លាភាព និង ប្រសិទ្ធភាពផែនការថវិកា ការអនុវត្តថវិកា និង ការត្រួតពិនិត្យ ។

-អភិវឌ្ឍន៍រៀបចំផែនការមេ (Master plan ) របស់ស្រុកទីប្រជុំជនខេត្ត

-អភិវឌ្ឍន៍ទៅលើការប្រតិបត្តិផែនការសកម្មភាព ដើម្បីធ្វើអោយកាន់តែប្រសើរឡើងទៅលើអភិបាលកិច្ច និង ការចូលរួមរបស់ប្រជាពលរដ្ឋ ។

-អភិវឌ្ឍន៍ប្រព័ន្ធពត៌មានវិទ្យា វិស័យរដ្ឋបាល សំរាប់ស្រុកទាំង ០២ ។

-អភិវឌ្ឍន៍មធ្យោបាយផ្សព្វផ្សាយឃោសនា និង ពត៌មាន លើវិស័យប្រតិបត្តិរដ្ឋបាល ។

-អភិវឌ្ឍន៍ លើកិច្ចសហប្រតិបត្តិការរវាងស្រុកទាំង ០២ របស់កម្ពុជាជាមួយស្រុកទាំង ០២ របស់ ប្រទេសអាល្លឺម៉ង់ និង អ៊ីតាលី ។

## I.- សកម្មភាពការងារគាំទ្រនៅក្នុងដំណាក់កាលទី ១
## (ចាប់ពីខែ កក្កដា ដល់ ខែ ធ្នូ ឆ្នាំ ២០០៤)

សកម្មភាពការងារគាំទ្រអនុវត្តគំរោងនៅក្នុងដំណាក់កាលទី ១ មានគោលបំណង និង គោលដៅដូចតទៅ ៖

**គោលបំណង និង គោលដៅ**

គោលបំនងនៃការបន្តអនុវត្តគំរោងសាកល្បងនៅស្រុកទាំង ០២ គឺ កសាង និង ពង្រឹងសមត្ថភាពមន្ត្រីរាជការនៅថ្នាក់មូលដ្ឋាន ចាប់តាំងពីថ្នាក់ខេត្តរហូតដល់ស្រុក ឃុំក្នុងទីប្រជុំជននៃខេត្តទាំង០២ និងធ្វើអោយមានការយល់ដឹងជាទូទៅក្នុងចំណោមប្រជាពលរដ្ឋក្នុងទីប្រជុំជនអំពីភារកិច្ច រួមកសាងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្មីអោយមានប្រសិទ្ធភាព និង តម្លាភាព ។

រៀបចំមន្ត្រីរាជការចូលកាន់ភារកិច្ចតាមប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្មី ដូចមានចែងក្នុងប្រកាសទាំង ០៣ របស់ក្រសួងមហាផ្ទៃ ។

រៀបចំអោយមានការចាប់ផ្តើមដំណើរការរដ្ឋបាលថ្មីនៅតាមស្រុកទាំង ០២ ចាប់តាំងពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៥ តទៅ ដោយមានការចូលរួមពិធីសម្ពោធបើកដំណើរការរដ្ឋបាលស្រុកទាំង ០២ ដោយថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ។

ឆ្លងកាត់ដំណើរការអនុវត្តសាកល្បងនៅតាមស្រុកទាំង ០២ គំរោងនេះ នឹងផ្តល់បទពិសោធន៍ តាមរយៈការប្រជុំទស្សនកិច្ចសិក្សាពីបណ្តាស្រុកទីប្រជុំជនផ្សេងៗទៀត ហើយនឹងឈានទៅរៀបចំ អោយមានប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមគំរូថ្មីនេះ នៅតាមស្រុកទីប្រជុំជន នៃខេត្តផ្សេងៗទៀត ។

**ខ្លឹមសារ**

ឯកសារដែលនឹងត្រូវផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ មន្ត្រីរាជការនៅតាមគោលដៅស្រុកទាំង ០២ គឺ ៖

-សេចក្តីសំរេច លេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពី រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាប នៃខេត្តសៀមរាប និង ស្រុកបាត់ដំបង នៃខេត្តបាត់ដំបង ។

-ប្រកាសលេខ ៧៩១ ប្រក ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពី រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

-ប្រកាស លេខ ៧៩២ ប្រក ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញ-ចូលតែមួយ ។

-ប្រកាស លេខ ៧៩០ប្រក ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃការិយាល័យប្រជាពលរដ្ឋ ។

ទន្ទឹមនោះ មានប្រកាសរបស់ក្រសួងស្ថាប័នមួយចំនួនបន្ថែមទៀត ដែលពាក់ព័ន្ធដល់ការអនុវត្តគំរោងសាកល្បងនេះ ។

ដើម្បីសំរេចបានគោលដៅក្នុងការអនុវត្តគំរោង ត្រូវមាន ការវិភាគមុខងារ ការងារហ្វឹកហ្វឺនបណ្តុះបណ្តាលមន្ត្រីបំពេញការងារនៅនឹងកន្លែង អំពីរបៀបរបបធ្វើការងារ និង ត្រូវរៀបចំមន្ត្រី បំពាក់មូលដ្ឋានសំភារៈអោយ បានសមស្រប ។

**ពេលវេលាអនុវត្ត**

ចាប់ពីខែកក្កដាដល់ខែធ្នូ ឆ្នាំ ២០០៤ ត្រូវរៀបចំការងារក្នុងដំណាក់កាលទី ១ ជា ៣ ជំហានដូចតទៅ ÷

**ជំហានទី ១ :** ( ខែកក្កដា )

ផ្សព្វផ្សាយលិខិតបទដ្ឋានរបស់ថ្នាក់ជាតិ ដែលពាក់ព័ន្ធដល់ការអនុវត្តគំរោងសាកល្បងបន្ត នៅស្រុកទាំង ០២ ក្នុងនោះត្រូវមានការចូលរួមពី តំណាងប្រជាពលរដ្ឋ តំណាងអាជីវករ តំណាងសង្គមស៊ីវិល តំណាងក្រុម-ប្រឹក្សាឃុំ មន្ទីរជុំវិញខេត្ត ការិយាល័យជំនាញជុំវិញស្រុក មន្ត្រីរាជការនៅថ្នាក់ខេត្ត ស្រុក និង មន្ត្រីរាជការនៅតាមអង្គភាព ដែលបោះទីតាំងនៅក្នុងខេត្តរបស់ខ្សែបណ្ដោយក្រសួងស្ថាប័នថ្នាក់ជាតិ ។ នៅក្នុងជំហានទី ១ នេះ ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានរដ្ឋបាល ដោយមានកិច្ចសម្របសម្រួល និង សហការជាមួយ អគ្គលេខាធិការដ្ឋានកំណែទំរង់រដ្ឋបាល មូលនិធិខុនរាដអាដេណៅអ៊ែរ (KAS) នឹងរៀបចំកម្មវិធីការងារលំអិតជាក់ស្តែង ( ឧបសម្ព័ន្ធ ខែ កក្កដា ) សំរាប់ចុះបំពេញការងារនៅតាមខេត្តទាំង ០២ សៀមរាប និង បាត់ដំបង ។

* គណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង នឹងត្រូវជំរុញអោយមានការបង្កើតឡើង និងដាក់អោយដំណើរការសកម្មភាពរបស់ខ្លួនអោយបានទាន់ពេលវេលា ។ សំរាប់ការបន្តកសាងសមត្ថភាពមន្ត្រីនៅថ្នាក់ស្រុក និង ខេត្ត គណៈកម្មការសម្របសម្រួលនេះ មានភារកិច្ចជ្រើសរើសមន្ត្រីគ្រូបង្គោលថ្នាក់ខេត្ត និង ស្រុក ដែលមានលទ្ធភាព និង សមត្ថភាពសំរាប់ ការហ្វឹកហ្វឺនបន្តនៅថ្នាក់ខេត្ត ស្រុក ក្នុងគោលដៅពង្រឹងសមត្ថភាពនៅនឹងកន្លែងដោយផ្ទាល់ ។

* ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានរដ្ឋបាល និង អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ក្នុងជំហានទី ១នេះ នឹង រៀបចំកំណត់មន្ត្រីដែលជាគ្រូបង្គោលថ្នាក់ជាតិ (Master Trainer ) ចំនួន ០៤ នាក់ ដែលក្នុងនោះមកពី ( អគ្គលេខាធិ-ការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ០២ នាក់ ) ( ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានរដ្ឋបាល ០២ នាក់ ) ។
គ្រូបង្គោលថ្នាក់ជាតិដែលពាក់ព័ន្ធដល់ប្រធានបទនីមួយ ៗ ត្រូវរៀបចំឯកសារសំរាប់ហ្វឹកហ្វឺន (Training Manual) ដល់មន្ត្រីគ្រូបង្គោលរបស់ខេត្ត ។

**ជំហានទី ២ :** ( ខែសីហា-កញ្ញា )

ហ្វឹកហ្វឺនមន្ត្រីគ្រូបង្គោលរបស់ខេត្ត សំរាប់ហ្វឹកហ្វឺនបន្តដល់មន្ត្រី រាជការសំខាន់ៗដែលនឹងបំពេញការងារ នៅតាមស្រុក និង ការិយាល័យនានានៅថ្នាក់ ស្រុក ។ ជំហានទី ២ នេះ ត្រូវមានការហ្វឹកហ្វឺនអំពីរបៀបរបបធ្វើការងារ និង ខ្លឹមសារនៃសេចក្តីសំរេច និង ប្រកាសនានា របស់ក្រសួង ស្ថាប័នថ្នាក់ជាតិ ។ ដើម្បីសំរេចគោលដៅនេះ មន្ត្រីគ្រូបង្គោលនៅថ្នាក់ជាតិ ដោយផ្អែកលើឯកសារសំរាប់ ហ្វឹកហ្វឺន (Training Manual) ត្រូវរៀបចំកម្មវិធីលំអិតជាក់ស្តែង សំរាប់ហ្វឹកហ្វឺនដល់មន្ត្រីគ្រូបង្គោលខេត្តទាំងនោះ ដោយក្នុងមួយខេត្ត មានមន្ត្រីថ្នាក់ខេត្ត ស្រុក ក្នុងបរិមាណ ០៨ នាក់ ( ០៤នាក់គ្រូបង្គោល ០៤នាក់អ្នកសម្របសម្រួល ) ។

មន្ត្រីគ្រូបង្គោលរបស់ខេត្តទាំងនោះ នឹងបន្តរៀបចំកម្មវិធីហ្វឹកហ្វឺនដល់មន្ត្រីរាជការនៅក្នុងស្រុកទីប្រជុំជន ដូចបានកំណត់ខាងលើទៅតាមពេលវេលាសមស្រប និង ដោយទទួលខុសត្រូវផ្ទាល់ ក្នុងការកសាងសមត្ថភាពបន្តដល់មន្ត្រី ប្រតិបត្តិការងារនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលថ្មីរបស់ស្រុកទីប្រជុំជនទាំង ០២ ។ ( ឧបសម្ព័ន្ធ ខែ សីហា កញ្ញា )

ក្នុងជំហានទី ២ នេះ ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានរដ្ឋបាល និង សហការជាមួយខេត្តសាមី ដើម្បីស្រង់បញ្ជី ចលនទ្រព្យ និង អចលនទ្រព្យសំរាប់ការត្រៀមប្រគល់ ផ្ទេរដល់រដ្ឋបាលស្រុកថ្មី ។

**ជំហានទី ៣ :** ( ខែ តុលា-វិច្ឆិកា-ធ្នូ )

ជាជំហានដែលត្រូវជ្រើសរើស និង តែងតាំងមន្ត្រីរាជការ ដែលមានលទ្ធភាព និង សមត្ថភាព សមស្របអាច បំពេញការងារនៅតាមការិយាល័យចំណុះមន្ទីរស្រុក និង ក្រោមមន្ទីរស្រុក ។ ការជ្រើសរើស**ក្រុមប្រឹក្សាស្រុក** និង **បោះឆ្នោតជ្រើសរើសតំណាងប្រជាពលរដ្ឋ**សំរាប់ស្រុកទាំង ០២ ។ ទន្ទឹមនោះ ត្រូវមានការរៀបចំទីកន្លែងធ្វើការងារ ការបំពាក់មូលដ្ឋានសំភារៈសមស្រប ដើម្បីការិយាល័យទាំងអស់របស់ស្រុកទាំង ០២ អាចដំណើរការបាន ។ ការផ្ទេរចលនទ្រព្យ និង អចលន-ទ្រព្យដល់រដ្ឋបាលថ្មីរបស់ស្រុក ។ នៅក្នុងជំហានទី ៣ នេះ ដោយឡែក ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានរដ្ឋបាល ដែលក្នុងនោះមាននាយកដ្ឋានមួយចំនួនទៀត ត្រូវបន្តកិច្ចសហប្រតិបត្តិការ គាំទ្រដល់គណៈកម្មការសម្របសម្រួលខេត្ត លើការងារដែលពាក់ព័ន្ធរបស់ក្រសួង ក្នុងនោះនាយកដ្ឋានរដ្ឋបាលមូលដ្ឋានគាំទ្រសម្របសម្រួលការងាររៀបចំបង្កើត ក្រុមប្រឹក្សាស្រុក និង ការងាររៀបចំការិយាល័យប្រជាពលរដ្ឋ ។ នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ គាំទ្រ សម្របសម្រួលការងាររៀបចំមន្ត្រីរាជការនៅក្នុងរដ្ឋបាលថ្មីរបស់ស្រុក ។ នាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គាំទ្រ សម្របសម្រួល ស្រង់បញ្ជី ចលនទ្រព្យ និង អចលនទ្រព្យ និង ការងាររៀបចំថវិការបស់ស្រុក សំរាប់កិច្ចដំណើរការរដ្ឋបាលថ្មី ។

## តារាងបែងចែកពេលវេលាអនុវត្ត

| ល.រ | សកម្មភាព | កក្កដា | | | | សីហា | | | | កញ្ញា | | | | តុលា | | | | វិច្ឆិកា | | | | ធ្នូ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| I | ការផ្សព្វផ្សាយលិខិតបទដ្ឋាន | | | | | | | | | | | | | | | | | | | | | | | | | |
| | .ស្រុកសៀមរាប | | | | ■ | | | | | | | | | | | | | | | | | | | | | MoI-CAR |
| | .ស្រុកបាត់ដំបង | | | | ■ | | | | | | | | | | | | | | | | | | | | | MoI-CAR |
| | .សម្រង់ចលន-អចលនទ្រព្យ ស្រុកសៀមរាបនិងស្រុកបាត់ដំបង | | | | | ■ | ■ | | | | | | | | | | | | | | | | | | | MoI |
| II | វគ្គតម្រង់ទិសមន្ត្រីរាជការ ក្រុមប្រឹក្សាឃុំ និង ការប្រមើលមើលតម្រូវការ | | | | | | | | | | | | | | | | | | | | | | | | | |
| | .ហ្វឹកហ្វឺនមន្ត្រីគ្រូបង្គោលខេត្ត( ទីកន្លែងនៅភ្នំពេញ) (KAFs office) | | | | | | ■ | | | | | | | | | | | | | | | | | | | MoI CAR LM's |
| | .ស្រុកសៀមរាប | | | | | | | | | | | | | | | | | | | | | | | | | |
| | ១-ហ្វឹកហ្វឺនបន្តនៅខេត្ត | | | | | | | | ■ | ■ | | | | | | | | | | | | | | | | SR |
| | ២-ការប្រមើលមើលតម្រូវការ | | | | | | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | CAR-MoI-KAS |
| | .ស្រុកបាត់ដំបង | | | | | | | | | | | | | | | | | | | | | | | | | |
| | ១-ហ្វឹកហ្វឺនបន្តនៅខេត្ត | | | | | | | | ■ | ■ | | | | | | | | | | | | | | | | BB |
| | ២-ការប្រមើលមើលតម្រូវការ | | | | | | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | CAR-MoI-KAS |

| | | |
|---|---|---|
| III | ការរៀបចំមន្ត្រីរាជការនិងបំពាក់មូលដ្ឋានសំភារៈ | |
| | . ហ្វឹកហ្វឺនមន្ត្រីគ្រូបង្គោលខេត្តទាំង០២ (ទីកន្លែងនៅភ្នំពេញ) (KAS's office) | MoI CAR LM's |
| | . ស្រុកសៀមរាប | |
| | ១-ការរៀបចំមន្ត្រីរាជការ | SR MoI (CAR .LM's ) |
| | ២-ហ្វឹកហ្វឺនបន្តនៅខេត្ត | SR |
| | ៣-បំពាក់មូលដ្ឋានសំភារៈ | SR (MoI-CAR-KAS) |
| | ៤-រៀបចំក្រុមប្រឹក្សាស្រុក | SR |
| | ៥-បោះឆ្នោតជ្រើសរើសតំណាងប្រជាពលរដ្ឋ | SR (MoI-CAR-KAS) |
| | . ស្រុកបាត់ដំបង | |
| | ១-ការរៀបចំមន្ត្រីរាជការ | BB MoI (CAR.LM's) |
| | ២-ហ្វឹកហ្វឺនបន្តនៅខេត្ត | BB |
| | ៣-បំពាក់មូលដ្ឋានសំភារៈ | SR (MoI-CAR-KAS) |
| | ៤-រៀបចំក្រុមប្រឹក្សាស្រុក | BB |
| | ៥-បោះឆ្នោតជ្រើសរើសតំណាងប្រជាពលរដ្ឋ | BB (MoI-CAR-KAS) |
| IV | ការកសាងសមត្ថភាព (បណ្តុះបណ្តាលនៅនឹងកន្លែង) | |
| | . ស្រុកសៀមរាប | SR (MoI-CAR-LM'S) |
| | . ស្រុកបាត់ដំបង | BB (MoI-CAR-LM'S) |
| V | ប្រជុំបូកសរុប វាយតម្លៃ (នៅតាមខេត្តទាំង ០២ ) | SR BB (MoI. CAR LM's) |

**លទ្ធផលរំពឹងទុក**

ដើម្បីអោយការប្រតិបត្តិគំរោងសំរេចបានជោគជ័យនៅដំណាក់កាលទី ១ ក្រសួងមហាផ្ទៃ ដែលជាស្ថាប័ន ថ្នាក់ជាតិ គណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បងនៅថ្នាក់ខេត្ត នឹងទទួលបានការចូលរួមសហប្រតិបត្តិការពីក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្រសួងស្ថាប័នផ្សេងៗទៀតដែលពាក់ព័ន្ធ និង មូលនិធិខុនរាដអាដេណោអ៊ែរ ។

នៅដំណាក់កាលទី២ ការបន្តអនុវត្តគំរោងតាមរយៈការគាំទ្រដោយគណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង នៅថ្នាក់ខេត្ត និង ពីគ្រប់ក្រសួងស្ថាប័ននៅថ្នាក់ជាតិ មានសារៈសំខាន់សំរាប់អោយគំរោងទទួលបានជោគជ័យ ក្នុងកិច្ចដំណើរការ តាមប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្មីចាប់ពីដើមឆ្នាំ ២០០៥ តទៅ។

**ជំហានទី ១.. ឧបសម្ព័ន្ធ ខែ កក្កដា**

## II- ការផ្សព្វផ្សាយលិខិតបទដ្ឋាន នៅតាមស្រុកគំរូ ០២

( ស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង )

**កាលបរិច្ឆេទ**

ខេត្ត សៀមរាប

-ថ្ងៃទី.........ខែ កក្កដា ឆ្នាំ ២០០៤

-រយៈពេល = ០១ ថ្ងៃ

-ទីកន្លែង = សាលាខេត្ត សៀមរាប ឬ ទីកន្លែងផ្សេងទៀតអាស្រ័យលើលទ្ធភាពជាក់ស្តែង

ខេត្ត បាត់ដំបង

-ថ្ងៃទី.........ខែ កក្កដា ឆ្នាំ ២០០៤

-រយៈពេល = ០១ ថ្ងៃ

-ទីកន្លែង = សាលាខេត្ត បាត់ដំបង ឬ ទីកន្លែងផ្សេងទៀតអាស្រ័យលើលទ្ធភាពជាក់ស្តែង

**សមាសភាពចូលរួម**

ក្រុមទី ១ .-

១- អភិបាលខេត្ត-អភិបាលរងខេត្ត

២- អភិបាល-អភិបាលរងស្រុកទីប្រជុំជនខេត្ត

៣- អភិបាលស្រុកផ្សេងៗទៀត

៤- ប្រធាន-អនុប្រធានអង្គភាពទាំង ០៥ ក្នុងសាលាខេត្ត

៥-ប្រធាន-អនុប្រធានមន្ទីរ ជុំវិញខេត្ត

៦-ប្រធានអង្គភាពដែលបោះទីតាំងនៅក្នុងខេត្ត

៧- តំណាងកម្មវិធីសីលា PLG ប្រចាំខេត្ត

៨-មន្ត្រីក្នុងសាលាស្រុកទីប្រជុំជនខេត្ត

៩-ប្រធានការិយាល័យជំនាញជុំវិញស្រុកទីប្រជុំជនខេត្ត

ក្រុមទី ២ -

១-មេឃុំ-ជំទប់ទី១-២ និង ស្មៀន ក្នុងស្រុកទីប្រជុំជនខេត្ត

២- តំណាងពាណិជ្ជករ នៅក្នុងខេត្ត (សភាពាណិជ្ជកម្មខេត្ត)

៣-តំណាងអង្គការមិនមែនរដ្ឋាភិបាល

ក្រុមនីមួយៗមានសមាជិកសរុបចំនួន ៦០ នាក់

**ខ្លឹមសារផ្សព្វផ្សាយ**

※ សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ៤០០៣ ស្តីពីរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

※ ប្រកាសរបស់ក្រសួងមហាផ្ទៃលេខ ៧៩១ ប្រក ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រង រដ្ឋបាល ស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

* ប្រកាសរបស់ក្រសួងមហាផ្ទៃលេខ ៧៩២ ប្រក ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្ត ទៅ នៃ ការិយាល័យច្រកចេញ-ចូលតែមួយ ។

* ប្រកាសរបស់ក្រសួងមហាផ្ទៃលេខ ៧៩០ ប្រក ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្ត ទៅ នៃ ការិយាល័យប្រជាពលរដ្ឋ ។

**តារាងសង្ខេបបែងចែកពេលវេលា ប្រជុំផ្សព្វផ្សាយ**

| ល.រ | ប្រធានបទ | ថ្ងៃទី១ | ផ្សេងៗ |
|---|---|---|---|
| ១ | -ផ្សព្វផ្សាយ សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៤៧ សសរ | ព្រឹក ក្រុមទី១ | MoI |
| ២ | -ផ្សព្វផ្សាយ ប្រកាស របស់ក្រសួងមហាផ្ទៃ ស្តីពីរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលស្រុក | ព្រឹក ក្រុមទី១ | MoI |
| ៣ | -ផ្សព្វផ្សាយ ប្រកាសរបស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ការិយាល័យច្រកចេញ-ចូលតែមួយ | រសៀលក្រុមទី១ | CAR |
| ៤ | -ផ្សព្វផ្សាយ ប្រកាសរបស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ការិយាល័យ ប្រជាពលរដ្ឋ | រសៀលក្រុមទី១ | CAR |

| ល.រ | ប្រធានបទ | ថ្ងៃទី២ | ផ្សេងៗ |
|---|---|---|---|
| ១ | -ផ្សព្វផ្សាយ សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៤៧ សសរ | ព្រឹក ក្រុមទី២ | MoI |
| ២ | -ផ្សព្វផ្សាយ ប្រកាស របស់ក្រសួងមហាផ្ទៃ ស្តីពីរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលស្រុក | ព្រឹក ក្រុមទី២ | MoI |
| ៣ | -ផ្សព្វផ្សាយ ប្រកាសរបស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ការិយាល័យច្រកចេញ-ចូលតែមួយ | ព្រឹក ក្រុមទី២ | CAR |
| ៤ | -ផ្សព្វផ្សាយ ប្រកាសរបស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ការិយាល័យ ប្រជាពលរដ្ឋ | ព្រឹក ក្រុមទី២ | CAR |

ជំហានទី ២.- ឧបសម្ព័ន្ធ ខែ សីហា-កញ្ញា

III-កម្មវិធីបណ្តុះបណ្តាលវគ្គគរុកោសល្យ មន្ត្រីគ្រូបង្គោលខេត្ត នៅភ្នំពេញ (KAS's office)

ចំនួនមន្ត្រីគ្រូបង្គោលខេត្តចូលរួម ខេត្តសៀមរាប ០៨ នាក់ ( ថ្នាក់ខេត្ត ០៤ ថ្នាក់ស្រុក ០៤ )

ខេត្តបាត់ដំបង ០៨ នាក់ ( ថ្នាក់ខេត្ត ០៤ ថ្នាក់ស្រុក ០៤ ) សរុប ១៦ នាក់

តារាងសង្ខេបបែងចែកពេលវេលា វគ្គគរុកោសល្យមន្ត្រីគ្រូបង្គោលខេត្ត

| ល.រ | ប្រធានបទ | ថ្ងៃទី១ | ថ្ងៃទី២ | ថ្ងៃទី៣ | ថ្ងៃទី៤ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | -សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៤៧ សសរ<br>-របៀបរបបធ្វើការងារ | MoI | | | | |
| ២ | -ប្រកាស របស់ក្រសួងមហាផ្ទៃ ស្តីពីរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលស្រុក | | MoI | | | |
| ៣ | -ប្រកាសរបស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ការិយាល័យច្រកចេញ-ចូលតែមួយ | | | CAR | | |
| ៤ | -ប្រកាសរបស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ការិយាល័យ ប្រជាពលរដ្ឋ<br>-បែបបទ នីតិវិធី នៃ ការបង្កើតក្រុមកន្សោមអាទិភាព | | | | CAR | |
| ៥ | -ប្រកាសផ្សេងៗទៀតរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ | | | | | LM's |

IV- ការបណ្តុះបណ្តាលគរុកោសល្យ មន្ត្រីរាជការ នៅតាមស្រុកទាំង ០២

វគ្គបណ្តុះបណ្តាលបន្ត អនុវត្តដោយមន្ត្រីគ្រូបង្គោលខេត្ត

សំរាប់ស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង

កាលបរិច្ឆេទ

សំរាប់ស្រុកសៀមរាប

-ពីថ្ងៃទី ..... ដល់ ថ្ងៃទី ..... ខែ ..... ឆ្នាំ ២០០៤ ក្រុមទី១ និង ក្រុមទី២

-ទីកន្លែង = សាលាស្រុកសៀមរាប

សំរាប់ស្រុកបាត់ដំបង

-ពីថ្ងៃទី ..... ដល់ ថ្ងៃទី ..... ខែ ..... ឆ្នាំ ២០០៤ ក្រុមទី១ និង ក្រុមទី២

-ទីកន្លែង = សាលាស្រុកបាត់ដំបង

**គ្រោងសមាសភាពចូលរួម**

១-តំណាងអភិបាលខេត្ត និងជាប្រធានគណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង ០១នាក់

២- សមាជិកទាំងអស់របស់ គណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង ១៥នាក់

៣-ប្រធានការិយាល័យរបស់ គណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង ០១នាក់

៤- អភិបាលស្រុក និង អភិបាលរងស្រុកទីប្រជុំជនខេត្ត ០៤នាក់

៥- ប្រធាន-អនុប្រធានមន្ទីរស្រុកទីប្រជុំជនខេត្ត ០២នាក់

៦- ប្រធាន-អនុប្រធានមន្ទីរជុំវិញខេត្ត ២៥នាក់

៧- ប្រធាន-អនុប្រធានការិយាល័យជំនាញជុំវិញស្រុក ១០នាក់

៨- ប្រធាន-អនុប្រធានការិយាល័យចំណុះមន្ទីរស្រុក ០៦នាក់

៩-មេឃុំ ជំទប់ទី១-២ -ស្មៀនឃុំ និង ស្មៀនបំរុងក្នុងស្រុកទីប្រជុំជនខេត្ត ៤២នាក់

១០-តំណាងពាណិជ្ជករក្នុងខេត្ត ( សភាពាណិជ្ជកម្ម ) ០៤នាក់

សរុបទាំងអស់ប្រមាណ <u>១១០ នាក់</u> នឹងចែកជា ០២ ក្រុម ក្នុងមួយក្រុមមាន ៥៥នាក់

**ខ្លឹមសារ**

១-សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣

២-របៀបរបបធ្វើការងារ

៣-លិខិតបទដ្ឋានរបស់ក្រសួងមហាផ្ទៃ ក្នុងនោះមានប្រកាស ស្តីពីរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។ ប្រកាស ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ការិយាល័យច្រកចេញ-ចូលតែមួយ ។ ប្រកាស ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ការិយាល័យប្រជាពលរដ្ឋ ។

៤-លិខិតបទដ្ឋានរបស់ក្រសួងផ្សេងៗដែលពាក់ព័ន្ធ អនុលោមតាមការហ្វឹកហ្វឺនពីថ្នាក់ជាតិ ។

<u>បញ្ជាក់</u> : សំរាប់ជំហានទី ៣ នឹងមានភ្ជាប់ឧបសម្ព័ន្ធផ្សេងទៀតនៅពេលក្រោយ

**មន្ទីរ អង្គភាព**

**ដែលត្រូវចូលរួមក្នុងកម្មវិធី ផ្សព្វផ្សាយលិខិតបទដ្ឋាន**

| ខេត្តសៀមរាប | ខេត្តបាត់ដំបង |
|---|---|
| .-ក្រុមទី ១ ៦០នាក់ | .-ក្រុមទី ១ ៦០នាក់ |
| ១- អភិបាលខេត្ត-អភិបាលរងខេត្ត ០៦នាក់ | ១- អភិបាលខេត្ត -អភិបាលរងខេត្ត ០៥នាក់ |
| ២- អភិបាល-អភិបាលរងស្រុកទីប្រជុំជនខេត្ត ០៤នាក់ | ២- អភិបាល-អភិបាលរងស្រុកទីប្រជុំជនខេត្ត ០៤នាក់ |
| ៣- អភិបាលស្រុកផ្សេងៗទៀតក្នុងខេត្ត ១១នាក់ | ៣- អភិបាលស្រុកផ្សេងៗទៀតក្នុងខេត្ត ១២នាក់ |
| ៤-ប្រធាន.អនុប្រធានអង្គភាពទាំង០៥ក្នុងសាលាខេត្ត១០នាក់ | ៤-ប្រធាន-អនុប្រធានអង្គភាពទាំង០៥ក្នុងសាលាខេត្ត១០នាក់ |
| ៥-ប្រធាន-អនុប្រធានមន្ទីរ ជុំវិញខេត្ត ១៦នាក់ | ៥-ប្រធាន-អនុប្រធានមន្ទីរ ជុំវិញខេត្ត ១៦នាក់ |
| ៦-ប្រធានអង្គភាពដែលបោះទីតាំងនៅក្នុងខេត្ត ០៤នាក់ | ៦-ប្រធានអង្គភាពដែលបោះទីតាំងនៅក្នុងខេត្ត ០៤នាក់ |
| ៧- តំណាងកម្មវិធីសីលា PLG ប្រចាំខេត្ត ០១នាក់ | ៧- តំណាងកម្មវិធីសីលា PLG ប្រចាំខេត្ត ០១នាក់ |
| ៨-មន្ត្រីក្នុងសាលាស្រុកទីប្រជុំជនខេត្ត ០៣នាក់ | ៨-មន្ត្រីក្នុងសាលាស្រុកទីប្រជុំជនខេត្ត ០៣នាក់ |
| ៩-ប្រធានការិយាល័យជំនាញជុំវិញស្រុកទីប្រជុំជន ០៥នាក់ | ៩-ប្រធានការិយាល័យជំនាញជុំវិញស្រុកទីប្រជុំជន ០៥នាក់ |
| -ក្រុមទី ២ ៦០នាក់ | -ក្រុមទី ២ ៦០នាក់ |
| ១-មេឃុំ.ជំទប់ទី១-និងស្មៀនក្នុងស្រុកទីប្រជុំជនខេត្ត ៤០នាក់ | ១-មេឃុំ-ជំទប់ទី១-និងស្មៀនក្នុងស្រុកទីប្រជុំជនខេត្ត៤០នាក់ |
| ២-ំណាងពាណិជ្ជករនៅក្នុងខេត្ត( សភាពាណិជ្ជកម្មខេត្ត) ១០នាក់ | ២-តំណាងពាណិជ្ជករនៅក្នុងខេត្ត( សភាពាណិជ្ជកម្មខេត្ត) ១០នាក់ |
| ៣-តំណាងអង្គការមិនមែនរដ្ឋាភិបាល ១០នាក់ | ៣-តំណាងអង្គការមិនមែនរដ្ឋាភិបាល ១០នាក់ |

សេចក្តីសំរេចលេខ ៤៧ ស.ស.រ រដ្ឋាភិបាលស្តីពីរចនាសម្ព័ន្ធ
និងប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាប នៃខេត្តសៀមរាប
និងស្រុកបាត់ដំបង នៃខេត្តបាត់ដំបង ៗ

ក្របខ័ណ្ឌគតិយុត្តសំរាប់ការអនុវត្តន៍
សាកល្បងនៅស្រុកសៀមរាប
និងស្រុកបាត់ដំបង ត្រូវបានរៀបចំរួចជាស្រេច

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា                    ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...៤១៧...សសរ..

# សេចក្ដីសំរេច

# ស្ដីពី

# ចេនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រង

# ស្រុកសៀមរាប នៃខេត្តសៀមរាប និង ស្រុកបាត់ដំបង នៃខេត្តបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

## សំ រេ ច

**ប្រការ ១.-**

សេចក្ដីសំរេចនេះ កំណត់រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាបនៃខេត្តសៀមរាប និង ស្រុកបាត់ដំបងនៃខេត្តបាត់ដំបង ដើម្បីសាកល្បងក្នុងការបង្កើតជាមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចអោយមានគុណភាព និង ចូលរួមកាត់បន្ថយភាពក្រីក្រ ។

**ប្រការ ២.-**

រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងបច្ចុប្បន្ន នៃស្រុកសៀមរាប និង ស្រុកបាត់ដំបង ត្រូវធ្វើការពិនិត្យវាយតំលៃសាកល្បងរៀបចំជាជំហានៗ ឱ្យបានសមស្របតាមសភាពការណ៍ជាក់ស្ដែង និង ស្របតាមស្មារតីនៃសេចក្ដីសំរេចនេះ ។

ប្រការ ៣.-

ក្នុងការអនុវត្តន៍សាកល្បង ស្រុកទាំងពីរត្រូវបំពេញតួនាទី និង មុខងារដូចខាងក្រោមនេះ ÷

តួនាទី :

- រដ្ឋបាលស្រុកទាំងពីរ មានតួនាទីជំរុញ និង គាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធានដែលស្រុកមាន ប្រកបដោយនិរន្តរភាព សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានរបស់ស្រុក សំដៅបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋផង និង គោរពផលប្រយោជន៍របស់ជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលផងដែរ ។

- ជាមណ្ឌលសាកល្បងរបស់ខេត្តក្នុងការបំរើសេចក្តីត្រូវការ និង ការផ្តល់សេវាកម្មសាធារណៈផ្សេងៗដល់ប្រជាពលរដ្ឋ ។

មុខងារ :

- ផ្តល់សេវាកម្មរដ្ឋបាលសាធារណៈ ដែលប្រជាពលរដ្ឋ សហគ្រាស ឬ ក្រុមហ៊ុន អាជីវករនានា ត្រូវការជាចាំបាច់ក្នុងជីវភាពប្រចាំថ្ងៃ និង ក្នុងធុរកិច្ច តាមរបៀបដែលមានប្រសិទ្ធភាព មានតម្លាភាព និង ចំណាយធនធានតិច ដើម្បីបង្កើតបានជាគំរូអភិបាលកិច្ចល្អ ។

- រៀបចំផែនការអភិវឌ្ឍន៍ស្រុក ដោយមានការចូលរួមរបស់ប្រជាពលរដ្ឋ ដែលមានលក្ខណៈសមស្របទៅនឹងផែនការអភិវឌ្ឍន៍ខេត្ត និង ផែនការសេដ្ឋកិច្ច សង្គមកិច្ចរបស់រដ្ឋ ដោយមានការសំរបសំរួលជាមួយផែនការអភិវឌ្ឍន៍ឃុំ ព្រមទាំងកំណត់ធនធានចាំបាច់សំរាប់អនុវត្តផែនការរបស់ខ្លួន។

- សំរបសំរួល និង គាំទ្រដល់ក្រុមប្រឹក្សាឃុំនានា នៃស្រុករបស់ខ្លួន តាមការណែនាំរបស់អភិបាលខេត្តសាមី ដើម្បីឱ្យក្រុមប្រឹក្សាឃុំអនុវត្តបានពេញលេញនូវអំណាច តួនាទី និង ភារកិច្ចដែលបានប្រគល់ឱ្យដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង លិខិតបទដ្ឋានជាធរមានផ្សេងៗ ទៀត ។

- បង្កើនប្រសិទ្ធភាព ក្នុងការអនុវត្តន៍គោលនយោបាយជាតិ និង កម្មវិធីរបស់ក្រសួងស្ថាប័ននានា នៃរាជរដ្ឋាភិបាល ក្រោមការសម្របសម្រួលពីអភិបាលខេត្តសាមី ដោយមានកិច្ចសហប្រតិបត្តិការ ជាមួយប្រជាពលរដ្ឋ ។

ប្រការ ៤.-

ក្នុងការអនុវត្តន៍គំរោងសាកល្បងនេះ ស្រុកទាំងពីរត្រូវបានទទួលប្រតិភូកម្មអំណាច ក្នុងនោះមានការដឹកនាំ និង/ឬ សំរបសំរួល និង/ឬ ជំរុញ និង/ឬ ត្រួតពិនិត្យក្នុងការរៀបចំប្លង់គោល ផែនការប្រើប្រាស់ ដីធ្លី

ការសាងសង់ សំណង់នានាតាមការកំណត់ ការកសាង ជួសជុល ថែទាំផ្លូវថ្នល់ ការធ្វើចរាចរ ការចុះបញ្ជី យានយន្ត អាជ្ញាប័ណ្ណ និង លិខិតអនុញ្ញាតដល់ក្រុមហ៊ុនពាណិជ្ជកម្ម សេវាកម្ម សិប្បកម្មខ្នាតតូច និង មធ្យម ការសិក្សាអប់រំ សង្គមកិច្ច វប្បធម៌ សុខាភិបាល និង ការធ្វើនីត្យានុកូលកម្ម ឬ បញ្ជាក់លើឯកសារ ព្រមទាំងឯកសារថតចម្លង ផ្លូវការនានា ។

ប្រការ ៥.-

ការអនុវត្តន៍តួនាទី មុខងារ និង អំណាច ដូចមានចែងក្នុងមាត្រា ៣ និង មាត្រា ៤ នៃ សេចក្ដីសំរេចនេះ ត្រូវផ្អែកតាមការណែនាំរបស់ក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ និង ធ្វើឡើងជាជំហាន១ ស្របតាមសមត្ថភាព និង ធនធានដែលមាន ។

ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ត្រូវធ្វើការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ដើម្បីសំរបសំរួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធអំពីការធ្វើប្រតិភូកម្មអំណាច និង ការអនុវត្តនូវ តួនាទី មុខងារ អំណាចរបស់ស្រុកទាំងពីរឱ្យបានសមស្រប ។

ប្រការ ៦.-

ក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវធ្វើប្រតិភូកម្មអំណាច និង ភារកិច្ចដល់ស្រុកទាំងពីរអោយបានសមស្រប ក្រោមការសំរបសំរួលពីក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង អភិបាលខេត្តសាមី ។

ប្រការ ៧.-

ការធ្វើប្រតិភូកម្មអំណាច ដែលធ្វើឡើងដោយក្រសួងស្ថាប័ននីមួយ១ ត្រូវភ្ជាប់ជាមួយនូវការបណ្ដុះបណ្ដាលការកសាងសមត្ថភាព និង ការផ្គត់ផ្គង់មធ្យោបាយ សំភារៈ ថវិកាសមស្របសំរាប់ស្រុកទាំងពីរ ។

ប្រការ ៨.-

ស្រុកនីមួយ១ត្រូវដឹកនាំដោយអភិបាលស្រុក ០១ រូប អមដោយអភិបាលរងស្រុកមួយចំនួន ជាជំនួយការ។

ការកំណត់ចំនួនអភិបាលរងស្រុក និង ការបែងចែកភារកិច្ច របៀបរបបធ្វើការងាររបស់អភិបាល អភិបាលរងស្រុកត្រូវកំណត់ដោយ ប្រកាសរបស់ក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

ប្រការ ៩.-

សាលាស្រុក ជាទីចាត់ការរដ្ឋបាលរបស់ស្រុក និង ត្រូវគ្រប់គ្រងដោយផ្ទាល់ពីអភិបាលស្រុក មានជំនួយពីប្រធានមន្ទីរស្រុក ។

ប្រធានមន្ទីរស្រុក មានអនុប្រធានមន្ទីរ ០១ រូប ជាជំនួយការ ។

សាលាស្រុក មានការិយាល័យ មួយចំនួន ជាជំនួយការ ។

ការរៀបចំ និង ការប្រព្រឹត្តិទៅនៃសាលាស្រុក ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

ប្រការ ១០.-

ស្រុកនីមួយៗត្រូវបង្កើតឱ្យមានក្រុមប្រឹក្សាស្រុក ។

ក្រុមប្រឹក្សាស្រុក មានអភិបាលស្រុកជាប្រធាន និងមានអភិបាលរងស្រុក ប្រធានមន្ទីរស្រុក ប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ទី ១ ជំទប់ទី ២ គ្រប់ឃុំចំណុះស្រុក ជាសមាជិក ។

ក្រុមប្រឹក្សាស្រុក ជាអង្គការដែលអភិបាលស្រុក ត្រូវពិគ្រោះយោបល់លើបញ្ហាដែលទាក់ទងនឹង ÷

- ផែនការអភិវឌ្ឍន៍ស្រុក
- គំរោងមេ ផែនការប្រើប្រាស់ដីធ្លី
- គំរោងចំណាយថវិកា
- ការងារផ្សេងទៀត ដែលអភិបាលស្រុកយល់ឃើញថាចាំបាច់ ។

ការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាស្រុក និង ទំនាក់ទំនងរវាងអភិបាលស្រុក និងក្រុមប្រឹក្សាស្រុក ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

ប្រការ ១១.-

ត្រូវបង្កើតអោយមាន ការិយាល័យ " ច្រកចេញចូលតែមួយ " ចំណុះសាលាស្រុកនីមួយៗ ។ ការិយាល័យ "ច្រកចេញចូលតែមួយ" មានសមត្ថកិច្ចផ្តល់ជូនប្រជាពលរដ្ឋ និងសហគ្រាស នូវសេវាកម្មរដ្ឋបាល ដែលប្រជាពលរដ្ឋត្រូវការជាប្រចាំ អោយបានទាន់ពេលវេលា មានតម្លាភាព និង តាមនីតិវិធីសាមញ្ញ ។

ការិយាល័យនេះត្រូវរៀបចំប្រមូលផ្តុំសេវាកម្ម និង នីតិវិធីរដ្ឋបាលមួយចំនួននៅកន្លែងតែមួយ ។

( ការិយាល័យនេះ ជាកន្លែងអតិថិជនត្រូវបានទទួលទម្រង់បែបបទ និង ទទួលពត៌មានគ្រប់គ្រាន់ច្បាស់លាស់ ស្តីពីការផ្តល់សេវាកម្មសាធារណៈផ្សេងៗ នឹងត្រូវបង់កម្រៃសេវាកម្ម ឬ អាករផ្សេងៗ និង ជាកន្លែងផ្តល់នូវលទ្ធផលសំរេចជាផ្លូវការលើសេចក្តីស្នើសុំដល់អតិថិជនវិញ ។ )

ការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យ " ច្រកចេញចូលតែមួយ " ត្រូវកំណត់ដោយប្រកាស

របស់ក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និង មានកិច្ចសហការពីក្រសួងស្ថាប័នដែលពាក់ព័ន្ធ ។

ប្រការ ១២.-

ដើម្បីលើកកំពស់អភិបាលកិច្ចល្អ នៅស្រុកនីមួយៗត្រូវបង្កើតអោយមានការិយាល័យ " ប្រជាពលរដ្ឋ " ដែលមានសមត្ថកិច្ចទទួលពាក្យបណ្តឹង និង ផ្តល់ពត៌មានជូនប្រជាពលរដ្ឋ ក្រុមហ៊ុន សហគ្រាស និង អង្គការសង្គមស៊ីវិល ក្នុងករណីមានភាពមិនប្រក្រតី ឬកំហុសឆ្គងរបស់បុគ្គលិកដែលបំរើការងារក្នុងរដ្ឋបាលស្រុក ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃការិយាល័យ " ប្រជាពលរដ្ឋ " ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

ប្រការ ១៣.-

ក្រសួងស្ថាប័នពាក់ព័ន្ធនានា ត្រូវចាត់មន្ត្រីមានសមត្ថភាពឱ្យទៅបំរើការងារនៅក្នុងការិយាល័យនានារបស់ស្រុក ដើម្បីជួយអភិបាលស្រុក ក្នុងការអនុវត្តន៍កិច្ចការតាមជំនាញរបស់ខ្លួន។

ប្រការ ១៤.-

បុគ្គលិក នៃការិយាល័យនានារបស់ស្រុក ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និង ដឹកនាំរបស់អភិបាលស្រុក ។

មន្ត្រីរាជការរបស់ក្រសួងស្ថាប័ន ដែលបំរើការងារនៅស្រុកទាំងពីរនេះ ត្រូវស្ថិតនៅជាមន្ត្រីរាជការរបស់ក្រសួងស្ថាប័នដើមដដែល ប៉ុន្តែការដាក់ពិន្ទុ តំឡើងថ្នាក់ និង ការតែងតាំងក្នុងមុខតំណែង ត្រូវតែមានការយល់ព្រមពីអភិបាលស្រុក ។

រាល់សេចក្តីណែនាំលើការងារជំនាញពីក្រសួងស្ថាប័នសាមី ត្រូវធ្វើតាមរយៈមន្ទីររបស់ខ្លួននៅថ្នាក់ខេត្ត និង ត្រូវឆ្លងកាត់អភិបាលស្រុក ដែលទទួលខុសត្រូវរៀបចំការអនុវត្តន៍ និង រាយការណ៍ជូនសាលាខេត្ត និង មន្ទីរជំនាញរបស់ក្រសួងស្ថាប័ននោះ ។

ប្រការ ១៥.-

ក្នុងរយៈពេលដំបូងនៃការអនុវត្តន៍សាកល្បង អភិបាលស្រុកត្រូវរៀបចំគំរោងចំណាយថវិកាតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ១៦.-

ក្រសួងមហាផ្ទៃ គឺជាស្ថាប័ននៅថ្នាក់ជាតិ ក្នុងការសំរបសំរួលអនុវត្តគំរោងសាកល្បងនេះ ។

ក្នុងការអនុវត្តន៍គំរោងសាកល្បងនេះ ក្រសួងមហាផ្ទៃត្រូវធ្វើការពិគ្រោះ ពិភាក្សាជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និងក្រសួងស្ថាប័នពាក់ព័ន្ធនានា ។

ក្នុងការអនុវត្តន៍គំរោងសាកល្បងនេះ ក្រសួងមហាផ្ទៃអាចទទួលជំនួយគាំទ្រ ខាងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីអ្នកផ្តល់ជំនួយក្នុង និង ក្រៅប្រទេស ។

ប្រការ ១៧._

ថ្នាក់ខេត្តត្រូវបង្កើតអោយមាន គណៈកម្មការសំរបសំរួលមួយ ដែលមានសមាសភាព ÷

- អភិបាលខេត្ត ឬ អភិបាលខេត្តរង ១ រូប ដែលតែងតាំងដោយអភិបាលខេត្ត ជាប្រធាន
- តំណាង ១ រូប មកពីក្រសួងមហាផ្ទៃ ជាសមាជិក
- តំណាង ១ រូប មកពីគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ជាសមាជិក
- តំណាង ១ រូប មកពីក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ជាសមាជិក
- តំណាង ១ រូប មកពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសមាជិក
- តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគំរោងនេះ ជាសមាជិក
- តំណាងមកពីមន្ទីរជំនាញដែលពាក់ពន្ធ័នឹងគំរោងនេះ ជាសមាជិក

គណៈកម្មការសំរបសំរួល ត្រូវមានការិយាល័យរបស់ខ្លួនក្នុងសាលាខេត្តបាត់ដំបង និង សាលាខេត្តសៀមរាប ព្រមទាំងមានបុគ្គលិកចាំបាច់សំរាប់ការិយាល័យនេះ ។ ក្នុងការអនុវត្តការងារ សមាជិកគណៈកម្មការត្រូវបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានគណៈកម្មការ ។ ប្រធានគណៈកម្មការត្រូវធ្វើការពិភាក្សាជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដើម្បីកំណត់នូវតំណាងក្រសួង ស្ថាប័ន និង មន្ទីរជំនាញពាក់ព័ន្ធ ដែលត្រូវចូលរួមក្នុងគណៈកម្មការនេះ ។ មុនចាប់ផ្តើមបំពេញការងារ គណៈកម្មការត្រូវរៀបចំរបៀបរបបធ្វើការងារ របបប្រជុំ និង របបរាយការណ៍ ឱ្យបានសមស្រប ។

ប្រការ ១៨._

គណៈកម្មការសំរបសំរួលថ្នាក់ខេត្ត មានភារកិច្ចគាំទ្រ និង ត្រួតពិនិត្យការអនុវត្តន៍គំរោងសាកល្បងនេះ ដោយអនុលោមតាមស្មារតីនៃសេចក្តីសំរេចនេះ ច្បាប់ និង លិខិតបទដ្ឋាននានាជាធរមាន ។

ប្រការ ១៩._

ក្រសួងមហាផ្ទៃមានភារកិច្ចធ្វើសេចក្តីរាយការណ៍រៀងរាល់ ៣ ខែម្តង ជូនគណៈរដ្ឋមន្ត្រី គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល អំពីដំណើរការ អនុវត្តគំរោងនេះ និង

សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ធ្វើសេចក្តីរាយការណ៍ជូនគណៈរដ្ឋមន្ត្រី អំពី អនុសាសន៍ បទពិសោធន៍ នៃការអនុវត្តន៍គំរោងនេះ ដើម្បីពង្រីកការរៀបចំគ្រប់គ្រងស្រុក នៅទីប្រជុំជនខេត្ត ដទៃទៀត ។

ប្រការ ២០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ អភិបាលខេត្តបាត់ដំបង និងអភិបាលខេត្តសៀមរាប ត្រូវទទួលបន្ទុក អនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែ មិថុនា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- ក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- សាលាខេត្តសៀមរាប
- សាលាខេត្តបាត់ដំបង
- ឯកសារ-កាលប្បវត្តិ

# ប្រកាសទាំងបីរបស់ក្រសួងមហាផ្ទៃ

- ស្ដីពី រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់រដ្ឋបាល ស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

- ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យប្រជាពលរដ្ឋ ស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

- ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យច្រកចេញ-ចូលតែមួ ស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ៧៩២ ប្រក

725
05-07-04 8:00

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យប្រជាពលរដ្ឋ
## នៅស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង

## សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២.នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស.រកម.០១៩៦.០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសម្រេចលេខ ៤៧សស.រ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០០៣ ស្តីពី វេទនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រង ស្រុកសៀមរាប នៃខេត្តសៀមរាប និង ស្រុកបាត់ដំបង នៃខេត្តបាត់ដំបង
- យោងតាមស្មារតីនៃកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ថ្ងៃទី១០ខែ មិថុនា ឆ្នាំ ២០០៤
- យោងលិខិតលេខ ១៦០/០៤ សជណ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤ របស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

BB-SR Asia Urbs

# សំរេច

ប្រការ១.-

សំរេចបង្កើតការិយាល័យមួយឈ្មោះថា " ការិយាល័យប្រជាពលរដ្ឋ " ប្រចាំ ស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ប្រការ២.-

ការិយាល័យប្រជាពលរដ្ឋមានតួនាទី និងមុខងារ ដូចខាងក្រោម ÷

-<u>តួនាទី</u>

ជាអង្គភាពធ្វើសកម្មភាពដោយអព្យាក្រឹតក្នុងការទទួលពាក្យបណ្តឹងតវ៉ាពីប្រជាពលរដ្ឋ អំពីរដ្ឋបាលស្រុក និង សំរុះសំរួលដោះស្រាយពាក្យបណ្តឹងតវ៉ាទាំងនោះ ។

-<u>មុខងារ</u>

ធានាអោយបានថា បញ្ហានានារបស់ប្រជាពលរដ្ឋត្រូវបានដោះស្រាយដោយបុគ្គលិករបស់រដ្ឋបាលស្រុក ស្របតាមលក្ខណៈច្បាប់លិខិតបទដ្ឋាននានាដោយគ្មានបែបបទរដ្ឋបាលច្រើន និង គ្មានការពន្យារពេលក្រៅពីការកំណត់ ។

ការពារប្រជាពលរដ្ឋ និងសហគ្រាសដែលមានក្នុងស្រុក នៅក្នុងការធ្វើទំនាក់ទំនងជាមួយរដ្ឋបាលស្រុក និងកិច្ចការអាជីវកម្មដែលមានការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់រដ្ឋបាលស្រុក ប្រឆាំងនឹងការធ្វើសេចក្តីសំរេចទាំងឡាយណាដែលខុសឆ្គងដែលបំពាន ទៅលើច្បាប់ និង លិខិតបទដ្ឋានជាធរមាន ។

ប្រឆាំងនឹងអំពើពុករលួយមន្ត្រីរាជការរបស់ស្រុក ជួយរួមវិភាគទានដល់ការកសាងទំនាក់-ទំនងល្អ និងគួរជាទីទុកចិត្តរវាងរដ្ឋបាលស្រុកជាមួយប្រជាពលរដ្ឋ និងសហគ្រាសនានាដែលស្ថិតនៅក្នុងស្រុករបស់ខ្លួន ។

ប្រការ៣.-

ប្រធានការិយាល័យប្រជាពលរដ្ឋ គឺជាតំណាងអព្យាក្រឹតរបស់ប្រជាពលរដ្ឋ ។

តំណាងប្រជាពលរដ្ឋនេះ មានភារកិច្ចទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ និង សហគ្រាសស្ថិតនៅក្នុងស្រុករបស់ខ្លួន ដែលតវ៉ានឹងការសំរេចឬសកម្មភាពរបស់មន្ត្រីនៅរដ្ឋបាលស្រុក ហើយត្រូវសហការជាមួយមន្ត្រីបុគ្គលិកនានាធ្វើការស្រាវជ្រាវ តាមដានពាក្យបណ្តឹងទាំងនោះ ។

ពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ និងរបស់សហគ្រាសនានាដែលការិយាល័យប្រជាពលរដ្ឋដោះស្រាយ គឺ ជាពាក្យបណ្តឹង ដែលមានការទាក់ទងដល់ ការសំរេចចិត្ត អាកប្បកិរិយា និងការបំពេញការងាររបស់មន្ត្រីរាជការនៅក្នុងរដ្ឋបាលស្រុក ដែលធ្វើឡើងមិនត្រឹមត្រូវទៅតាមតួនាទីភារកិច្ច និងករណីយកិច្ចរបស់ខ្លួនជាមន្ត្រីរាជការ ។

ពាក្យបណ្តឹងខាងលើនេះ អាចលើកឡើងអំពីករណីណាមួយដូចខាងក្រោម ÷

-ការសំរេចចិត្ត ឬអាកប្បកិរិយា ដែលផ្ទុយនឹងគោលការណ៍ច្បាប់ ។

-ការបដិសេធឬការស្ទាក់ស្ទើរ ក្នុងការទទួលយកពាក្យស្នើសុំត្រឹមត្រូវតាមច្បាប់របស់ប្រជា-ពលរដ្ឋ សហគ្រាស ឬ មិនបានផ្តល់លទ្ធផល ឬ ដំណោះស្រាយសមស្របតាមពេលវេលាមួយដែលបានកំណត់

-ករណីពុករលួយ ឬ ជិវិតទារប្រាក់

-មានឥរិយាបថមិនអាចទទួលយកបានដូចជាការបំភិតបំភ័យ ឬ ការនិយាយប្រមាថមាក់ងាយដល់ប្រជាពលរដ្ឋ ឬ តំណាងសហគ្រាសនានា ។

ក្នុងករណីដែលតំណាងប្រជាពលរដ្ឋបានរកឃើញថា ពាក្យបណ្តឹងប្រជាពលរដ្ឋ ឬតំណាងសហគ្រាសពិតជាត្រឹមត្រូវតំណាងនោះ ត្រូវខិតខំស្វែងរកដំណោះស្រាយមួយ ដែលអាចទទួលយកបានដោយប្រជាពលរដ្ឋ ឬសហគ្រាសដែលដាក់ពាក្យបណ្តឹង នោះ ។

ក្នុងការដោះស្រាយ តំណាងប្រជាពលរដ្ឋ ត្រូវស្វែងរកកិច្ចសហការសំរបសំរួលជាមួយសាមីបុគ្គលិករបស់រដ្ឋបាលស្រុក ឬជាមួយប្រធានបុគ្គលិកដែលមានបញ្ហានោះ ។

ក្នុងករណីដែលតំណាងប្រជាពលរដ្ឋបានប្រើប្រាស់គ្រប់វិធីក្នុងការសំរបសំរួលរួចហើយ ប៉ុន្តែមិនអាចដោះស្រាយបាន អាស្រ័យដោយការប្រកែកដោះសារ ឬ ការប្រកែកមិនព្រមទទួលយកការសំរបសំរួលពីសាមីបុគ្គលិកនោះ ឬ របស់ប្រធានបុគ្គលិកនោះ តំណាងប្រជាពលរដ្ឋត្រូវរៀបចំសំណុំរឿងដោយភ្ជាប់ជាមួយនូវអនុសាសន៍របស់ខ្លួន និងការសំរេចចិត្តរបស់ខ្លួនបញ្ជូនមកអភិបាលស្រុក ដើម្បីបន្តដោះស្រាយ ។

អភិបាលស្រុកត្រូវសហការជាមួយតំណាងប្រជាពលរដ្ឋ ចាត់គ្រប់វិធានការដើម្បីដោះស្រាយពាក្យបណ្តឹងខាងលើនេះ ។

ទោះស្ថិតក្នុងករណីណាក៏ដោយ តំណាងប្រជាពលរដ្ឋត្រូវជូនពត៌មានដល់ប្រជាពលរដ្ឋ ឬតំណាងសហគ្រាសដែលដាក់ពាក្យបណ្តឹងវិញ អំពីលទ្ធផលនៃការស្រាវជ្រាវរបស់ខ្លួន និងលទ្ធផលនៃដំណោះស្រាយ ។

ប្រការ៤.-

តំណាងប្រជាពលរដ្ឋ ត្រូវជ្រើសចេញពីអ្នកដែលទទួលបានគោរពរាប់អានពីសហគមន៍របស់ខ្លួនមានកេរ្តិ៍ឈ្មោះល្អ ស្អាតស្អំ មិនស្ថិតក្នុងវចនាសម្ព័ន្ធចាត់តាំងរបស់គណបក្សនយោបាយណាមួយ ហើយមានការសិក្សាមានបទពិសោធន៍ក្នុងជីវភាព និង ការងារដែលអាចស្វែងយល់និងវិនិច្ឆ័យនូវនីតិវិធី និងមធ្យោបាយ ដើម្បីប្រតិបត្តិការការងារនៅក្នុងរដ្ឋបាលស្រុកនោះបាន ។

ប្រការ៥.-

តំណាងប្រជាពលរដ្ឋត្រូវជ្រើសចេញពីក្នុងចំណោមបេក្ខជន ដោយគណៈកម្មាធិការបោះឆ្នោតមួយ ដែលមានសមាជិកដប់ប្រាំមួយ(១៦)រូប ។

សមាជិកទាំង១៦រូប នៃគណៈកម្មាធិការបោះឆ្នោតនេះត្រូវបានកំណត់ដូចខាងក្រោម ÷

-សមាជិក១០រូប ជាតំណាងគណបក្សនយោបាយខ្លួនក្នុងក្រុមប្រឹក្សាស្រុក ។

-សមាជិក៣រូប ជាតំណាងសហគមន៍ពាណិជ្ជករក្នុងស្រុក ។

-សមាជិក៣រូប ជាតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានចុះបញ្ជីត្រឹមត្រូវ ហើយដែលបានធ្វើសកម្មភាពក្នុងមូលដ្ឋានស្រុកនោះ ។

សមាជិក១០រូបដែលជាតំណាងគណបក្សនយោបាយ ត្រូវជ្រើសរើសឡើងដោយក្រុមប្រឹក្សាស្រុក តាមរយៈការបោះឆ្នោតជាសំងាត់ដោយសម្លេងភាគច្រើន នៃក្រុមប្រឹក្សាស្រុកពីក្នុងចំណោមបេក្ខជន៣០រូប ជាសមាជិកក្រុមប្រឹក្សាឃុំក្នុងស្រុកគិតតាមភាគរយ នៃគណបក្សនយោបាយដែលមានអាសនៈក្នុងក្រុមប្រឹក្សាឃុំ ។

សមាជិកដែលជាតំណាងសហគមន៍ពាណិជ្ជករ និង អង្គការមិនមែនរដ្ឋាភិបាលត្រូវជ្រើសរើសឡើងដោយក្រុមប្រឹក្សាស្រុកតាមរយៈការបោះឆ្នោតជាសំងាត់ដោយសម្លេងភាគ ច្រើននៃក្រុម-ប្រឹក្សាស្រុក នៅក្នុងអង្គប្រជុំដាច់ដោយឡែកពីគ្នាដែលដឹកនាំដោយប្រធានក្រុមប្រឹក្សាស្រុក ។

លក្ខណៈសម្បត្តិបេក្ខជន និងរបៀបដាក់ស្នើបេក្ខជនជាតំណាងពាណិជ្ជករក្នុងស្រុក និងតំណាងអង្គការមិនមែនរដ្ឋាភិបាល ត្រូវកំណត់ដោយតាមសំលេងភាគច្រើន នៃការសំរេចរបស់ក្រុមប្រឹក្សាស្រុក តាមសំណើរបស់អភិបាលស្រុក ។

គ្រប់តំណាងសហគ្រាស និង តំណាងអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីនិងកំពុងធ្វើសកម្មភាពក្នុងស្រុកនោះ ត្រូវបានអញ្ជើញអោយចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការ ។

ប្រការ៦.-

គណៈកម្មាធិការបោះឆ្នោតជ្រើសរើសតំណាងប្រជាពលរដ្ឋ គឺ ជាគណៈកម្មាធិការបើកចំហ

មួយរបស់ក្រុមប្រឹក្សាស្រុក ។

គណៈកម្មាធិការនេះមានប្រធានមួយរូប និងអនុប្រធានមួយរូប ដែលបោះឆ្នោតជ្រើសរើសឡើងតាមសំលេងឆ្នោតភាគច្រើននៃគណៈកម្មាធិការ ។

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្រុក គឺជាលេខាធិការដ្ឋាននៃគណៈកម្មាធិការបោះឆ្នោតនេះ។

**ប្រការ៧.-**

គណៈកម្មាធិការបោះឆ្នោតជ្រើសរើសតំណាងប្រជាពលរដ្ឋ ក្រោយពីបានជ្រើសតាំងតំណាងប្រជាពលរដ្ឋរួចហើយ ត្រូវធ្វើការកោះប្រជុំយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ។

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្រុក ជាអ្នករៀបចំលិខិតអញ្ជើញរៀបចំឯកសារ និង រៀបចំកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈកម្មាធិការ តាមការណែនាំរបស់ប្រធានក្រុមប្រឹក្សាស្រុក ។

**ប្រការ៨.-**

សមាជិកគ្រប់រូបនៃគណៈកម្មាធិការបោះឆ្នោតជ្រើសរើសតំណាងប្រជាពលរដ្ឋ មានសិទ្ធិធ្វើសនាមបេក្ខជនយ៉ាងច្រើន០២រូប សំរាប់ជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតំណាងប្រជា-ពលរដ្ឋ ។

គណៈកម្មាធិការត្រូវធ្វើការបោះឆ្នោតជាសំងាត់ ដើម្បីជ្រើសបេក្ខជនយ៉ាងតិច០២រូប ពីក្នុងចំណោមបេក្ខជនឈរឈ្មោះ ដោយសំលេងឆ្នោតភាគច្រើន នៃចំនួនសមាជិកគណៈកម្មាធិការ ។

កំណត់ហេតុនៃការប្រជុំបោះឆ្នោត និង ឈ្មោះបេក្ខជនដែលជាប់ឆ្នោតទាំង០២រូប ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាស្រុក រួចហើយត្រូវដាក់ស្នើទៅអភិបាលខេត្ត ។

អភិបាលខេត្តត្រូវជ្រើសយកបេក្ខជនម្នាក់ក្នុងចំណោមបេក្ខជនទាំង០២រូប ដែលបានដាក់ស្នើនោះ ដើម្បីតែងតាំងជាតំណាងប្រជាពលរដ្ឋ ។

តំណាងប្រជាពលរដ្ឋមានអាណត្តិបំពេញការងារបីឆ្នាំ ។

នៅពេលផុតអាណត្តិ តំណាងប្រជាពលរដ្ឋមានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជាថ្មី និង អាចទទួលបានការតែងតាំងសំរាប់អាណត្តិថ្មីជាបន្តទៀតបាន ។

**ប្រការ៩.-**

តំណាងប្រជាពលរដ្ឋត្រូវដកហូតពីមុខតំណែងក្នុងករណីណាមួយដូចខាងក្រោម ៖

-ត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬមជ្ឈឹមណាមួយ ។

-ត្រូវសមាជិកគណៈកម្មាធិការបោះឆ្នោតយ៉ាងតិច០៣រូបបានសំដែងការមិនទុកចិត្ត ហើយបានដាក់សំណើជាលាយលក្ខណ៍អក្សរ ទៅកាន់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្រុក ។

ក្នុងករណីនេះ ប្រធានគណៈកម្មាធិការបោះឆ្នោតត្រូវធ្វើការប្រជុំគណៈកម្មាធិការ ។

លិខិតអញ្ជើញប្រជុំត្រូវចុះហត្ថលេខាដោយប្រធាន ឬអនុប្រធានក្នុងករណីប្រធានមានធុរៈ ហើយត្រូវប្រគល់ជូនសមាជិកនៃគណៈកម្មាធិការ យ៉ាងយូរបំផុតមួយសប្តាហ៍ មុនថ្ងៃប្រជុំ ។ ក្នុងកិច្ចប្រជុំ ប្រសិនបើសមាជិកគណៈកម្មាធិការលើសពីពាក់កណ្តាលគាំទ្រចំពោះការមិនពេញចិត្តនោះ តំណាងប្រជាពលរដ្ឋ ត្រូវដកហូតចេញពីការងារ ។

ក្នុងករណីតំណាងប្រជាពលរដ្ឋត្រូវដកហូតពីមុខតំណែង ការជ្រើសរើសតំណាងប្រជាពលរដ្ឋជាថ្មីត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរពីរខែសំរាប់អាណត្តិមួយថ្មីរយៈពេល៣ឆ្នាំបន្តទៀត ដោយអនុវត្តទៅតាមបែបបទនីតិវិធី ដូចមានក្នុងប្រការ៨ នៃប្រកាសនេះ ។

**ប្រការ១០.-**

ក្នុងការអនុវត្តការងារ តំណាងប្រជាពលរដ្ឋមិនត្រូវទទួលការណែនាំណាមួយពីអភិបាលស្រុក និង មិនតម្រូវអោយធ្វើសេចក្តីរាយការណ៍ ឬជូនពត៌មានណាមួយទៅអភិបាលស្រុកឡើយ លើកលែងតែក្នុងករណីដូចមានចែងនៅក្នុងប្រការ ៣ និង ប្រការ ១៥ នៃ ប្រកាសនេះ ។

តំណាងប្រជាពលរដ្ឋ ត្រូវធ្វើសេចក្តីរាយការណ៍ពីរដងក្នុងមួយឆ្នាំអំពីលទ្ធផលការងាររបស់ខ្លួនជូនទៅគណៈកម្មាធិការបោះឆ្នោតជ្រើសរើសតំណាងប្រជាពលរដ្ឋ ។

**ប្រការ១១.-**

តំណាងប្រជាពលរដ្ឋអាចទទួលបានប្រាក់ឧបត្ថម្ភ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ១២.-**

តំណាងប្រជាពលរដ្ឋត្រូវបំពេញការងារ៤០ម៉ោងក្នុងមួយសប្តាហ៍ ។

ក្នុងរយៈពេល៤០ម៉ោងនេះ ត្រូវបែងចែកដូចខាងក្រោម ÷

-១២ម៉ោងត្រូវបំពេញការងារនៅតុពិសេសនៃការិយាល័យច្រកចេញចូលតែមួយដោយបែងចែកជាពីរព្រឹក និង មួយរសៀល ។

-២៨ម៉ោងធ្វើក្នុងការិយាល័យប្រជាពលរដ្ឋនិងនៅតាមអង្គភាពនានារបស់រដ្ឋបាលស្រុក។

ក្នុងរយៈ២៨ម៉ោងដូចបានកំណត់ខាងលើ តំណាងប្រជាពលរដ្ឋត្រូវធ្វើការ[illegible] ករណី និងពាក្យបណ្តឹងនានា ព្រមទាំងធ្វើការសំរុះសំរួលសំដៅអោយមានដំណោះស្រាយចំពោះពាក្យបណ្តឹងនានា ដោយឈរលើមូលដ្ឋាន នៃការស្រុះស្រួលគ្នាពីភាគីទាំងសងខាង ។ តំណាងប្រជាពលរដ្ឋអាចស្នើសុំកិច្ចសហការពី អភិបាល រងស្រុកមួយរូប ដែល[illegible]

ភារកិច្ចដោយអភិបាលស្រុក ដើម្បីពិគ្រោះយោបល់ជាមួយគ្នាអំពីវិធីដែលមានប្រសិទ្ធភាព ក្នុងការស្វែងរកការពិតនៃករណីនីមួយៗ ដែលពាក់ព័ន្ធដល់ពាក្យបណ្តឹង ។

**ប្រការ១៣.-**

កាវិយាល័យប្រជាពលរដ្ឋមានតំណាងប្រជាពលរដ្ឋជាប្រធានការិយាល័យ និង មានលេខាធិការមួយចំនួនជាជំនួយការ ។

លេខាធិការ គឺជាមន្ត្រីដែលស្ថិតក្នុងក្របខ័ណ្ឌរដ្ឋបាលក្រសួងមហាផ្ទៃ ហើយដែលកំពុងបំពេញការងារក្នុងសាលាស្រុក តាមការស្នើសុំពីប្រធានការិយាល័យប្រជាពលរដ្ឋ និង ដោយមានការឯកភាពពីអភិបាលស្រុក ។

លេខាធិការត្រូវបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានការិយាល័យប្រជាពលរដ្ឋ។

**ប្រការ១៤.-**

ក្នុងពេលទទួលបានពាក្យបណ្តឹងតវ៉ាពីប្រជាពលរដ្ឋ និងសហគ្រាសដែលតវ៉ាពាក់ព័ន្ធទៅនឹងការសំរេច ឬ អាកប្បកិរិយារបស់មន្ត្រីរាជការក្នុងរដ្ឋបាលស្រុក តំណាងប្រជាពលរដ្ឋមានសិទ្ធិកោះអញ្ជើញមន្ត្រីរាជការដែលមានបញ្ហានោះ និងអ្នកគ្រប់គ្រងផ្ទាល់របស់មន្ត្រីរាជការនោះ ដោយអោយចូលមកកាន់ការិយាល័យប្រជាពលរដ្ឋដើម្បីបំភ្លឺ ។

ក្នុងករណីមន្ត្រីរាជការដែលមានបញ្ហានោះ ឬ អ្នកគ្រប់គ្រងផ្ទាល់របស់មន្ត្រីរាជការមានភារកិច្ចចាំបាច់មិនអាចមកកាន់ការិយាល័យប្រជាពលរដ្ឋបានភ្លាម តាមការកោះអញ្ជើញមន្ត្រីរាជការ និង អ្នកគ្រប់គ្រងនោះអាចមានពេលវេលាបីថ្ងៃ ដើម្បីឆ្លើយតបចំពោះការអញ្ជើញរបស់តំណាងប្រជាពលរដ្ឋ ។

ក្នុងករណីខាងលើនេះ មន្ត្រីរាជការដែលមានបញ្ហានោះ និងអ្នកគ្រប់គ្រងរបស់ខ្លួន ត្រូវជូនពត៌មានជាមុន ដល់តំណាងប្រជាពលរដ្ឋ ។

តំណាងប្រជាពលរដ្ឋមានសិទ្ធិសុំអោយមន្ត្រីរាជការដែលមានបញ្ហានោះ និង អ្នកគ្រប់គ្រងមន្ត្រីរាជការនោះធ្វើការពន្យល់បកស្រាយជាលាយលក្ខណ៍អក្សរអំពីហេតុផល នៃការចេញសេចក្តីសំរេច ឬ ហេតុផលដែលបណ្តាលអោយមានអាកប្បកិរិយាប៉ះទង្គិច ជាមួយប្រជាពលរដ្ឋ ឬ តំណាងសហគ្រាស រួចហើយត្រូវប្រគល់សេចក្តីពន្យល់នោះជូនតំណាងប្រជាពលរដ្ឋយ៉ាងយូរបីថ្ងៃ បន្ទាប់ពីបានទទួលការស្នើសុំអោយបំភ្លឺពីការិយាល័យប្រជាពលរដ្ឋ ។

តំណាងប្រជាពលរដ្ឋមានសិទ្ធិសុំពិនិត្យមើលឯកសារផ្សេងៗ ដែលពាក់ព័ន្ធពាក្យបណ្តឹងតវ៉ា នៅតាមអង្គភាព និងតាមការិយាល័យនានាក្នុងរដ្ឋបាលស្រុកតាមការចាំបាច់ដោយមិនគិតថ្លៃ ជាជូន ។

ដំណឹងជាមុន ហើយអាចធ្វើនៅពេលណាក៏បាន ក្នុងពេលម៉ោងបំពេញការងារ ។

ក្នុងពេលពិនិត្យឯកសារដែលពាក់ព័ន្ធទាំងនោះ តំណាងប្រជាពលរដ្ឋមានសិទ្ធិ ដកយកឯកសារដែលខ្លួនយល់ឃើញថា ចាំបាច់ក្នុងរយៈពេលមួយថ្ងៃ ដើម្បីថតចម្លង ទុកជាភស្តុតាងរួចហើយត្រូវប្រគល់ឯកសារច្បាប់ដើមទៅអង្គភាព ឬការិយាល័យនោះវិញ នៅថ្ងៃបន្ទាប់ ។

**ប្រការ១៥.ៈ**

ក្នុងដំណើរការស្រាវជ្រាវស៊ើបអង្កេតស្វែងរកការពិត និងក្នុងដំណើរការសំរុះសំរួល ប្រសិនបើមន្ត្រីរាជការដែលមានបញ្ហា ឬ អ្នកគ្រប់គ្រងមន្ត្រីរាជការ ដែលមានបញ្ហានោះមិនសហការ ឬធ្វើព្រងើយកណ្តើយចំពោះអនុសាសន៍នានាដែលពាក់ព័ន្ធដល់ដំណោះស្រាយនៃពាក្យបណ្តឹង ដែលតំណាងប្រជាពលរដ្ឋយល់ឃើញថា ជាពាក្យបណ្តឹងមានហេតុផលសមស្របតំណាងប្រជាពលរដ្ឋត្រូវជំរាបជូនផ្ទាល់ទៅអភិបាលស្រុក ដោយភ្ជាប់ជាមួយនូវសេចក្តីរាយការណ៍អំពីដំណើររឿង និងអនុសាសន៍របស់ខ្លួនផង ។

អភិបាលស្រុកត្រូវចាត់គ្រប់វិធានការ ដើម្បីដោះស្រាយអោយបានស្រុះស្រួលគ្នានូវពាក្យបណ្តឹងនេះ ។

**ប្រការ១៦.ៈ**

តំណាងប្រជាពលរដ្ឋ អាចធ្វើការផ្សព្វផ្សាយពាក្យបណ្តឹងតវ៉ានិងឯកសារដែលពាក់ព័ន្ធ ជូនសាធារណជនបាន ក្នុងករណីដែលប្រជាពលរដ្ឋ ឬ តំណាងសហគ្រាសដែលដាក់ពាក្យបណ្តឹងតវ៉ានោះយល់ព្រមអោយផ្សព្វផ្សាយ ។

**ប្រការ១៧.ៈ**

ពាក្យបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋឬសហគ្រាសដែលជំទាស់នឹងការសំរេចឬអាកប្បកិរិយារបស់អភិបាលស្រុក ត្រូវផ្ញើជូនទៅអភិបាលខេត្ត តាមរយៈតំណាងប្រជាពលរដ្ឋ ក្នុងករណីដែលតំណាងប្រជាពលរដ្ឋយល់ឃើញថា ពាក្យបណ្តឹងនោះមានហេតុផលសមស្រប ។

អភិបាលខេត្តត្រូវចាត់អោយមានការស្រាវជ្រាវស៊ើបអង្កេតហើយចាត់វិធានការសំរុះសំរួល។ ក្នុងករណីមិនអាចសំរុះសំរួលបាន អភិបាលខេត្តត្រូវធ្វើសេចក្តីរាយការណ៍ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ក្រសួងស្ថាប័នដែលពាក់ព័ន្ធដោយភ្ជាប់ជាមួយនូវដំណើររឿង និង អនុសាសន៍របស់ខ្លួនផង ។

**ប្រការ១៨.ៈ**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គលេខានៃអគ្គលេខាធិការដ្ឋាន អគ្គាធិការ នៃ

អគ្គាធិការដ្ឋាន កិច្ចការនយោបាយរដ្ឋបាល និង នគរបាល អភិបាល ខេត្តសៀមរាប អភិបាល ខេត្តបាត់ដំបង អភិបាលស្រុកសៀមរាប និង អភិបាលស្រុកបាត់ដំបង ត្រូវអនុវត្តអោយបាន សំរេចនូវប្រកាសនេះ ។

**ប្រការ១៩.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

**ស ខេង**

យូ-ហុកគ្រី

**ចម្លងជូន**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន

"ដើម្បីជូនជ្រាប" ។

-ដូចប្រការ ១៨

"ដើម្បីអនុវត្ត" ។

-ឯកសារ-កាលប្បវត្តិ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ ៖ ៧៩៤ ប្រក

726
05-7-04 8:20

# ប្រកាស
## ស្តីពី
## ការរៀបចំ និង ការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញ-ចូលតែមួយ នៅស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង

## សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសំរេច លេខ៤៧ សស.រ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រង ស្រុកសៀមរាបនៃខេត្តសៀមរាប និង និង ស្រុកបាត់ដំបងនៃខេត្តបាត់ដំបង
- យោងតាមស្មារតីនៃកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំសង្កាត់នាថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៤
- យោងលិខិតលេខ ១៦០/០៤ សជណ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

# សម្រេច

**ប្រការ១.-**

បង្កើតការិយាល័យមួយ ឈ្មោះ " ការិយាល័យច្រកចេញ-ចូលតែមួយ " នៅក្នុងវេទនាសម្ព័ន្ធរដ្ឋបាលស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

**ប្រការ២.-**

ការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីលើកកំពស់គោលការណ៍អភិបាលកិច្ចល្អ ការកែទម្រង់ប្រព័ន្ធរដ្ឋបាល ដោយពង្រីក វិសាលភាពសេវាកម្មដែលផ្តល់ដោយរដ្ឋបាលស្រុកឱ្យបានទូលំទូលាយ តាមរយៈការប្រមូលផ្តុំសេវាកម្មទាំងអស់ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ស្រុក ដែលត្រូវផ្តល់ជូនអតិថិជននៅកន្លែងតែមួយ ។

**ប្រការ៣.-**

ការិយាល័យច្រកចេញ-ចូលតែមួយ គឺជាការិយាល័យផ្តល់សេវាកម្មដល់ប្រជាពលរដ្ឋ មានគោលដៅបំរើអតិថិជន ពលរដ្ឋ សហគ្រាស និង អង្គការទាំងឡាយ ដែលកំពុងធ្វើសកម្មភាពក្នុងមូលដ្ឋានស្រុក ក្នុងទិសដៅប្រើប្រាស់ឱ្យមានប្រសិទ្ធភាពនូវធនធានដែលមានស្រាប់នៅថ្នាក់ស្រុក ទៅតាមនីតិវិធីរដ្ឋបាលដែលអាចសំរេចការងារ ប្រកបដោយប្រសិទ្ធភាព និងមានរយៈពេលខ្លីជាងមុន ។

ការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវអនុវត្តតាមនីតិវិធីរដ្ឋបាលដែលបានកំណត់ ។

ឯកសារផ្លូវការនានា រួមមាន លិខិតស្នាម ត្រូវតែបំពេញបែបបទតាមនីតិវិធីរដ្ឋបាល ដែលបានកំណត់ រួមទាំងការបញ្ជាក់លើច្បាប់ចម្លង និង បង្កាន់ដៃទទួលប្រាក់ផង ។

ការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវផ្តល់ពត៌មានពិស្តារ និង ពត៌មានជាទូទៅជូនដល់ប្រជាពលរដ្ឋ និង អតិថិជននានាក្នុងស្រុក អំពីកិច្ចការរដ្ឋបាលនៅថ្នាក់ខេត្ត ក្រុង ស្រុក ឃុំ និងផ្តល់ពត៌មានអំពីនីតិវិធីរដ្ឋបាល ដែលជាសមត្ថកិច្ចរបស់ថ្នាក់ជាតិ និង ថ្លៃសេវាកម្មសំរាប់នីតិវិធីទាំងនេះ ដែលពាក់ព័ន្ធទៅនឹងវិស័យសេដ្ឋកិច្ច ដីធ្លី ផែនការប្រើប្រាស់ដីធ្លី រួមទាំងពត៌មាន អំពីការគាំពារសុខភាព ការអប់រំ វប្បធម៌ និងបញ្ហាសង្គមផងដែរ ។

**ប្រការ៤.-**

រាល់សេវាកម្មក្នុងការពិគ្រោះយោបល់ការផ្តល់ពត៌មាន និង នីតិវិធីរដ្ឋបាលត្រូវគោរពតាមច្បាប់ លិខិតបទដ្ឋាននានា និង ការណែនាំជាលាយលក្ខណ៍អក្សរ ដែលបានឯកភាពគ្នារវាងអភិបាលខេត្ត អភិបាលស្រុក និង ក្រសួងស្ថាប័នពាក់ព័ន្ធ ។

គណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង ត្រូវចូលរួមក្នុងការផ្តល់យោបល់ជូនក្រសួងស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងគណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់

លើបញ្ហាដែលទាក់ទងនឹងការផ្ទេរសេវាកម្មនានាទៅឱ្យការិយាល័យច្រកចេញ-ចូលតែមួយ ។

**ប្រការ៥.-**

មន្ត្រីរាជការរបស់ស្រុក ដែលចាត់ឱ្យបំពេញការងារក្នុងការិយាល័យច្រកចេញ-ចូលតែមួយ គឺជា "បុគ្គលិក" របស់ការិយាល័យនេះផ្ទាល់ ។

**ប្រការ៦.-**

ការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវមានប្រធានការិយាល័យមួយរូបអមដោយ អនុប្រធាន និង បុគ្គលិកមួយចំនួនទៀតតាមការចាំបាច់ ជាជំនួយការ ។

ការតែងតាំងមុខតំណែងនានាក្នុងការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវអនុវត្តតាមបែបបទ នីតិវិធី ដូចការិយាល័យនានាក្នុងរដ្ឋបាលស្រុកដែរ ។

ប្រធានការិយាល័យច្រកចេញ-ចូលតែមួយ ជាអ្នកដឹកនាំការិយាល័យ និង ជាអ្នកទទួលខុសត្រូវរាល់សកម្មភាពរបស់ការិយាល័យឱ្យដំណើរការបានត្រឹមត្រូវតាមច្បាប់ និងតួនាទី ភារកិច្ចរបស់ខ្លួនដែលបានកំណត់ ។

បុគ្គលិកទាំងអស់ ដែលបំពេញការងារក្នុងការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវស្ថិតក្រោមការចាត់ចែងរបស់ប្រធានការិយាល័យ ។

ក្នុងករណីដែលមន្ត្រីណាម្នាក់ មិនគោរពតាមនីតិវិធីរដ្ឋបាល ពេលវេលា ឬ នីតិវិធី ផ្សេងទៀតដែលបានកំណត់ ប្រធានការិយាល័យមានសិទ្ធិទំនាក់ទំនងជាមួយការិយាល័យជំនាញរបស់ក្រសួងនានានៅថ្នាក់ស្រុក ឬ មន្ទីរជំនាញនានានៅថ្នាក់ ខេត្តដោយផ្ទាល់ ។

**ប្រការ៧.-**

អនុប្រធានការិយាល័យច្រកចេញ-ចូលតែមួយ មានភារកិច្ចជំនួសប្រធានក្នុងករណីប្រធានអវត្តមានលើសពីមួយថ្ងៃ ។

ក្នុងករណីចាំបាច់តាមការណែនាំរបស់ប្រធាន អនុប្រធានការិយាល័យអាចជំនួសប្រធានការិយាល័យបាន ។

ក្នុងករណីដែលប្រធានមានជម្ងឺធ្ងន់ អនុប្រធានការិយាល័យត្រូវបំពេញភារកិច្ចជំនួសប្រធានភ្លាមចាប់ពីពេលដែលប្រធានមានជម្ងឺ ។

**ប្រការ៨.-**

មុខតំណែងទាំងអស់ក្នុងការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវបានកំណត់ និងតែងតាំងដោយអភិបាលស្រុក តាមសំណើរបស់ប្រធានការិយាល័យច្រកចេញ-ចូលតែមួយ ។

ចំពោះការកំណត់ និង ការស្នើតែងតាំងមុខតំណែង មន្ត្រី បុគ្គលិកការិយាល័យនេះ ប្រធានការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវធ្វើការពិគ្រោះពិភាក្សាជាមុនជាមួយការិយាល័យបុគ្គលិកនៃមន្ទីរស្រុក ។

ការតែងតាំង និងការចាត់តាំងមន្ត្រីបុគ្គលិកក្នុងការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវតែផ្អែកលើមូលដ្ឋាននៃការវាយតម្លៃសមត្ថភាពបុគ្គលិក ។

ការជ្រើសរើសបុគ្គលិកឱ្យបំពេញមុខតំណែងត្រូវពិចារណាគ្រប់វិស័យការងារ ដែលបានផ្ទេរប្រគល់ឱ្យក្នុងការិយាល័យច្រកចេញ-ចូលតែមួយ ។

ក្នុងករណីចាំបាច់ ប្រធានការិយាល័យអាចស្នើសុំបុគ្គលិករបស់ក្រសួងស្ថាប័ននានាឱ្យមកបំពេញការងារជាមន្ត្រីបុគ្គលិកនៃការិយាល័យច្រកចេញ-ចូលតែមួយ បាន ។

**ប្រការ៩.-**

ចំនួនមន្ត្រីរាជការ ឬ បុគ្គលិក ការបណ្តុះបណ្តាល ការគាំទ្រខាងសមត្ថភាព ការណែនាំដល់មន្ត្រីបុគ្គលិកត្រូវធ្វើឡើងតាមសំណើរបស់អភិបាលស្រុក និងសំរេចដោយគណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង ។

អភិបាលស្រុកត្រូវពិគ្រោះយោបល់ជាមួយការិយាល័យជំនាញថ្នាក់ស្រុកទាំងអស់លើការងារដែលពាក់ព័ន្ធ ដូចមានចែងខាងលើមុននឹងលើកសំណើជូនគណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង ។

**ប្រការ១០.-**

មន្ត្រីបុគ្គលិកទាំងអស់នៃការិយាល័យច្រកចេញ-ចូលតែមួយត្រូវបំពេញការងារ ៥ ថ្ងៃក្នុង០១សប្តាហ៍ ក្នុងមួយថ្ងៃ ៨ ម៉ោង ។ មន្ត្រីបុគ្គលិក ដែលបានចាត់ឱ្យបំពេញការងារបន្ថែមម៉ោង នឹងទទួលបានប្រាក់កម្រៃតាមការកំណត់ ។

ការកំណត់ម៉ោងពេលធ្វើការងារប្រចាំថ្ងៃរបស់មន្ត្រីនៃការិយាល័យច្រកចេញ-ចូលតែមួយរបស់ស្រុកទាំងពីរ ត្រូវសំរេចដោយគណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បងតាមសំណើរបស់អភិបាលស្រុក ។

ការកែប្រែកាលវិភាគ និងវេនការងារនឹងអាចធ្វើទៅបានលុះត្រាតែមានការអនុញ្ញាតពីប្រធានការិយាល័យ ។

ប្រធាន ឬអនុប្រធានការិយាល័យជាអ្នកទទួលខុសត្រូវក្នុងការជានាឱ្យបុគ្គលិកទាំងអស់

គោរពតាមកាលវិភាគការងារនេះ ។

**ប្រការ១១.-**

មន្ត្រីរាជការ ដែលបំពេញការងារក្នុងការិយាល័យ ច្រកចេញ-ចូលតែមួយត្រូវផ្តល់អាទិភាពរៀបចំចាត់បញ្ចូលក្នុងក្រុមមន្ត្រីនៃកន្សោមអាទិភាព តាមការកំណត់របស់រាជរដ្ឋាភិបាល។

**ប្រការ១២.-**

ក្នុងការបំពេញការងារមន្ត្រី បុគ្គលិកទាំងអស់នៃការិយាល័យច្រកចេញ-ចូលតែមួយ មានកាតព្វកិច្ចដូចខាងក្រោម ÷

-ខិតខំប្រឹងប្រែងបញ្ចេញសមត្ថភាពបំពេញការងារ ក្រោមការចាត់ចែងរបស់ប្រធានការិយាល័យ ។

-អនុវត្តមុខងារដែលបានប្រគល់ឱ្យស្របតាមបញ្ញត្តិច្បាប់ លិខិតបទដ្ឋាន និង បទបញ្ជាបុគ្គលិក ដោយមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន បក្សពួក គ្រួសារ ។

-ខិតខំបង្កើនចំណេះដឹងខាងបច្ចេកទេស និង ចំណេះដឹងផ្ទាល់ខ្លួនឱ្យបានទៀងទាត់ ។

-សហការប្រកបដោយផ្ទៃផ្តា និងត្រូវជួយគ្នាទៅវិញទៅមកក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ។

-អនុវត្តតាមការណែនាំ និង បទបញ្ជាដែលចេញដោយថ្នាក់លើ ។

**ប្រការ១៣.-**

ក្នុងពេលបំពេញការងារ ក្នុងករណីមន្ត្រីបុគ្គលិកណាម្នាក់មានការសង្ស័យពីសុពលភាព នៃបទបញ្ជា មន្ត្រីបុគ្គលិកនោះត្រូវតែសាកសួរទៅអ្នកគ្រប់គ្រងផ្ទាល់ភ្លាម ។

ក្នុងករណីអ្នកគ្រប់គ្រងផ្ទាល់បានបញ្ជាក់ហើយ ប៉ុន្តែមន្ត្រីបុគ្គលិកនោះនៅតែបន្តមានការការសង្ស័យអំពីសុពលភាពនៃបទបញ្ជាអ្នកគ្រប់គ្រងត្រូវបញ្ជូនបញ្ហានេះ ទៅថ្នាក់លើបន្តទៀត ។

ក្នុងករណីថ្នាក់លើបានបញ្ជាក់លើបទបញ្ជានោះ ថាពិតជាត្រឹមត្រូវហើយ បុគ្គលិកត្រូវតែគោរពតាម និង អនុវត្តតាមបទបញ្ជានោះ ។

ក្នុងករណីនេះ បុគ្គលិកនោះត្រូវបានលើកលែងពីការទទួលខុសត្រូវផ្ទាល់ខ្លួន ។

ក្នុងករណីខាងលើនេះ មន្ត្រីបុគ្គលិកនោះអាចស្នើសុំឱ្យមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរបាន ។

**ប្រការ១៤.-**

មន្ត្រីរាជការដែលបំរើការងារក្នុងការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវហាមឃាត់ដាច់ខាតនូវសកម្មភាពណាមួយ ដូចខាងក្រោម ÷

១-យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត ។

២-យកឥទ្ធិពលនិងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬ ដើម្បីសំឡុត គំរាមកំហែង បំពានសិទ្ធិរបស់ប្រជាពលរដ្ឋ ។

៣-ប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃអ្នករាជការ ។

៤-ចូលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬ គ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬ ដោយប្រយោល ។

៥-បោះពុម្ពផ្សាយ ឬ ធ្វើការផ្សាយពត៌មានដែលមានពាក់ព័ន្ធនៅក្នុងមុខងារក្រសួងស្ថាប័ន ដោយពុំមានការអនុញ្ញាតជាមុនពីប្រធានស្ថាប័ន ដែលសាមីខ្លួននៅក្រោមឱវាទ។

៦-ប្រកបមុខរបរបន្ថែមត្រួតលើមុខងាររបស់ខ្លួនជាអ្នករាជការ ។

**ប្រការ១៥.-**

ក្នុងករណីមន្ត្រីបុគ្គលិកណាម្នាក់ផ្លាស់ប្តូរអាសយដ្ឋាន ឬ មានការកែប្រែស្ថានភាពរបស់ខ្លួន ឬរបស់គ្រួសារខ្លួន មន្ត្រី បុគ្គលិកនោះត្រូវជូនពត៌មានភ្លាមទៅការិយាល័យបុគ្គលិកនៃមន្ទីរស្រុក ។

**ប្រការ១៦.-**

រាល់ការទទួលរង្វាន់ អំណោយ ឬគ្រប់រូបភាពនៃសាគុណដែលស្នើផ្តល់ឱ្យបុគ្គលិកទាក់ទិននឹងមុខងាររបស់បុគ្គលិកនោះ ត្រូវហាមឃាត់ដាច់ខាត ។

ការប៉ុនប៉ងណាមួយរបស់ប្រជាពលរដ្ឋដើម្បីផ្តល់សំណូកដល់បុគ្គលិក នឹងត្រូវបានរាយការណ៍ជាបន្ទាន់ដោយបុគ្គលិក ដែលបានទទួលសំណើសុំផ្តល់រង្វាន់ ឬ អំណោយនោះទៅថ្នាក់លើដែលទទួលបន្ទុក និង ប្រធានការិយាល័យសវនកម្មផ្ទៃក្នុង ។

រាល់ចំណាយធ្វើដំណើរសំរាប់បំពេញការងារផ្លូវការ ត្រូវបញ្ជូនទៅការិយាល័យបុគ្គលិក ដើម្បីពិនិត្យ ហើយការិយាល័យបុគ្គលិកអាចបដិសេធលើការចំណាយបាន ប្រសិនបើមានហេតុផលសង្ស័យថា ការចំណាយនោះធ្វើឡើងមិនត្រឹមត្រូវតាមគោលការណ៍ ។

ក្នុងករណីដែលការិយាល័យបុគ្គលិកបដិសេធលើការចំណាយ ការិយាល័យបុគ្គលិក ត្រូវធ្វើសេចក្តីរាយការណ៍ជូនអភិបាលស្រុក និង ការិយាល័យសវនកម្មផ្ទៃក្នុង ។

អភិបាលស្រុកត្រូវធ្វើសេចក្តីសំរេចចុងក្រោយលើករណីទាំងនេះដោយផ្អែកតាមអនុសាសន៍របស់ការិយាល័យសវនកម្មផ្ទៃក្នុង ។

**ប្រការ១៧.-**

មន្ត្រី បុគ្គលិកត្រូវរក្សាឱ្យបានដាច់ខាតនូវការសម្ងាត់របស់រដ្ឋ ឯកសារ ស៊ើឡិតសម្ងាត់ និង

បញ្ហានានា ដែលសាមីខ្លួនបានដឹងក្នុងពេលបំពេញការងារ ទោះបីជាមន្ត្រី បុគ្គលិកនោះ ត្រូវបញ្ឈប់ពីការងារ ឬ ចូលនិវត្តន៍ហើយក៏ដោយ ។

ក្នុងករណីមានការស្នើសុំឱ្យមន្ត្រីបុគ្គលិកផ្តល់កស្សិណលើរឿងក្តីរដ្ឋ មន្ត្រីបុគ្គលិកនោះត្រូវមានការអនុញ្ញាតជាមុនពីអភិបាលស្រុក ។

**ប្រការ១៨.-**

មន្ត្រី បុគ្គលិកដែលធ្វេសប្រហែសធ្វើការងារបំពានទៅលើច្បាប់រដ្ឋ ត្រូវទទួលខុសត្រូវតាមច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ១៩.-**

មន្ត្រី បុគ្គលិក និងអតិថិជន ត្រូវហាមឃាត់ការពិសាបារី និង គ្រឿងស្រវឹងគ្រប់ប្រភេទនៅក្នុងការិយាល័យ ។

**ប្រការ២០.-**

ការឈប់សំរាកពីការងាររបស់មន្ត្រី បុគ្គលិក ទោះក្នុងករណីណាក៏ដោយត្រូវមានការអនុញ្ញាតជាមុនពីប្រធានការិយាល័យ ។

ក្នុងករណីដែលមានមន្ត្រី បុគ្គលិកណាម្នាក់ឈប់សំរាកពីការងារ ប្រធានការិយាល័យ ត្រូវចាត់មន្ត្រីដែលមានសមត្ថភាពមកជំនួស ដើម្បីធានានិរន្តរភាពការងារ ។

ដើម្បីធានានិរន្តរភាពការងារក្នុងពេលដែលខ្លួនឈប់សំរាកមន្ត្រី បុគ្គលិកអាចដាក់គំរោងឈប់សំរាកប្រចាំឆ្នាំ ដោយបញ្ជាក់កាលបរិច្ឆេទដែលត្រូវឈប់សំរាកនៅដើមឆ្នាំនីមួយៗ ។

សិទ្ធិអនុញ្ញាតអោយមន្ត្រី បុគ្គលិកឈប់សំរាកត្រូវអនុវត្តតាមគោលការណ៍ ដូចខាងក្រោម÷

-ក្រោម០៣ថ្ងៃ សំរេចដោយប្រធានការិយាល័យ ។

-ចាប់ពី០៣ថ្ងៃ ដល់០៧ថ្ងៃ សំរេចដោយអភិបាលរងស្រុកទទួលបន្ទុក ។

-ចាប់ពី០៧ថ្ងៃឡើងទៅ ត្រូវសំរេចដោយអភិបាលស្រុក ។

ក្នុងករណីមន្ត្រី បុគ្គលិកមានជម្ងឺ សាមីខ្លួន ឬ ក្រុមគ្រួសារត្រូវផ្តល់ដំណឹងជូនប្រធានការិយាល័យបុគ្គលិកអំពីសភាពនៃជម្ងឺ នៅថ្ងៃដំបូងនៃជម្ងឺ ។

ក្នុងករណីជម្ងឺត្រូវអូសបន្ទាយច្រើនជាង០៣ថ្ងៃ (រាប់ទាំងថ្ងៃមិនធ្វើការ) នៅថ្ងៃទី០៣ មន្ត្រី បុគ្គលិក ឬ ក្រុមគ្រួសារ ត្រូវមានសំបុត្រពេទ្យ ដែលតម្រូវឱ្យមន្ត្រីរាជការ នោះឈប់សំរាកពីការងារមួយរយៈ ដើម្បីព្យាបាលជម្ងឺ ។

ក្នុងករណីមន្ត្រីបុគ្គលិកមិនអាចមកបំពេញការងារបានដោយមានឧបសគ្គ [illegible]

នោះត្រូវផ្តល់ពត៌មានភ្លាមជូនទៅអ្នកគ្រប់គ្រងផ្ទាល់របស់ខ្លួន ។

ពេលមានបុគ្គលិកណាម្នាក់អវត្តមានពីការងារ ទោះបីមានឬគ្មានមូលហេតុនិងការចូលបំពេញការងារវិញ អ្នកគ្រប់គ្រងផ្ទាល់បុគ្គលិកនោះត្រូវរាយការណ៍ជូនប្រធានការិយាល័យច្រកចេញ-ចូលតែមួយ និងការិយាល័យបុគ្គលិក ។

**ប្រការ២១.-**

ក្នុងករណីដែលបុគ្គលិកណាម្នាក់ត្រូវទៅចូលរួមប្រជុំ ឬសិក្ខាសាលា ឬចុះបំពេញបេសកកម្មការងារក្រោមមួយថ្ងៃ ត្រូវធ្វើលិខិតស្នើសុំពីប្រធានគ្រប់គ្រងផ្ទាល់ ។

ក្នុងករណីដែលត្រូវទៅចូលរួមប្រជុំ ឬសិក្ខាសាលា ឬចុះបំពេញការងារលើសពី០១ថ្ងៃពាក្យសុំនោះត្រូវដាក់ទៅប្រធានការិយាល័យច្រកចេញ-ចូលតែមួយ តាមរយៈប្រធានគ្រប់គ្រងផ្ទាល់ ។

ក្នុងពេលម៉ោងបំពេញការងារ មន្ត្រីបុគ្គលិកត្រូវមានវត្តមានជាប្រចាំនៅការិយាល័យរបស់ខ្លួន ។

ក្នុងម៉ោងបំពេញការងារ ប្រសិនបុគ្គលិកណាម្នាក់មានភារកិច្ចត្រូវទៅការិយាល័យផ្សេង ត្រូវជូនពត៌មានឱ្យអ្នកគ្រប់គ្រងផ្ទាល់ ។

**ប្រការ២២.-**

បន្ទាប់ពីបានទៅចូលរួមប្រជុំ សិក្ខាសាលា ឬ បេសកកម្ម មន្ត្រីបុគ្គលិកត្រូវធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលការងារជូនប្រធានការិយាល័យច្រកចេញ-ចូលតែមួយ តាមរយៈប្រធានគ្រប់គ្រងផ្ទាល់ និង ចម្លងជូនការិយាល័យបុគ្គលិក ។

**ប្រការ២៣.-**

ការិយាល័យច្រកចេញ-ចូលតែមួយ មានភារកិច្ចផ្តល់ពត៌មានដល់អតិថិជន អំពីរដ្ឋបាលរបស់ខេត្ត ស្រុក និងឃុំ ដោយផ្ទាល់មាត់ ឬ តាមទូរស័ព្ទ និងតាមរយៈសៀវភៅពត៌មាននានាដែលបានបោះពុម្ព ។

សៀវភៅពត៌មានខាងលើនេះ ត្រូវផ្តល់ពត៌មានជូនអតិថិជន អំពីទំរង់បែបបទ រយៈពេល នីតិវិធីរដ្ឋបាល តំលៃសេវា ដែលត្រូវបង់ជូនការិយាល័យច្រកចេញ-ចូលតែមួយ ។

ក្នុងករណីការិយាល័យច្រកចេញ-ចូលតែមួយ មិនអាចផ្តល់ពត៌មានដែលត្រូវការជូនអតិថិជនបាន ការិយាល័យច្រកចេញ-ចូលតែមួយត្រូវផ្តល់អាសយដ្ឋានអង្គភាព ដែលអាចផ្តល់ពត៌មានអំពីសេវានោះដល់អតិថិជនត្រូវការ ។

ពត៌មានអំពីរដ្ឋបាលខេត្ត ស្រុក ឃុំរាប់បញ្ចូលទាំងពត៌មានអំពីសេវាកម្មទីតាំងការិយាល័យជំនាញ ការអភិវឌ្ឍន៍ដីធ្លី ផែនការអភិវឌ្ឍន៍ កិច្ចប្រជុំក្រុមប្រឹក្សា ស្រុក ឃុំ ឈ្មោះ[illegible]

បញ្ហាអប់រំ សុខភាព សង្គម វប្បធម៌... ។

ទ្រង់ទ្រាយសៀវភៅពត៌មាន និង ពត៌មានផ្សេងៗដែលចុះក្នុងសៀវភៅនេះ ត្រូវរៀបចំដោយប្រធានការិយាល័យច្រកចេញ-ចូលតែមួយ និង សុំការឯកភាពពីអភិបាលស្រុក និង គណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង ។

អតិថិជនអាចទទួលបានពត៌មាន និង ការពិគ្រោះយោបល់បន្ថែមលើទំរង់បែបបទ និងពាក្យសុំដែលប្រើក្នុងការិយាល័យច្រកចេញ-ចូលតែមួយ ។

ការផ្តល់ពត៌មានការពិគ្រោះយោបល់ខាងលើនេះ ត្រូវតែផ្តល់អាទិភាពដល់អ្នកមិនចេះអក្សរ។

**ប្រការ២៤.-**

ការផ្តល់សេវាកម្មរដ្ឋបាលតាមច្រកចេញ-ចូលតែមួយ ត្រូវរ៉ាប់រងដោយការិយាល័យច្រកចេញ-ចូលតែមួយ និង សំរបសំរួលដោយក្រុមការងារចំរុះមួយដែលហៅថា "ក្រុមសំរបសំរួលរដ្ឋបាល " ។

ការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវមានផ្នែកសំខាន់ចំនួនពីរ គឺ ផ្នែកជួរមុខ និង ផ្នែកជួរក្រោយ ។

**ប្រការ២៥.-**

ផ្នែកជួរមុខត្រូវបានចាត់ទុកថាជាផ្នែកស្នូលនៃការិយាល័យច្រកចេញ-ចូលតែមួយ ជាកន្លែងដែលប្រជាពលរដ្ឋមកប្រាស្រ័យទាក់ទងដោយផ្ទាល់ ដើម្បីទទួលសេវាពីរដ្ឋបាលស្រុក ។

ផ្នែកជួរមុខមានបីក្រុម ។

ក្រុមទី ១ មានភារកិច្ចទទួលពាក្យសុំ ប្រគល់ឯកសារនិងផ្តល់ពត៌មានជូនប្រជាពលរដ្ឋដោយផ្ទាល់ ។

ក្រុមទី ២ មានភារកិច្ចធ្វើនីត្យានុកូលកម្មឯកសារ និង ត្រូវសំរេច បញ្ចប់ភ្លាមនៅផ្នែកជួរមុខតែម្តង ។

ក្រុមទី ៣ មានភារកិច្ចទទួលកំរៃសេវាកម្មរដ្ឋបាលដែលផ្តល់អោយដោយការិយាល័យច្រកចេញចូលតែមួយ និង ត្រូវរ៉ាប់រងប្រមូលថ្លៃសេវាកម្ម និង រក្សាបញ្ជីប្រមូលថ្លៃសេវាទាំងអស់ដែលបានប្រមូល ។

ផ្នែកជួរមុខអាចបញ្ជូនអតិថិជនទៅផ្នែកជួរក្រោយបានតែក្នុងករណីចាំបាច់ ដើម្បីអោយអតិថិជននោះធ្វើការការពារជាពិសេសនូវទិន្នន័យឯកជនរបស់ខ្លួន តែប៉ុណ្ណោះ ។

ផ្នែកជួរមុខមិនត្រូវបញ្ជូនអតិថិជនទៅការិយាល័យជួរក្រោយឡើយ ប្រសិនបើអតិថិជននោះ

មិនបានទាមទារធ្វើការការពារជាពិសេសនូវទិន្នន័យឯកជនរបស់ខ្លួន ។

បន្ទាប់ពីទទួលពាក្យស្នើសុំរួចហើយ ក្រុមទទួលឯកសារនៃផ្នែកជួរមុខត្រូវបញ្ជូនឯកសារទៅមន្ត្រី ភ្នាក់ងារមានសមត្ថកិច្ចមិនអោយលើសពី ៤ម៉ោង ។

បុគ្គលិកដែលទទួលការងារនីមួយៗ ត្រូវតែធានាឱ្យសេវាកម្មទាំងអស់បានអនុវត្តនៅក្នុងកំរិតខ្ពស់ជានិច្ច ។

**ប្រការ២៦.-**

ផ្នែកជួរក្រោយជាផ្នែកដែលទទួលរ៉ាប់រងសេវា ដែលមាននីតិវិធីរដ្ឋបាល ស្មុគស្មាញ និង សាំញ៉ាំ ឬនីតិវិធីរដ្ឋបាលដែលត្រូវការពេលវេលា ដើម្បីពិនិត្យបច្ចេកទេស និងត្រូវសំរេចបញ្ចប់ ដោយផ្នែកជួរក្រោយរបស់ការិយាល័យច្រកចេញ-ចូលតែមួយ ឬតម្រូវឱ្យសេវានោះត្រូវសំរេច និង បញ្ចប់ដោយសហការរវាងការិយាល័យច្រកចេញ-ចូលតែមួយជាមួយអង្គភាព ការិយាល័យជំនាញនានានៃរដ្ឋបាលស្រុក ក្នុងរយៈពេលមួយជាកំណត់ ។

ការិយាល័យជំនាញនានា ដែលត្រូវបំពេញមុខងារជាអង្គភាពជួរក្រោយ ត្រូវរៀបចំសំណើតែងតាំងមន្ត្រីជំនាញមួយរូបឬច្រើនរូបពីក្នុងការិយាល័យរបស់ខ្លួនទៅតាមការចាំបាច់ ដើម្បីទទួលពិនិត្យសំណើ ឬសំណុំលិខិតដែលបានផ្តល់អោយដោយផ្ទាល់ពីអង្គភាពជួរមុខ ឬក្នុងករណីពិសេសពីក្រុមសំរបសំរួលរដ្ឋបាល ។

មន្ត្រីដែលបានបញ្ជូនមក នោះជាមន្ត្រី ភ្នាក់ងារមានសមត្ថកិច្ច និង ត្រូវស្ថិតនៅក្រោមការដឹកនាំចាត់ចែងដោយផ្ទាល់ ពីប្រធានការិយាល័យច្រកចេញ-ចូលតែមួយ ។

ប្រធានក្រសួងស្ថាប័នជំនាញនីមួយៗ អាចធ្វើការផ្លាស់ប្តូរទៅតាមតំរូវការចាំបាច់ចំពោះមន្ត្រីភ្នាក់ងារមានសមត្ថកិច្ច ដែលប្រចាំការនៅក្នុងការិយាល័យច្រកចេញ-ចូលតែមួយដោយមានការពិគ្រោះយោបល់ជាមួយអភិបាលស្រុក ។

**ប្រការ២៧.-**

ក្រុមសំរបសំរួលរដ្ឋបាលជាក្រុមចំរុះសំរាប់ទទួលរ៉ាប់រងការបែងចែកសំណើ និងសំណុំលិខិតរបស់ប្រជាពលរដ្ឋដែលមានលក្ខណៈសាំញ៉ាំស្មុគស្មាញ និង មានការពាក់ព័ន្ធ នឹងវិស័យជាច្រើនដោយពិបាកក្នុងការបែងចែងសមត្ថកិច្ច ។ ក្រុមសំរបសំរួលរដ្ឋបាលនេះ ត្រូវធានាបែងចែកសំណើ និង សំណុំលិខិតស្មុគស្មាញទាំងនោះអោយ ចំសមត្ថកិច្ច ។

សមាសភាពក្រុមសំរបសំរួលរដ្ឋបាលមាន ÷

១-អភិបាលរងស្រុក ទទួលបន្ទុកផ្នែកច្រកចេញ-ចូលតែមួយ

២-ប្រធានការិយាល័យ ច្រកចេញ-ចូលតែមួយ

៣-ប្រធានការិយាល័យពាណិជ្ជកម្ម

៤-ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ សមាជិក

៥-ប្រធានការិយាល័យសាធារណការ និង ដឹកជញ្ជូន សមាជិក

៦-ប្រធានការិយាល័យ ឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៧-ប្រធានការិយាល័យ ទេសចរណ៍ សមាជិក

៨-ប្រធានការិយាល័យ វប្បធម៌ និង វិចិត្រសិល្បៈ សមាជិក

ដំណើរការប្រជុំរបស់ក្រុមសម្របសម្រួលរដ្ឋបាល ត្រូវប្រជុំមួយពេលយ៉ាងតិចក្នុងមួយសប្តាហ៍ និងត្រូវដឹកនាំប្រជុំដោយអភិបាលរងស្រុកទទួលបន្ទុក ឬ ក្នុងករណីខ្វះត្រូវដឹកនាំដោយប្រធានការិយាល័យច្រកចេញ-ចូលតែមួយតាមការផ្ទេរសិទ្ធិរបស់អភិបាលរងស្រុកទទួលបន្ទុក ។

ប្រធានការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវរៀបចំឯកសារដែលពាក់ព័ន្ធនឹងសំណើ និងសំណុំលិខិតដែលមានលក្ខណៈស្មុគស្មាញ និង មានការពាក់ព័ន្ធទៅនឹងវិស័យជាច្រើននោះ ជូនអង្គប្រជុំរបស់ក្រុមសម្របសម្រួលរដ្ឋបាល ។

គណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង អាចកំណត់បន្ថែមចំនួនសមាជិក នៃក្រុមសម្របសម្រួលរដ្ឋបាល ក្នុងករណីចាំបាច់ ។

**ប្រការ២៨.-**

ក្នុងករណីចាំបាច់ គណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង អាចចេញសេចក្តីណែនាំលំអិតអំពីនីតិវិធីបំពេញការងាររបស់ផ្នែកជួរមុខ ផ្នែកជួរក្រោយ និងក្រុមសម្របសម្រួលរដ្ឋបាលបាន ។

បុគ្គលិកដែលបំពេញការងារក្នុងផ្នែកជួរមុខ និង ផ្នែកជួរក្រោយ ត្រូវផ្តល់ពត៌មានដោយប្រុងប្រយ័ត្ន និងត្រូវធានាឱ្យសាធារណជនទុកចិត្តលើការសន្យារបស់ការិយាល័យច្រកចេញ-ចូលតែមួយព្រមទាំងទុកចិត្តលើភាពត្រឹមត្រូវនិងភាពពេញលេញនៃពត៌មាន ដែលបានផ្តល់ជូនសាធារណជន។

បុគ្គលិកទាំងអស់មិនត្រូវធ្វើការសន្យាណាមួយក្រៅពីវង្វង់សមត្ថកិច្ចសំរេចរបស់ខ្លួនឡើយ ។

ក្នុងការផ្តល់សេវាជូនអតិថិជន បុគ្គលិកត្រូវតែអនុវត្តស្របតាមបទបញ្ជា ដែលទាក់ទិននឹងរយៈពេលនៃដំណើរការរដ្ឋបាល និងថ្លៃសេវាកម្មដែលប្រជាពលរដ្ឋត្រូវបង់ ។

ក្នុងករណីមានសំណើពីអតិថិជន បុគ្គលិកត្រូវតែផ្តល់ពត៌មានភ្លាមជូនអតិថិជន អំពីដំណាក់កាលដែលបានបញ្ចប់ ក្នុងនីតិវិធីរដ្ឋបាល ។

ពត៌មានខាងលើនេះ អាចផ្តល់ជូនជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន ។

**ប្រការ២៩.-**

បុគ្គលិកទាំងអស់ត្រូវបំពេញការងារប្រកបដោយភាពរាក់ទាក់ រួសរាយចំពោះអតិថិជន និង

ក្នុងករណីដែលសំណើណាមួយរបស់អតិថិជនត្រូវបដិសេធ បន្ទាប់ពីការពិនិត្យ ល្អិតល្អន់រួចហើយ បុគ្គលិកត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីមូលហេតុនៃការបដិសេធជាលាយលក្ខណ៍អក្សរជូនទៅអតិថិជនវិញ ។

ក្នុងការប្រាស្រ័យទាក់ទងជាមួយអតិថិជន បុគ្គលិកត្រូវជៀសវាងឱ្យបាននូវវិវាទ និងការខ្វែងគំនិតគ្នា ។

ក្នុងករណីអតិថិជនបានប្រព្រឹត្តអាកប្បកិរិយាក្រអឺតក្រទម និងមិនសមរម្យ ហើយបុគ្គលទទួលបន្ទុកមិនអាចសំរបសំរួលដោះស្រាយបានតាមវិធីសមស្រប ប្រធានគ្រប់គ្រងផ្ទាល់របស់បុគ្គលិកនេះត្រូវចូលរួមធ្វើការសំរបសំរួលដោះស្រាយ ។

**ប្រការ៣០.-**

ក្នុងករណីដែលមានអតិថិជនច្រើនជាប្រចាំនៅការិយាល័យច្រកចេញ-ចូលតែមួយ ដែលធ្វើឱ្យបាត់សណ្តាប់ធ្នាប់ ឬ ធ្វើឱ្យប្រជាពលរដ្ឋត្រូវរង់ចាំយូរ ប្រធានការិយាល័យត្រូវចាត់ឱ្យចែកលេខដល់អតិថិជនទៅតាមលំដាប់អតិថិជនដែលមកដល់ការិយាល័យ ហើយការផ្តល់សេវាកម្មជូនអតិថិ-ជន ត្រូវធ្វើតាមលំដាប់លេខរៀងដែលបានចែកជូន ។

**ប្រការ៣១.-**

ការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវរៀបចំឱ្យស្ថិតនៅទីកន្លែងដែលសាធារណជន អាចប្រាស្រ័យទាក់ទងបានងាយស្រួល ។

ការិយាល័យ ត្រូវរៀបចំឱ្យមានបរិយាកាស និង សំភារៈឧបករណ៍សមស្រប សំរាប់សាធារណជន ។

**ប្រការ៣២.-**

ថ្លៃសេវាកម្ម ដែលផ្តល់ដោយការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវធ្វើការប្រកាសជាសាធារណៈ តាមការបិទផ្សាយនៅកន្លែងដែលប្រជាពលរដ្ឋអាចចេញ ចូលបានងាយស្រួលគ្រប់ពេលវេលា ។

បញ្ជរទទួលប្រាក់ត្រូវមានពត៌មានអំពីថ្លៃសេវា ហើយនឹងត្រូវចុះផ្សាយពត៌មាននេះនៅក្នុងព្រឹត្តិបត្រ ឯកសារ ពត៌មាននានារបស់រដ្ឋបាលស្រុកផងដែរ ។

**ប្រការ៣៣.-**

ក្នុងពេលដែលបុគ្គលិកបានប្រគល់ទំរង់បែបបទ ឬឯកសារពេញលេញជូនអតិថិជនរួចហើយ

អតិថិជនត្រូវទៅបង់ថ្លៃសេវាកម្មដោយខ្លួនឯងផ្ទាល់នៅបញ្ជរទទួលប្រាក់នៃការិយាល័យច្រកចេញ-ចូលតែមួយ ។

នៅពេលទទួលប្រាក់ បេឡាករត្រូវចេញបង្កាន់ដៃជូនអតិថិជន ហើយបង្កាន់ដៃផ្តិត ដោយកាបូនមួយច្បាប់ទៀតត្រូវបញ្ជូនទៅកាន់ការិយាល័យគណនេយ្យ ។

បង្កាន់ដៃទទួលប្រាក់ត្រូវមានហត្ថលេខាប្រគល់ទទួល និងចុះកាលបរិច្ឆេទដោយបុគ្គលិក និងអតិថិជន ។

**ប្រការ៣៤.-**

ទំរង់បែបបទនានាក្នុងនីតិវិធីរដ្ឋបាលសំរាប់ផ្តល់ជូនប្រជាពលរដ្ឋបំពេញ និងទំរង់បែបបទលិខិតឆ្លើយតបចំពោះសំណើសំណូមពររបស់ប្រជាពលរដ្ឋ ត្រូវរៀបចំឱ្យមានលក្ខណៈសាមញ្ញ ខ្លីច្បាស់លាស់ និង ងាយយល់ ។

ទំរង់បែបបទនៃនីតិវិធីរដ្ឋបាលទាំងនោះ ត្រូវដាក់សុំការសំរេចពីអភិបាលស្រុក និង គណៈ-កម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង ។

លិខិតស្នាមផ្សេងៗសំរាប់ទំនាក់ទំនងការងារក្នុងរដ្ឋបាលស្រុក និងថ្នាក់រដ្ឋបាលនានា ត្រូវអនុវត្តតាមគោលការណ៍ទូទៅនៃការរៀបចំការគ្រប់គ្រង និងការតំកល់ឯកសាររបស់រដ្ឋ។

**ប្រការ៣៥.-**

ការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំសប្តាហ៍អំពីសកម្មភាពការងាររបស់ការិយាល័យ ចំនួនអតិថិជន និងករណីដែលបានដោះស្រាយហេតុការណ៍នានា ដែលបានកើតឡើង និងសេវាកម្មដែលស្នើដោយប្រជាពលរដ្ឋ ហើយដែលមិនទាន់ បានដោះស្រាយរួមនឹងសភាពការណ៍ផ្សេងៗទៀតដែលចាំបាច់ ។

ផ្អែកតាមរបាយការណ៍ប្រចាំសប្តាហ៍ ការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវរៀបចំរបាយការណ៍ផ្សេងៗទៀតតាមកាលកំណត់ ។

គណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង ត្រូវធ្វើការពិភាក្សាអំពីទំរង់មាតិកានៃរបាយ-ការណ៍និងកាលបរិច្ឆេទជាក់ស្តែងដែលការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវរៀបចំរបាយការណ៍ ។

រៀងរាល់០៦ខែម្តងអភិបាលស្រុក ត្រូវចាត់ឱ្យមានការស្ទង់មតិប្រជាពលរដ្ឋអំពីសកម្មភាពការងារនៃការិយាល័យច្រកចេញ-ចូលតែមួយ ។

បែបបទ នីតិវិធី និង ខ្លឹមសារសំរាប់ស្ទង់មតិ ត្រូវកំណត់ដោយគណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង ។

**ប្រការ៣៦.-**

រាល់សេចក្តីសំរេចឬការអនុញ្ញាតអំពីសេវាកម្មរដ្ឋបាលទាំងអស់ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ស្រុក ត្រូវប្រើប្រាស់ត្រាសាលាស្រុកតែមួយ ។

មន្ត្រីមានសមត្ថកិច្ចដែលមានសិទ្ធិក្នុងការចុះហត្ថលេខា មានសមាសភាពដូចខាងក្រោម ÷

-អភិបាលស្រុក

-អភិបាលរងស្រុកដែលទទួលបន្ទុកការងារ ច្រកចេញ-ចូលតែមួយ

-ប្រធានការិយាល័យ ច្រកចេញ-ចូលតែមួយ

-ប្រធានការិយាល័យជំនាញដែលកំពុងបំពេញមុខងារនៅផ្នែកជួរក្រោយ

ចំពោះការបែងចែកសមត្ថកិច្ចក្នុងការចុះហត្ថលេខាសំរាប់មន្ត្រីមានសមត្ថកិច្ចដូចបានរៀបរាប់ខាងលើត្រូវកំណត់ដោយអភិបាលស្រុកដោយមានការពិគ្រោះយោបល់ជាមួយក្រុមសំរបសំរួលរដ្ឋបាល។

**ប្រការ៣៧.-**

អភិបាលស្រុក ឬមន្ត្រីមានសមត្ថកិច្ចក្នុងការចុះហត្ថលេខាត្រូវចេញអាជ្ញាប័ណ្ណ ការអនុញ្ញាត សេចក្តីសំរេច ឬការបដិសេធជាលាយល័ក្ខអក្សរលើការស្នើសុំមិនអោយលើសពី០២ថ្ងៃ បន្ទាប់ពីការទទួលយោបល់ពីផ្នែកជួរក្រោយ ។

**ប្រការ៣៨.-**

ដើម្បីធានាអោយកិច្ចដំណើរការនៃការិយាល័យច្រកចេញ-ចូលតែមួយ បានចាប់ផ្តើមដំណើរការ និង ដំណើរការប្រកបដោយភាពរលូន ស៊ីសង្វាក់គ្នា អភិបាលស្រុក ត្រូវផ្តួចផ្តើមរៀបចំផែនការសកម្មភាព និងជំហានការងារ ដើម្បីធ្វើការ ពិគ្រោះពិភាក្សាក្នុងគណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង រួចហើយត្រូវផ្តល់ការគាំទ្រ និងពិនិត្យមើលជាប្រចាំចំពោះកិច្ចដំណើរការនៃការិយាល័យនេះ ។

គណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង ត្រូវធ្វើការសំរបសំរួលជាមួយ ជាមួយក្រសួងស្ថាប័ននៅថ្នាក់ជាតិ មន្ទីរ អង្គភាពនានានៅថ្នាក់ខេត្ត ដើម្បីប្រមូលផ្តុំការគាំទ្រ ការដឹកនាំណែនាំជាប្រចាំ ចំពោះកិច្ចដំណើរការនៃការិយាល័យច្រកចេញ-ចូលតែមួយ ។

ប្រការ៣៩.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៤

**ស ខេង**

<u>**ចម្លងជូន**</u>

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន

"ដើម្បីជូនជ្រាប"

-ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធការិយាល័យច្រកចេញ-ចូលតែមួយ សំរាប់ស្រុកសៀមរាប និង ស្រុកបាត់ដំបង



**រាជរដ្ឋាភិបាលកម្ពុជា**
ក្រសួងមហាផ្ទៃ
លេខ : ៧៥១ ប្រក

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

724
05-07-04 ៨:៥០

# ប្រកាស
## ស្តីពី
## រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង

## សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស,៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នសរកម,០១៩៦,០៥ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលបាន ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសំរេចលេខ ៤៧ សស.រ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពី រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រង ស្រុកសៀមរាប នៃខេត្តសៀមរាប និង ស្រុកបាត់ដំបងនៃខេត្តបាត់ដំបង
- យោងតាមស្មារតីនៃកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំសង្កាត់ថ្ងៃទី ១០ខែ មិថុនា ឆ្នាំ ២០០៤
- យោងលិខិតលេខ ១៦០/០៤ សជណ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ដើម្បីសាកល្បងអនុវត្តនូវប្រព័ន្ធអភិបាលកិច្ចថ្មី សំរាប់ស្រុកទាំងពីរ ដោយអនុលោមទៅតាមសេចក្តីសំរេច លេខ ៤៧ សស.រ របស់រាជរដ្ឋាភិបាលចុះថ្ងៃទី១១ ខែ មិថុនា ឆ្នាំ២០០៣ ។

**ប្រការ២.-**

ស្រុកត្រូវដឹកនាំដោយអភិបាលស្រុកមួយរូប អមដោយអភិបាលរងស្រុក ០៣ រូបជាជំនួយការ ។

**ប្រការ៣.-**

អភិបាលស្រុកត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់អភិបាលខេត្តសាមីដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងចំណោមមន្ត្រី ដែលមានឋានន្តរសក្តិអនុមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ។

អភិបាលរងស្រុកត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលខេត្តសាមីក្នុងចំណោមមន្ត្រីរាជការដែលមានឋានន្តរសក្តិជានាយក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ។

**ប្រការ៤.-**

រចនាសម្ព័ន្ធរដ្ឋបាលស្រុកត្រូវរៀបចំដូចខាងក្រោម ÷

១-សាលាស្រុក មានមន្ទីរស្រុក និង ការិយាល័យមួយចំនួនដូចតទៅ :

- ក្រុមជំនួយការ
- ការិយាល័យច្រកចេញ-ចូលតែមួយ
- ការិយាល័យអភិវឌ្ឍន៍ទេសចរណ៍ វប្បធម៌ អប់រំ កីឡា និង សាសនា
- ការិយាល័យលើកកំពស់សុខមាលភាពកិច្ចការសង្គម និងភ្ជាប់ទំនាក់ទំនងការងារ
- ការិយាល័យសវនកម្មផ្ទៃក្នុង
- ការិយាល័យផែនការ និង វិនិយោគស្រុក

- ការិយាល័យបុគ្គលិក
- ការិយាល័យហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ
- ការិយាល័យរដ្ឋបាលទូទៅ និងលទ្ធកម្ម

២-ក្រុមប្រឹក្សាស្រុក មានលេខាធិការដ្ឋានមួយជាជំនួយការ ។

៣-ការិយាល័យជំនាញជុំវិញស្រុក ដែលរៀបចំសមស្របតាមការកំណត់របស់ក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ។

៤-ការិយាល័យប្រជាពលរដ្ឋគឺជាការិយាល័យធ្វើសកម្មភាពដោយអព្យាក្រឹត្យ និងត្រូវកំណត់ដោយប្រកាស ដោយឡែករបស់ក្រសួងមហាផ្ទៃ ។

**ប្រការ៥.-**

ការិយាល័យនានាចំណុះសាលាស្រុក ត្រូវដឹកនាំដោយប្រធានការិយាល័យមួយរូបអមដោយអនុប្រធានការិយាល័យមួយរូប និងមានបុគ្គលិកមួយចំនួនជាជំនួយការ ។

ប្រធានការិយាល័យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលស្រុក ដោយមានការឯកភាពពីអភិបាលខេត្ត ក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរសក្តិក្រមការនៃក្របខ័ណ្ឌ មន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ។

អនុប្រធានការិយាល័យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃតាមសំណើរបស់អភិបាលស្រុក ដោយមានការឯកភាពពីអភិបាលខេត្តក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរសក្តិ នាយលេខាធិការរដ្ឋបាល នៃ ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ក្រសួងមហាផ្ទៃ ។

បុគ្គលិក ដែលបំរើការងារតាមការិយាល័យនីមួយៗចំណុះសាលាស្រុក ត្រូវចាត់ឱ្យបំរើការងារដោយដីការបស់អភិបាលខេត្ត តាមសំណើរបស់អភិបាលស្រុក ក្នុងចំណោមមន្ត្រីដែលស្ថិតនៅក្នុងក្របខ័ណ្ឌ លេខាធិការរដ្ឋបាល ក្រសួងមហាផ្ទៃ ។

**ប្រការ៦.-**

មន្ទីរស្រុក ត្រូវដឹកនាំដោយប្រធានមន្ទីរមួយរូប អមដោយអនុប្រធានមួយរូបជាជំនួយការ។

ប្រធានមន្ទីរស្រុក ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលស្រុក ដោយមានការឯកភាពពីអភិបាលខេត្ត ក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរសក្តិក្រមការដើមខ្សែនៃក្របខ័ណ្ឌ មន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ។

អនុប្រធានមន្ទីរស្រុក ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃតាមសំណើរបស់អភិបាលស្រុក ដោយមានការឯកភាពពីអភិបាលខេត្ត ក្នុងចំណោមមន្ត្រីដែលស្ថិតក្នុង

ឋានន្តរសក្តិក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ។

## ជំពូកទី ២

## តួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់អភិបាល និងអភិបាលរងស្រុក

**ប្រការ៧.-**

អភិបាលស្រុកមានតួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវ ដូចខាងក្រោម ÷

ក/. តួនាទីរបស់អភិបាលស្រុក

- ជាតំណាងផ្ទាល់របស់អភិបាលខេត្ត រាជរដ្ឋាភិបាល និង ស្ថាប័ននានា នៃ រាជរដ្ឋាភិបាលនៅថ្នាក់ស្រុក ។
- ការទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលបានប្រគល់អោយថ្នាក់ស្រុក ។
- ទទួលខុសត្រូវផ្ទាល់ចំពោះអភិបាលខេត្តនិងទទួលខុសត្រូវអំពីការដឹកនាំ ប្រតិបត្តិការិយាល័យជំនាញជុំវិញស្រុក ។
- ទទួលខុសត្រូវដឹកនាំរួម និង ដឹកនាំផ្ទាល់ការិយាល័យក្រុមជំនួយការ ។

ខ/. សិទ្ធិអំណាចរបស់អភិបាលស្រុក

- ត្រូវបំពេញរាល់កិច្ចការរដ្ឋបាលនៅថ្នាក់ស្រុក ក្រោមការត្រួតពិនិត្យប្រសិទ្ធភាពរបស់អភិបាលខេត្តសាមី ។
- ដឹកនាំគ្រប់សកម្មភាពរបស់រដ្ឋបាលស្រុក ហើយត្រូវត្រួតពិនិត្យប្រសិទ្ធភាពការងាររបស់មន្ត្រីក្នុងសាលាស្រុក និងមន្ត្រីនៃការិយាល័យជំនាញជុំវិញស្រុក ។
- ដឹកនាំសាលាស្រុកនិងគ្រប់គ្រងផ្ទាល់លើកិច្ចការនានារបស់សាលាស្រុកដោយមានប្រធានមន្ទីរមួយរូប អមដោយអនុប្រធានមន្ទីរសាលាស្រុកមួយរូបជាជំនួយការ ។
- ការដឹកនាំ និងការណែនាំបន្តរបស់មន្ទីរឬអង្គភាពជំនាញនានានៅថ្នាក់ខេត្តទៅកាន់ការិយាល័យជំនាញនានានៅថ្នាក់ស្រុកពាក់ព័ន្ធទៅនឹងការបំពេញភារកិច្ចរបស់ការិយាល័យជំនាញទាំងនោះ ត្រូវធ្វើឡើងតាមរយៈអភិបាលស្រុក ។
- ជាអ្នកសំរបសំរួលលើសំណើ និង ពាក្យបណ្តឹងតវ៉ានានាពីការិយាល័យប្រជាពលរដ្ឋដែលតវ៉ាអំពីសេចក្តីសំរេច និង អាកប្បកិរិយារបស់មន្ត្រីនានាក្នុងសាលាស្រុក មន្ត្រីនៃការិយាល័យជំនាញជុំវិញស្រុក ក្នុងករណីដែលសំណើ និងពាក្យបណ្តឹងតវ៉ានេះ

មិនអាចសម្របសម្រួលដោះស្រាយបាន ដោយការព្រមព្រៀងគ្នារវាងមន្ត្រីរាជការដែលមានបញ្ហានោះជាមួយប្រធានអង្គភាពរបស់ខ្លួនឬមិនអាចដោះស្រាយបានបន្ទាប់ពីមានអន្តរាគមន៍របស់អភិបាលរងស្រុក ដែលទទួលបន្ទុកការងារនោះ ។

- ក្នុងនាមអភិបាលខេត្ត អភិបាលស្រុកត្រូវផ្តល់ការគាំទ្រ និងត្រួតពិនិត្យនីត្យានុកូលភាព នៃការបំពេញការងាររបស់ក្រុមប្រឹក្សាឃុំទាំងអស់ក្នុងស្រុករបស់ខ្លួន ។
- ចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុក និងធ្វើជាអធិបតីនៃកិច្ចប្រជុំនេះ ។
- ធ្វើសំណើតែងតាំង ផ្លាស់ប្តូរភារកិច្ច តម្លើងថ្នាក់ ឋានន្តរសក្តិ ដាក់វិន័យដល់មន្ត្រីរដ្ឋបាលស៊ីវិលនៃការិយាល័យនានា ចំណុះសាលាស្រុក ។
- ការផ្តល់យោបល់ឯកភាពជាមុនលើការតែងតាំង ការវាយតំលៃ ការផ្លាស់ប្តូរ និងការតំលើងថ្នាក់ ឋានន្តរសក្តិរបស់មន្ត្រីនៃការិយាល័យជំនាញជុំវិញស្រុក ។
- រៀបចំគំរោងថវិការបស់ស្រុក ស្របតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ជាប្រធានគណៈបញ្ជាការឯកភាពស្រុកស្របតាមការកំណត់របស់រាជរដ្ឋាភិបាល ។
- ធានាអោយមានការផ្សព្វផ្សាយនូវព័ត៌មាននានារបស់រដ្ឋបាលស្រុក ដែលមានការពាក់ព័ន្ធជាមួយប្រជាពលរដ្ឋ សហគ្រាស ធុរៈជន សង្គមស៊ីវិល និងសាធារណជនក្នុងស្រុករបស់ខ្លួន អោយបានទៀងទាត់ និង ទាន់ពេលវេលា ។
- ធានាអោយមានការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក អោយបានទៀងទាត់អំពីកិច្ចការរដ្ឋបាលរវាងថ្នាក់ស្រុក និង ខេត្ត ។
- ត្រូវធានាធ្វើសេចក្តីរាយការណ៍ អោយបានទៀងទាត់ តាមកាលកំណត់ជូនអភិបាលខេត្តសាមី ។

**ប្រការ៨.-**

អភិបាលរងស្រុកមានតួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវ ដូចខាងក្រោម :

ក/. <u>តួនាទី</u>

- ជាជំនួយការអោយអភិបាលស្រុកក្នុងការដឹកនាំនិងសម្របសម្រួលគ្រប់សមត្ថកិច្ចរបស់រដ្ឋបាលស្រុក ។

ខ/. <u>សិទ្ធិអំណាច</u>

- ជំនួសអភិបាលស្រុក ក្នុងករណីអភិបាលស្រុកអវត្តមាន តាមលិខិតប្រគល់សិទ្ធិ

ជំនួសជាលាយល័ក្ខណ៍អក្សរពីអភិបាលស្រុក ។

- ក្នុងករណីអភិបាលស្រុកអវត្តមានដោយមានជំងឺ ឬ ដោយគ្រោះថ្នាក់ ឬ ដោយមូលហេតុផ្សេងដែលមិនអាចធ្វើលិខិតប្រគល់សិទ្ធិជំនួសបាន អភិបាលខេត្ត ត្រូវចេញដីកាប្រគល់ភារកិច្ច អោយអភិបាលរងស្រុកមួយរូបជំនួស ។
- មានសិទ្ធិចុះហត្ថលេខាលើឯកសារ លិខិតស្នាមនានារបស់រដ្ឋបាលស្រុក ក្នុងនាមអភិបាលស្រុក បន្ទាប់ពីមានការប្រគល់សិទ្ធិជាលាយល័ក្ខណ៍អក្សរ ឬ ការពិគ្រោះពិភាក្សាឯកភាពច្បាស់លាស់ជាមុន ពីអភិបាលស្រុក ។

គ/. ការទទួលខុសត្រូវ

- ទទួលខុសត្រូវចំពោះអភិបាលស្រុកនូវតួនាទីភារកិច្ច ដែលបែងចែកប្រគល់អោយអនុវត្ត។
- បំពេញការងារក្រោមការចាត់ចែង និងការប្រគល់ភារកិច្ចរបស់អភិបាលស្រុក ។

**ប្រការ៩.-**

អភិបាលរងស្រុក ត្រូវបែងចែកការទទួលខុសត្រូវដូចខាងក្រោម ÷

- អភិបាលរងស្រុកមួយរូបទទួលខុសត្រូវការិយាល័យច្រកចេញចូលតែមួយ ។
- អភិបាលរងស្រុកមួយរូប ទទួលខុសត្រូវការិយាល័យអភិវឌ្ឍន៍ទេសចរណ៍ វប្បធម៌ អប់រំ កីឡា និង សាសនា និង ការិយាល័យលើកកំពស់សុខុមាលភាព កិច្ចការសង្គម និង ភ្ជាប់ទំនាក់ទំនងការងារ ។
- អភិបាលរងស្រុកមួយរូបទទួលបន្ទុកការិយាល័យសវនកម្មផ្ទៃក្នុង ការិយាល័យផែនការ និងវិនិយោគស្រុក ក្នុងគោលដៅ អភិវឌ្ឍតំបន់ទីប្រជុំជនក្នុងស្រុក ។

  ក្រៅពីភារកិច្ច និង ការទទួលខុសត្រូវខាងលើនេះ អភិបាលស្រុកអាចធ្វើការប្រគល់ភារកិច្ចបន្ថែមដល់អភិបាលរងស្រុកតាមការចាំបាច់ ។

**ប្រការ១០.-**

អភិបាលស្រុកត្រូវចេញដីកាប្រគល់ភារកិច្ចដល់អភិបាលរងនីមួយៗ នៃស្រុករបស់ខ្លួនអោយបានសមស្របតាមការបែងចែកការទទួលខុសត្រូវ ដូចមានចែងក្នុងប្រការ ៨ និង ប្រការ ៩ នៃប្រកាសនេះ ។

**ប្រការ១១.-**

អភិបាល អភិបាលរងស្រុក និង ប្រធានមន្ទីរស្រុក ត្រូវកំណត់របបប្រជុំរៀងរាល់សប្តាហ៍

ដើម្បីផ្លាស់ប្តូរពត៌មាន សភាពការណ៍ វាយតំលៃការងារនិងដាក់ចេញផែនការសំរាប់អនុវត្តបន្ត ។

កិច្ចប្រជុំនេះមានឈ្មោះថា “ កិច្ចប្រជុំរដ្ឋបាលទូទៅរបស់ស្រុក ” ។

កិច្ចប្រជុំរដ្ឋបាលទូទៅរបស់ស្រុក មានគោលបំណងធ្វើការពិភាក្សាអំពីបញ្ហានានាដែលប៉ះពាល់ដល់ការិយាល័យក្នុងស្រុកដើម្បីរៀបចំគោលការណ៍ វិធានការនានាការប្រគល់ភារកិច្ច និងការទទួលខុសត្រូវ ព្រមទាំងទំនាក់ទំនងរវាងស្រុកជាមួយសាធារណៈជន សំដៅកែលំអការគ្រប់គ្រងផ្ទៃក្នុង អោយបានកាន់តែប្រសើរឡើង ។

រាល់កិច្ចប្រជុំរដ្ឋបាលទូទៅរបស់ស្រុក ត្រូវមានកំណត់ហេតុដែលរៀបចំដោយប្រធានមន្ទីរស្រុក ។

## ជំពូកទី ៣
## សាលាស្រុក

**ប្រការ១២.-**

សាលាស្រុកជាមណ្ឌលចាត់ការទូទៅរបស់ស្រុក ។

សាលាស្រុកត្រូវមានអាស័យដ្ឋានច្បាស់លាស់ និង មានទីតាំងសមស្របដែលបង្កភាព ងាយស្រួលសំរាប់ទំនាក់ទំនងការងារពីគ្រប់មូលដ្ឋាន ។

សាលាស្រុកមានមន្ទីរស្រុក និង ការិយាល័យក្រោមមន្ទីរស្រុក ។

**ប្រការ១៣.-**

មន្ទីរស្រុកជាអង្គភាពកណ្តាលទទួលបន្ទុកផ្ទៃក្នុង និង ជាអង្គភាពមួយសំរាប់សម្របសម្រួលការងារក្នុងរដ្ឋបាលស្រុក ។

**ប្រការ១៤.-**

មន្ទីរស្រុក ត្រូវស្ថិតក្រោមការណែនាំដោយផ្ទាល់របស់អភិបាលស្រុក និង ទទួលខុសត្រូវដឹកនាំដោយប្រធានមន្ទីរមួយរូប អមដោយអនុប្រធានមន្ទីរមួយរូបជាជំនួយការ ។

**ប្រការ១៥.-**

មន្ទីរស្រុកមានការិយាល័យចំនុះចំនួន ៣ គឺ ៖

- ការិយាល័យបុគ្គលិក
- ការិយាល័យហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ
- ការិយាល័យរដ្ឋបាលទូទៅ និងលទ្ធកម្ម

ប្រការ១៦.-

ការិយាល័យនានាចំណុះមន្ទីរស្រុក ត្រូវបំពេញតួនាទីធ្វើជាជំនួយការអភិបាលស្រុក ។

ភារកិច្ចជាក់ស្តែងរបស់ការិយាល័យនីមួយៗ ចំណុះមន្ទីរស្រុកមានដូចខាងក្រោម ÷

១. ការិយាល័យបុគ្គលិក មានភារកិច្ច

- រៀបចំនិងរក្សាសំនុំឯកសារផ្ទាល់ខ្លួនរបស់មន្ត្រីរាជការក្នុងរដ្ឋបាលស្រុក ។
- រៀបចំសំណើ វាយតំលៃ តែងតាំង ផ្លាស់ប្តូរភារកិច្ច តំលើងឋានន្តរសក្តិ ថ្នាក់ និង ដាក់វិន័យដល់មន្ត្រីរដ្ឋបាលស៊ីវិល ។
- បកស្រាយ ពន្យល់ និង វាយតំលៃអំពីតួនាទីភារកិច្ចរបស់ការិយាល័យអង្គភាពនីមួយៗ សំរាប់រៀបចំមន្ត្រីរាជការ ។
- ផ្តួចផ្តើមរៀបចំ ចាត់ចែងផែនការបណ្តុះបណ្តាល និងកសាងសមត្ថភាពដល់មន្ត្រីរាជការនៅក្នុងស្រុក ។
- រៀបចំកែលំអបទបញ្ជាផ្ទៃក្នុងជាទូទៅ និងពេលវេលាបំពេញការងារនៅតាមការិយាល័យ អង្គភាពនានា ក្នុងរដ្ឋបាលស្រុក ។
- រៀបចំបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ លិខិតបញ្ជាបេសកកម្ម ច្បាប់ឈប់សំរាក ការផ្លាស់ប្តូរមន្ត្រីរាជការ និង គណនាប្រាក់បេសកកម្មរបស់មន្ត្រីរាជការ តាមការកំណត់ ។

២. ការិយាល័យហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ មានភារកិច្ច

- រៀបចំគំរោងថវិកាស្រុក ស្របតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- ពិនិត្យចំណូល ចំណាយរបស់ស្រុក ។
- រៀបចំសេចក្តីរាយការណ៍ហិរញ្ញវត្ថុតាមកាលកំណត់ ដើម្បីដាក់ជូនអភិបាលរងស្រុកទទួលបន្ទុក និង អភិបាលស្រុកពិនិត្យសំរេច ។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ ដែលបានផ្ទេរអោយស្រុក និងចាត់វិធានការថែទាំ និងប្រើប្រាស់ចលនទ្រព្យ អចលនទ្រព្យទាំងនោះអោយបានល្អស្របតាមលិខិតបទដ្ឋានកំណត់ និងតាមអនុសាសន៍របស់ក្រុមប្រឹក្សាស្រុកព្រមទាំងការណែនាំរបស់អភិបាលស្រុក ។
- គ្រប់គ្រងសាច់ប្រាក់ និងគណនីនានារបស់រដ្ឋបាលស្រុក ។

- ចុះបញ្ជីឯទទួលប្រ[illegible]
  ស្រុក ។
- បើកប្រាក់ជូនមន្ត្រីរាជការ បគ្គលិកក្នុងរដ្ឋបាលស្រុក ។
- ទូទាត់ប្រាក់តាមវិក័យប័ត្រ ចំណាយក្នុងរដ្ឋបាលស្រុកស្របតាមនីតិវិធីដែលបានកំណត់ ។
- ចាត់អោយមានភ្នាក់ងារទទួលកំរៃ ដែលទទួលបានពីសេវាច្រកចេញចូលតែមួយ។
- ធ្វើសេចក្តីរាយការណ៍អំពីសាច់ប្រាក់ប្រចាំសប្តាហ៍ ប្រចាំខែឬតាមការតំរូវរបស់អភិបាលស្រុក ។

៣. ការិយាល័យរដ្ឋបាលទូទៅ និងលទ្ធកម្ម មានភារកិច្ច

- ទទួលលិខិតចូល ចេញ លេខហារី វិទ្យុទាក់ទង ទូរស័ព្ទ ទូរសារ ....។
- គ្រប់គ្រងត្រា តំកល់ឯកសារ ពិធីការ ។
- រក្សាការពារសន្តិសុខសណ្តាប់ធ្នាប់ សោភ័ណភាពអនាម័យក្នុងសាលាស្រុក។
- រៀបចំលក្ខ័ខ័ណ្ឌ និងក្របខ័ណ្ឌការងារ ដើម្បីធានា អោយកិច្ចការតាមការិយាល័យ អង្គភាពនានាក្នុងរដ្ឋបាលស្រុក ដំណើរការស៊ីសង្វាក់គ្នាមានភាពរលូន និង មានប្រសិទ្ធភាព ។
- ផ្តួចផ្តើមលើកសំណើជូនអភិបាល អភិបាលរងស្រុកសំរេចអំពីការរៀបចំកន្លែងធ្វើការ បរិក្ខារសំភារៈជូនអង្គភាពនិងការិយាល័យនានាក្នុងរដ្ឋបាលស្រុកអោយបានសមស្រប តាមភារកិច្ចទទួលខុសត្រូវរបស់ អង្គភាព និងការិយាល័យទាំងនោះ។
- ថែរក្សានិងជួសជុលអាគារ ចលនទ្រព្យ អចលនទ្រព្យ ។
- ធ្វើបញ្ជីសារពើភ័ណ្ឌអាគារ ចលនទ្រព្យ អចលនទ្រព្យតាមកាលកំណត់ ។
- អនុវត្តការងារលទ្ធកម្ម និងចែកចាយសំភារៈការិយាល័យ និងសំភារៈឧបករណ៍ផ្សេងៗដល់អង្គភាព និង ការិយាល័យនានាក្នុងរដ្ឋបាលស្រុកតាមការកំណត់ ។
- ផ្គត់ផ្គង់អគ្គិសនី ទឹក ដល់អង្គភាព ការិយាល័យនានាក្នុងរដ្ឋបាលស្រុក ។
- ថែរក្សា និង ចម្លងឯកសារអត្រានុកូលដ្ឋានគ្រប់ប្រភេទ ។

ប្រការ១៧.-

ការិយាល័យក្រោមន្ទីរស្រុក ត្រូវបានកំណត់ភារកិច្ចដូចខាងក្រោម ÷

១.ក្រុមជំនួយការ

ក-សមាសភាព និង ភារកិច្ចរួមរបស់ក្រុមជំនួយការ

អភិបាលស្រុកមានសិទ្ធិស្នើសុំមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃតាមរយៈអភិបាលខេត្ត នូវការតែងតាំងជំនួយការចំនួន ២រូប និងលេខា ១រូបដែលមានភារកិច្ចដូចខាងក្រោម ÷

១-ផ្សព្វផ្សាយពត៌មានអំពីរដ្ឋបាលស្រុក ដែលមានការពាក់ព័ន្ធនឹងប្រជាពលរដ្ឋ និង សហគ្រាសនានាក្នុងស្រុក ។

២-រៀបចំចងក្រងបោះពុម្ពផ្សាយនូវព្រឹត្តប័ត្រពត៌មាន កូនសៀវភៅតូចៗ និងខិត-ប័ណ្ណផ្សេងៗសំរាប់ជាពត៌មានស្តីពីរចនាសម្ព័ន្ធ និងសេវាដែលផ្តល់ដោយរដ្ឋបាល-ស្រុក ព្រមទាំងចាត់ចែងផ្សព្វផ្សាយជូនសាធារណជន ។

៣-ជួយដល់អភិបាលស្រុកក្នុងការធ្វើសេចក្តីរាយការណ៍ជូនអង្គប្រជុំប្រចាំខែ ឬអង្គ-ប្រជុំណាមួយរបស់ស្រុក និង ក្រុមប្រឹក្សាស្រុក ។

ខ-ជំនួយការទី១ ទទួលបន្ទុកទំនាក់ទំនងជាមួយខេត្តនិងការិយាល័យជុំវិញស្រុក មានភារកិច្ច ÷

-សម្របសម្រួលនិងជួយអភិបាល អភិបាលរងស្រុកក្នុងការប្រាស្រ័យទាក់ទងតាមរយៈលិខិតស្នាម ទូរសារ និង ប្រព័ន្ធពត៌មានវិទ្យា ឬទូរស័ព្ទ ក្នុងនាមអភិបាល អភិបាលរងស្រុក ជាមួយអភិបាល អភិបាលរងខេត្ត មន្ទីរនានា ការិយាល័យ-ជំនាញនានា អង្គភាពនានានៅថ្នាក់ខេត្ត និងអង្គភាពនានារនៅថ្នាក់ស្រុក ។

-រៀបចំសេចក្តីរាយការណ៍របស់រដ្ឋបាលស្រុកតាមកាលកំណត់នឹងអាចរាយកាណ៍អំពីសកម្មភាពសំខាន់ៗរបស់ស្រុក តាមការអនុញ្ញាតពីអភិបាលខេត្ត ឬប្រធានមន្ទីរនិងអង្គភាពជំនាញជុំវិញខេត្ត ។

-ផ្តល់ពត៌មានអំពីថ្នាក់ខេត្តដល់អង្គភាព ការិយាល័យជំនាញនានានៅក្នុងរដ្ឋបាលស្រុក

គ-ជំនួយការទី២ ទទួលបន្ទុកទំនាក់ទំនងជាមួយក្រុមប្រឹក្សាស្រុកនិងជាមួយប្រជាពលរដ្ឋ មានភារកិច្ច ÷

-រៀបចំទុកដាក់ឯកសារផ្តល់យោបល់របស់ក្រុមប្រឹក្សាស្រុកជូនអភិបាលស្រុក

-រៀបចំធ្វើសេចក្តីរាយការណ៍សកម្មភាពរបស់ការិយាល័យប្រជាពលរដ្ឋជូនអភិបាល-ស្រុក ។

-ទទួលនិងបញ្ជូនសំណុំរឿងដែលភ្ជាប់ជាមួយនូវអនុសាសន៍ និងការសំរេចចិត្តរបស់ការិយាល័យប្រជាពលរដ្ឋ ជូនអភិបាលខេត្ត ។

-រៀបចំកម្មវិធីសំរាប់អភិបាល អភិបាលរងស្រុកបំពេញការងារសាធារណៈនិងផ្សព្វ-ផ្សាយកម្មវិធីនេះដល់សាធារណជន ។

ឃ-លេខាធិការមួយរូប ទទួលបន្ទុកការងារពិធីការ

-ទទួល និងពិនិត្យលិខិតព្រមទាំងឯកសារគ្រប់ប្រភេទដែលបានផ្ញើមកអភិបាលស្រុក

-ពិភាក្សាជាមួយអភិបាលស្រុកអំពីលិខិត និងឯកសារដែលបានទទួល ។

-ជួយពិនិត្យឡើងវិញនូវលិខិតនិងសំណុំឯកសារទាំងអស់របស់ស្រុក មុននឹងឯកសារទាំងអស់នោះផ្ញើចេញ ដើម្បីធានាអោយលិខិតទាំងអស់របស់ស្រុក ឬឯកសារទាំងអស់នោះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-ការិយាល័យច្រកចេញ-ចូលតែមួយ ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យនេះនឹងត្រូវកំណត់ ដោយប្រកាសដោយឡែករបស់ក្រសួងមហាផ្ទៃ ។

៣-ការិយាល័យអភិវឌ្ឍន៍ទេសចរណ៍ វប្បធម៌ អប់រំ កីឡា និងសាសនា

-សំរបសំរួលការអភិវឌ្ឍន៍ទេសចរណ៍ វប្បធម៌ អប់រំ កីឡា និងសាសនារបស់ស្រុកអោយស៊ីសង្វាក់ និងមានភាពរលូនជាមួយផែនការអភិវឌ្ឍន៍របស់ស្រុក និងខេត្ត និងបណ្តាស្រុក ដែលមានព្រំប្រទល់ជាប់ជាមួយ ។

-សំរបសំរួល និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ និងអ្នកប្រើប្រាស់សេវាទាំងអស់ ក្នុងការទទួលបានសេវាដែលពាក់ព័ន្ធវិស័យទេសចរណ៍ វប្បធម៌ អប់រំ កីឡា និងសាសនា នៅក្នុងដែនដីរបស់ស្រុកផ្ទាល់ ។

-ពិនិត្យ និង វាយតំលៃការអនុវត្តន៍ការងាររបស់ការិយាល័យជំនាញតាមវិស័យដូចកំណត់ខាងលើ ជូនថ្នាក់ដឹកនាំស្រុក ។

៤-ការិយាល័យលើកកំពស់សុខុមាលភាព កិច្ចការសង្គម និងភ្ជាប់ទំនាក់ទំនងការងារ :

-ជំរុញ សំរបសំរួល និងសំរួលសមត្ថកិច្ចជំនាញ ខាងវិស័យសុខាភិបាលដើម្បីអនុវត្តគោលនយោបាយសុខាភិបាលបានប្រសើរ ។

-ជំរុញនិងសំរបសំរួលការសហការរបស់អ្នកពាក់ព័ន្ធក្នុងមូលដ្ឋានស្រុកដូចជា៖ អង្គភាពជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ដើម្បីបង្កើតមណ្ឌលបណ្តុះ-បណ្តាលអប់រំវិជ្ជាជីវៈ តាមមូលដ្ឋាន តាមលទ្ធភាព និងមានរយៈពេលសមស្របតាមកំណត់របស់ក្រសួងមានសមត្ថកិច្ច ។

-សំរបសំរួល និងភ្ជាប់ទំនាក់ទំនងជាមួ[illegible]

គ្រោសជាមួយប្រជាពលរដ្ឋដែលស្វែងរកការងារ ។

-តាមដានត្រួតពិនិត្យការអនុវត្តន៍ការងាររបស់ការិយាល័យជំនាញជុំវិញស្រុកដែលពាក់ព័ន្ធនឹងវិស័យសុខុមាលភាព កិច្ចការសង្គម និងភ្ជាប់ទំនាក់ទំនងការងារ ។

៥.ការិយាល័យសវនកម្មផ្ទៃក្នុង មានភារកិច្ចដូចខាងក្រោម :

-ត្រួតពិនិត្យរាល់សកម្មភាព ផ្នែកហិរញ្ញវត្ថុនៃរដ្ឋបាលស្រុក ។

-ធ្វើការត្រួតពិនិត្យដោយមិនបានជូនដំណឹងជាមុន ស្របតាមពេលវេលាដែលព្រមព្រៀងគ្នា ដោយអភិបាលស្រុក និងអភិបាលរងស្រុក ឬ តាមការចាំបាច់ដែលកំណត់ដោយអភិបាលស្រុក ទៅលើបេឡារបស់ស្រុក ចំណូល ចំណាយចំណាយរបស់ស្រុក ការចុះបញ្ជី ការចំណាយ សកម្មភាព និង កិច្ចសន្យារបស់ផ្នែកហិរញ្ញវត្ថុ ថវិការបស់ស្រុក ការគ្រប់គ្រងថែរក្សា ការប្រើប្រាស់ចលនវត្ថុ និងការងារក្នុងការិយាល័យរដ្ឋបាលទូទៅ និង លទ្ធកម្មនៃមន្ទីរស្រុក ព្រមទាំងពិនិត្យមើលការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងសន្សំសំចៃ ធនធាន ថវិកា និងសំភារៈឧបករណ៍ ដែលមានក្នុងអង្គភាពការិយាល័យនានានៃរដ្ឋបាលស្រុក ។

-រៀបចំកំណត់ហេតុ និងសេចក្តីរាយការណ៍រៀងរាល់លើកនៃការត្រួតពិនិត្យទាំងនេះ។

៦-ការិយាល័យផែនការ និង វិនិយោគស្រុក

-រៀបចំផែនការអភិវឌ្ឍន៍រួមរបស់ស្រុក ដោយបញ្ចូលនូវផែនការតាមវិស័យនានានិងធានាអោយផែនការនេះស៊ីសង្វាក់គ្នានឹងផែនការខេត្តនិងផែនការជាតិ ។

-សំរបសំរួលការិយាល័យពាក់ព័ន្ធទាំងអស់ អោយអនុវត្តការងាររបស់ខ្លួនបានតាមផែនការ ។

-សំរបសំរួល និងបង្កគ្រប់លក្ខណៈសម្បត្តិស្របតាមច្បាប់ និងបទប្បញ្ញត្តិនានាដល់វិនិយោគិន ពាណិជ្ជករ អាជីវករ ដែលមានបំណងប្រកបមុខរបរ និងអ្នកដែលកំពុងប្រកបមុខរបរក្នុងដែនដីរបស់ខ្លួន ។

-តាមដានការអនុវត្តន៍ច្បាប់ បទបញ្ជា សេចក្តីសំរេចនានា និងលិខិតបទដ្ឋានក្នុងវិស័យរបស់ការិយាល័យជំនាញជុំវិញស្រុក ។

-តាមដាន និងត្រួតពិនិត្យជាប្រចាំនូវភាពត្រឹមត្រូវតាមច្បាប់រាល់ដំណើរការនិងសកម្មភាពនានារបស់ក្រុមប្រឹក្សាឃុំ និង រដ្ឋបាលឃុំក្នុងស្រុករបស់ខ្លួន ។

-ធ្វើការឆ្លើយតបចំពោះសំនួរ និងសំណើនានារបស់មេឃុំឬក្រុមប្រឹក្សាឃុំពាក់ព័ន្ធដល់ការអនុវត្តមុខងារ ភារកិច្ច តាមគោលនយោបាយវិមជ្ឈការ ។

-ផ្តល់ការគាំទ្រ និងការបណ្តុះបណ្តាលកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ និងមន្ត្រីភ្នាក់ងាររដ្ឋបាលឃុំ និង អ្នកដែលពាក់ព័ន្ធនានាក្នុងស្រុក ។

-សំរុះសំរួលដោះស្រាយទំនាស់ក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំ រវាងឃុំនិងឃុំដែលមានព្រំប្រទល់ជាប់គ្នា រវាងឃុំជាមួយស្រុកនិងរវាងឃុំជាមួយខេត្ត ។

-សំរបសំរួលផែនការអភិវឌ្ឍឃុំជាមួយស្រុក ការធ្វើសមាហរណកម្មផែនការឃុំនៅថ្នាក់ស្រុក សំរបសំរួលរាល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសេវាអប់រំ និងសុខភាពតាមឃុំនានាក្នុងស្រុក ។

-ក្នុងការអនុវត្តភារកិច្ចដែលទាក់ទងដល់ឃុំ ដូចបានចែងខាងលើត្រូវផ្អែកលើគោល-នយោបាយវិមជ្ឈការ ច្បាប់ និងលិខិតបទដ្ឋាននានាដែលសំរេចដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**ប្រការ១៨.-**

ក្រៅពីភារកិច្ច ដែលបានកំណត់សំរាប់ការិយាល័យនានា ដូចមានចែងក្នុងប្រការ១៦ និងប្រការ១៧ នៃ ប្រកាសនេះ ការិយាល័យទាំងនោះ អាចទទួលភារកិច្ចបន្ថែមទៀត តាមការចាំបាច់ដែលប្រគល់ឱ្យដោយដីការបស់អភិបាលស្រុក ។

## ជំពូកទី ៤
## ការិយាល័យជំនាញនានាជុំវិញស្រុក

**ប្រការ១៩.-**

ការិយាល័យជំនាញនានាជុំវិញស្រុក គឺ ជាអង្គភាពខ្សែបណ្តោយរបស់ក្រសួងស្ថាប័ននានានៅថ្នាក់ជាតិ ត្រូវបានរៀបចំឡើងស្របតាមការកំណត់របស់ក្រសួងស្ថាប័ននីមួយៗ ។

នៅថ្នាក់ស្រុក ការិយាល័យជំនាញទាំងនេះ គឺជាផ្នែកមួយនៃរដ្ឋបាលស្រុក ត្រូវស្ថិតក្រោមការគ្រប់គ្រងផ្នែកគោលនយោបាយ និង រដ្ឋបាលរបស់អភិបាលស្រុក និងអភិបាលរងស្រុកទទួលបន្ទុក ។

ការិយាល័យជំនាញទាំងនេះមានភារកិច្ចធ្វើជាជំនួយការឱ្យ អភិបាល អភិបាលរងក្នុងវិស័យជំនាញរបស់ខ្លួន ដើម្បីចូលរួមក្នុងការចាត់ចែងកិច្ចការជាទូទៅ និង ការអភិវឌ្ឍន៍ស្រុក ។

ប្រការ២០.-

ក្នុងការអនុវត្តការងារ ការិយាល័យជំនាញជុំវិញស្រុកត្រូវផ្អែកលើច្បាប់ លិខិតបទដ្ឋាន គោលការណ៍ណែនាំរបស់ក្រសួង ស្ថាប័នសាមី និង មន្ទីរជំនាញ ដែលជាខ្សែបណ្តោយរបស់ខ្លួននៅថ្នាក់ខេត្ត ។

ក្នុងការអនុវត្តការងារ មន្ត្រីជំនាញ ដែលជាខ្សែបណ្តោយនៅថ្នាក់ខេត្ត អាចធ្វើការប្រគល់ភារកិច្ចតាមការជាក់ស្តែងក្នុងរង្វង់សមត្ថកិច្ច សិទ្ធិអំណាចរបស់ការិយាល័យជំនាញរបស់ខ្លួន ហើយត្រូវធ្វើសេចក្តីរាយការណ៍ជូនអភិបាលស្រុក ។

ក្នុងការចាត់ចែងការងារ និងការប្រគល់ភារកិច្ចដល់ការិយាល័យជំនាញនៅថ្នាក់ស្រុក អភិបាលស្រុកត្រូវតែផ្អែកទៅលើច្បាប់ លិខិតបទដ្ឋាន និង គោលការណ៍ណែនាំរបស់ក្រសួងស្ថាប័ននានា នៅថ្នាក់ជាតិ ។

អភិបាលស្រុកត្រូវទទួលខុសត្រូវ តាមរយៈអភិបាលខេត្តនិងប្រធានមន្ទីរជំនាញជុំវិញខេត្តក្នុងការអនុវត្តគោលនយោបាយតាមវិស័យជំនាញនីមួយៗស្របតាមគោលនយោបាយរបស់ជាតិ ។

ប្រការ២១.-

ក្នុងរយៈពេលនៃការអនុវត្តគំរោងសាកល្បងនេះ មន្ត្រីរាជការដែលបំពេញការងារតាមការិយាល័យជំនាញនីមួយៗ ត្រូវស្ថិតក្នុងក្របខ័ណ្ឌរបស់ក្រសួងនីមួយៗ និង ត្រូវគ្រប់គ្រងតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល លក្ខន្តិកៈដោយឡែករបស់ក្រសួងស្ថាប័នសាមី ។

ប្រការ២២.-

ថវិកា មធ្យោបាយ សំភារៈ បំពេញការងាររបស់ការិយាល័យជំនាញនានានៅថ្នាក់ស្រុក គឺជា ថវិកា មធ្យោបាយ សំភារៈ ដែលផ្គត់ផ្គង់ដោយក្រសួងស្ថាប័ន និង មន្ទីរសាមី ។

ប្រការ២៣.-

អភិបាលស្រុក ត្រូវចាត់ឱ្យមានកិច្ចប្រជុំជាមួយការិយាល័យជំនាញទាំងអស់នៅក្នុងស្រុករបស់ខ្លួនយ៉ាងហោចឱ្យបានម្តងក្នុងមួយខែ មានឈ្មោះថា "កិច្ចប្រជុំសំរបសំរួល" ។

កិច្ចប្រជុំនេះចាំបាច់ត្រូវមានការចូលរួមពីអភិបាលរងស្រុក ប្រធាន ឬ អនុប្រធាន មន្ទីរស្រុកប្រធានការិយាល័យច្រកចេញចូលតែមួយ និង ប្រធានការិយាល័យប្រជាពលរដ្ឋ ។

គោលបំណងសំខាន់នៃកិច្ចប្រជុំនេះ គឺ ដើម្បីពិភាក្សាសំរបសំរួលអំពីផលប៉ះពាល់ នៃការអនុវត្តការងាររបស់ការិយាល័យជំនាញ ការពិនិត្យសមត្ថកិច្ច និងការសំរបសំរួលសមត្ថកិច្ចរវាងមន្ទីរជំនាញថ្នាក់ខេត្ត និង ការិយាល័យជំនាញថ្នាក់ស្រុក ។

រាល់កិច្ចប្រជុំខាងលើនេះត្រូវមានកំណត់ហេតុ ដែលរៀបចំដោយប្រធានមន្ទីរស្រុក ។

## ជំពូកទី ៥

## ក្រុមប្រឹក្សាស្រុក និង លេខាធិការដ្ឋាន

**ប្រការ២៤.-**

ក្រុមប្រឹក្សាស្រុកមានតួនាទីជួយឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងកិច្ចការសំខាន់ៗរបស់ស្រុក និង ផ្ដល់យោបល់ដល់អភិបាលស្រុកក្នុងការងារអភិវឌ្ឍន៍ស្រុក ។

ក្រុមប្រឹក្សាស្រុកជួយសំរបសំរួលការងាររបស់តំណាងដែលជាប់ឆ្នោតនៅក្នុងក្រុមប្រឹក្សាឃុំជាមួយ រដ្ឋបាលឃុំនានាក្នុងស្រុក និង សំរបសំរួលការងាររបស់សមាជិកក្រុមប្រឹក្សាឃុំ ជាមួយរដ្ឋបាលឃុំទាំងអស់ ក្នុងស្រុកទៅលើសកម្មភាព និង វិធានការនានា របស់រដ្ឋបាលស្រុក ។

**ប្រការ២៥.-**

ក្រុមប្រឹក្សាស្រុកមានអាណត្តិស្មើអាណត្តិរបស់ក្រុមប្រឹក្សាឃុំ ។

អាណត្តិក្រុមប្រឹក្សាស្រុកអាចនឹងត្រូវបញ្ចប់នៅក្នុងករណីណាមួយ ដូចខាងក្រោម ÷

- មានការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ។
- មានច្បាប់ លិខិតបទដ្ឋានថ្មី ចែងអំពីរដ្ឋបាលស្រុក ។

**ប្រការ២៦.-**

ក្រុមប្រឹក្សាស្រុកមានសមាសភាព ដូចខាងក្រោម ÷

| | |
|---|---|
| - អភិបាលស្រុក | ប្រធាន |
| - អភិបាលរងស្រុក០១រូបដែលចាត់តាំងដោយអភិបាលស្រុក | អនុប្រធាន |
| - អភិបាលរងស្រុក ០២ រូបទៀត | សមាជិក |
| - ប្រធានមន្ទីរស្រុក | សមាជិក |

- មេឃុំ ជំទប់ទី ១ និង ជំទប់ទី ២នៃឃុំទាំងអស់ចំណុះស្រុកជាសមាជិក។

ការងាររបស់ក្រុមប្រឹក្សាស្រុកជាការងារកិត្តិយសពុំមានប្រាក់កំរៃឡើយ ។

ក្នុងពេលប្រជុំក្រុមប្រឹក្សាស្រុក និង គណៈកម្មាធិការនៃក្រុមប្រឹក្សាស្រុកព្រមទាំងពេលបំពេញបេសកកម្ម សមាជិកក្រុមប្រឹក្សាស្រុក និង សមាជិកគណៈកម្មាធិការនៃក្រុមប្រឹក្សាស្រុកត្រូវទទួលបានប្រាក់កំរៃ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ២៧.-**

ក្រុមប្រឹក្សាស្រុកមានភារកិច្ចផ្ដល់យោបល់ដល់អភិបាលស្រុក ទៅលើកិច្ចការដូចខាងក្រោម÷

- ការធ្វើសមាហរណកម្មផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមទូទៅរបស់ឃុំនានាក្នុងស្រុកជាផែនការមួយរបស់ស្រុក និងពិនិត្យការអនុវត្តផែនការអភិវឌ្ឍន៍ស្រុក ។
- ការរៀបចំ និង កែសំរួលផែនការប្រើប្រាស់ដីធ្លី ក្នុងស្រុក ។
- ការរៀបចំអនុវត្ត និង កែសំរួលផែនការមេរបស់ស្រុក ។
- ការរៀបចំគំរោងថវិកាស្រុក និង ពិនិត្យការអនុត្តថវិកាស្រុក ។
- ការរួមយោបល់ក្នុងការជ្រើសរើសមន្ត្រីឱ្យបំពេញការងារ ក្នុងការិយាល័យប្រជាពលរដ្ឋ ។
- ការពិភាក្សា វាយតំលៃរបាយការណ៍ថវិកាប្រចាំឆ្នាំរបស់ស្រុកនិងរបាយការណ៍របស់ការិយាល័យសវនកម្មផ្ទៃក្នុង ទៅលើរបាយការណ៍ថវិកានេះ ។
- ការងារផ្សេងទៀត ដែលអភិបាលស្រុកយល់ឃើញថាចាំបាច់ត្រូវពិគ្រោះយោបល់ក្នុងក្រុមប្រឹក្សាស្រុក ។

**ប្រការ២៨.-**

ការផ្តល់យោបល់ដោយក្រុមប្រឹក្សាស្រុក លើកិច្ចការដូចមានចែងក្នុងប្រការ ២៧ នៃប្រកាសនេះ ត្រូវធ្វើឡើងដោយសេចក្តីសំរេចរបស់ក្រុមប្រឹក្សា ដែលមានលក្ខណៈជាអនុសាសន៍មិនមែនជាវិធានការចាំបាច់ ដែលត្រូវអនុវត្តឡើយ ។

**ប្រការ២៩.-**

ក្រុមប្រឹក្សាស្រុកត្រូវប្រជុំសាមញ្ញរៀងរាល់ត្រីមាសនៅក្នុងសប្តាហ៍ទី២ នៃខែទី៣ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ក្រុមប្រឹក្សាស្រុកត្រូវពិភាក្សា និង អនុម័តបទបញ្ជាផ្ទៃក្នុងតាមការណែនាំរបស់ក្រសួងមហាផ្ទៃ ។

កិច្ចប្រជុំក្រុមប្រឹក្សាស្រុកនៅត្រីមាសទី ៣ ត្រូវដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំនូវសេចក្តីព្រាងថវិកាស្រុកសំរាប់ឆ្នាំក្រោយ ។

កិច្ចប្រជុំក្រុមប្រឹក្សាស្រុក នៅត្រីមាសទី ២ ត្រូវដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ស្រុក និងរបាយការណ៍របស់ការិយាល័យសវនកម្មផ្ទៃក្នុង ។

ក្រុមប្រឹក្សាស្រុកអាចកោះប្រជុំជាវិសាមញ្ញបាន តាមសំណើរបស់ប្រធាន ឬ សមាជិកក្រុមប្រឹក្សាស្រុកចំនួន២០ភាគរយនៃចំនួនសមាជិកទាំងអស់ ។

រាល់កិច្ចប្រជុំក្រុមប្រឹក្សាស្រុកត្រូវមានកូរ៉ុមចំនួន៥០ភាគរយនៃចំនួនសមាជិកទាំងអស់ ។

**ប្រការ៣០.-**

រាល់កិច្ចប្រជុំក្រុមប្រឹក្សាស្រុកត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ ដែលចុះហត្ថលេខាដោយ

អធិបតីនៃអង្គប្រជុំ និងអ្នកកត់ត្រាកំណត់ហេតុ ។

សេចក្តីព្រាងកំណត់ហេតុប្រជុំនេះ ត្រូវបញ្ជូនទៅសមាជិកក្រុមប្រឹក្សាស្រុកដែលចូលរួមប្រជុំយ៉ាងយូរ០១សប្តាហ៍បន្ទាប់ពីកិច្ចប្រជុំ ដើម្បីពិនិត្យ និងផ្តល់យោបល់ ។

ក្នុងរយៈពេល០១សប្តាហ៍យ៉ាងយូរបន្ទាប់ពីបានប្រគល់កំណត់ហេតុនោះ ប្រសិនបើគ្មានការស្នើជាលាយល័ក្ខណ៍អក្សរ ដើម្បីកែសំរួលទេនោះ កំណត់ហេតុនោះត្រូវបានចាត់ទុកថាឯកភាព ។ ក្នុងករណីមានការកែសំរួល ឬ ការជំទាស់នោះជំរើសនេះត្រូវសំរេចក្នុងកិច្ចប្រជុំលើកក្រោយរបស់ក្រុមប្រឹក្សាស្រុក ។ ការសំរេចនេះ ត្រូវធ្វើឡើងដោយសំលេងភាគច្រើននៃសមាជិកក្រុមប្រឹក្សាបានចូលរួមក្នុងកិច្ចប្រជុំ ។

**ប្រការ៣១.-**

ប្រធានក្រុមប្រឹក្សាស្រុកជាអ្នកកោះអញ្ជើញ និង ធ្វើជាអធិបតីនៃកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញ របស់ក្រុមប្រឹក្សាស្រុក ។

ករណីប្រធានមានធុរៈមិនអាចកោះអញ្ជើញប្រជុំ និង ធ្វើជាអធិបតីនៃអង្គប្រជុំបានអនុប្រធានក្រុមប្រឹក្សាស្រុក ដោយមានជំនួយពីលេខាធិការដ្ឋានជាអ្នកកោះអញ្ជើញ និង ធ្វើជាអធិបតីនៃកិច្ចប្រជុំក្រុមប្រឹក្សាស្រុក ។

លិខិតអញ្ជើញចូលរួមប្រជុំត្រូវភ្ជាប់មកជាមួយនូវរបៀបវារៈប្រជុំ ឯកសារតាមប្រធានបទនីមួយៗនៃរបៀបវារៈប្រជុំ និង សេចក្តីព្រាងសេចក្តីសំរេចតាមប្រធានបទនីមួយៗ ព្រមទាំងកំណត់ហេតុប្រជុំលើកមុន ។

លិខិតអញ្ជើញចូលរួមប្រជុំ ព្រមទាំងសំណុំឯកសារសម្រាប់ការប្រជុំ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាស្រុកឱ្យបាន១៥ថ្ងៃ មុនកាលបរិច្ឆេទនៃកិច្ចប្រជុំ ។

របៀបវារៈនៃកិច្ចប្រជុំអាចនឹងបន្ថែមបានក្នុងករណីមានការស្នើសុំជាលាយល័ក្ខណ៍អក្សរដោយសមាជិកក្រុមប្រឹក្សាស្រុកយ៉ាងតិច០២រូប ហើយដែលបានទទួល ដោយលេខាធិការដ្ឋានយ៉ាងតិចប្រាំពីរ(៧)ថ្ងៃមុនពេលប្រជុំ ។

**ប្រការ៣២.-**

កិច្ចប្រជុំក្រុមប្រឹក្សាស្រុកត្រូវធ្វើឡើងជាសាធារណៈ ។

ប្រជាពលរដ្ឋអាចចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុកបាន ប៉ុន្តែគ្មានសិទ្ធិពិភាក្សានិងអនុម័តបញ្ហានានាក្នុងកិច្ចប្រជុំនេះឡើយ ហើយត្រូវគោរពបទបញ្ជានៃកិច្ចប្រជុំ ដែលកំណត់ដោយក្រុមប្រឹក្សាស្រុក។

លេខាធិការដ្ឋានត្រូវធានារៀបចំសម្របសម្រួល ដើម្បីធានាជូនប្រជាពលរដ្ឋ ដែលមានបំណងចូលរួមក្នុងអង្គប្រជុំ ឱ្យមានលទ្ធភាពស្មើៗគ្នា ដើម្បីបានចូលរួមក្នុងកិច្ចប្រជុំ និង ធានារៀបចំសណ្តាប់ធ្នាប់ក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា អោយបានល្អប្រសើរ ។

**ប្រការ៣៣.-**

កិច្ចប្រជុំក្រុមប្រឹក្សាស្រុកត្រូវដំណើរការតាមនីតិវិធី ដូចខាងក្រោម ÷

- ពិនិត្យកូរ៉ុម សំរាប់ការប្រជុំ ។
- ពិនិត្យការចែកចាយលិខិតអញ្ជើញចូលរួមប្រជុំ ដើម្បីធានាថា លិខិតអញ្ជើញប្រជុំ របៀបវារៈ និងសំណុំឯកសារនានា ត្រូវបានចាត់បញ្ជូនត្រឹមត្រូវគ្រប់គ្រាន់តាមពេលវេលាដល់សមាជិកក្រុមប្រឹក្សាស្រុក ។
- ក្នុងករណីមានសមាជិកមួយ ឬ ច្រើនរូប ចោទសួរអំពីភាពមិនត្រឹមត្រូវ នៃលិខិតអញ្ជើញខាងលើនេះ កិច្ចប្រជុំនឹងអាចដំណើរការទៅបាន លុះត្រាណាមានសមាជិក ដែលបានចូលរួមក្នុងកិច្ចប្រជុំយ៉ាងតិច៨០ភាគរយ បញ្ជាក់ថា លិខិតអញ្ជើញនោះ ពិតជាត្រឹមត្រូវតាមការកំណត់ហើយ ។
- ពិនិត្យរបៀបវារៈនៃកិច្ចប្រជុំ និងអនុម័តតាមលំដាប់លំដោយនូវប្រធានបទដែលបានចែងក្នុងរបៀបវារៈ ដោយសំលេងភាគច្រើននៃសមាជិកដែលបានចូលរួមប្រជុំ ។
- ពិភាក្សា និងអនុម័តជាបន្តបន្ទាប់នូវប្រធានបទ ដែលបានចែងក្នុងរបៀបវារៈនៃកិច្ចប្រជុំដោយសំលេងភាគច្រើននៃសមាជិក ដែលចូលរួមក្នុងអង្គប្រជុំ ។
- ប្រកាសជូនពត៌មានអំពីកាលបរិច្ឆេទជាក់លាក់នៃកិច្ចប្រជុំលើកក្រោយ ។

ក្នុងករណីចាំបាច់ អភិបាលស្រុក និងជាប្រធានក្រុមប្រឹក្សាស្រុកអាចកែប្រែកាលបរិច្ឆេទនៃកិច្ចប្រជុំលើកក្រោយនេះបាន ។

**ប្រការ៣៤.-**

ក្នុងពេលប្រជុំ សមាជិកក្រុមប្រឹក្សាស្រុកត្រូវគោរពឱ្យបាននូវបទបញ្ជាផ្ទៃក្នុង នៃអង្គប្រជុំ រក្សាឱ្យបាននូវសណ្តាប់ធ្នាប់ និង វិន័យអង្គប្រជុំ មិនត្រូវរំខាន និង មិនត្រូវប្រើពាក្យសំដីប្រមាថមើលងាយ ឬ ពាក្យអសុរស ទៅលើអ្នកដទៃឡើយ ។

សមាជិកក្រុមប្រឹក្សាស្រុកណាដែលបំពាន នឹងត្រូវព្រមានដោយអធិបតីនៃអង្គប្រជុំ ។

ក្នុងករណីមិនរាងចាល បន្ទាប់ពីបានព្រមានជាច្រើនដង អធិបតីអង្គប្រជុំអាចស្នើសុំឱ្យ បណ្តេញសមាជិកនោះ ចេញពីអង្គប្រជុំ ។

ប្រសិនបើសមាជិក ដែលបានចូលរួមប្រជុំផ្តល់សំលេង៦០ភាគរយ [illegible] ខាងលើនេះ សមាជិកដែលបំពាននោះ ត្រូវបណ្តេញចេញពីអង្គប្រជុំ ។

**ប្រការ៣៥.-**

លទ្ធផលនៃអង្គប្រជុំក្រុមប្រឹក្សាស្រុក និង ការសំរេចចិត្តនានានៃកិច្ចប្រជុំត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ តាមរយៈការបិទផ្សាយនៅការិយាល័យច្រកចេញ-ចូលតែមួយ និង តាមរយៈការប្រកាសផ្សាយរបស់ផ្នែកទទួល ប្រគល់ឯកសារ ផ្តល់ពត៌មាន និងជាមួយប្រជាពលរដ្ឋ ។

**ប្រការ៣៦.-**

ត្រូវបង្កើតឱ្យមានគណៈកម្មាធិការមួយរបស់ក្រុមប្រឹក្សាស្រុក ដើម្បីជួយក្រុមប្រឹក្សាស្រុកលើការរៀបចំផែនការ ។

គណៈកម្មាធិការនេះត្រូវយកអភិបាលរងស្រុកទទួលបន្ទុករៀបចំផែនការជាប្រធាន និងមានអនុប្រធាន ព្រមទាំងសមាជិក០៨រូបទៀត ដែលជ្រើសរើសចេញពីបេក្ខជនយ៉ាងតិច៣០រូប ជាមេឃុំ ជំទប់ និង សមាជិកក្រុមប្រឹក្សាឃុំក្នុងស្រុក ដោយយោងទៅតាមសមាមាត្រនៃគណបក្សនយោបាយ ដែលមានតំណាងនៅក្នុងក្រុមប្រឹក្សាឃុំ ។

គណៈកម្មាធិការផែនការស្រុក មានភារកិច្ចលើកយោបល់ជូនក្រុមប្រឹក្សាស្រុកអំពីការរៀបចំ និងអនុវត្តផែនការស្រុក ផែនការប្រើប្រាស់ដីធ្លីនិងផែនការមេរបស់ស្រុក ។

ក្រុមប្រឹក្សាស្រុក អាចនឹងបង្កើតគណៈកម្មាធិការផ្សេងទៀតបាន ក្នុងករណីមានការស្នើសុំពីសមាជិកក្រុមប្រឹក្សាស្រុក យ៉ាងតិចចំនួន៥០ភាគរយនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងអស់ ។

គណៈកម្មាធិការដែលបង្កើតបន្ថែមនោះ ត្រូវដឹកនាំដោយអភិបាលស្រុក ឬអភិបាលរងស្រុក ដែលទទួលខុសត្រូវតាមវិស័យការងារនីមួយៗក្នុងរដ្ឋបាលស្រុក ហើយអនុប្រធាន និង សមាជិក ត្រូវជ្រើសរើសតាមនីតិវិធី ដូចគណៈកម្មាធិការផែនការដែរ ។

**ប្រការ៣៧.-**

គណៈកម្មាធិការនៃក្រុមប្រឹក្សាស្រុកត្រូវធ្វើការកោះប្រជុំយ៉ាងតិច០១ខែម្តងដែលកោះអញ្ជើញដោយប្រធានគណៈកម្មាធិការ ។

លិខិតអញ្ជើញ ដែលភ្ជាប់ជាមួយនូវរបៀបវារៈនៃអង្គប្រជុំ ព្រមទាំងឯកសារនានា តាមប្រធានបទស្របតាមរបៀបវារៈនៃអង្គប្រជុំ ត្រូវផ្ញើឱ្យដល់សមាជិកគណៈកម្មាធិការយ៉ាងតិច ៣ថ្ងៃ មុនថ្ងៃប្រជុំ ។

សមាជិកនៃគណៈកម្មាធិការ អាចស្នើបន្ថែមប្រធានបទទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំបានក្នុងករណីដែលសមាជិកនោះបានធ្វើសំណើជាលាយល័ក្ខណ៍អក្សរ ហើយត្រូវបញ្ជូនសំណើនោះដល់

លេខាធិការដ្ឋាននៃក្រុមប្រឹក្សា យ៉ាងយឺតបំផុត០៤ថ្ងៃ មុនថ្ងៃប្រជុំ ។

**ប្រការ៣៨.-**

ប្រធានគណៈកម្មាធិការត្រូវធ្វើជាអធិបតីរាល់កិច្ចប្រជុំគណៈកម្មាធិការ ។

ក្នុងករណី ប្រធានអវត្តមាន អនុប្រធានគណៈកម្មាធិការត្រូវធ្វើជាអធិបតី នៃអង្គប្រជុំគណៈកម្មាធិការ ។

រាល់កិច្ចប្រជុំគណៈកម្មាធិការធ្វើឡើងជាសាធារណៈ និងមានលក្ខណៈបើកចំហ ។

ប្រជាពលរដ្ឋអាចចូលរួមស្តាប់រាល់កិច្ចប្រជុំរបស់គណៈកម្មាធិការ តែពុំមានសិទ្ធិធ្វើការពិភាក្សា និង ការអនុម័តឡើយ ហើយត្រូវរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយតាមការកំណត់របស់ក្រុមប្រឹក្សាស្រុក ។

របៀបរបប និង នីតិវិធីនៃការប្រជុំគណៈកម្មាធិការរបស់ក្រុមប្រឹក្សាស្រុក ត្រូវអនុវត្តដូចគ្នានឹងរបៀបរបប និង នីតិវិធីនៃការប្រជុំក្រុមប្រឹក្សាស្រុកដែរ ។

**ប្រការ៣៩.-**

ត្រូវបង្កើតឱ្យមានលេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្រុកដែលមានថ្នាក់ស្មើនឹងការិយាល័យនានានៃរដ្ឋបាលស្រុក ខណ្ឌ ។

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្រុកត្រូវដឹកនាំដោយប្រធាន(លេខាធិការ)០១រូប អមដោយអនុប្រធាន(លេខាធិការរង)០១រូបជាជំនួយការ និងមានបុគ្គលិកមួយចំនួន តាមការចាំបាច់ ។

ប្រធាន (លេខាធិការ) នៃលេខាធិការដ្ឋានមានឋានៈស្មើប្រធានការិយាល័យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលស្រុកដោយមានការឯកភាពពីអភិបាលខេត្ត ក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរសក្តិក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ។

អនុប្រធាន(លេខាធិការរង)នៃលេខាធិការដ្ឋាន មានឋានៈស្មើអនុប្រធានការិយាល័យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលស្រុក ដោយមានការឯកភាពពីអភិបាលខេត្ត ក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរសក្តិនាយលេខាធិការរដ្ឋបាលនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ។

បុគ្គលិកនៃលេខាធិការដ្ឋាន ត្រូវចាត់ឱ្យបំពេញការងារ ដោយដីការបស់អភិបាលខេត្ត តាមសំណើរបស់លេខាធិការនៃលេខាធិការដ្ឋាន ដោយមានការឯកភាពពីអភិបាលស្រុកក្នុងចំណោមមន្ត្រី ដែលស្ថិតនៅក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាល ។

ប្រការ៤០.-

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្រុកត្រូវស្ថិតក្រោមការដឹកនាំដោយផ្ទាល់របស់អភិបាលស្រុក និង មានតួនាទីភារកិច្ចដូចខាងក្រោម ÷

- រៀបចំលិខិតអញ្ជើញ និងចាត់ចែងផ្ញើលិខិតអញ្ជើញ ព្រមទាំងឯកសារនានា សំរាប់ការប្រជុំក្រុមប្រឹក្សាស្រុក និង គណៈកម្មាធិការនៃក្រុមប្រឹក្សាស្រុក ។

- ប្រធាន(លេខាធិការ) និងអនុប្រធាន (លេខាធិការរង) នៃលេខាធិការដ្ឋាន និងបុគ្គលិកតាមចំនួនចាំបាច់ត្រូវចូលរួមរាល់កិច្ចប្រជុំក្រុមប្រឹក្សាស្រុកនិងគណៈកម្មាធិការនៃក្រុមប្រឹក្សាស្រុក ។

- ជួយកត់ត្រានៃកិច្ចប្រជុំ ដើម្បីរៀបចំកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាស្រុក និង គណៈកម្មាធិការនៃក្រុមប្រឹក្សាស្រុក ។

- រក្សាទុកដាក់កំណត់ហេតុ សេចក្តីសំរេច និងឯកសារនានារបស់ក្រុមប្រឹក្សាស្រុក និង គណៈកម្មាធិការនៃក្រុមប្រឹក្សាស្រុក ។

- គិតគូរប្រោក់ឧបត្ថម្ភផ្សេងៗដល់ក្រុមប្រឹក្សាស្រុក និង គណៈកម្មាធិការនានានៃក្រុមប្រឹក្សាស្រុក ព្រមទាំងរៀបចំបែបបទសំរាប់បើកប្រាក់ឧបត្ថម្ភទាំងឡាយ ដល់ក្រុមប្រឹក្សាស្រុក និង គណៈកម្មាធិការនៃក្រុមប្រឹក្សាស្រុក ។

- សហការជាមួយការិយាល័យដែលពាក់ព័ន្ធក្នុងរដ្ឋបាលស្រុក និងបណ្តាញផ្សព្វផ្សាយនានា ដើម្បីធ្វើការជូនពត៌មានដល់ប្រជាពលរដ្ឋ អំពីការប្រជុំ លទ្ធផលនៃការប្រជុំ និងសេចក្តីសំរេចរបស់អង្គប្រជុំ ព្រមទាំងពត៌មានផ្សេងៗទៀតនៃក្រុមប្រឹក្សាស្រុក និងគណៈកម្មាធិការនានានៃក្រុមប្រឹក្សាស្រុក ។

## ជំពូក ទី ៦

## គណៈកម្មការខេត្តទទួលបន្ទុកការអនុវត្តគំរោងសាកល្បង

ប្រការ៤១.-

សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលបានសំរេចបង្កើតឱ្យមានគណៈកម្មការសម្របសម្រួលមួយនៅថ្នាក់ខេត្តឈ្មោះថា " គណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង " ដែលមានឈ្មោះជាអក្សរកាត់ " គអគ " ។

**ប្រការ៤២.-**

គណៈកម្មការខេត្តទទួលបន្ទុកអនុវត្តគំរោងសាកល្បង មានសមាសភាព ដូចតទៅ ÷

- អភិបាលខេត្តឬអភិបាលរងខេត្ត០១រូបដែលតែងតាំងដោយអភិបាលខេត្ត ជាប្រធាន
- តំណាង ១រូបមកពីក្រសួងមហាផ្ទៃ សមាជិក
- តំណាង ១រូបគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ សមាជិក
- តំណាង ១រូបក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល សមាជិក
- តំណាង ១រូបក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក
- តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តគំរោងសាកល្បង សមាជិក
- តំណាងមន្ទីរពាក់ព័ន្ធក្នុងការអនុវត្តគំរោងសាកល្បង សមាជិក

ដោយឡែកនៅខេត្តសៀមរាបត្រូវមានមន្ត្រីតំណាងមកពីអាជ្ញាធរអប្សរា០១រូបជាសមាជិក។

ប្រធានគណៈកម្មការនិងត្រូវធ្វើការពិភាក្សា ដើម្បីកំណត់សមាសភាពតំណាងក្រសួងស្ថាប័ន និងមន្ទីរពាក់ព័ន្ធគំរោងសាកល្បង តាមការចាំបាច់ ។

ផ្អែកតាមឈ្មោះមន្ត្រីដែលត្រូវបានចាត់បញ្ជូនឱ្យចូលរួមក្នុងគណៈកម្មការដោយក្រសួងស្ថាប័នពាក់ព័ន្ធខាងលើនេះ ប្រធានគណៈកម្មការត្រូវចេញសេចក្ដីសំរេច ស្ដីពីការទទួលស្គាល់សមាសភាពនៃ គណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង ។

អភិបាលស្រុកត្រូវបានអញ្ជើញឱ្យចូលរួមរាល់កិច្ចប្រជុំរបស់គណៈកម្មការ ។

ក្រៅពីនេះ ប្រធាន អាចស្នើអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតឱ្យចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការ តាមការចាំបាច់ ។

**ប្រការ៤៣.-**

គណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង ត្រូវមានការិយាល័យរបស់ខ្លួនក្នុងរដ្ឋបាលខេត្ត ។

ការិយាល័យគំរោងសាកល្បងនេះ គឺជាលេខាធិការដ្ឋានរបស់គណៈកម្មការ ។

ប្រធានការិយាល័យគំរោងសាកល្បង ជាលេខាធិការកត់ត្រារបស់គណៈកម្មការ ។

**ប្រការ៤៤.-**

គណៈកម្មការទទួលបន្ទុកអនុវត្តគំរោងសាកល្បង មានភារកិច្ចដូចខាងក្រោម ÷

- ត្រួតពិនិត្យមើលជាប្រចាំនូវគ្រប់សកម្មភាពជាជំហានៗ ដើម្បីឈានទៅសំរេចបាននូវគំរូរដ្ឋបាលថ្មីមួយនៅស្រុកនីមួយៗ សមស្របតាមលិខិតបទដ្ឋានដែលមាន ។

- ជួយអភិបាលស្រុក និង មន្ត្រីនៅរដ្ឋបាលស្រុក ព្រមទាំងសំរបសំរួលនូវគ្រប់សកម្មភាពរបស់រដ្ឋបាលថ្មីនេះ ជាមួយនឹងរដ្ឋបាលខេត្តនិងមន្ទីរជំនាញនៅថ្នាក់ខេត្ត ។

- ចូលរួមក្នុងការផ្តួចផ្តើម អោយមានការព្រមព្រៀងគ្នា ដែលនាំអោយមានការផ្សារភ្ជាប់ និងការប្រមូលផ្តុំគ្នានូវរាល់ការសំរេច និងសកម្មភាព រវាងមន្ទីរអង្គភាពនានានៅថ្នាក់ខេត្ត។

- ចូលរួមស្វែងរកនូវដំណោះស្រាយ និងការសម្រុះសម្រួលគ្នា ក្នុងករណីកើតមានឡើងនូវបញ្ហា និង ទំនាស់រវាងស្ថាប័នដែលពាក់ព័ន្ធនៅក្នុងការអនុវត្តគំរោងនេះ ទាំងនៅថ្នាក់ជាតិថ្នាក់ខេត្ត និង ថ្នាក់ស្រុក ។

- ចូលរួមក្នុងការផ្តល់យោបល់អំពីគោលការណ៍ផ្នែកច្បាប់ និង រដ្ឋបាលដែលត្រូវការចាំបាច់ សំរាប់អនុវត្តអោយបានសំរេចនូវគំរូរដ្ឋបាលថ្មីនេះ ។

- ចូលរួមនៅក្នុងការរៀបចំ និង សំរបសំរួលថវិកា ការបណ្តុះបណ្តាល និង ការកសាងសមត្ថភាព សំរាប់រដ្ឋបាលថ្មីនេះ ។

- ចូលរួមនៅក្នុងការវិភាគនិងវាយតំលៃជាជំហានៗនូវដំណើរការអនុវត្តគំរោងរៀបចំរដ្ឋបាលថ្មីនេះ ព្រមទាំងធ្វើរបាយការណ៍ឱ្យបានទៀងទាត់ ចំពោះកិច្ចការខាងលើនេះ ។

**ប្រការ៤៥.-**

គណៈកម្មការទទួលបន្ទុកអនុវត្តគំរោង ត្រូវប្រជុំជាសាមញ្ញមួយខែម្តង ។

ដោយមានជំនួយពីការិយាល័យរបស់គណៈកម្មការ ប្រធានគណៈកម្មការត្រូវធ្វើលិខិតអញ្ជើញប្រជុំ និងផ្ញើជូនសមាជិកគណៈកម្មការយ៉ាងតិច៥ថ្ងៃ មុនថ្ងៃប្រជុំ ។

ក្នុងករណីមានសំណើពីសមាជិកគណៈកម្មការយ៉ាងតិច០៣រូប ប្រធានគណៈកម្មការត្រូវធ្វើការកោះប្រជុំពិសេស ដើម្បីដោះស្រាយបញ្ហា តាមការចាំបាច់ ។

លិខិតអញ្ជើញប្រជុំពិសេសត្រូវផ្ញើដល់សមាជិកគណៈកម្មការយ៉ាងតិច៣ថ្ងៃ មុនថ្ងៃប្រជុំ។

លិខិតអញ្ជើញប្រជុំទាំងអស់ ត្រូវភ្ជាប់ជាមួយនូវរបៀបវារៈនៃការប្រជុំ កំណត់ហេតុនៃការប្រជុំលើកមុន និង ឯកសារ លិខិតស្នាមតាមប្រធានបទ ស្របតាមរបៀបវារៈនៃការប្រជុំ ។

ប្រធានគណៈកម្មការត្រូវពិចារណានូវសំណើរបស់សមាជិកគណៈកម្មការដែលស្នើសុំបញ្ចូលនូវប្រធានបទទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំ និង អាចបញ្ចូលប្រធានបទនោះទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំលើកក្រោយបាន លុះត្រាតែសំណើនោះបានទទួលនៅលេខាធិការដ្ឋានរបស់គណៈកម្មការយ៉ាងតិចបំផុត២ថ្ងៃ មុនថ្ងៃចែកចាយលិខិតអញ្ជើញ។

**ប្រការ៤៦.–**

អភិបាលខេត្តត្រូវធ្វើជាអធិបតីគ្រប់កិច្ចប្រជុំរបស់គណៈកម្មការ ។

ក្នុងករណី អភិបាលខេត្តអវត្តមាន អភិបាលរងខេត្តដែលចាត់តាំងដោយអភិបាលខេត្ត ត្រូវធ្វើជាអធិបតី ។

កិច្ចប្រជុំរបស់គណៈកម្មការ ដែលអាចយកជាការបាន លុះត្រាតែមានសមាជិកចំនួនលើសពាក់កណ្តាលនៃចំនួនសមាជិកទាំងអស់ ។

អភិបាលខេត្ត មានសិទ្ធិជំទាស់ចំពោះការសំរេចណាមួយ ស្តីពីបញ្ញបុគ្គលិក ថវិកា និង ផែនការអភិវឌ្ឍន៍ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខេត្ត ឬ ស្រុក ។

**ប្រការ៤៧.–**

ការចូលរួម និង ការបំពេញការងារនៅក្នុងគណៈកម្មការ គឺជាការងារកិត្តិយស ។

សមាជិកគណៈកម្មការ ដែលធ្វើដំណើរចូលរួមក្នុងកិច្ចប្រជុំនឹងបានទទួលប្រាក់ សំរាប់ធ្វើដំណើរ និង ប្រាក់ចំណាយផ្សេងៗ នៅនឹងកន្លែងប្រជុំ ។

សមាជិកណា ដែលបំពេញភារកិច្ចចំណាយពេលយូរ តាងនាមអោយគណៈកម្មការ និង បន្ទាប់ ពីមានការសំរេចពីគណៈកម្មការ ដូចជា ការសិក្សា ការស្រាវជ្រាវនិងជំនាញដែលជួយជំរុញការងាររដ្ឋបាលថ្មីនេះ នឹងទទួលបានកំរៃសំរាប់ការបំពេញភារកិច្ចនោះ ។

**ប្រការ៤៨.–**

កំណត់ហេតុនៃការប្រជុំត្រូវធ្វើជូនទៅក្រសួងស្ថាប័ននៅថ្នាក់ជាតិ និង មន្ទីរអង្គភាពនៅថ្នាក់ខេត្ត តាមរយៈសមាជិកគណៈកម្មការ ។

រៀងរាល់បីខែម្តង លេខាធិការដ្ឋានត្រូវរៀបចំធ្វើរបាយការណ៍លំអិតជាក់ស្តែងមួយ ដែលរៀបរាប់ជាលំអិតអំពីសកម្មភាពនានាជាជំហានៗ ដើម្បីឆ្ពោះទៅសំរេចនូវរូបរាង រដ្ឋបាលថ្មីនោះ បទពិសោធន៍ពេលធ្វើសកម្មភាព និង វាយតំលៃពីដំណើរការទាំងមូលដាក់ជូនគណៈកម្មការ ដើម្បីសំរេច ។

របាយការណ៍នេះត្រូវផ្ញើមកក្រសួងមហាផ្ទៃ ដើម្បីជាមូលដ្ឋានសំរាប់រៀបចំធ្វើសេចក្តីរាយការណ៍ ជូនគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**ប្រការ៤៩.-**

ក្នុងរយៈពេលនៃការអនុវត្តសាកល្បងនេះ ការតែងតាំងមន្ត្រីរាជការដូចមានចែងក្នុងប្រការ៥ ប្រការ៦ និងប្រការ៣៩ នៃប្រកាសនេះ ត្រូវធ្វើឡើងក្នុងលក្ខណៈបណ្ដោះអាសន្នដោយត្រូវជ្រើសយកមន្ត្រី ដែលមានឋានន្តរសក្តិតាមការកំណត់នៃប្រកាសនេះ ។

**ប្រការ៥០.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៥១.-**

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥២.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាលនិងនគរបាល ខេត្តសៀមរាប ខេត្តបាត់ដំបង ស្រុកសៀមរាប និង ស្រុកបាត់ដំបង ត្រូវអនុវត្តតាមស្មារតីនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ។/.

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០០៤

**ស ខេង**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សមាជិក "គ.ឃ.ស."
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- សាលាខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

"*ដើម្បីជ្រាប*" ។

- ឯកសារ-កាលប្បវត្តិ ។

## របនាសម្ព័ន្ធថ្មី នៃ ស្រុកសៀមរាប និង ស្រុកបាត់ដំបង




BB-SR Asia Unit

# ប្រកាសស្តីពី ការបង្កើតថវិកាផ្នែក សំរាប់ ស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**DRAFT**



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ........................ សហវ......

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពីការបង្កើតថវិកាផ្នែក សំរាប់ស្រុកសៀមរាប និងស្រុកបាត់ដំបង

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២

- បានឃើញព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសេចក្តីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាបនៃខេត្តសៀមរាប និងស្រុកបាត់ដំបងនៃខេត្តបាត់ដំបង
- បានឃើញប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីបទបញ្ជាថវិការបស់ខេត្ត ក្រុង
- ប្រកាសលេខ ២០៥ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីកិច្ចប្រតិបត្តិការអនុវត្តថវិកាខេត្ត ក្រុង
- តាមតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

***ប្រការ១:*** ត្រូវបានបង្កើតថវិកា សំរាប់ស្រុកសៀមរាប ដែលជាថវិកាផ្នែកនៃថវិការបស់ខេត្តសៀមរាប និងថវិកាសំរាប់ស្រុកបាត់ដំបង ដែលជាថវិកាផ្នែកនៃថវិកាខេត្តបាត់ដំបង

***ប្រការ២:*** ប្រភពធនធាន និងបន្ទុកចំណាយ របស់ថវិកាស្រុកទាំងពីរខាងលើ គឺជាការបែងចែកផ្ទៃក្នុងនៃសរុបថវិការបស់ខេត្ត ក្រុងសាមី តាមរយៈការធ្វើប្រតិភូកម្មពីអភិបាលខេត្ត ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

***ប្រការ៣:*** អភិបាលស្រុកសៀមរាប និងស្រុកបាត់ដំបងមានភារកិច្ចរៀបចំ និងអនុវត្តថវិការបស់ខ្លួនតាមប្រកាសណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការជួយគាំទ្រពីអភិបាលខេត្តសៀមរាប និងខេត្តបាត់ដំបង

**ប្រការ៤:** អភិបាលខេត្តសៀមរាប និងខេត្តបាត់ដំបង ក្រោយពីបានទទួលប្រកាសថវិកាប្រចាំឆ្នាំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចេញដីការបែងចែកថវិកា និងផ្ទេរសិទ្ធិអាណាប័កទៅអោយអភិបាលស្រុកសៀមរាប និងស្រុកបាត់ដំបង ក្នុងការគ្រប់គ្រងនិងអនុវត្តថវិការបស់ខ្លួន និងផ្ញើទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ច្បាប់ និងរតនាគារខេត្ត ១ច្បាប់ (ច្បាប់ដើម)

**ប្រការ៥:** រតនាគារជាតិ ត្រូវណែនាំដល់រតនាគារខេត្តសៀមរាប និងបាត់ដំបង អោយបើកអនុគណនីរបស់ថវិកាខេត្តសៀមរាប និងបាត់ដំបង ដើម្បីកត់ត្រាតាមដានដោយឡែកការអនុវត្តថវិការបស់ស្រុកសៀមរាប និងស្រុកបាត់ដំបង

**ប្រការ៦:** ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រធានរតនាគារខេត្តសៀមរាប និងបាត់ដំបង ត្រូវជួយអភិបាលខេត្ត និងអភិបាលស្រុកទាំងពីរខាងលើ ក្នុងការរៀបចំ និងអនុវត្តថវិការបស់ខ្លួនអោយប្រព្រឹត្តទៅតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ។

**ប្រការ៧:** ឯកឧត្តមអភិបាលខេត្តសៀមរាប ឯកឧត្តមអភិបាលខេត្តបាត់ដំបង លោកអភិបាលស្រុកសៀមរាប លោកអភិបាលស្រុកបាត់ដំបង លោកប្រធានរតនាគារខេត្តសៀមរាប លោកប្រធានរតនាគារខេត្តបាត់ដំបង លោកប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តសៀមរាប លោកប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តបាត់ដំបង និងអស់លោកប្រធានអង្គភាពដែលមានការពាក់ព័ន្ធត្រូវអនុវត្តតាមសេចក្តីប្រកាសនេះចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ តទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**កន្លែងទទួល:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- គណៈកម្មាធិការជាតិ គាំទ្រឃុំ សង្កាត់
- ក្រសួងមហាផ្ទៃ
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
  "ដើម្បីសហការ"
- ដូចមាត្រា ៧
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**សេចក្តីព្រាងប្រកាសប្រតិភូកម្មអំណាច ជូនដល់ស្រុកសៀមរាប នៃខេត្តសៀមរាប ស្រុកបាត់ដំបង នៃខេត្តបាត់ដំបង របស់ក្រសួងជំនាញទាំង៥មាន :**

- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីប្រតិភូកម្មអំណាចការងារ ឧស្សាហកម្ម
- សេចក្តីព្រាងប្រកាសរបស់ក្រសួងទេសចរណ៍ ស្តីពីប្រតិភូកម្មអំណាចកាងារទេសចរណ៍
- សេចក្តីព្រាងប្រកាស របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ស្តីពីប្រតិភូកម្មអំណាចការងារ សាធារណការ និងដឹកជញ្ជូន
- សេចក្តីព្រាងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ស្តីពីប្រតិភូកម្មអំណាចការងារពាណិជ្ជកម
- សេចក្តីព្រាងប្រកាស របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ស្តីពីប្រតិភូកម្មអំណាចការងារវប្បធម៌ និងវិចិត្រសិល្បៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N°

**DRAFT**

## ប្រកាស
## ស្តីពី
## ប្រតិភូកម្មអំណាចនៃការចេញអាជ្ញាប័ណ្ណឧស្សាហកម្ម
## ជូនដល់ស្រុកសៀមរាបនៃខេត្តសៀមរាបនិង ស្រុកបាត់ដំបងនៃខេត្តបាត់ដំបង

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម
- បានឃើញសេចក្តីសំរេចលេខ៤៧សសរ ចុះថ្ងៃទី១១ខែមិថុនាឆ្នាំ២០០៣ ស្តីពីរចនាសម្ព័ន្ធនិងប្រពន្ធ័គ្រប់គ្រងស្រុកសៀមរាបនៃខេត្តសៀមរាប និងស្រុកបាត់ដំបងនៃខេត្តបាត់ដំបង
- បានឃើញប្រកាសលេខ ៤១ ជក.ប្រក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៩២ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និងសិប្បកម្ម
- បានឃើញសារាចរណែនាំលេខ ០១ ជក.សរណន ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩២ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម
- បានឃើញសេចក្តីណែនាំបន្ថែមលេខ ០៧ ជក.សរណន ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីការគ្រប់គ្រង និងបែបបទអនុញ្ញាតច្បាប់ឧស្សាហកម្មតូច និងសិប្បកម្ម
- បានឃើញស្មារតីអង្គប្រជុំនៅក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ចុះថ្ងៃទី........ខែ.......... ឆ្នាំ............
- បានឃើញស្មារតីអង្គប្រជុំពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ចុះថ្ងៃទី......ខែ........ឆ្នាំ..........

## សំរេច

**ប្រការ១:-** ធ្វើប្រតិភូកម្មអំណាចពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជូនដល់ស្រុកសៀមរាបនៃខេត្តសៀមរាប និង ស្រុកបាត់ដំបង នៃខេត្តបាត់ដំបង ដើម្បីសាកល្បងក្នុងការបង្កើតជាមជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌចេញការអនុញ្ញាតិច្បាប់បង្កើត និងបន្តមូលដ្ឋាន ឧស្សាហកម្ម សិប្បកម្ម ដែលមានទុនសរុបតិចជាង ៥.០០០.០០០ រៀល (ប្រាំលានរៀល) និង ប្រើប្រាស់ម៉ាស៊ីនមានកំលាំង ១២សេះ (ដប់ពីរសេះ)ចុះ លើកលែងតែផលិតកម្ម ភេសជ្ជៈ សៀង ម្ហូបអាហារ ថ្នាំជក់ និង គីមី ។ ចំពោះការផ្គត់ផ្គង់ទឹកស្អាតអាចអនុវត្តបាននៅតាមបណ្តាភូមិសាស្ត្រណា ដែលបណ្តាញផ្គត់ផ្គង់ទឹកស្អាតរបស់រដ្ឋាករទឹកខេត្តទៅមិនដល់ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ :(៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣. ៤២៨២៦៣
45 Preah Norodom Boulevard , Khan Daun Penh, Phnom Penh , Phone : 355. 23 . 211141 Fax : 855 23 428263

DRAFT

**ប្រការ២:-** ក្រសួងនឹងចេញនូវសេចក្តីណែនាំអំពីលិខិតបទដ្ឋាន និងគំរូបែបបទដែលពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត និង ផ្តល់សេចក្តីព្រាងគណនាកំរៃដែលទាក់ទងទៅនិងការចេញលិខិតអនុញ្ញាតច្បាប់សំរាប់មន្ត្រីជំនួយការប្រតិភូកម្ម នៅការិយាល័យឧស្សាហកម្ម រ៉ែ និង ថាមពល ប្រចាំស្រុកដែលជាសេនាធិការអោយអភិបាលស្រុកទាំងពីរខាងលើ ។

**ប្រការ៣:-** សាលាស្រុកទាំងពីរ ត្រូវចម្លងជូនមកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល តាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលខេត្ត នូវលិខិតអនុញ្ញាតអោយមូលដ្ឋានផលិតកម្ម-អាជីវកម្ម និង ផ្តល់នូវរបាយការណ៍ ស្ថិតិប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ និង ផែនការប្រចាំឆ្នាំ តាមការណែនាំដូចបានកំណត់ ។

**ប្រការ៤:-** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**កន្លែងទទួល:**

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ ២០០....

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-សាលាខេត្ត សៀមរាប
-សាលាខេត្ត បាត់ដំបង
-មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តសៀមរាប
-មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តបាត់ដំបង
-ដូចប្រការ ២និង៣ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

... 23 426263

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
Nation Religion King

**DRAFT**

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº

# ប្រកាស
# ស្តីពីប្រតិភូកម្មអំណាចនៃការទារធនធានរ៉ែ
# ជូនដល់ស្រុកបាត់ដំបង នៃខេត្តបាត់ដំបង

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញ សេចក្តីសំរេចលេខ ៤៧សសរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រង ស្រុកសៀមរាប នៃខេត្តសៀមរាប និងស្រុកបាត់ដំបង នៃខេត្តបាត់ដំបង
- បានឃើញស្មារតីអង្គប្រជុំនៅក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលចុះថ្ងៃទី..............ខែ.................ឆ្នាំ......................
- បានឃើញស្មារតីអង្គប្រជុំពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រក្រុមប្រឹក្សាឃុំ ចុះថ្ងៃទី.................ខែ............ ឆ្នាំ...............

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ :(៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣. ៤២៨២៦៣
45 Preah Norodom Boulevard , Khan Daun Penh, Phnom Penh , Phone : 855. 23 . 211141 Fax : 855 23 428263

**DRAFT**

## សំរេច

**ប្រការ ១.-** ធ្វើប្រតិភូកម្មអំណាចពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ជូនដល់ស្រុកបាត់ដំបង ដើម្បីសាកល្បងក្នុងការបង្កើតជាមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌចេញអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ ដើម្បីធ្វើអាជីវកម្មធនធានរ៉ែសំណង់ (ខ្សាច់ គ្រួស និងថ្មបំបែកគ្រប់ប្រភេទ) ជាលក្ខណៈគ្រួសារ នៅតំបន់ទាំងឡាយ ដែលមានទីតាំងនៅក្នុងស្រុកបាត់ដំបង នៃខេត្តបាត់ដំបង ដូចមានបញ្ជីសរុបនៃសេវា ដែលក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល បានផ្តល់ជូន មានបញ្ជាក់ក្នុង "ឧបសម្ព័ន្ធ ទី ១" ។

**ប្រការ ២.-** ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នឹងចេញនូវសេចក្តីណែនាំស្តីពីការអនុវត្តន៍លើគំរូបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការចេញអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែសំរាប់មន្ត្រីជំនួយការប្រតិភូកម្ម នៅការិយាល័យឧស្សាហកម្ម ប្រចាំស្រុក ដែលជាសេនាធិការឱ្យអភិបាលស្រុកខាងលើ ។

**ប្រការ ៣.-** សាលាស្រុកបាត់ដំបងត្រូវផ្ញើជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល តាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តបាត់ដំបង នូវលិខិតចំលងស្តីពី ការសំរេចចេញអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ របាយការណ៍-ស្ថិតិប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ និង ផែនការប្រចាំឆ្នាំ ។

**ប្រការ ៤.-** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ ២០០......

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សាលាខេត្តបាត់ដំបង

  "ដើម្បីជ្រាប"

- សាលាស្រុកបាត់ដំបង
- មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តបាត់ដំបង
- ដូចប្រការ ២ និង ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**

Nation Religion King

**DRAFT**

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

Nº

# ប្រកាស

## ស្តីពីប្រតិភូកម្មអំណាចនៃការទារថាមពលអគ្គិសនី
## ជូនដល់ស្រុកសៀមរាបក្នុងខេត្តសៀមរាប និង ស្រុកបាត់ដំបងនៃខេត្តបាត់ដំបង

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ សន/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០០១/០៣ ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងឧស្សហកម្ម រ៉ែ និង ថាមពល
- បានឃើញសេចក្តីសំរេចលេខ៤៧ សសរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៣ស្តីពីរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រង ស្រុកសៀមរាបនៃខេត្តសៀមរាប និង ស្រុកបាត់ដំបងនៃខេត្តបាត់ដំបង
- បានឃើញស្មារតីនៃអង្គប្រជុំនៅក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលចុះថ្ងៃទី......ខែ..........ឆ្នាំ.........
- បានឃើញស្មារតីនៃអង្គប្រជុំពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រក្រុមប្រឹក្សាឃុំ ចុះថ្ងៃទី.... ......ខែ..........ឆ្នាំ................



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ :(៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣. ៤២៨២៦៣
45 Preah Norodom Boulevard , Khan Daun Penh, Phnom Penh , Phone : 355. 23 . 211141 Fax : 855 23 428263

**DRAFT**

## សម្រេច

**ប្រការ១** ៖ ផ្ទេរប្រតិភូកម្មអំណាចពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ជូនដល់ស្រុកសៀមរាបនៃខេត្តសៀមរាប និង ស្រុកបាត់ដំបងនៃខេត្តបាត់ដំបង ដើម្បីសាកល្បងក្នុងការបង្កើតជាមជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងក្របខ័ណ្ឌចេញលិខិតអនុញ្ញាតវិនិយោគអគ្គិសនីដែលមានកំលាំងផលិតមិនលើសពី 75 KVA និង ការផលិតអគ្គិសនីសំរាប់សាកអាគុយ ។

**ប្រការ២** ៖ ក្រសួងនឹងចេញសេចក្ដីណែនាំអំពីលិខិតបទដ្ឋាន និង បែបបទដែលពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាតវិនិយោគអគ្គិសនីសំរាប់មន្ត្រីជំនួយការឱ្យការងារប្រតិភូកម្មការិយាល័យឧស្សាហកម្ម រ៉ែ និង ថាមពល ប្រចាំស្រុកដែលជាសេនាធិការឱ្យអភិបាលស្រុកទាំងពីរខាងលើ ។

**ប្រការ៣** ៖ សាលាស្រុកទាំងពីរ ត្រូវចំលងជូនមកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល តាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលខេត្ត និង អាជ្ញាធរអគ្គិសនីកម្ពុជានូវលិខិតអនុញ្ញាតវិនិយោគអគ្គិសនី និង របាយការណ៍ ស្ថិតិប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ និង ផែនការប្រចាំឆ្នាំ តាមការណែនាំដូចបានកំណត់ ។

**ប្រការ៤** ៖ ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ ២០០.....

<u>កន្លែងទទួល</u>

-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-សាលាខេត្តសៀមរាប
-សាលាខេត្តបាត់ដំបង
-មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តសៀមរាប
-មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តបាត់ដំបង
"ដើម្បីអនុវត្ត"
- ដូចប្រការ ២ + ៣ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា **DRAFT**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខៈ ..........................

ភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ.............

# ប្រកាស

## ស្តីពីប្រតិភូកម្មអំណាចនៃការងារទេសចរណ៍
## ជូនដល់ស្រុកសៀមរាបនៃខេត្តសៀមរាប

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការកែសំរួលមុខងារ និង ភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១០៧ អនក្រ-បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រសួងទេសចរណ៍ ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាប នៃខេត្តសៀមរាប និងស្រុកបាត់ដំបង នៃខេត្តបាត់ដំបង
- យោងប្រកាសលេខ ៣៦ ប្រក ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ជូនភ្នាក់ងារ និងក្រុមហ៊ុនប្រកបអាជីវកម្មសណ្ឋាគារ-ផ្ទះភ្ញៀវ និង សារាចរណែនាំលេខ ១២ សរណន ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងភ្នាក់ងារ និងក្រុមហ៊ុនប្រកបអាជីវកម្មសណ្ឋាគារ-ផ្ទះភ្ញៀវ
- យោងប្រកាសលេខ ៣២ ប្រក ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ជូនភ្នាក់ងារ និងក្រុមហ៊ុនប្រកបអាជីវកម្មភោជនីយដ្ឋាន និង សារាចរណែនាំលេខ ០៨ សរណន ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងភ្នាក់ងារ និងក្រុមហ៊ុនប្រកបអាជីវកម្មភោជនីយដ្ឋាន

**DRAFT**

- យោងប្រកាសលេខ ៣១ ប្រក ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់មធ្យោបាយដឹកជញ្ជូន ភ្ញៀវទេសចរតាមផ្លូវគោក និង សារាចរណែនាំលេខ ០៧ សរណន ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវគោក
- យោងប្រកាសលេខ ៣៥ ប្រក ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ជូនភ្នាក់ងារ និងក្រុមហ៊ុនប្រកាបសេវាកម្មម៉ាស្សា និងសារាចរណែនាំលេខ ១១ សរណន ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងភ្នាក់ងារ និងក្រុមហ៊ុនប្រកបសេវាកម្មម៉ាស្សា
- យោងស្មារតីនៃកិច្ចប្រជុំក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល កាលពីថ្ងៃទី ....... ខែ .......... ឆ្នាំ .........
- យោងតាមស្មារតីនៃកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ នាថ្ងៃទី ........ ខែ ........ ឆ្នាំ .......... ។

## <u>សំរេច</u>

**ប្រការ ១ :**

ធ្វើប្រតិភូកម្មអំណាចពីក្រសួងទេសចរណ៍ ជូនដល់ស្រុកសៀមរាប នៃខេត្តសៀមរាប ដើម្បីសាកល្បងក្នុងក្របខ័ណ្ឌចេញអាជ្ញាប័ណ្ណទេសចរណ៍ ដើម្បីធ្វើអាជីវកម្មលើសេវាកម្មទេសចរណ៍ដូចជា :

- មធ្យោបាយដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោក : រថយន្តដឹកទេសចរចំណុះ ០៥កៅអីក្រៅសមាគម ម៉ូតូឌុបទេសចរ រឺម៉កម៉ូតូដឹកទេសចរ
- ផ្ទះភ្ញៀវ (Guest House) ក្រោម ១០បន្ទប់ និង ផ្ទះភ្ញៀវប៉ៅអ៊ី
- ភោជនីយដ្ឋានធម្មតាក្រោម ៥០កៅអី អាហារដ្ឋាន អាហារដ្ឋានតាមរមណីយដ្ឋាន តូបលក់អាហារ ហាងលក់គុយទាវ-កាហ្វេ បំរើភ្ញៀវទេសចរ
- កន្លែងម៉ាស្សាតាមរបៀបបុរាណក្រោម ០៥ គ្រែ ដែលមានទីតាំងក្នុងស្រុកសៀមរាបនៃខេត្តសៀមរាប ។

**ប្រការ ២ :**

មន្ត្រីនៃការិយាល័យស្រុកសៀមរាប ត្រូវរៀបចំអនុវត្តតាមបែបបទ គំរូរបស់ក្រសួងទេសចរណ៍បានកំណត់ រួមទាំងឯកសារបច្ចេកទេសពាក់ព័ន្ធសំរាប់ដល់ការចេញអាជ្ញាប័ណ្ណទេសចរណ៍ ដូចមានចែងក្នុងប្រការ១ ខាងលើ ។

**ប្រការ ៣ :**

ក្រសួងទេសចរណ៍ នឹងចេញនូវសេចក្តីណែនាំស្តីពីនីតិវិធីអនុវត្តន៍ និងគំរូបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការចេញអាជ្ញាប័ណ្ណទេសចរណ៍ សំរាប់មន្ត្រីនៅការិយាល័យទេសចរណ៍ស្រុកសៀមរាប ដើម្បីធ្វើជាសេនាធិការអោយសាលាស្រុកសៀមរាប ។

**DRAFT**

ប្រការ ៤ :

សាលាស្រុកសៀមរាប ក្រោយពីសំរេចចេញអាជ្ញាប័ណ្ណទេសចរណ៍ដល់បណ្តាអាជីវកម្មដូចក្នុងប្រការ១ រួចមក ត្រូវធ្វើលិខិតចំលងស្តីពីការចេញអាជ្ញាប័ណ្ណទេសចរណ៍ និងផ្តល់នូវរបាយការណ៍ស្ថិតិប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ តាមរយៈមន្ទីរទេសចរណ៍ខេត្តសៀមរាប មកក្រសួងទេសចរណ៍ ។

ប្រការ ៥ :

ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

<u>កន្លែងទទួល</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សាលាខេត្តសៀមរាប
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៣ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**DRAFT**

ក្រសួងទេសចរណ៍

លេខ: ..........................

ភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ............

# <u>ប្រកាស</u>

## ស្តីពីប្រតិភូកម្មអំណាចនៃការងារទេសចរណ៍ ជូនដល់ស្រុកបាត់ដំបង នៃខេត្តបាត់ដំបង

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការកែសំរួលមុខងារ និង ភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១០៧ អនក្រ-បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រសួងទេសចរណ៍ ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ៣៦ ប្រក ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ជូនភ្នាក់ងារ និងក្រុមហ៊ុនប្រកបអាជីវកម្មសណ្ឋាគារ-ផ្ទះភ្ញៀវ និង សារាចរណែនាំលេខ ១២ សរណន ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងភ្នាក់ងារ និងក្រុមហ៊ុនប្រកបអាជីវកម្មសណ្ឋាគារ-ផ្ទះភ្ញៀវ
- យោងប្រកាសលេខ ៣២ ប្រក ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១ ស្តិពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ជូនភ្នាក់ងារ និងក្រុមហ៊ុនប្រកបអាជីវកម្មភោជនីយដ្ឋាន និង សារាចរណែនាំលេខ ០៨ សរណន ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងភ្នាក់ងារ និងក្រុមហ៊ុនប្រកបអាជីវកម្មភោជនីយដ្ឋាន
- យោងប្រកាសលេខ ៣១ ប្រក ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់មធ្យោបាយដឹកជញ្ជូន ភ្ញៀវទេសចរតាមផ្លូវគោក និង សារាចរណែនាំលេខ ០៧ សរណន ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១ ស្តិពីការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវគោក

DRAFT

- យោងប្រកាសលេខ ០៨៦ ប្រក ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់មធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវទឹក និងសារាចរណែនាំលេខ ០០២ សរណន ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវទឹក
- យោងប្រកាសលេខ ៣៥ ប្រក ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ជូនភ្នាក់ងារ និងក្រុមហ៊ុនប្រកាបសេវាកម្មម៉ាស្សា និងសារាចរណែនាំលេខ ១១ សរណន ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងភ្នាក់ងារ និងក្រុមហ៊ុនប្រកបសេវាកម្មម៉ាស្សា
- បានឃើញសេចក្តីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីវេទនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាប នៃខេត្តសៀមរាប និងស្រុកបាត់ដំបង នៃខេត្តបាត់ដំបង
- យោងស្មារតីនៃកិច្ចប្រជុំក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល កាលពីថ្ងៃទី ....... ខែ .......... ឆ្នាំ .........
- យោងតាមស្មារតីនៃកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ នាថ្ងៃទី ........ ខែ ........ ឆ្នាំ .......... ។

## សំរេច

**ប្រការ ១ :**

ធ្វើប្រតិភូកម្មអំណាចពីក្រសួងទេសចរណ៍ ជូនដល់ស្រុកបាត់ដំបង នៃខេត្តបាត់ដំបង ដើម្បីសាកល្បងក្នុងក្របខ័ណ្ឌចេញអាជ្ញាប័ណ្ណទេសចរណ៍ ដើម្បីធ្វើអាជីវកម្មលើសេវាកម្មទេសចរណ៍ដូចជា :

- មធ្យោបាយដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោក និងផ្លូវទឹក : រថយន្តដឹកទេសចរចំណុះ ០៥កៅអី ម៉ូតូឌុបដឹកទេសចរ និងអូប័រដឹកទេសចរចំណុះ ០៦ នាក់ចុះក្រោម
- ផ្ទះភ្ញៀវ (Guest House) ក្រោម ១០បន្ទប់ និង ផ្ទះភ្ញៀវប៉ៅអ៊ី
- ភោជនីយដ្ឋានធម្មតាក្រោម ៥០កៅអី អាហារដ្ឋាន អាហារដ្ឋានតាមរមណីយដ្ឋាន តូបលក់អាហារ ហាងលក់គុយទាវ-កាហ្វេ បំរើភ្ញៀវទេសចរ
- កន្លែងម៉ាស្សាតាមរបៀបបុរាណក្រោម ០៥ គ្រែ ដែលមានទីតាំងក្នុងស្រុកបាត់ដំបងនៃខេត្តបាត់ដំបង ។

**ប្រការ ២ :**

មន្ត្រីនៃការិយាល័យទេសចរណ៍ស្រុកបាត់ដំបង ត្រូវរៀបចំអនុវត្តតាមបែបបទគំរូរបស់ក្រសួងទេសចរណ៍បានកំណត់ រួមទាំងឯកសារបច្ចេកទេសពាក់ព័ន្ធសំរាប់ដល់ការចេញអាជ្ញាប័ណ្ណទេសចរណ៍ ដូចមានចែងក្នុងប្រការ ១ ខាងលើ ។

**ប្រការ ៣ :**

ក្រសួងទេសចរណ៍ នឹងចេញនូវសេចក្តីណែនាំស្តីពីនីតិវិធីអនុវត្តន៍ និងគំរូបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការចេញអាជ្ញាប័ណ្ណទេសចរណ៍ សំរាប់មន្ត្រីនៅការិយាល័យទេសចរណ៍ស្រុកបាត់ដំបង ដើម្បីធ្វើជាសេនាធិការឱ្យសាលាស្រុកបាត់ដំបង ។

**DRAFT**

ប្រការ ៤ ៖

សាលាស្រុកបាត់ដំបង ក្រោយពីសំរេចចេញអាជ្ញាប័ណ្ណទេសចរណ៍ដល់បណ្តាអាជីវកម្មដូចក្នុងប្រការ ១ រួចម
ត្រូវធ្វើលិខិតចំលងស្តីពីការចេញអាជ្ញាប័ណ្ណទេសចរណ៍ និង ផ្តល់នូវរបាយការណ៍ស្ថិតិប្រចាំខែ ត្រីមាស ឆមាស
និងឆ្នាំ តាមរយៈមន្ទីរទេសចរណ៍ខេត្តបាត់ដំបង មកក្រសួងទេសចរណ៍ ។

ប្រការ ៥ ៖

ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

<u>កន្លែងទទួល</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សាលាខេត្តបាត់ដំបង
  " ដើម្បីជូនជ្រាប "
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**DRAFT**

ក្រសួងសាធារណការ និង ដឹកជញ្ជូន

លេខ ប្រក.សក.បជ ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០០៤

# ប្រកាស
## ស្តីពីការធ្វើប្រតិភូកម្មអំណាច
## រដ្ឋបាលកណ្តាល ពីក្រសួងសាធារណការនិង ដឹកជញ្ជូន
## ជូនដល់ ស្រុកសៀមរាប ខេត្តសៀមរាប

## រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣៩៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញ អនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញ សេចក្តីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាប នៃខេត្តសៀមរាប និង ស្រុកបាត់ដំបង នៃខេត្តបាត់ដំបង

-បានឃើញ អនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការចេញផ្លាកលេខសម្គាល់ យានជំនិះ

DRAFT

# សំរេច

**ប្រការ ១ :** ធ្វើប្រតិភូកម្មអំណាច រដ្ឋបាលកណ្តាល ពីក្រសួងសាធារណការ និង ដឹកជញ្ជូន ជូនដល់ស្រុកបាត់ដំបង ខេត្តបាត់ដំបង ដើម្បីសាកល្បងក្នុងក្របខ័ណ្ឌការចុះបញ្ជីយានយន្ត និង ការអនុញ្ញាតិធ្វើអាជីវកម្មដឹកជញ្ជូន មានដូចតទៅ ÷

**១-វិស័យសាធារណការ :**

-ការងារថែទាំផ្លូវ-ស្ពាន-លូ ក្នុងក្រុងប្រវែង ១៤៤ គម

-ការងារថែទាំ ជួសជុលផ្លូវខូច ៥ ភាគរយចុះ ( លុបសំបុកមាន់ )

-ការសំអាតមុខលូ ក្បាលស្ពាន និង ក្រោមស្ពាន

-ការសំអាតចិញ្ចើមផ្លូវទាំងសងខាង

-ការរំលោភបំពានដីចំណីផ្លូវ

**២-វិស័យដឹកជញ្ជូន :**

-ការចុះបញ្ជី ទោចក្រយានយន្ត ត្រីចក្រយាន ត្រីចក្រយានយន្ត ដែលមានអាស័យដ្ឋានពិតប្រាកដស្ថិតនៅក្នុងស្រុកសៀមរាប ។

-លិខិតអនុញ្ញាតិធ្វើអាជីវកម្មដឹកជញ្ជូន នៅក្នុងរង្វង់ស្រុក ចំពោះ ÷

. ទោចក្រយានសណ្តោងរ៉ឺម៉ក ( រ៉ឺម៉កកង់ )

. ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ( រ៉ឺម៉កម៉ូតូ )

. ត្រីចក្រយាន ( ស៊ីក្លូ )

. ត្រីចក្រយានយន្ត ( ម៉ូតូកង់បី )

**ប្រការ ២ :** អគ្គនាយកដ្ឋាន រដ្ឋបាល អគ្គនាយកដ្ឋាន សាធារណការ អគ្គនាយកដ្ឋាន ដឹកជញ្ជូន មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តសៀមរាប ជាអង្គភាពទ្រទ្រង់ផ្នែកបច្ចេកទេស មានភារកិច្ច :

-សំរបសំរួលការងារ រដ្ឋបាល ដល់មន្ត្រីបំពេញការងារ នៅអង្គភាពឈានមុខ

-រៀបចំកម្មវិធីបណ្តុះបណ្តាល កសាងសមត្ថភាពមន្ត្រីបច្ចេកទេស

-រៀបចំលិខិតបទដ្ឋានបច្ចេកទេស សារាចរណែនាំ និង បែបបទកំណត់ដោយគំរូផ្សេងៗ

-ផ្តល់ឧបករណ៍សំភារៈបច្ចេកទេស របស់វិស័យសាធារណការ និងដឹកជញ្ជូន ដល់ស្រុកទាំពីរ ដែលនៅមានកំរិត

**DRAFT**

<u>ប្រការ ៣</u> : អង្គភាពច្រកចេញ-ចូលតែមួយ របស់ស្រុកសៀមរាប នៃ ខេត្តសៀមរាបជាសេនាធិការស្ថិតក្រោមការគ្រប់គ្រងដឹកនាំផ្ទាល់របស់សាលាស្រុក និងស្ថិតនៅក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត និង ក្រសួង ហើយផ្តល់នូវរបាយការណ៍អំពីសកម្មភាពការងារ ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ ឆ្លងតាមសេចក្តីសំរេចពីអភិបាលស្រុក ផ្ញើ ជូនមកអង្គភាពជំនាញ និង ក្រសួងសាមុី ។

<u>ប្រការ ៤</u> : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

**<u>កន្លែងទទួល</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
-ក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ
-ក្រសួងមហាផ្ទៃ
" **ដើម្បីជូនជ្រាប** "
-សាលាខេត្តសៀមរាប
" **ដើម្បីសហការអនុវត្ត** "
-ដូចប្រការ ៤
" **ដើម្បីអនុវត្ត** "
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន

**DRAFT**

លេខ : ប្រក.សក.បច

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០០៤

# ប្រកាស

## ស្ដីពីការធ្វើប្រតិភូកម្មអំណាច
## រដ្ឋបាលកណ្ដាល ពីក្រសួងសាធារណការនិង ដឹកជញ្ជូន
## ជូនដល់ ស្រុកបាត់ដំបង ខេត្តបាត់ដំបង

## រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣៩៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញ អនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញ សេចក្ដីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ ស្ដីពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាប នៃខេត្តសៀមរាប និង ស្រុកបាត់ដំបង នៃខេត្តបាត់ដំបង

-បានឃើញ អនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្ដីពីការចេញផ្លាកលេខសម្គាល់ យានជំនិះ ។

DRAFT

# សំរេច

**ប្រការ ១ :** ធ្វើប្រតិភូកម្មអំណាច រដ្ឋបាលកណ្តាល ពីក្រសួងសាធារណការ និង ដឹកជញ្ជូន ជូនដល់ស្រុកបាត់ដំបង ខេត្តបាត់ដំបង ដើម្បីសាកល្បងក្នុងក្របខ័ណ្ឌការចុះបញ្ជីយានយន្ត និង ការអនុញ្ញាតិធ្វើអាជីវកម្មដឹកជញ្ជូន មានដូចតទៅ ÷

**១.ទិស័យសាធារណការ :**

-ការងារថែទាំផ្លូវ-ស្ពាន-លូ ប្រវែង ១០១. គម ៣០៣ និង ផ្លាកសញ្ញាចរាចរ - ផ្លាកសញ្ញាផ្លូវក្នុងក្រុង

-ការងារថែទាំ ជួសជុលផ្លូវខូច ៥ ភាគរយចុះ ( លុបសំបុកមាន់ )

-ការសំអាតមុខលូ ក្បាលស្ពាន និង ក្រោមស្ពាន

-ការសំអាតចិញ្ចើមផ្លូវទាំងសងខាង

-ការរំលោកបំពានដីចំណីផ្លូវ

**២.ទិស័យដឹកជញ្ជូន :**

-ការចុះបញ្ជី ទោចក្រយានយន្ត ត្រីចក្រយាន ត្រីចក្រយានយន្ត ដែលមានអាស័យដ្ឋានពិតប្រាកដ ស្ថិតនៅក្នុងស្រុកបាត់ដំបង ។

-លិខិតអនុញ្ញាតិធ្វើអាជីវកម្មដឹកជញ្ជូន នៅក្នុងរង្វង់ស្រុក ចំពោះ ÷

. ទោចក្រយានសណ្តោងរ៉ឺម៉ក ( រ៉ឺម៉កកង់ )

. ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ( រ៉ឺម៉កម៉ូតូ )

. ត្រីចក្រយាន ( ស៊ីក្លូ )

. ត្រីចក្រយានយន្ត ( ម៉ូតូកង់បី )

ប្រ

**ប្រការ ២ :** អគ្គនាយកដ្ឋាន រដ្ឋបាល អគ្គនាយកដ្ឋាន សាធារណការ អគ្គនាយកដ្ឋាន ដឹកជញ្ជូន មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តបាត់ដំបង ជាអង្គភាពទ្រទ្រង់ផ្នែកបច្ចេកទេស មានភារកិច្ច ÷

-សំរបសំរួលការងារ រដ្ឋបាល ដល់មន្ត្រីបំពេញការងារ នៅអង្គភាពឈានមុខ

-រៀបចំកម្មវិធីបណ្តុះបណ្តាល កសាងសមត្ថភាពមន្ត្រីបច្ចេកទេស

-រៀបចំលិខិតបទដ្ឋានបច្ចេកទេស សារាចរណែនាំ និង បែបបទកំណត់ដោយគំរូផ្សេងៗ

-ផ្តល់ឧបករណ៍សំភារៈបច្ចេកទេស របស់វិស័យសាធារណការនិងដឹកជញ្ជូន ដល់ស្រុកទាំពីរដែលនៅមានកំរិត ។

DRAFT

សេចក្តីព្រាង

# ប្រកាស
## ស្តីពីការធ្វើប្រតិភូកម្មអំណាចការងារពាណិជ្ជកម្ម
## ជូនដល់ស្រុកសៀមរាប នៃខេត្តសៀមរាប និងស្រុកបាត់ដំបង នៃខេត្តបាត់ដំបង

---

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណា ចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញសេចក្តីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្រុក សៀមរាប នៃខេត្តសៀមរាប និងស្រុកបាត់ដំបង នៃស្រុកបាត់ដំបង
- យោងតាមស្មារតីប្រជុំរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- យោងតាមស្មារតីប្រជុំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់

## <u>សំរេច</u>

<u>ប្រការ</u> ១.- ធ្វើប្រតិភូកម្មអំណាច ពីក្រសួងពាណិជ្ជកម្មជូនដល់ ស្រុកសៀមរាប នៃខេត្តសៀមរាប និង ស្រុកបាត់ដំបង នៃខេត្តបាត់ដំបង ក្នុងក្របខ័ណ្ឌចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម-សេវាកម្ម ជូនគ្រប់អាជីវករ គ្រប់សេវាករ ដែលមានទីតាំងនៅស្រុកសៀមរាប នៃខេត្តសៀមរាប និងស្រុកបាត់ដំបង នៃខេត្តបាត់ដំបងដែលមិនជាប់ពន្ធលើប្រាក់ចំណេញ។

<u>ប្រការ</u> ២.- មន្ត្រីទទួលការងារធ្វើលិខិតអនុញ្ញាតធ្វើអាជីវកម្ម -សេវាកម្ម របស់ស្រុកទាំងពីរត្រូវរៀបចំបែបបទដែលកំណត់ ដោយគំរូផ្សេងៗរួម ទាំងឯកសារ បច្ចេកទេសពាក់ព័ន្ធ សំរាប់សំរេចដល់ការចេញលិខិតអនុញ្ញាត ធ្វើអាជីវកម្ម-សេវាកម្ម ដូចមានចែងក្នុងប្រការ១ ។

<u>ប្រការ</u> ៣.- សាលាស្រុកទាំងពីរខាងលើ ត្រូវធ្វើរលិខិតចម្លង ស្តីពីការចេញលិខិតនុញ្ញាតធ្វើអាជីវកម្ម-សេវាកម្ម និងផ្តល់របាយការណ៍ស្ថិតិជូនមន្ទីរពាណិជ្ជកម្មខេត្តសៀមរាប ឬ មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង ។

<u>ប្រការ</u> ៤.- អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស នាយកខុទ្ទកាល័យ និងប្រធាននាយកដ្ឋានពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ ២០០៤

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

<u>កន្លែងទទួល</u>

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្តសៀមរាប
- សាលាខេត្តបាត់ដំបង
- ដូចប្រការ៤ ដើម្បីអនុវត្ត
- ឯកសារ-កាលបរិច្ឆេទ

**DRAFT**

<u>**ប្រការ ៣**</u> : អង្គភាពច្រកចេញ-ចូលតែមួយ របស់ស្រុកបាត់ដំបង នៃខេត្តបាត់ដំបង ជាសេនាធិការ ស្ថិតក្រោមការគ្រប់គ្រង ដឹកនាំផ្ទាល់របស់សាលាស្រុក និង ស្ថិតនៅក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត និង ក្រសួង ហើយផ្តល់នូវរបាយការណ៍អំពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ ឆ្លងតាមសេចក្តីសំរេចពីអភិបាលស្រុក ផ្ញើជូនមកអង្គភាពជំនាញ និង ក្រសួងសាមុី ។

<u>**ប្រការ ៥**</u> : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

<u>**កន្លែងទទួល**</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
-ក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ
-ក្រសួងមហាផ្ទៃ
" **ដើម្បីជូនជ្រាប** "
-សាលាខេត្តបាត់ដំបង
" **ដើម្បីសហការអនុវត្ត** "
-ដូចប្រការ ៥
" **ដើម្បីអនុវត្ត** "
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**DRAFT**

សេចក្តីព្រាង

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខ :..........................

រាជធានីភ្នំពេញ, ថ្ងៃទី.......ខែ.........ឆ្នាំ ២០០...

# ប្រ កា ស

## ស្តីពីប្រតិភូកម្មអំណាច ការងារវប្បធម៌ និង វិចិត្រសិល្បៈ
## ជូនដល់ស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស រកម ០១៩៦-០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ នឹង វិចិត្រសិល្បៈ
- យោងសេចក្តីសំរេចលេខ ៤៧ សសរ. ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីវេទនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

## សំ រេ ច

<u>ប្រការ១</u> : ត្រូវបានធ្វើប្រតិភូកម្មអំណាចពី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជូនដល់ស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង ក្នុងក្របខ័ណ្ឌចេញជាអជ្ញាប័ណ្ណដើម្បីធ្វើអាជីវកម្ម សេវាកម្មវប្បធម៌ និង វិចិត្រសិល្បៈ ដូចខាងក្រោម :

-លើ កម្មវិធីសំដែងផ្សេងៗ ( ក្រៅផ្លូវការ )

-លើ ការបញ្ចាំងភាពយន្តវីដេអូចល័ត ( ទាំងផ្សព្វផ្សាយ និងការធ្វើអាជីវកម្ម )

-លើ ក្រុមថតវីដេអូ ថតរូប ( ចល័ត )

-លើ អាជីវកម្មជួល-លក់ ស្នាដៃសិល្បៈភាពយន្តវីដេអូ

-លើ ផ្លាកសញ្ញាអាជីវកម្មផ្សេងៗដែលមានទំហំ ២ ㎡ ចុះ ( លើកលែងបដាផ្សាយពាណិជ្ជកម្ម )

DRAFT

-លើ អាជីវកម្មទាក់ទងនិងគ្រឿងបំពងសម្លេង

-លើ តូបលក់សៀវភៅ

-លើ អាជីវកម្មសិល្បៈសូនរូបខ្នាតតូច

**ប្រការ២** : មន្ត្រីទទួលបន្ទុកការងារបច្ចេកទេសវប្បធម៌ និង វិចិត្រសិល្បៈ ត្រូវរៀបចំបែបបទដែលត្រូវកំណត់ដោយគំរូផ្សេងៗរួមទាំងឯកសារពាក់ព័ន្ធ សំរាប់សំរេចដល់ការចេញអាជ្ញាប័ណ្ណវប្បធម៌ និងវិចិត្រសិល្បៈ ដូចមានចែងក្នុងប្រការ ១ ខាងលើ ។

**ប្រការ៣** : ការអនុវត្តលើគំរូបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការចេញអាជ្ញាប័ណ្ណវប្បធម៌ និងវិចិត្រសិល្បៈ របស់មន្ត្រីជំនួយការអភិបាលស្រុកទាំងពីរខាងលើ ត្រូវកំណត់ដោយសេចក្តីណែនាំមួយដោយឡែករបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

បញ្ជីលំអិតរាយមុខសេវាកម្មវប្បធម៌ និងវិចិត្រសិល្បៈ ដែលត្រូវធ្វើប្រតិភូកម្មអំណាចជូនស្រុកបាត់ដំបង ខេត្តបាត់ដំបង និងស្រុកសៀមរាប ខេត្តសៀមរាប ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ៤** : សាលាស្រុកទាំងពីរ ត្រូវធ្វើលិខិតចម្លងស្តីពីការចេញអាជ្ញាប័ណ្ណខាងលើ និងផ្តល់របាយការណ៍ស្ថិតិតាមរយៈមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត មកក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

**ប្រការ៥** : នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប និងខេត្តបាត់ដំបង មានភារកិច្ចអនុវត្តនូវប្រកាសនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ចម្លងជូន** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- សាលាខេត្ត សៀមរាប
- សាលាខេត្ត បាត់ដំបង

"ដើម្បីជ្រាបជាពត៌មាន"

- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រ ដ្ឋ ម ន្ត្រី

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ជាតិ សាសនា ព្រះមហាក្សត្រ

**DRAFT**

## បញ្ជីលំអិតរាយមុខសេវាកម្មវប្បធម៌ និង វិចិត្រសិល្បៈ
## ដែលត្រូវធ្វើប្រតិភូកម្មអំណាចជូនស្រុកបាត់ដំបង ខេត្តបាត់ដំបង និង ស្រុកសៀមរាប ខេត្តសៀមរាប

~~~~~~~~~~~~~~~~

| ល.រ | មុខជំនាញ | សេវាកម្មប្រតិភូកម្មអំណាច | សេវាកម្មលំអិតដែលត្រូវធ្វើប្រតិភូកម្មអំណាច | សេចក្តីផ្សេងៗ |
|---|---|---|---|---|
| ១ | - សិល្បៈទស្សនីយភាព | - កម្មវិធីសំដែងផ្សេងៗ ( ក្រៅផ្លូវការ ) | - ការប្រគំតន្ត្រីនៅទីប្រជុំសាធារណៈ<br>- ការសម្តែងល្ខោនគ្រប់ទម្រង់ ដោយការលក់សំបុត្រ<br>( លើកលែងតែរបាំប្រពៃណី-របាំ ឬល្ខោនក្បាច់បុរាណខ្មែរ )<br>- កម្មវិធីរាំកំសាន្ត ( ធ្វើអាជីវកម្ម) | |
| | | - អាជីវកម្មលក់ស្នាដៃសិល្បៈ | - តូបលក់កាសែតបទចំរៀង | |
| ២ | - សិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ | - ការបញ្ចាំងភាពយន្ត វីដេអូ ចល័ត | - ការបញ្ចាំងភាពយន្ត វីដេអូ ផ្សាយពាណិជ្ជកម្មនៅទីសាធារណៈ<br>- ការបញ្ចាំងភាពយន្ត វីដេអូ កំដរក្នុងពិធីបុណ្យផ្សេងៗ<br>- ការបញ្ចាំងវីដេអូកំដរភ្ញៀវតាមភោជនីយដ្ឋាន និង ហាងកាហ្វេ | |
| | | - ក្រុមថតវីដេអូ ថតរូប ចល័ត ( ដែលធ្វើអាជីវកម្ម ) | - ថតវីដេអូ ថតរូបក្នុងពិធីបុណ្យផ្សេង ៗ<br>- ថតរូប តាមទីសាធារណៈ | |
| | | - អាជីវកម្មជួល-លក់ កាសែត ស្នាដៃភាពយន្ត វីដេអូ | - តូបលក់ និងជួលកាសែតតាមទីផ្សារ | |
| ៣ | - អភិវឌ្ឍន៍វប្បធម៌ | - ផ្លាកសញ្ញាអាជីវកម្មផ្សេងៗដែលមានទំហំ ២ ម$^{2}$ ចុះ<br>( លើកលែងបដាផ្សាយពាណិជ្ជកម្ម ) | - ផ្លាកយីហោតូប និងតូបលក់ទំនិញគ្រប់ប្រភេទ<br>- បដាផ្សព្វផ្សាយពាណិជ្ជកម្ម<br>- ផ្ទាំងរូបភាព និងនិមិត្តសញ្ញាផ្សេងៗ<br>- Poster ផ្សាយពាណិជ្ជកម្ម | |
| | | - អាជីវកម្មទាក់ទងនិងគ្រឿងបំពងសម្លេង | - ជួលឧឃោសនសព្ទ - ម៉ាស៊ីនភ្លើង | |
| ៤ | - សៀវភៅ និងការអាន | - គ្រប់គ្រងតូបលក់សៀវភៅ | - តូបលក់សៀវភៅតាមទីផ្សារ និងទីសាធារណៈ | |
| ៥ | - សិល្បៈសូនរូប និង សិប្បកម្ម | - អាជីវកម្មសិល្បៈសូនរូប ខ្នាតតូច | - ការផលិតសិល្បៈសូនរូបតាមគ្រួសារ<br>- ការលក់សិល្បៈសូនរូប តាមតូប ទំហំ ៤ ម$^{2}$ ចុះ | |

រាជធានីភ្នំពេញ . ថ្ងៃទី ខែ ឆ្នាំ ២០០៤

**រដ្ឋមន្ត្រី**
~~~~~~~~~~~~~~~~

# ឯកសារមូលដ្ឋានបច្ចេកទេស

របាយការណ៍ទស្សនៈកិច្ចសិក្សានៅប្រទេសវៀតណាម
ស្តីពីការផ្តល់សេវាជូនប្រជាពលរដ្ឋតាមគោលការណ៍ "ទ្វារមួយ ត្រាមួយ"
កាលពីថ្ងៃទី ៣០ មិថុនា ដល់ថ្ងៃទី ១១ កក្កដា ២០០៣

# របាយការណ៍នៃទស្សនកិច្ចសិក្សានៅប្រទេសវៀតណាម
# ស្តីពី
# ការផ្តល់សេវាជូនប្រជាពលរដ្ឋតាមគោលការណ៍ "ទ្វារមួយ-ត្រាមួយ"
# ៣០ មិថុនា ដល់ ១១ កក្កដា ២០០៣

## I- សេចក្តីផ្តើម

តាមរយៈកម្មវិធីបង្វិតរដ្ឋបាលសាធារណៈទៅជិតប្រជាពលរដ្ឋ ដែលអនុម័តដោយគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០១ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកថា ការបង្កើតការិយាល័យ "ច្រកចេញ-ចូលតែមួយ" ជាអាទិភាព ខ្ពស់បំផុត ដើម្បីសំរួលដល់ប្រជាពលរដ្ឋឱ្យងាយទទួលបានសេវាកម្មរដ្ឋបាលពីរដ្ឋ ដែលមានដូចជា ការចុះបញ្ជី ការបញ្ជាក់ និងការអនុញ្ញាតនានា និងជាឧបករណ៍មួយខានមិនបានដើម្បីបង្កើនតម្លាភាព និងកាត់បន្ថយនូវអំពើ ពុករលួយ ។

ដោយមានការគាំទ្រហិរញ្ញវត្ថុពីគម្រោង Asia-Urb នៃខេត្តសៀមរៀប និងខេត្តបាត់ដំបង នៃព្រះរាជាណាចក្រកម្ពុជា និងមានសហប្រតិបត្តិការខ្ពស់ រវាងដៃគូររដ្ឋបាលមូលដ្ឋាន នៃស្រុក Rhein-Sieg-Kreis ប្រទេសអាល្លឺម៉ង់ ស្រុក Spoleto ប្រទេសអ៊ីតាលី , ស្រុកសៀមរាប និងស្រុកបាត់ដំបង ដោយមានការសំរបសំរួលពីមូលនិធិ ខុនរ៉ាដ-អាដូណូអ័រ និងមានការសហការយ៉ាងជិតស្និទ ជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និងពីក្រសួងមហាផ្ទៃ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំបញ្ជូនគណៈប្រតិភូអន្តរក្រសួង[1] មួយក្រុម ដឹកនាំដោយ ឯកឧត្តម **ឈួន ឆាម** អគ្គលេខាធិការរងនៃ ក.ក.រ ដើម្បីធ្វើទស្សនកិច្ចសិក្សា និងដកស្រង់បទពិសោធមួយចំនួន ពីដំណើរការអនុវត្តន៍គោលការណ៍ "ទ្វារមួយ-ត្រាមួយ" **(one door-one stamp)** នៅខណ្ឌទី១ នៃក្រុងហូជីមិញ ចាប់ពីថ្ងៃទី ៣០ ខែមិថុនា ដល់ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០០៣ ដើម្បីរៀបចំគោលការណ៍ និង ដំណើរការអនុវត្តយន្តការ " ច្រកចេញ-ចូលតែមួយ" ក្នុងការផ្តល់សេវារដ្ឋបាល នៅកម្ពុជា ជាពិសេស ការរៀបចំអនុវត្តសាកល្បងនៅ **ស្រុកបាត់ដំបង** នៃខេត្តបាត់ដំបង **ស្រុកសៀមរាប** នៃខេត្ត សៀមរាប និង បណ្តាទីប្រជុំជនផ្សេងៗទៀត ។

ក្នុងការធ្វើទស្សនកិច្ចសិក្សានេះ គណៈប្រតិភូមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយបានការអញ្ជើញចូលរួមបើកកម្មវិធីជាផ្លូវការពីឯកឧត្តម **ស៊ុំ ម៉ានិត** រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី និងជាអគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ព្រមទាំងបានទទួលការស្វាគមន៍យ៉ាងកក់ក្តៅពីភាគីវៀតណាមតាំងពីថ្ងៃដំបូងរហូតដល់ ទស្សនកិច្ចត្រូវបានបញ្ចប់ ដោយជោគជ័យ ។

---

[1] - ដូចមានចែងនៅក្នុង ឧបសម្ព័ន្ធ២

សូមជំរាបផងដែរថា ខណ្ឌទី១ នៃទីក្រុងហូជីមិញ ជាខណ្ឌឈានមុខក្នុងការដាក់ឱ្យដំណើរការការិយាល័យ "ទ្វារមួយ-ត្រាមួយ" ក្នុងក្របខណ្ឌនៃកម្មវិធីកំណែទំរង់រដ្ឋបាលសាធារណៈ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលកំណែទំរង់ នេះបានដំណើរការអស់រយៈ ១៦ ឆ្នាំមកហើយ ដោយឡែកការិយាល័យ "ទ្វារមួយ-ត្រាមួយ" នេះបានដាក់ឱ្យដំណើរការនៅខណ្ឌទី១នៃក្រុងហូជីមិញ ចាប់តាំងពីឆ្នាំ ១៩៩៥ មកម្ល៉េះ ។

ការធ្វើកំណែទំរង់រដ្ឋបាលសាធារណៈនៅប្រទេសវៀតណាម បានផ្ដោតការយកចិត្តទុក ដាក់លើបញ្ហាពីរគឺ :

- **បញ្ហាសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
- **បញ្ហាដីធ្លី**

ដប់ប្រាំមួយឆ្នាំកន្លងមកនេះ ប្រទេសវៀតណាម តាមរយៈកម្មវិធីកំណែទំរង់ដែលរៀបចំឡើងសំរាប់រយៈពេល ១០ ឆ្នាំម្ដងៗ បានទទួលលទ្ធផលដូចតទៅ :

- ក្បាលម៉ាស៊ីនរដ្ឋបាលនៅថ្នាក់ខេត្ត-ក្រុង និង ថ្នាក់ស្រុក-ខណ្ឌ បានបន្ថយពី ២៦ការិយាល័យមកនៅ ត្រឹមពី ១១ ទៅ ១៣ ការិយាល័យប៉ុណ្ណោះ ។
- ក្បាលម៉ាស៊ីនរដ្ឋបាលរបស់ក្រសួងស្ថាប័នជំនាញ បានបន្ថយពី ៤៤ ក្រសួងស្ថាប័នជំនាញ មកនៅត្រឹម ២២ ស្ថាប័ន ជំនាញ ។
- កសាងឡើងវិញរចនាសម្ព័ន្ធ និងមុខងាររបស់គណៈកម្មាការប្រជាជននៅថ្នាក់ខេត្ត-ក្រុង និងថ្នាក់ ស្រុក-ខណ្ឌ ។
- កែសំរួលរចនាសម្ព័ន្ធ និង មុខងាររបស់ក្រុមហ៊ុន សហគ្រាសរដ្ឋ ដោយបើកទូលាយឱ្យមានការអនុវត្តរូបភាព រដ្ឋចំរុះ ឯកជន និងឯកជនភាវូបនីយកម្ម ។

លទ្ធផលដែលទទួលបានពីកំណែទំរង់នេះ បានធ្វើឱ្យសេដ្ឋកិច្ចរបស់ប្រទេសវៀតណាមកើនឡើង១០% ជារៀងរាល់ឆ្នាំ ដោយឡែកនៅក្រុងហូជីមិញ ប្រាក់ចំណូលប្រចាំឆ្នាំ (GDP) គឺមានប្រមាណ ១៦០០ ដុល្លារអាមេរិកនៅឆ្នាំ ២០០២ បើប្រៀបធៀបទៅនិង GDP របស់ប្រទេសទាំងមូលដែលមានប្រមាណ ៤០០ ដុល្លារអាមេរិក ។ ការកើន ឡើងខាងវិស័យសេដ្ឋកិច្ច ជាពិសេសខាងវិស័យឯកជន គឺតំរូវឱ្យរដ្ឋត្រូវពង្រឹងតួនាទីរបស់ខ្លួនក្នុងការធ្វើជាដៃគូជាមួយ ឯកជន និងផ្ដល់សេវាជូនដៃគូ របស់ខ្លួនឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ។

ដើម្បីសំរេចឱ្យបាននូវគោលដៅនេះ សាធារណរដ្ឋសង្គមនិយមវៀតណាម បានរៀបចំដោយម៉ត់ចត់បំផុតក្នុងការផ្លាស់ប្ដូរក្បាលម៉ាស៊ីនរដ្ឋបាលរបស់ខ្លួន ឱ្យឆ្លើយតបទៅនឹងតំរូវការរបស់ប្រជាពលរដ្ឋដោយ :

- កាត់បន្ថយភាពស្មុគស្មាញ នៃនីតិវិធីរដ្ឋបាល (ការិយាធិបតេយ្យ) ដោយមានការបង្រួមនីតិវិធីខ្លីសាមញ្ញ និងមានតម្លាភាព
- កាត់បន្ថយអំពើពុករលួយ និង អាកប្បកិរិយានាម៉ឺននិយម
- កាត់បន្ថយការប្រើប្រាស់តាមរបៀបបុរាណ ដោយជំនួសជាបណ្ដើរៗនូវបច្ចេកពត៌មានវិទ្យា និងឧបករណ៍ ទំនើប

- បង្កើននូវទំនុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋ និងបង្កើនសិទ្ធិប្រជាពលរដ្ឋក្នុងការពិនិត្យមើល កំហុសឆ្គង របស់កម្មាភិបាល បុគ្គលិករដ្ឋ តាមរយៈ ការផ្តល់ពត៌មានត្រឡប់វិញ ។

## II- ទ្វារមួយ-ត្រាមួយ

ដោយឡែក នៅទីក្រុងហូជីមិញ តាមរយៈសេចក្តីសំរេចរបស់រដ្ឋាភិបាលលេខ ៥៨ ចុះ ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ១៩៩៥ ដែលបានជ្រើសរើសយកខណ្ឌទី១ ឱ្យដំណើរការនូវការិយាល័យ "ទ្វារមួយ-ត្រាមួយ " ចាប់តាំងពីខែ ១២ ឆ្នាំ១៩៩៥ មក ដោយបាន :

▪កែសំរួលឡើងវិញនូវរចនាសម្ព័ន្ធរបស់ខណ្ឌនិងរៀបចំយន្តការទំនើប ដើម្បីដំណើរការផ្តល់សេវាសាធារណៈតាម រយៈ ក្រុមទទួលសំណុំលិខិតនិង ក្រុមឯកទេសរដ្ឋបាល

▪ជ្រើសរើសយកគោលការណ៍ ISO ៩000 និង ៩00២ ក្នុងការគ្រប់គ្រងការផ្តល់សេវា

▪ ដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធពត៌មានវិទ្យា ក្នុងការផ្តល់សេវា និងការរក្សាទុកនូវទិន្នន័យ

▪បណ្តុះបណ្តាលកម្មាភិបាល បុគ្គលិករដ្ឋការិយាល័យ "ទ្វារមួយ-ត្រាមួយ " អនុវត្តនៅខណ្ឌទី១នេះ បានដំណើរការដោយផ្តល់សេវាសាធារណៈជូនប្រជា ពលរដ្ឋលើវិស័យបួន ដែលមាន :

- សេវាកម្ម និងអាជីវកម្មពាណិជ្ជកម្ម
- សេវាកម្មផ្នែកវប្បធម៌ ព័ត៌មាន
- ការកាន់កាប់ដីធ្លី ការប្រើប្រាស់ដីធ្លី និង សំណង់
- ការធ្វើនីត្យានុកូលកម្មលើឯកសារច្បាប់ចំលងផ្សេងៗតាមសំណៅដើម ។

១. ការរៀបចំ និងដំណើរការផ្តល់សេវាសាធារណៈតាមរយៈគោលការណ៍ "ទ្វារមួយ-ត្រាមួយ " និង ការផ្តល់សេវាសាធារណៈលើវិស័យទាំងបួន (មានចែងក្នុង ឧបសម្ព័ន្ធទី១)

## III- បទពិសោធន៍ដែលដកស្រង់បានពីការអនុវត្តន៍គោលការណ៍ "ទ្វារមួយ-ត្រាមួយ " នៅខណ្ឌទី១ នៃទីក្រុងហូជីមិញ ( Lesson Learnt)

ក្រោយពីបានស្តាប់ និងពិគ្រោះយោបល់គ្នារវាងភាគីទាំងពីរ ជាពិសេសការបកស្រាយរបស់មន្ត្រីជំនាញ នានា នៅខណ្ឌទី១របស់ក្រុងហូជីមិញ គណៈប្រតិភូរបស់កម្ពុជាបានទទួលបទពិសោធន៍មួយចំនួន ក្នុងការការ អនុវត្តន៍ គោលការណ៍ "ទ្វារមួយ-ត្រាមួយ " ដើម្បីផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋ ក្រុមហ៊ុន និង សហគ្រាសនានា ដូចមាន រៀបរាប់ខាងក្រោមនេះ :

១-ការិយាល័យ "ទ្វារមួយ-ត្រាមួយ " នៅខណ្ឌទី១ ដែលបានដំណើរការអស់រយៈពេលជាង ៧ឆ្នាំមកហើយនេះ បានឆ្លុះបញ្ចាំងអោយឃើញថា រដ្ឋបាលសាធារណៈបានប្រែក្លាយពីឧបករណ៍សំរាប់តែត្រួតត្រា និងគ្រប់គ្រងប្រជាពលរដ្ឋ ទៅជាឧបករណ៍បំរើឱ្យប្រជាពលរដ្ឋ ដោយផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋ បានរហ័ស ទាន់ចិត្ត និងមានប្រសិទ្ធភាពខ្ពស់ ដោយហេតុថា មុនពេលធ្វើកំណែទំរង់រដ្ឋបាល មិនទាន់មាន ការបែងចែក ច្បាស់លាស់រវាងសេវារបស់រដ្ឋ និងសេវារបស់ប្រជាពលរដ្ឋទេ ។ ពេលខ្លះកិច្ចការរបស់រដ្ឋ ត្រូវបានប្រជាពលរដ្ឋ ធ្វើជំនួសឱ្យរដ្ឋ ដោយស្វែងរកឯកសារពីកន្លែង មួយទៅកន្លែងមួយទៀត ដើម្បីបានការអនុញ្ញាត ។ តែពេល បច្ចុប្បន្ននេះ តាមរយៈការិយាល័យ "ទ្វារមួយ-ត្រាមួយ " នេះ កិច្ចការរបស់រដ្ឋ និងកិច្ចការរបស់រាស្ត្រ ត្រូវបាន បែងចែកច្បាស់លាស់ ។

២-ដើម្បីឱ្យដំណើរការ "ទ្វារមួយ-ត្រាមួយ" នេះទទួលបានជោគជ័យ គឺចាំបាច់ត្រូវមានការ រៀបចំប្រុងប្រៀប ជាមុនអោយបានម៉ត់ចត់ :

- មានឆន្ទៈខ្ពស់ក្នុងការដឹកនាំអនុវត្ត ពោលគឺមានការប្តេជ្ញាចិត្តរបស់អ្នកដឹកនាំ ផ្សព្វផ្សាយឱ្យមន្ត្រីបានជ្រួត ជ្រាបអំពីកំណែទំរង់ជាមុនសិន មុននិងឈានទៅអនុវត្តគំរោងណាមួយនោះ ។
- កំណត់គោលដៅ ពេលវេលា និង ទីកន្លែងឱ្យបានច្បាស់លាស់
- កំណត់ការលំបាក និងឧបសគ្គឱ្យបានច្បាស់លាស់ និងមានការដោះស្រាយឱ្យបានសមស្រប និងជាពិសេស សមស្របទៅនឹងសភាពការណ៍ជាក់ស្តែងនៅមូលដ្ឋាន ។

៣-ការរៀបចំនៅមុនពេលអនុវត្ត គោលការណ៍ "ទ្វារមួយ-ត្រាមួយ" មានជួបការលំបាក ៤ គឺ :

- ការប្តេជ្ញាចិត្ត និងការឯកភាពគ្នា ( មិនងាយសំរេចបាន)
- ការវិភាគសមត្ថភាពមន្ត្រី និងការបណ្តុះបណ្តាលឡើងវិញ
- ការរៀបចំកសាងគំរោង (design)
- ការរៀបំទីស្នាក់ការ និងការបំពាក់ឧបករណ៍ទំនើប ដូចជានិង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (IT) និងការ គ្រប់គ្រងតាមស្តង់ដារអន្តរជាតិ (ISO) ។

នៅទីក្រុង ហូជីមិញ សំរាប់ ខណ្ឌទី១ នៅពេលរៀបចំអនុវត្តន៏គោលការណ៍ "ទ្វារមួយ-ត្រាមួយ" នេះកត្តាដែល លំបាកបំផុតនោះ គឺការស្វែងរកការឯកភាពគ្នា និងការប្តេជ្ញាចិត្ត របស់ថ្នាក់ដឹកនាំ ។

៤-គោលការណ៍ "ទ្វារមួយ-ត្រាមួយ" នេះបានសំរួលដល់មន្ត្រីរបស់រដ្ឋក្នុងកិច្ចការជាច្រើន ដោយបានបែងចែក យ៉ាងច្បាស់លាស់ ថាតើកិច្ចការណាជាកិច្ចការរដ្ឋបាល និងកិច្ចការណា ជាកិច្ចការជំនាញ

បច្ចេកទេសសុទ្ធសាធ ។ កិច្ចការរដ្ឋបាលត្រូវបានរ៉ាប់រងដោយក្រុមទទួលសំណុំលិខិត និងក្រុមឯកទេសរដ្ឋបាល រីឯកិច្ចការបច្ចេកទេស សុទ្ធសាធ ធ្វើឡើងដោយការិយាល័យជំនាញ ។

***ធ្វើបែបនេះអាចជៀសវៀងបាននូវ :***

- ការជាន់ភារកិច្ចគ្នា
- ការឆ្លើយដាក់គ្នាដោយគ្មានការទទួលខុសត្រូវ
- ការខ្វះខ្នាយថវិកា
- បញ្ហាអណាធិបតេយ្យរដ្ឋបាល

***ធ្វើបែបនេះនឹងទទួលបាន :***

- គំរូ ឯកភាពតែមួយគត់សំរាប់សំណុំរឿងប្រភេទតែមួយ
- កិច្ចការទំនាក់ទំនងផ្ទៃក្នុងរវាងជំនាញមួយទៅជំនាញមួយ ត្រូវរ៉ាប់រងដោយមន្ត្រីរបស់រដ្ឋ មិនត្រូវឱ្យ ប្រជាពលរដ្ឋ ធ្វើកិច្ចការនេះជំនួសមន្ត្រី ដោយរត់សំណុំឯកសារ ពីជំនាញមួយទៅជំនាញមួយទៀតទេ ព្រោះ ជាប្រការមួយធ្វើឱ្យប្រជាពលរដ្ឋនឿយហត់ និង ធុញទ្រាន់ ។
- រដ្ឋបំរើប្រជាពលរដ្ឋបានទាន់ពេល មានតម្លាភាព មានប្រសិទ្ធភាព និងឆ្លើយតបទៅនិងសំណូមពររបស់ ប្រជាពលរដ្ឋ " *រដ្ឋពិតជាបំរើប្រជាពលរដ្ឋប្រាកដមែន*" ២

**៥**-ការអនុវត្តនី " ត្រាមួយ " ពេលចាប់ផ្ដើមមានការលំបាកខ្លះ ដោយមានអ្នកខ្លះគេមិនសូវសប្បាយចិត្ត ព្រោះ គេគិតថាបាត់ផលប្រយោជន៏ សិទ្ធិអំណាច តែការពិត តាមការអនុវត្ត ៧ឆ្នាំកន្លងមក អ្នកពាក់ព័ន្ធមិនបាន បាត់សិទ្ធិអំណាច ដូចការគិតទុកនោះទេ ផ្ទុយទៅវិញ អ្នកពាក់ព័ន្ធនៅតែមានសិទ្ធិអំណាចដដែល និងកាន់តែ ច្បាស់លាស់ជាងមុន ដោយមានការបែងចែកសិទ្ធិអំណាចសំរេច និងចុះហត្ថលេខារវាងប្រធាន អនុប្រធាន ខណ្ឌ និងប្រធានការិយាល័យជំនាញនីមួយៗយ៉ាងច្បាស់លាស់ ដោយគ្រាន់តែប្រើប្រាស់ត្រារូមតែមួយរបស់គណៈ កម្មាធិការប្រជាជនខណ្ឌ ប៉ុណ្ណោះ (មេសោតែមួយ តែមានកូនសោច្រើន)។ អ្នកកាន់កូនសោ មានសិទ្ធិបើកសោ តាមកិរិតទទួលខុសត្រូវច្បាស់លាស់រៀងៗខ្លួន ដែលខុសពីមុន អង្គភាពនីមួយៗ មានមេសោ និង កូនសោ ផ្សេងៗគ្នា និងស្ថិតនៅកន្លែងទីទៃពីគ្នា ហើយទាល់តែបើកសោទាំងអស់ ទើបប្រជា ពលរដ្ឋអាចទទួលការ អនុញ្ញាតពីរដ្ឋបាន ។ មានន័យថាប្រជាពលរដ្ឋត្រូវចំណាយពេលវេលាច្រើនបំផុត ។

**៦**-ការផ្ដល់សេវាសាធារណៈតាម "ទ្វារមួយ-ត្រាមួយ" នេះត្រូវមានការកំណត់ :

- *ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធឱ្យបានច្បាស់លាស់*

- ពេលវេលាទទួល និង ផ្តល់ចំលើយឱ្យបានច្បាស់លាស់
- ពេលវេលារបស់ជំនាញនីមួយៗ ក្នុងការ សំរេចការងារឱ្យបានច្បាស់លាស់
- ក្នុងករណី សំណើរបស់ប្រជាពលរដ្ឋពុំត្រូវបានទទួលការអនុញ្ញាត ក៏ត្រូវមានចំលើយច្បាស់លាស់ដែរ ។

**៧**-ការចុះពិនិត្យការដ្ឋានជាក់ស្តែង ដើម្បីធ្វើការសេចក្តីសំរេចបែបណាមួយនោះ បើមានករណីពាក់ព័ន ទៅនឹង ជំនាញច្រើន ត្រូវលៃយ៉ាងណាឱ្យមានការឯកភាពគ្នា ចុះពិនិត្យព្រមៗគ្នា ជៀសវៀងការធ្វើឡើងដោយ បណ្តាក់គ្នា ដែលនាំឱ្យខាតពេល និងថវិកា ។

**៨**-ដំណើរការអនុវត្ត គោលការណ៍ "ទ្វារមួយ-ត្រាមួយ" នេះត្រូវមានការតាមដាន និងត្រួតពិនិត្យជាប់ជាប្រចាំនិងម៉តចត់ ដោយបង្កើតតារាងត្រួតពិនិត្យមួយសំរាប់តាមដានដំណើរការពិនិត្យសំណុំឯកសារ (Dossiers) ដើម្បីដឹងថា ថ្ងៃនេះរត់ដល់កន្លែងណា ការិយាល័យណា ធ្វើការផ្ទៀងផ្ទាត់ទៅនឹងរយៈពេលកំណត់ក្នុងការ ពិនិត្យ ដែលបានកំណត់ទុកជាមុនរួចហើយ ។ តារាងត្រួតពិនិត្យនេះ គឺទាំងប្រធានខណ្ឌ ទាំងមន្ត្រីជំនាញ និងប្រជាពលរដ្ឋ អាចចូលមើលបានដោយចំហ ។

**៩**-"ទ្វារមួយ-ត្រាមួយ" នេះ ជាកន្លែងផ្តល់សេវាជូនប្រជាពលរដ្ឋ តាមវិធីដែលមានប្រសិទ្ធភាព ដូចនេះការគ្រប់គ្រង"ទ្វារមួយ-ត្រាមួយ" ត្រូវអនុវត្តតាមគោលការណ៍ **ISO** ៩០០០ ឬ ៩០០២ និងប្រើប្រាស់ប្រពន្ធ័ពត៌មានវិទ្យា នៅក្នុងការចុះបញ្ជី សេវាកម្ម អាជីវកម្ម ។ ការយកគោលការណ៍ **ISO** មកគ្រប់គ្រងមានគោលដៅ ៣ :

- កែសំរួលរបៀបរបបការងារ
- ផ្តោតការទទួលខុសត្រូវលើគុណភាព
- ជួយអ្នកដឹកនាំឱ្យធ្វើការវិនិច្ឆ័យ និងសំរេចបានត្រឹមត្រូវ

**១០**-ការផ្តល់សេវាសាធារណៈត្រូវធ្វើការកែសំរួលជាប្រចាំ ដោយផ្អែកទៅលើយោបល់របស់អតិថិជនប្រជា ពលរដ្ឋជានិច្ច។ ការផ្សព្វផ្សាយកិច្ចការរដ្ឋបាល និងសេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបានជ្រួតជ្រាប ជាការ ចាំបាច់ និងខានមិនបាន។ ឧទាហរណ៍ កម្មសិទ្ធិដីធ្លី ខណ្ឌត្រូវធ្វើជូនប្រជាពលរដ្ឋតាមការស្នើសុំ និងត្រូវជំរុញឱ្យ ប្រជាពលរដ្ឋមកធ្វើ និងមានកម្មវិធីមួយធ្វើកម្មសិទ្ធិជូន ប្រជាពលរដ្ឋតាមផែនការ ។

**១១**-នីតិវិធី និងខ្លឹមសារឯកសារ ត្រូវផ្សព្វផ្សាយជូនប្រជាពលរដ្ឋដោយផ្អែកលើច្បាប់ជាធំ មិនត្រូវបកស្រាយ អ្វីដែលផ្សេងពីច្បាប់បានកំណត់ឡើយ ។

**១២**-កំណែទម្រង់រដ្ឋបាល បានធ្វើឡើងទន្ទឹមគ្នានឹងកំណែទម្រង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់នូវទៅប្រសិទ្ធភាព ធ្វើឱ្យមានកំណើនសេដ្ឋកិច្ច ។ លទ្ធផលនៃការធ្វើរបៀបនេះ ធ្វើឱ្យផ្នែកឯកជននៅទីក្រុងហូជីមិញ មាន សកម្មភាពរីកចំរើនយ៉ាងខ្លាំងក្លា ជាពិសេសលើវិស័យផលិតកម្ម និងសេវាកម្មទេសចរណ៍ ។ សេដ្ឋកិច្ច របស់វៀតណាម មានកំណើន ១០% ជារៀងរាល់ឆ្នាំ ។

## ឯកសារឧបសម្ព័ន្ធ

ឧបសម្ព័ន ១ - ការរៀបចំ និងដំណើរការផ្តល់សេវាសាធារណៈតាមរយៈគោលការណ៍ "ទ្វារមួយ-គ្រាមួយ"

ឧបសម្ព័ន ២ - សមាសភាពគណៈប្រតិភូកម្ពុជា

ឧបសម្ព័ន្ធ ៣ - សមាសភាពភាគីវៀតណាម

ឧបសម្ព័ន ៤ - តារាងរចនាសម្ព័ន្ធគណៈកម្មាធិការកំណែទំរង់រដ្ឋបាលក្រុងហូជីមិញ

ឧបសម្ព័ន ៥- កម្មវិធីនៃទស្សនកិច្ចសិក្សា

ភ្នំពេញ, ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៣

**ប្រធានក្រុមគណៈប្រតិភូ**

**ឈួន ឆាម**

**អ្នកទទួលខុសត្រូវការងារបច្ចេកទេស**

**ហុក ប៉េងសែ**

# ឧបសម្ព័ន្ធ ១

## ក ~ ការរៀបចំ និងដំណើរការផ្តល់សេវាសាធារណៈតាមរយៈគោលការណ៍ "ទ្វារមួយ~ត្រាមួយ" (One Stop, one Stamp) នៅ ទីក្រុងហូជីមិញ

### ១. និយមន័យ

**ក- "ទ្វារមួយ"** គឺជាគំរូទំនាក់ទំនងសំខាន់មួយសំរាប់ទទួល សំរាប់ដំណើរការ និងសំរាប់ផ្តល់លទ្ធផលត្រលប់ទៅវិញអំពីការចាត់ចែងដោះស្រាយឯកសាររដ្ឋបាលជូនប្រជាពលរដ្ឋ និងចំពោះក្រុមហ៊ុនឯកជន និងចំពោះអតិថិជននានា។

**ខ- "ត្រាមួយ"** គឺជាការបញ្ជាក់អំពីឯកភាពនៃអំណាចរបស់រដ្ឋនៅថ្នាក់រដ្ឋាភិបាលនិមួយៗ។ នាយកដ្ឋានជំនាញនៅក្រោមថ្នាក់រដ្ឋាភិបាលគឺជានាយកដ្ឋានគាំទ្រ ដែលគ្មានការទទួលខុសត្រូវ តាមផ្លូវច្បាប់ពេញលេញ និងដោយគ្មានត្រាផ្ទាល់ខ្លួនឡើយ។

### ២. គោលដៅ និងលក្ខ័ណ្ឌចាំបាច់

### ១. គោលដៅ

- កសាងរដ្ឋបាលសាធារណៈមួយដែលមានតំលាភាពហើយស្ថិតកាន់តែកៀកជាមួយប្រជាពលរដ្ឋ បំរើប្រជាពលរដ្ឋនិងឆ្លើយតបនឹងកាតព្វកិច្ចផ្សេងៗនៃការផ្តល់សេវាសាធារណៈចំពោះ *អតិថិជន* *អោយ* បានប្រសើរបំផុត។
- កាត់បន្ថយផលអវិជ្ជមាន ភាពធុញទ្រាន់ និងការបំពារបំពានពីសំណាក់មន្ត្រីរដ្ឋការទៅលើ អតិថិជន។
- លុបបំបាត់ចោលនូវបទប្បញ្ញត្តិដែលបង្កបញ្ហាចំពោះអតិថិជន
- ជំនះរបៀបរបបធ្វើការដោយដៃ ឈានទៅរកការកសាងរដ្ឋបាលសាធារណៈដែលមានលក្ខណៈ វិទ្យាសាស្ត្រ និងទំនើប ប្រកបដោយវិន័យនិងប្រសិទ្ធភាពខ្ពស់។
- រៀបចំនិងធ្វើអោយនីតិវិធីសាធារណៈនានាមានលក្ខណៈសាមញ្ញ ហើយចាត់ចែងសំណុំឯកសាររដ្ឋបាលដើម្បីសំរួលលទ្ធភាពទទួលរបស់អតិថិជន ហើយម្យ៉ាងវិញទៀត អោយអតិថិជនអាចតាមដានភារកិច្ចរបស់មន្ត្រីរដ្ឋការ។
- បង្កើនសមត្ថភាព បង្កើនការយល់ដឹង បង្កើនការទទួលខុសត្រូវ និងលើកកំពស់ឥរិយាបថមន្ត្រីរដ្ឋការចំពោះអតិថិជន។
- ជាបណ្តើរៗ បង្កើនប្រសិទ្ធភាព និងបង្កើនផលល្អនៃការគ្រប់គ្រងរបស់រដ្ឋនៅក្នុងផ្នែកនេះ។

## ២. លក្ខ័ណ្ឌនានា

- ដើម្បីអនុវត្តអោយមានផ្លែផ្កានៃគំរូ "ច្រកមួយ" និងយន្តការ "ត្រាមួយ" ចាំបាច់ត្រូវមានការរៀបចំចាត់ចែងល្អ។
- ផ្នែកដែលត្រូវបានជ្រើសរើសសំរាប់ធ្វើការសាកល្បងគប្បីជាផ្នែកដែលមានតំរូវការបន្ទាន់ពីប្រជាពលរដ្ឋនិងពីស្ថាប័ន។
- បង្កើតអោយមានការផ្លាស់ប្តូរជាដុំកំភួននៅក្នុងស្ថាប័នអនុវត្តន៏ ហើយធ្វើកំណែទំរង់ជាមូលដ្ឋានអំពីបែបបទធ្វើការងារនៃយន្តការគ្រប់គ្រងរបស់រដ្ឋចំពោះសេវាអតិថិជន។
- ជំហានដែលមានសនិទានភាព និងការកែលំអជាបណ្តើរៗ។
- មន្ត្រីរដ្ឋការយល់ដឹងពេញលេញអំពីតំរូវការក្នុងការអនុវត្តន៏គំរូរដ្ឋបាល "ច្រកមួយ ត្រាមួយ" ដើម្បីសំរេចបាននូវលទ្ធផលដែលចង់បាន។

## ៣. របៀបរៀបចំចាត់ចែង

### ១. ចំពោះស្ថាប័ន និងចំពោះបុគ្គលិក

- បង្កើតគណៈកម្មាធិការដឹកនាំ PAR ថ្នាក់ស្រុក
- បង្កើតគំរោងស្នើនានា និងស្នើសុំអោយមានការអនុវត្តន៏សាកល្បងនូវគំរូ "ច្រកមួយ ត្រាមួយ" នៅថ្នាក់ស្រុក។
- ពិនិត្យមុខងារ ពិនិត្យភារកិច្ច និងពិនិត្យលក្ខន្តិកៈធ្វើការងារសារឡើងវិញនៃនាយកដ្ឋានពាក់ព័ន្ធ ដើម្បីអោយមានការរៀបចំចាត់ចែងសារឡើងវិញដែលមានការតឹមតំរង់និងដែលមាន ប្រសិទ្ធភាព។
- វិភាគ វាយតំលៃ និងតែងតាំងមន្ត្រីរដ្ឋការសារឡើងវិញ។
- ជំរុញសមត្ថភាព និងអនុវត្តការជ្រើសរើសបុគ្គលិកក្នុងគោលបំណងធ្វើអោយមានស្តង់ដារនៃជំហានរៀបចំមុខតំណែងរបស់បុគ្គលិក។

### ២. ចំពោះបញ្ហាសំភារៈ

- ធ្វើកន្លែងធ្វើការងារអោយទៅជាតំបន់រដ្ឋបាលដែលមានលក្ខណៈប្រមូលផ្តុំ
- ដាក់ការិយាល័យទទួលឯកសារចូល ចាត់ចែងដំណើរការឯកសារ និងផ្តល់ឯកសារត្រលប់ទៅអោយអតិថិជនវិញតាមបែបងាយស្រួល និងមានភាពកក់ក្តៅ។
- បង្កើតមណ្ឌលតំកល់ឯកសារកាលប្បវត្តិដែលឆ្លើយតបទៅនឹងស្តង់ដារដែលបានកំណត់។
- ដាក់បញ្ចូលគ្នានូវចំណុចស្នូលទាំងឡាយដែលពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូល-ចំណាយអោយនៅមួយកន្លែង។ នោះគឺការិយាល័យគណៈកម្មាធិការនិងក្រុមប្រឹក្សាប្រជាជន។

### ៣. ចំពោះនីតិវិធី និងដំណើរការចាត់ចែងសំណុំឯកសារ

- កំណត់អត្តសញ្ញាណផ្នែកជាក់លាក់សំរាប់អនុវត្តដំណើរការរដ្ឋបាលច្រកតែមួយ និងកំណត់អត្តសញ្ញាណជំហាននានាក្នុងការដកហូតត្រាពីនាយកដ្ឋានផ្សេងៗ ដើម្បីប្រើប្រាស់ត្រាផ្លូវការរបស់រដ្ឋាភិបាលថ្នាក់ស្រុកនៅក្រោមយន្តការនៃការផ្ទេរអោយមានការទទួលខុសត្រូវ ។
- ពិនិត្យសារឡើងវិញនូវឯកសារដែលមានលក្ខណៈជាបទដ្ឋានច្បាប់ និងឯកសារពាក់ព័ន្ធដទៃ ទៀត ។
- ផ្អែកលើមូលដ្ឋានច្បាប់ដែលមានស្រាប់ ដើម្បីពិនិត្យសារឡើងវិញ និងដើម្បីរៀបចំឯកសាររដ្ឋបាលតាមលំដាប់ប្រភេទនិមួយៗ ។ បំបាត់ចោលនូវនីតិវិធីនានាដែលមិនពាក់ព័ន្ធ ។ ចំពោះករណីដែលហួសពីសមត្ថភាពរបស់អាជ្ញាធរ លើកសំណើទៅថ្នាក់លើស្នើសុំអោយមាន វិសោធនកម្ម ឬស្នើសុំអោយមានការបន្ថែម ឬលុបចោល ។
- ពិនិត្យមុខចំណូលសារឡើងវិញៈ រួមមានការយកថ្លៃឈ្នួល ប្រាក់បន្ទុក និងយកថ្លៃសេវា (ប្រសិនបើអាចធ្វើបាន)...
- ពិនិត្យមើលសារឡើងវិញនូវសនិទានភាវូបនីយកម្មនៃដំណើការទទួល ចាត់ចែងដំណើរការ សំណុំឯកសារ និងដោះស្រាយតាមប្រភេទឯកសាររដ្ឋបាលនិមួយៗ ។
- បង្កើតដំណើរការនៃទំនាក់ទំនងរវាងនាយកដ្ឋានពាក់ព័ន្ធ
- ធ្វើអោយមានលក្ខណៈជាប្រព័ន្ធនូវឯកសារបទដ្ឋានច្បាប់ចំពោះផ្នែកនិមួយៗ ។
- ពិនិត្យសារឡើងវិញ ធ្វើអោយមានលក្ខណៈជាប្រព័ន្ធ និងកំណត់មុខងារនិងភារកិច្ចអោយបានច្បាស់លាស់របស់នាយកដ្ឋាននានា ។ ធ្វើបែបនេះអនុញ្ញាតិអោយប្រធាននានាអនុវត្តបានកាន់តែប្រសើរនូវការកែតំរូវ និងវិមជ្ឈការ ។
- ធ្វើអោយមានលក្ខណៈជាស្តង់ដារ និងឯកភាពគ្នាលើទំរង់នៃឯកសារផ្លូវការដែលមានចែងនៅក្នុងក្របខ័ណ្ឌនៃអំណាចដែលត្រូវបានអនុញ្ញាតិ ។
- ធ្វើអោយមានលក្ខណៈសុក្រឹត និងផ្សព្វផ្សាយជាសាធារណៈនូវខ្លឹមសារដែលមានរៀបរាប់ ខាងលើតាមវិធីផ្សេងៗគ្នា ។
- បណ្តុះបណ្តាលមន្ត្រីរដ្ឋការអំពីដំណើរការរដ្ឋបាល និងអំពីយន្តការថ្មីនៃការប្រើប្រាស់ត្រា ។
- បង្កើនការផ្សព្វផ្សាយ និងការណែនាំចំពោះអតិថិជន ដើម្បីអោយមានការឆ្លើយតបរបស់ខ្លួន និងដើម្បីអនុវត្តនៅពេលចាំបាច់ ។

# ៤. គំរូច្រកមួយ ត្រាមួយ

## ១. ដំណើរការ "ទ្វារមួយ"

- ស្ថាប័ន និងពលរដ្ឋដែលត្រូវការអោយសំណុំឯកសាររបស់ខ្លួនបានទទួលការដោះស្រាយស្រប ជាមួយបញ្ញត្តិច្បាប់នានា គឺគ្រាន់តែចូលហើយជួបក្រុមអ្នកទទួលឯកសារដែលស្ថិតនៅក្នុងផ្នែក សេវាសាធារណៈនៅ ក្នុងការិយាល័យគណៈកម្មាធិការប្រជាជន ដើម្បីសុំអោយមានការណែនាំ ការដាក់ជូន និងការយកចុងសន្លឹកប័ណ្ណបញ្ជាក់អំពីការទទួលសំណុំឯកសារ ។

- ផ្អែកលើថ្ងៃណាត់ដែលកំណត់នៅក្នុងចុងសន្លឹកប័ណ្ណទទួលឯកសារ អតិថិជនវិលមកជួបបុគ្គលិក ដែលបានទទួលសំណុំឯកសាររបស់ខ្លួនមុននេះ ដើម្បីទទួលលទ្ធផល ។

- នៅកន្លែងនៃក្រុមទទួលឯកសារ គេនឹងជួយណែនាំ ព្រមទាំងស្វាគមអតិថិជន ព្រោះថាគេជា អគ្គាហាកនៃសេវាសាធារណៈ ។

- អតិថិជនមិនចាំបាច់ធ្វើដំណើរច្រើនដូចដែលគេធ្លាប់ធ្វើពីមុននោះទេ ។ ការសិក្សា ការវាយតំលៃ និងការដោះស្រាយសំណុំឯកសារគឺជាភារកិច្ចទាំងស្រុងរបស់ទីភ្នាក់ងារមានសមត្ថកិច្ចនៅក្នុង យន្តការរបស់រដ្ឋ សំរាប់អនុវត្ត ។

- បរិធានរដ្ឋ និងមន្ត្រីរដ្ឋការបានបញ្ជាក់ជាថ្មីម្តងទៀតនូវភារកិច្ចរបស់ខ្លួនក្នុងការបំរើប្រជាពលរដ្ឋ ជជាងបណ្តោយអោយអតិថិជនទាក់ទងដោយខ្លួនឯងចំពោះទីភ្នាក់ងាររបស់រដ្ឋដូចលើកមុន ។ ប្រការនេះពិតជាបញ្ជាក់អោយឃើញអំពី "សេចក្តីក្លាហាន" របស់មន្ត្រីរដ្ឋការនៅក្នុងការផ្តល់ សេវាសាធារណៈ ។

- ដោះស្រាយសំណុំឯកសារដោយដំណើរការសាមញ្ញ មានលក្ខណៈវិទ្យាសាស្ត្រ និងមាន សទិទានភាព ជួយបញ្ជាក់អោយមានការទទួលខុសត្រូវ បញ្ជាក់អំពីសមត្ថកិច្ច និងពេលវេលានៃ ដំណាក់កាលនិមួយៗ និងដោយមន្ត្រីរដ្ឋការម្នាក់ៗ ។

- ភារកិច្ចត្រូវតែបញ្ជាក់តាមរយៈក្រដាសត្រួតពិនិត្យផ្ទៃក្នុង នៅក្នុងដំណើរការផ្ទេរសំណុំឯកសារ រវាងទីភ្នាក់ងារនានា ( ដោយផ្អែកលើភារកិច្ចដែលមានបញ្ជាក់នៅក្នុងតារាងរចនាសម្ព័ន្ធ ការងារ) ។

- ជាបណ្តើរៗផ្ទេររដ្ឋបាលពីយន្តការដែលមានចរិតជា big-offer "ទៅជា" ការបំរើអតិថិជន :
¬Gradually transfer the administration from "big-offer" mechanism to "customer service"

## ២. លទ្ធផលនិងអត្ថន័យនៃដំណើរការ "ទ្វារមួយ"

- ជាមធ្យមសំណុំឯកសាររដ្ឋបាលគ្រប់បែបជាង ៩៨% ត្រូវបានដោះស្រាយទាន់ពេលវេលា ស្របតាមច្បាប់ ។
- គុណភាពនៃសេវាសាធារណៈកាន់តែប្រសើរ ហើយកាន់តែធ្វើអោយអតិថិជនពេញចិត្ត ។
- រៀបចំនីតិវិធីសាធារណៈ ដែលមិនតំរូវអោយបង់ប្រាក់ ហើយធ្វើការចាត់ចែងដោះស្រាយសំណុំឯកសារ...ជួយសំរួលអោយប្រជាពលរដ្ឋមានលទ្ធភាពតាមដាននិងវាយតំលៃកិច្ចការរបស់ មន្ត្រីរដ្ឋការ ។
- ពេលវេលាធ្វើដំណើរ ការរំខាន និងការរំលោភបំពានផ្សេងៗដែលបង្កដោយមន្ត្រីរដ្ឋការត្រូវបានកាត់បន្ថយ ។
- ពង្រឹងជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋនៅក្នុងបក្ស និងក្នុងរដ្ឋាភិបាល ព្រមទាំងកាត់បន្ថយការតវ៉ាពីសំណាក់ប្រជាពលរដ្ឋ ។
- អតិថិជនត្រូវបានគេគោរពនិងបំរើប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីសំណាក់មន្ត្រីរដ្ឋការ ។
- ថ្នាក់ដឹកនាំធ្វើអោយការសន្យាចំពោះអតិថិជនអនុវត្តបាន ហើយរក្សាគោលការណ៍ដូចគ្នានេះតាំងពីដើមទី ។
- សមត្ថភាព និងការយល់ដឹងអំពីការទទួលខុសត្រូវរបស់មន្ត្រីរដ្ឋការត្រូវបានបង្កើន ។ មន្ត្រីរដ្ឋការម្នាក់ៗមានកាតព្វកិច្ចគោរពនីតិវិធី និងដំណើរការនានាដែលបានអនុម័ត ។
- ការសំរបសំរួលរវាងនាយកដ្ឋាននានាជាមួយមន្ត្រីរដ្ឋការកាន់តែកៀកជិតគ្នា ហើយកាត់បន្ថយភារកិច្ចដែលត្រូវរុញដាក់អោយគ្នាទៅវិញទៅមក ឬកាត់បន្ថយសភាពដែលទុកអោយប្រជាពលរដ្ឋធ្វើទៅតាមដំណើររបស់ខ្លួន ។

## ៣. យន្តការ "ត្រាមួយ"

- ជាមួយនឹងទស្សនៈស្តីពីឯកភាពនៃអំណាចរបស់រដ្ឋនៃរដ្ឋាភិបាលនៅថ្នាក់និមួយៗ
- ប្រធាននាយកដ្ឋានដែលត្រូវបានអភិបាលស្រុកប្រគល់ភារកិច្ចអោយ និងផ្តល់សមត្ថកិច្ចអោយប្រើត្រាស្រុកជាផ្លូវការ ដើម្បីបង្កើតឯកសារមួយចំនួន ។
- បណ្តានាយកដ្ឋានជំនាញគឺពិតជានាយកដ្ឋានទ្រទ្រង់គណៈកម្មាធិការប្រជាជនស្រុក ។

## ៤. លទ្ធផល និងអត្ថន័យនៃដំណើរការ "ត្រាមួយ"

- ការយល់ដឹង ភារកិច្ច និងភាពជាកម្មសិទ្ធនៃប្រធាននាយកដ្ឋាននានាត្រូវបានបង្កើន
- ការអនុម័តឯកសារផ្លូវការដែលមានចរិតបំពានត្រូវបានទប់ស្កាត់
- ថ្នាក់ដឹកនាំនៃគណៈកម្មាធិការស្រុកបានកាត់បន្ថយបន្ទុកការងារប្រតិបត្តិការប្រចាំថ្ងៃពី ៤០% ទៅ ៥០% ចំពោះការផ្តោតលើការណែនាំ និងគ្រប់គ្រងកិច្ចការស្នូលជាយុទ្ធសាស្ត្រ ។

## ៥. មេរៀន

- ក្រុមនៃថ្នាក់ដឹកនាំដែលមានមុខងារជាប្រធានកំណត់ជោគជ័យរបស់ PAR ហើយមន្ត្រីរដ្ឋការត្រូវមានការប្តេជ្ញាម៉ឺងម៉ាត់ជាលាយល័ក្ខអក្សរនិងជាសកម្មភាពជាក់ស្តែង។
- មានការចាំបាច់ក្នុងការកសាងបុគ្គលមានសមត្ថភាព និងមានការប្តេជ្ញាខ្ពស់ចំពោះ PAR ។
- បង្កើនការពិនិត្យមើលទំនាក់ទំនងរវាងថ្នាក់ដឹកនាំនិងប្រជាពលរដ្ឋ។
- ចាត់វិធានការម៉ឺងម៉ាត់ចំពោះមន្ត្រីរដ្ឋការទាំងឡាយណាដែលធ្វើអោយរាំងស្ទះ និងដែលមានឥរិយាបថច្រងេងច្រងាង និងបំពារបំពានលើអតិថិជន។
- បង្កើនការអនុវត្តន៍ឧបករណ៍ទំនើបដើម្បីទ្រទ្រង់និងកែលំអ PAR ដូចជា ISO ពត៌មានវិទ្យា អង្កេតអតិថិជន ការញែកចេញពីគ្នារវាងការគ្រប់គ្រងសេវាសាធារណៈនិងការគ្រប់គ្រងរបស់រដ្ឋ ស្វ័យភាពអំពីថវិកា និងការបើកប្រាក់បៀវត្សរ៍។

# (ខ)- ប្រើប្រាស់គោលការណ៍ "ទ្វារមួយ-ត្រាមួយ " សំរាប់ ការផ្តល់សេវាសាធារណៈលើវិស័យនាំមុន

១- ការចុះបញ្ជីពាណិជ្ជកម្ម

២- ការចុះបញ្ជីសេវាកម្មផ្នែកវប្បធម៌ និងពត៌មាន

៣- វិញ្ញាបនប័ត្រកម្មសិទ្ធិដីធ្លី សាងសង់ផ្ទះសម្បែង និងសំណង់

៤- ការបញ្ជាក់លើឯកសារថាត្រឹមត្រូវតាមច្បាប់ដើម ការធ្វើនីត្យានុកូលភាពលើច្បាប់ចំលងផ្សេងៗ (ចំពោះឯកសារថតចំលង)

# ឧបសម្ព័ន្ធ ២

## សមាសភាពគណៈប្រតិភូកម្ពុជា

គណៈប្រតិភូកម្ពុជាដែលបានទៅធ្វើទស្សនកិច្ចសិក្សាផ្លូវការ ដើម្បីដកស្រង់ និងផ្លាស់ ប្តូរ នូវបទពិសោធន៍ពី ការរៀបចំ ការបង្កើត ដំណើរការប្រព្រឹត្តិ ទៅ និងការគ្រប់គ្រង ការិយាល័យ "ទ្វារមួយ- ត្រាមួយ" នៅ សាធារណរដ្ឋសង្គមនិយមវៀតណាម មានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- | ឯកឧត្តម **ឈួន នាម** | អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល — ជាប្រធានគណៈប្រតិភូ |
| ២- | លោក **ហុក ម៉េងសែ** | ប្រធានគំរោងវិមជ្ឈការ វិសហមជ្ឈការ និងការកែលំអសេវាសាធារណៈ អ្នកសំរបសំរួលកម្មវិធីទស្សនកិច្ចសិក្សា |
| ៣- | លោក **នេង សារឿន** | អគ្គនាយករងបច្ចេកទេស នៃក្រសួងពាណិជ្ជកម្ម |
| ៤- | លោក **ជួង ពេជ្រ** | អនុប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងសាធារណការ និងដឹកជញ្ជូន |
| ៥- | លោក **ម៉ុ តី** | អនុប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ |
| ៦- | លោក **ចាន់ សារ៉ា** | នាយរងខុទ្ទកាល័យនៃសាលា ខេត្តសៀមរាប |
| ៧- | លោក **ចាន់ ធី** | នាយកហិរញ្ញវត្ថុឃុំ- សង្កាត់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៨- | លោក **សួន ដារ៉ា** | អនុប្រធានការិយាល័យស្រាវជ្រាវ នៃក្រសួងមហាផ្ទៃ |
| ៩- | លោក **សួស សុដារត** | ប្រធានការិយាល័យរបៀបនៃសាលាខេត្តបាត់ដំបង |
| ១០- | លោក **រស់ ថាច់សន** | នាយកគំរោង កម្មវិធីនគររូបនីយកម្មអាស៊ី |
| ១១- | លោក **ជន ស៊ីន** | ជំនួយការបច្ចេកទេស GTZ នៃគំរោងវិមជ្ឈការ និង វិសហមជ្ឈការនិងសេវាសាធារណៈនៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល |
| ១២- | លោក **ណុប ផល** | ជំនួយការបច្ចេកទេស GTZ នៃគំរោងវិមជ្ឈការ និង វិសហមជ្ឈការនិងសេវាសាធារណៈនៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល |
| ១៣- | លោក **សូ ឬទ្ធតុង** | អភិបាលរងស្រុកសៀមរៀប នៃខេត្តសៀមរាប |
| ១៤- | លោក **តូច ថុន** | នាយរងខុទ្ទកាល័យនៃសាលាខេត្តបាត់ដំបង |
| ១៥- | លោក **ជា សុវណ្ណនុម** | អ្នកបកប្រែ |

របាយការណ៍លទ្ធផលនៃកិច្ចប្រជុំ

ស្ដីពីការរៀបចំដាក់អោយដំណើរការការផ្ដល់សេវាកម្មរដ្ឋបាលតាមច្រកចេញ-ចូល

តែមួយនៅស្រុកបាត់ដំបង និងស្រុកសៀមរាបថ្ងៃទី ២១-២៤ ធ្នូ ឆ្នាំ ២០០៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ឧត្តមក្រុមប្រឹក្សា កំណែទំរង់រដ្ឋ

៚

ក្រុមប្រឹក្សា កំណែទំរង់រដ្ឋបាល

អគ្គលេខាធិការដ្ឋាន

លេខ: ០០៩/០៤ រ.ដ.ក

# របាយការណ៍លទ្ធផលនៃកិច្ចប្រជុំ

## ស្តីពីការរៀបចំដាក់ឱ្យដំណើរការការផ្តល់សេវាកម្មរដ្ឋបាល តាមច្រកចេញ-ចូលតែមួយនៅស្រុកបាត់ដំបង និងស្រុកសៀមរាប

(ថ្ងៃ ទី ២១ ដល់ទី ២៤ ធ្នូ ឆ្នាំ ២០០៣)

**យោង :** - តាមស្មារតីនៃសេចក្តីសំរេច លេខ ៤៧ ចុះថ្ងៃទី ១១ មិថុនា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីអំពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាប នៃខេត្តសៀមរាប និងស្រុកបាត់ដំបង នៃខេត្តបាត់ដំបង ។

- តាមស្មារតីនៃអង្គសិក្ខាសាលាកាលពីថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០០៣ ស្តីអំពី ការរៀបចំដើម្បីដាក់អោយអនុវត្តន៍សាកល្បងនូវការផ្តល់សេវាកម្មរដ្ឋបាលតាម "**ច្រកចេញ-ចូលតែមួយ**" នៅស្រុកបាត់ដំបង ស្រុកសៀមរាប និងទីប្រជុំជនមួយចំនួន ។

ដើម្បីអនុវត្តអោយបានជោគជ័យនូវកម្មវិធីបង្ហិតរដ្ឋបាលសាធារណៈ ទៅជិតប្រជាពលរដ្ឋ ដែលគណៈរដ្ឋមន្ត្រីបានអនុម័តកាលពី ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០១ និងសេចក្តីសំរេច លេខ ៤៧ លេខ ៤៧ ចុះថ្ងៃទី ១១ មិថុនា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីអំពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាប និងស្រុកបាត់ដំបង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដែលជាស្ថាប័ន សម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធនានា ក្នុងដំណើរការរៀបចំដាក់អោយអនុវត្តសាកល្បង នូវការផ្តល់ សេវាកម្មរដ្ឋបាលតាមគោលការណ៍ច្រកចេញ-ចូលតែមួយ នៅស្រុកបាត់ដំបង នៃខេត្តបាត់ដំបង និង ស្រុកសៀមរាប នៃខេត្តសៀមរាប បានរៀបចំទស្សនៈកិច្ចសិក្សាអន្តរក្រសួងមួយនៅស្រុកសាកល្បងទាំងពីរ កាលពី ថ្ងៃទី ២១ ខែធ្នូ ដល់ថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០០៣ ដែលមានសមាសភាពដូចខាងក្រោម :



ទីស្នាក់ការស្ថិតនៅ ទីស្តីការគណៈរដ្ឋមន្ត្រី មហាវិថីសហព័ន្ធរុស្ស៊ី រាជធានី ភ្នំពេញ
ទូរស័ព្ទ : (៨៥៥) ០២៣-៨៨ ១៣ ០៧ ប្រអប់សំបុត្រលេខ ១២៨១ ទូរសារ: (៨៥៥) ០២៣-៣៦ ២១ ៥១

**សមាសភាពគណៈប្រតិភូ :**

-ឯកឧត្តម ទេព ដារ៉ុង អគ្គលេខាធិការស្តីទីក.ក.រ និងជាសមាជិក STF ជាប្រធានគណៈប្រតិភូ

-លោក ហុក ប៉េងសែ ប្រធានគំរោងវិម្ឋការ-វិសហម្ឋការ និងសេវាសាធារណៈនៃក.ក.រ

-លោក ផន ស៊ីន មន្ត្រីបច្ចេកទេស គំរោងវិម្ឋការ-វិសហម្ឋការ និងសេវាសាធារណៈនៃក.ក.រ

-លោកម៉ាង គីណាល់ មន្ត្រីបច្ចេកទេស គំរោងវិម្ឋការ-វិសហម្ឋការ និងសេវាសាធារណៈនៃក.ក.រ

-លោក គីម ទូច តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-លោក ម៉ី ភី តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-លោក ម៉ុក ឃុនវុឌ្ឍន៍ តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-លោក ដួង វីរៈ តំណាងក្រសួងទេសចរណ៍

-លោក គីម វុឌ្ឍនៈសោភ័ណ តំណាងក្រសួងមហាផ្ទៃ

-លោក ប៊ូ វង្សសុខា តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-លោក ឃឹម សិរីវង្ស តំណាងក្រសួងពាណិជ្ជកម្ម

-លោកមាសមូនីកា ត្រំណាងក្រសួងសាធារណៈការនិងដឹកជញ្ជូន

-លោក ស្រី សិរីវឌ្ឍន៍ តំណាងក្រសួងសាធារណៈការនិងដឹកជញ្ជូន

-លោកហ៊ី លឹមសេង តំណាងកសួងសាធារណៈការនិងដឹកជញ្ជូន

-លោក រស់ ថាន់សន តំណាង Asia Urbs

**ដំណើរការកិច្ចប្រជុំ :**

ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៣ - ពេលព្រឹក : **ជួបប្រជុំតាមវិស័យ** តំណាងក្រសួងនីមួយៗជួបពិភាក្សា ដោយឡែកៗ ពីគ្នាទៅតាមជំនាញនីមួយៗ ទៅតាមវិស័យ នៅខេត្តបាត់ដំបង ។

- ពេលរសៀល : **ប្រជុំពិភាក្សាបូកសរុបរួម** គ្រប់មន្ទីរ និងការិយាល័យជំនាញទាំងអស់ ព្រមទាំងក្រុមគណៈប្រតិភូ ជួបពិភាក្សាជាមួយលោក លោកអភិបាលស្រុក និង អភិបាលខេត្ត បាត់ដំបង ។

ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៣ **ជួបប្រជុំតាមវិស័យ** តំណាងក្រសួងនីមួយៗជួបពិភាក្សា ដោយ

ឡែកៗ ពីគ្នាទៅតាមជំនាញនីមួយៗ នៅខេត្តសៀមរាប ។

ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៣ **ជួបប្រជុំពិភាក្សាបូកសរុបរួម** គ្រប់មន្ទីរ និងការិយាល័យ ជំនាញទាំងអស់ ព្រមទាំងក្រុមគណៈប្រតិភូ ជួបពិភាក្សាជាមួយ លោក លោកអភិបាលស្រុក និង អភិបាលខេត្ត សៀមរាប ។

## គោលបំណងនៃទស្សនៈកិច្ច :

គោលបំណងជាចំបង នៃទស្សនៈកិច្ចសិក្សានេះ គឺដើម្បីអោយក្រុមការងារអន្តរក្រសួង អាចពិនិត្យមើលស្ថានភាពជាក់ស្តែង និងប្រមូលពត៌មានចាំបាច់មួយចំនួន សំរាប់ជាប្រយោជន៍ពន្លឿន ការរៀបចំការដាក់អោយអនុវត្តន៍ការផ្តល់សេវាកម្មរដ្ឋបាលតាមគោលការណ៍ច្រកចេញ-ចូលតែមួយ ដូចដែលមានចែងនៅក្នុងសេចក្តីសំរេចលេខ ៤៧ ។

ជាពិសេស ដំណើរទស្សនៈកិច្ចនេះអាចជួយអោយក្រសួង ទាំងអស់អាចប្រមូលបាននូវអនុសាសន៍ និងសំណើជាក់ស្តែងនានា ដែលមន្ទីរ និងការិយាល័យជំនាញនីមួយៗ នៅស្រុកសាកល្បងទាំងពីរបានលើក ដើម្បីជាប្រយោជន៍អោយក្រសួងពាក់ព័ន្ធអាចរៀបចំបញ្ជីរាយនាម ប្រភេទសេវា និងចេញប្រកាសប្រតិភូកម្មអំណាច ដែលត្រូវប្រគល់អោយទៅស្រុកសាកល្បងទាំងពីរនេះ អោយបានសមស្រប ។

នៅក្នុងជំនួបរវាងគណៈប្រតិភូ ជាមួយនិងលោកអភិបាល អភិបាលរងស្រុកទាំងពីរ និងអភិបាលខេត្ត នៃខេត្តទាំងពីរ គណៈប្រតិភូ និងក្រុមការងារ បានពិភាក្សា និងស្តាប់យោបល់ជាក់ស្តែងនានា ដែលជា តម្រូវការជាមូលដ្ឋានរបស់ស្រុកទាំងពីរ ដើម្បីឈានទៅដល់ការដាក់អោយអនុវត្តបានជាស្ថាពរ នូវការផ្តល់សេវាកម្មរដ្ឋបាលជូនប្រជាពលរដ្ឋតាមគោលការណ៍ច្រកចេញ-ចូលតែមួយ ។ លើសពីនេះទៀត ក្រុមការងារ ក៏បានពិនិត្យមើលពីលទ្ធភាព ក្នុងការរៀបចំអាគារ និងការបំពាក់សំភារៈសំរាប់អោយ ការិយាល័យ ច្រកចេញ-ចូលតែមួយ អាចបើកដំណើរការបាន ។

## លទ្ធផលសរុបដែលទទួលបាន :

ក្រោយពីបានពិនិត្យមើលស្ថានភាពជាក់ស្តែង ស្តាប់របាយការណ៍ និងពិភាក្សា រវាងគណៈប្រតិភូ អន្តរក្រសួងជាមួយ និងស្ថាប័នពាក់ព័ន្ធនានានៅមូលដ្ឋាននៃខេត្តទាំងពីរ ជាពិសេសពិភាក្សាជាមួយ អភិបាលខេត្តបាត់ដំបង និងខេត្តសៀមរាប ក៏ដូចជាលោកអភិបាល អភិបាលរងស្រុកទាំងពីរ និងគ្រប់មន្ទីរ និងការិយាល័យជំនាញទាំងអស់ជុំវិញខេត្តទាំងពីរ ក្នុងទិសដៅរៀបចំ និងដាក់អោយដំណើរការ អនុវត្តន៍សាកល្បង ការផ្តល់សេវាកម្មរដ្ឋបាល តាមច្រកចេញ-ចូលតែមួយ អាចធ្វើទៅបានសមស្រប និងតាមពេលគ្រោងទុក ក្រុមការងារអន្តរក្រសួងយល់ថា :

*ការងារចាំបាច់មួយចំនួនដូចដែលមានចែងខាងក្រោម ត្រូវរៀបចំអោយហើយមុនដំណាច់ ខែមិនា ២០០៤ :*

១- **ក្របខ័ណ្ឌគតិយុត្ត :** ក្រសួង-ស្ថាប័នពាក់ព័ន្ធនានា រៀបចំប្រកាស សេចក្តីសំរេច ឬ សេចក្តីណែនាំមួយចំនួន អោយបានរួចរាល់មុនបំណាច់ខែមិនា ឆ្នាំ ២០០៤ ដែលក្នុងនោះមាន :

- ក្រសួងមហាផ្ទៃ និងចេញប្រកាស់ស្តីពី :

  ១- ការរៀបចំ និងប្រព្រឹត្តទៅរបស់ស្រុក

  ២- រចនាសម្ព័ន្ធរបស់ការិយាល័យច្រកចេញ-ចូលតែមួយ (OWS office) និង

  ៣- រចនាសម្ព័ន្ធរបស់ការិយាល័យប្រជាពលរដ្ឋ (Ombudsman )

- ចំណែកក្រសួងពាក់ព័ន្ធទាំង៦ មានក្រសួងសាធារណៈការណ៍និងដឹកជញ្ជូន , ក្រសួងពាណិជ្ជកម្ម , ក្រសួងទេសចរណ៍ , ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល , ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ , និង ក្រសួងដែនដីនគរូបនីយកម្ម នឹងរៀបចំប្រកាសដោយឡែកៗ តាមវិស័យរបស់ខ្លួន គឺ :

  ១-ប្រកាសស្តីពីប្រតិភូកម្មអំណាចជូនស្រុកសាកល្បងទាំងពីរ

  ២- រៀបចំ បញ្ជីរាយនាមសេវា ដែលត្រូវផ្តល់ជូនស្រុកទាំងពីរ

  ៣-រៀបចំសេចក្តីណែនាំ ដើម្បីអោយមន្ត្រី ដែលទទួលការងារនៅថ្នាក់ស្រុកទាំងពីរអាចអនុវត្តការផ្តល់សេវាកម្មរដ្ឋបាលជូនប្រជាពលរដ្ឋ មានប្រសិទ្ធិភាព ។

២- **បុគ្គលិក :**

- ការបញ្ជូនមន្ត្រីមកឱ្យធ្វើការងារនៅការិយាល័យច្រកចេញ-ចូកតែមួយ គួរតែធ្វើឡើងដោយតាមគោលការណ៍ច្បាស់លាស់ ដូចជា មានជំនាញសមស្រប មានសមត្ថភាព ឬមានអតីតភាពការងារធ្វើការនៅខេត្តទាំងពីរស្រាប់
- មន្ត្រីដែលមកធ្វើការនៅការិយាល័យច្រកចេញ-ចូលតែមួយ ជាមន្ត្រីរបស់ក្រសួង-ស្ថាប័នដើមដដែល គ្រាន់តែប្រមូលគ្នាមកធ្វើការនៅការិយាល័យរួមតែមួយ ។
- មន្ត្រីដែលក្រសួង មន្ទីរចាត់មកអោយធ្វើការនៅស្រុកទាំងពីរ គួរយកមន្ត្រីដែលកំពុងធ្វើការនៅក្នុងខេត្តស្រាប់ ។
- មន្ត្រីតាមជំនាញ ដែលបញ្ជូនមកអោយធ្វើការនៅស្រុកទាំងពីរ ត្រូវដាក់បញ្ចូលទៅក្នុងការិយាល័យ

ជំនាញជុំវិញស្រុកអោយបានរួចជាស្រេច ។

៣- **ការរៀបចំធនធាន ហិរញ្ញវត្ថុ និង សំភារៈ :**

- សំរាប់ថវិកា ឆ្នាំ ២០០៤ គួរប្រើប្រាស់ថវិកាសាលាខេត្ត ឬថវិកាមន្ទីរជំនាញ ។

- ឆ្នាំ ២០០៤ ក្រសួង រឺមន្ទីរជំនាញ ត្រូវផ្តល់សំភារៈ និងធនធានចាំបាច់មួយចំនួនមកជាមួយមន្ត្រី ដែលត្រូវចាត់អោយមកធ្វើការនៅការិយាល័យច្រកចេញ-ចូលតែមួយ ។

- ក្រោយឆ្នាំ ២០០៤ ទៅ ស្រុកទាំងពីរ និងមានញ្ចប់ថវិកាដោយឡែកសំរាប់ស្រុករបស់ខ្លួន ។ ករណីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំអោយមាន ក្រុមការងារមួយ ដើម្បីសិក្សា និងពិនិត្យមើលពីលទ្ធភាពអំពីប្រភពចំណូលផ្ទាល់សំរាប់ស្រុក ដើម្បីអោយស្រុក សាកល្បងទាំងពីរ អាចដំណើរការអនុវត្តន៍ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ អោយស្រុកសាកល្បងទាំងពីរអាច មានប្រភពចំណូលរបស់ខ្លួន ។

៤- **ចំពោះដៃគូផ្តល់ជំនួយ** : ដៃគូផ្តល់ជំនួញ គួរជួយបំពេញអតុល្យភាពថវិកាសំរាប់ឆ្នាំដំបូង ក្នុងជួយគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ លើការបណ្តុះបណ្តាល និងការបំពាក់សំភារៈចាំបាច់មួយចំនួន ដើម្បីអោយការិយាល័យ ច្រកចេញ-ចូលតែមួយ អាចដំណើរការបាន ។

៥- **សំណូមពរផ្សេងៗ :**

- សូមឱ្យស្ថាប័នមានសមត្ថកិច្ច ជួយទំលាក់ថវិកាបដិភាគរបស់រាជរដ្ឋាភិបាលចំនួន ៣ម៉ឺនអឺរ៉ូ អោយបានឆាប់ដើម្បីចាប់ផ្តើមដំណើរការ អនុវត្តសាកល្បងស្រុកទាំងពីរនេះ សំរាប់រយៈពេលដំបូង ។

- សុំអោយមានជំនាញការមកជួយដល់ដំណើរការរបស់ ការិយាល័យច្រកចេញ-ចូលតែមួយ និង ការិយាល័យប្រជាពលរដ្ឋ ។

**កិច្ចការដែលត្រូវធ្វើជាបន្ទាន់ :**

១- ត្រូវបង្កើតគណៈកម្មការសម្របសម្រួលថ្នាក់ខេត្ត យោងតាមមាត្រា១៧ នៃសេចក្តីសំរេច លេខ ៤៧ ស.ស.រ ចុះថ្ងៃ ទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ ដើម្បីធ្វើជាយន្តការគាំទ្រ និងសំរួលដល់ការដាក់អោយដំណើរការច្រកចេញ-ចូលតែមួយ ។ ចំពោះសមាសភាពនៅក្នុងគណៈកម្មការដែលមកពីមន្ទីរនានាជុំវិញខេត្ត

តំណាងនេះ គួរយកមកពីមន្ទីរជំនាញទាំង៦ ដូចមានកំណត់ខាងលើនេះ និងមានតំណាងមកពីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២- រៀបចំបញ្ជីតំរូវការបុគ្គលិក និងតំរូវការខាងការបណ្តុះបណ្តាល ។ ព្រមទាំង រៀបចំបញ្ជីសំភារៈដែលត្រូវការ និងអាគារ ។

៣- រៀបចំយន្តការការងារសំរាប់ធ្វើកិច្ចការនេះ ឱ្យមានប្រសិទ្ធិភាព គឺត្រូវមានយន្តការជាក់ស្តែងមួយ រវាងអភិបាលស្រុក ក្រុមសំរបសំរួលខេត្ត និងថ្នាក់ជាតិ ។

៤- ក្រសួងពាក់ព័ន្ធ និងមន្ទីរជំនាញរៀបចំប្រកាសប្រតិភូកម្មអំណាច បញ្ជីសេវា និងសេចក្តីណែនាំសំរាប់ស្រុកទាំងពីរអោយបានឆាប់បំផុត ។

***<u>ឯកសារភ្ជាប់មកជាមួយមាន</u>*** :

១ - របាយការណ៍ លំអិតនៃអង្គសិក្ខាសាលា ថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០០៣ ស្តីអំពី ការរៀបចំដើម្បីដាក់អោយអនុវត្តន៍សាកល្បងនូវការផ្តល់សេវាកម្មរដ្ឋបាលតាម "ច្រកចេញ- ចូលតែមួយ" នៅស្រុកបាត់ដំបង ស្រុកសៀមរាប និងទីប្រជុំជនមួយចំនួន ។

២ - មតិចូលរួមរបស់តំណាងក្រសួង និងស្ថាប័នពាក់ព័ន្ធនានា នៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ។

ភ្នំពេញ ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៤

**អ្នកសំរបសំរួលការងារបច្ចេកទេស**

**ហុក ប៉េងសែ**

**ខេព ជាវ៉ុង**

អគ្គលេខាធិការស្តីទី

# របាយការណ៍

ស្តីពីការចុះផ្សព្វផ្សាយខ្លឹមសារលិខិតបទដ្ឋានដែលពាក់ព័ន្ធដល់ការរៀបចំប្រព័ន្ធគ្រប់គ្រង

រដ្ឋបាលតាមច្រកចេញចូលតែមួយ នៅស្រុកបាត់ដំបង ខេត្តបាត់ដំបង

ស្រុកសៀមរាប ខេត្តសៀមរាប ថ្ងៃទី ២៥ ‐ ៣១ កក្កដា ឆ្នាំ ២០០៤

# របាយការណ៍

## ស្តីពី

## ការចុះផ្សព្វផ្សាយខ្លឹមសារលិខិតបទដ្ឋានដែលពាក់ព័ន្ធដល់ការរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាលច្រកចេញ-ចូលតែមួយនៅស្រុកបាត់ដំបង ខេត្តបាត់ដំបង ស្រុកសៀមរាប ខេត្តសៀមរាប ដែលដឹកនាំដោយឯកឧត្តម ង៉ោ ហុងលី អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

## (ចាប់ពី ថ្ងៃទី ២៥-៣១ ខែ កក្កដា ឆ្នាំ ២០០៤)

**សមាសភាពចូលរួមមាន :**

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | ង៉ោ | ហុងលី | អគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល |
| ២- ឯកឧត្តម | ទេព | ដារ៉ុង | អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល |
| ៣- ឯកឧត្តម | ប៉ូល | ពីខូ | អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល |
| ៤- លោក | មិន | ចណ្ឌីណារុថ | ប្រធានគំរោង នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល |
| ៥- លោក | ស្វាយ | សុវណ្ណរិទ្ធ | ប្រធានគំរោង នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល |
| ៦- លោក | អ៊ុក | ឧត្តម | មន្ត្រី នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល |

### I. ឯកសារផ្សព្វផ្សាយ :

- កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី ៣
- យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី ៣
- កម្មវិធីកំណែទំរង់រដ្ឋបាល
- ប្រកាសរបស់ក្រសួងមហាផ្ទៃលេខ ៧៩២ ប្រក. ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៤
- ប្រកាសរបស់ក្រសួងមហាផ្ទៃលេខ ៧៩០ ប្រក. ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៤

### II. គោលដៅផ្សព្វផ្សាយបានផ្តោតយកចិត្តទុកដាក់ទៅលើ :

១- តួនាទីការិយាល័យប្រជាពលរដ្ឋ ធ្វើយ៉ាងណាអោយការិយាល័យនេះធ្វើសកម្មភាពការងាររបស់ខ្លួនដោយអព្យាក្រឹតក្នុងការទទួលពាក្យបណ្តឹងតវ៉ាពីប្រជាពលរដ្ឋ អំពីរដ្ឋបាលស្រុក និងសំរុះសំរួល

ដោះស្រាយបណ្ដឹងទាំងអស់ ។ ការដោះស្រាយត្រូវធានាឱ្យបានផងដែរ ស្របតាមលក្ខណៈច្បាប់ លិខិតបទដ្ឋាន និងការអនុវត្តការងារតាមការកំនត់ ។

២- តួនាទីការិយាល័យច្រកចេញ-ចូលតែមួយ ក្នុងគោលបំណងដើម្បីលើកកំពស់អភិបាលកិច្ចល្អការកែទំរង់ប្រពន្ធ័រដ្ឋ បាលពង្រីកវិសាលភាពសេវាកម្មដែលផ្ដល់ដោយស្រុកអោយបានទូលាយ តាមរយៈការប្រមូលផ្ដុំសេវាកម្មទាំងអស់ក្នុងក្របខណ្ឌ័សមត្ថកិច្ចរបស់ស្រុក ហើយឱ្យផ្ដល់សេវាកម្មទាំងអស់នោះជូនអតិថិជននៅទីកន្លែងតែមួយ ។

III. **របាយការណ៍បន្ថែម :**

ឆ្លៀតក្នុងឱកាសនោះដែរ នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ក្រុមការងារដែលដឹកនាំដោយឯកឧត្តម **ម៉ៅ ហុងលី** បានចុះទៅសិក្សាស្វែងយល់ពីដំណើរការបើកបៀវត្សរបស់ លោកគ្រូ អ្នកគ្រូ ទទួលបានប្រចាំខែអាចបំពេញសេចក្ដីត្រូវការក្នុងការចំណាយរបស់គាត់ប្រចាំថ្ងៃបានដែរឬទេ? បើធៀបនឹងតំលៃទំនិញលើទីផ្សារនិងសិក្សាពីស្ថានភាពនៃការបង្រៀនសិស្សរបស់លោកគ្រូ អ្នកគ្រូ នៅសាលាបឋមសិក្សាត្រីញ៉រ័ ឃុំត្រីញ៉រ័ និង សាលាបឋមសិក្សា រើល ឃុំរើល ស្រុកពួក ខេត្ត សៀមរាប ។

តាមការឆ្លើយបំភ្លឺរបស់លោកគ្រូ អ្នកគ្រូ ដែលកំពុងជួបប្រទះបានអោយដឹងថា :

១- លោកគ្រូ អ្នកគ្រូជាប់កិច្ចសន្យា មិនទាន់ទទួលបានប្រាក់ខែរយៈពេល ៣ឆ្នាំ មកហើយគឺ ២០០២, ២០០៣, និងឆ្នាំ ២០០៤ ។

២- ប្រាក់បំប៉នសំរាប់គ្រូ (បណ្ដុះបណ្ដាលចំណេះដឹងបន្ថែមដល់ លោកគ្រូ អ្នកគ្រូ ក្នុងរយៈបិទបរិសេនកាល) រយៈពេលពីរឆ្នាំមកហើយ មិនទាន់ទទួលបានឡើយ ។

៣- ប្រាក់ខែគ្រូ បង្រៀនពីរពេល (ដោយសារខ្វះគ្រូ សាលាតម្រូវឱ្យគ្រូកាន់ថ្នាក់មួយហើយ ទៅជួយបង្រៀនមួយថ្នាក់ថែមទៀត) មិនទាន់បានទទួលអស់រយៈពេល ៣ឆ្នាំ មកហើយគឺ ឆ្នាំ២០០២ ២០០៣, និងឆ្នាំ ២០០៤ នេះ ។

៤- គ្រូបង្រៀនមួយចំនួន បង្ខំចិត្តខ្ចីបុលគេ ដើម្បីដោះស្រាយជីវភាព (ដោយសារក្រលំបាក) ។

៥- សព្វថ្ងៃនេះ ដើម្បីដោះស្រាយការលំបាករបស់លោកគ្រូ អ្នកគ្រូមួយចំនួន លោកនាយកសាលា បានបង្ខំចិត្តរៃអង្គាស់អង្ករ ពីសិស្សក្នុងមួយនាក់ មួយកំប៉ុង ក្នុងមួយខែ ។

៦- ដោយសារខ្វះគ្រូគំរូវឱ្យគ្រូម្នាក់ទទួលសិស្សចំនួន ៦៧ ទៅ ៩៧ នាក់ក្នុងមួយថ្នាក់ ។

៧- នៅក្នុងភូមិព្រលិត ឃុំរើល សាលាបឋមសិក្សាដែលមានពីរថ្នាក់ធ្វើអំពើឫស្សីប្រកស្លឹក ត្រូវខ្យល់បក់បោកដួលរលំអស់ដែលធ្វើឱ្យគ្រូ និងសិស្សបង្ខំចិត្តបោះបង់ចោលសាលា ជាច្រើនខែមកហើយ ។

៨- តាមសំណូមពរ និងតំរូវការជាមូលដ្ឋានរបស់លោកគ្រូ អ្នកគ្រូនៅទីនោះ បានលើកឡើកថា ដើម្បីដោះស្រាយជីវភាពជាមូលដ្ឋានរបស់ពួកគេបាន គឺចាំបាច់ត្រូវមានប្រាក់បៀវត្សអប្បបរមាចំនួន ៦០ ដុល្លារអាមេរិចក្នុងមួយខែ (ដោយមិនគិតដល់ការព្យាបាលជំងឺ ចំណាយបុណ្យទាន ឬចំណាយក្នុងពិធីសង្គម និងសាសនាផ្សេងៗឡើយ ) ។

ទាំងអស់នេះ គឺជាបញ្ហាលំបាកស្មុគស្មាញ និងចំពោះមុខដែលលោកគ្រូ អ្នកគ្រូនៅតាមជនបទដាច់ស្រយាល ជាពិសេស លោកគ្រូ អ្នកគ្រូ នៅក្នុងឃុំត្រីញរ៍ ស្រុកពួក ខេត្តសៀមរាប កំពុងជួបប្រទះនៅពេលសព្វថ្ងៃ ។

ភ្នំពេញ,ថ្ងៃទី១៤ ខែ មិថុនា ឆ្នាំ ២០០៤

អ្នកធ្វើរបាយការណ៍

អ៊ុក ឧត្តម

បានឃើញ និងឯកភាព

ភ្នំពេញ,ថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ ២០០៤

ប្រធាន គណៈប្រតិភូ

ទ៉ោ ហុងលី